# វិនយបិដក



១២

# VINAYA PITAKA

# ព្រះ

# ត្រៃបិដកបាឡិ

# និង

# សេចក្ដីប្រែជាភាសាខ្មែរ

# វិនយបិដក បរិវារ

# បឋមភាគ

# ១២



ផ្សព្វផ្សាយដោយសម្ដេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្ដេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា

ព. ស. ២៥៥៣

# Vinayapiṭaka Parivāra

## Paṭhamabhāga

## 12

សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំថ្វាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេសអ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នាកត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមកក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណាក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមានឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមានការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាកិច្ចយោភាពតរៀងទៅ ។

វត្តបទុមឆ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

ឬួរ-ត្រី

VATT Botum Dhammavutt Sangkat Chatumuk Khan Daun Penh P.Penh

# ទំព័រទទេ

# សេចក្ដីណែនាំក្នុងការអាន

១- ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះ គឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។

ឧទាហរណ៍

-ពាក្យខ្មែរៈ **សម̟ល** ក្នុងពាក្យនេះ ព្យញ្ជនៈ **ល** គឺជាជើងរបស់ព្យញ្ជនៈ **ម** ដូច្នេះពាក្យនេះគឺ **សម្ល** ។

-ពាក្យបាលីៈ **តស̟ស** គឺ **តស្ស** ។

២- ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្ដេចព្រះសង្ឃរាជជោតញ្ញាណោ (**ជួន-ណាត**) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។

៣- ចំពោះ **សន្លឹកច្បាប់ពាក្យខុស-ត្រូវ** ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។

# វិនយបិដក បរិវារៈ

## បឋមភាគ

## ១២

## មហាវិភង្គ សោឡសមហាវារៈ ភិក្ខុនីវិភង្គ

## សោឡសមហាវារៈ សមុដ្ឋានសីសសង្ខេប

## កតិបុច្ឆាវារៈ និង វីសតិវារៈ

# វិនយបិដកេ បរិវារោ

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

## មហាវិភង្គេ សោឡស មហាវារា

[១] យន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន បឋមំ ចាភជិកំ កត្ថ បញ្ញត្តំ ។ កំ អារព្ភ ។ កិស្មឹ វត្ថុស្មឹ ។ អត្ថិ តត្ថ បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នបញ្ញត្តិ សព្វត្ថ បញ្ញត្តិ បទេសបញ្ញត្តិ សាធារណបញ្ញត្តិ អសាធារណបញ្ញត្តិ ឯកតោ បញ្ញត្តិ ឧភតោ បញ្ញត្តិ ។ បញ្ចន្នំ ចាតិមោក្ខុទ្ទេសានំ កត្ថោគធំ កត្ថ បរិយាបន្នំ កតមេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតិ ។ ចតុន្នំ វិបត្តីនំ កតមា វិបត្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតមោ អាបត្តិក្ខន្ធោ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ ចតុន្នំ

# វិនយបិដក បរិវារៈ

*សូមនមស្ការ ចំពោះព្រះមានព្រះភាគ*

*អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ*

# មហាវិភង្គ មហាវារៈ ១៦

[១] *សួរថា បឋមបារាជិក ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ (នូវកាលនៃការបញ្ញត្តសិក្ខាបទ) ឃើញច្បាស់ (នូវប្រយោជន៍ ១០ យ៉ាងនៃការបញ្ញត្តសិក្ខាបទ) ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ព្រោះរឿងរ៉ាវដូចម្តេច ។ (បញ្ញត្តិ ៩ យ៉ាងគឺ) បញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ អនុប្បន្នបញ្ញត្តិ ១ សព្វត្ថបញ្ញត្តិ ១ បទេសបញ្ញត្តិ ១ សាធារណបញ្ញត្តិ ១ អសាធារណបញ្ញត្តិ ១ ឯកតោបញ្ញត្តិ ១ ឧភតោបញ្ញត្តិ ១ មានក្នុងបឋមបារាជិកនោះដែរឬទេ ។ បណ្តាបាតិមោក្ខុទ្ទេសទាំង ៥ បឋមបារាជិក ដាក់ចុះក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា មកកាន់ឧទ្ទេស ត្រង់ឧទ្ទេសណា ។ បណ្តាវិបត្តិ ៤ យ៉ាង បឋមបារាជិកចាត់ជាអ្វី ។ បណ្តាកងនៃអាបត្តិទាំង ៧ បឋមបារាជិកចាត់ចូលក្នុងកងអាបត្តិណា ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង បឋមបារាជិកតាំងឡើងដោយសមុដ្ឋានប៉ុន្មានយ៉ាង ។ បណ្តាអធិករណ៍ទាំង ៤ យ៉ាង*

អធិករណានំ កតមំ អធិករណំ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មតិ ។ កោ តត្ថ វិនយោ កោ តត្ថ អភិវិនយោ កឹ តត្ថ ចាតិមោក្ខំ កឹ តត្ថ អធិ-ប្បាតិមោក្ខំ កា វិបត្តិ កា សម្បត្តិ កា បដិបត្តិ ។ កតិ អត្ថវសេ បដិច្ច ភគវតា បបមំ ចារាជិកំ បញ្ញត្តំ ។ កេ សិក្ខន្តិ ។ កេ សិក្ខិតសិក្ខា ។ កត្ថ ឋិតំ ។ កេ ធារេន្តិ ។ កស្ស វចនំ ។ កេនាភតន្តិ ។

[២] យេន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន បបមំ ចារាជិកំ កត្ថ បញ្ញត្តន្តិ ។ វេសាលិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ សុទិន្នំ កលន្ទ-បុត្តំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ សុទិន្នោ កលន្ទ-បុត្តោ បុរាណទុតិយិកាយ មេថុនំ ធម្មំ បដិសេវិ តស្មឹ

បឋមបារាជិក ចាត់ចូលក្នុងអធិករណ៍ណា ។ បណ្ដាសមថៈទាំង ៧ យ៉ាង បឋមបារាជិក រម្ងាប់ដោយសមថៈប៉ុន្មានយ៉ាង ។ អ្វីជាវិន័យក្នុងបឋមបារាជិកនោះ អ្វីជាអភិវិន័យក្នុងបឋមបារាជិកនោះ អ្វីជាបាតិមោក្ខក្នុងបឋមបារាជិកនោះ អ្វីជាអធិប្បាតិមោក្ខក្នុងបឋមបារាជិកនោះ អ្វីជាវិបត្តិ អ្វីជាសម្បត្តិ អ្វីជាសេចក្ដីប្រតិបត្តិ (ក្នុងបឋមបារាជិកនោះ) ។ បឋមបារាជិក ព្រះមានព្រះភាគ ទ្រង់បញ្ញត្តទុកមក ព្រោះអាស្រ័យអំណាចប្រយោជន៍ប៉ុន្មានយ៉ាង ។ ជនពួកណា សិក្សា ។ ជនពួកណា ដែលមានសិក្ខាសិក្សាហើយ ។ បឋមបារាជិក ឋិតនៅក្នុងជនពួកណា ។ ជនពួកណាទ្រទ្រង់ទុក ។ បឋមបារាជិក ជាពាក្យរបស់នរណា ។ នរណានាំមក ។

[២] សួរថា បឋមបារាជិក ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ទ្រង់បញ្ញត្តក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរវេសាលី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវសុទិន្នភិក្ខុជាកូននៃកលន្ទសេដ្ឋី ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះរឿងរ៉ាវដែលសុទិន្នភិក្ខុជាបុត្ត នៃកលន្ទសេដ្ឋីសេពមេថុនធម្មនឹងបុរាណទុតិយិកា

វត្ថុស្មឹ ។ អត្ថិ តត្ថ បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តី-តិ ។ ឯកា បញ្ញត្តិ ទ្វេ អនុប្បញ្ញត្តិយោ អនុប្បន្នប្បញ្ញត្តិ តស្មឹ នត្ថិ ។ សព្វត្ថ បញ្ញត្តិ បទេសប្បញ្ញត្តីតិ ។ សព្វត្ថ បញ្ញត្តិ ។ សាធារណប្បញ្ញត្តិ អសាធារណប្បញ្ញត្តីតិ ។ សាធារណប្បញ្ញត្តិ ។ ឯកតោ បញ្ញត្តិ ឧភតោ បញ្ញត្តី-តិ ។ ឧភតោ បញ្ញត្តិ ។ បញ្ចន្នំ ចាតិមោក្ខុទ្ទេសានំ កត្ថោគធំ កត្ថ បរិយាបន្នន្តិ ។ និទានោគធំ និទាន-បរិយាបន្នំ ។ កតមេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតីតិ ។ ទុតិយេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតិ ។ ចតុន្នំ វិបត្តីនំ

(ភរិយារបស់ខ្លួនពីដើម) ។ បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តិ មានក្នុងបឋមបារាជិកនោះដែរឬទេ ។ មានតែបញ្ញត្តិ[១] ១ និងអនុប្បញ្ញត្តិ[២] ២ ឯអនុប្បន្នប្បញ្ញត្តិ[៣] មិនមានក្នុងបឋមបារាជិកនោះទេ ។ បឋមបារាជិកនោះ ជាសព្វត្ថប្បញ្ញត្តិ[៤] ឬជាបទេសប្បញ្ញត្តិ[៥] ។ ជាសព្វត្ថប្បញ្ញត្តិ ។ បឋមបារាជិកនោះ ជាសាធារណប្បញ្ញត្តិ[៦] ឬជាអសាធារណប្បញ្ញត្តិ[៧] ។ ជាសាធារណប្បញ្ញត្តិ ។ បឋមបារាជិកនោះ ជាឯកតោបញ្ញត្តិ ឬជាឧភតោ-បញ្ញត្តិ[៨] ។ ជាឧភតោបញ្ញត្តិ ។ បណ្តាបាតិមោក្ខុទ្ទេសទាំង ៥ យ៉ាង បឋម-បារាជិកដាក់ចុះក្នុងឧទ្ទេសណារាប់បញ្ចូលក្នុងឧទ្ទេសណា ។ បឋមបារាជិកដាក់ចុះក្នុងនិទាន រាប់បញ្ចូលក្នុងនិទាន ។ បឋមបារាជិកមកកាន់ឧទ្ទេសត្រង់ឧទ្ទេសណា ។ មកកាន់ឧទ្ទេសត្រង់ឧទ្ទេសទី ២ ។ បណ្តាវិបត្តិ ៤ យ៉ាង

---

១ អដ្ឋកថាថា សេចក្តីបញ្ញត្តថា ភិក្ខុណាមួយសេពមេថុនធម្ម ត្រូវបារាជិកគ្មានសំវាសនេះ ជាបញ្ញត្តិ ១ ។ ២ ពាក្យថា ភិក្ខុសេពមេថុនធម្ម ដោយហោចទៅ សូម្បីតែនឹងសត្វតិរច្ឆានក្តី មិនពោលលាសិក្ខាក្តី ទាំងនេះចាត់ជា អនុប្បញ្ញត្តិពីរ ។ ៣ សេចក្តីបញ្ញត្តិមុនកើតរឿងឡើងដូចជាទ្រង់បញ្ញត្តិគរុធម៌ ៨ ដល់ពួកភិក្ខុនី នេះចាត់ជាអនុប្បន្នប្បញ្ញត្តិ ។ នេះមិនមានក្នុងទីឯទៀតទេ ។ ៤ សិក្ខាបទដែលទ្រង់បញ្ញត្តទូទៅ ទាំងមជ្ឈិមបទេស ទាំងបច្ចន្តជនបទ ហៅថា សព្វត្ថប្បញ្ញត្តិ ។ ៥ សិក្ខាបទដែលទ្រង់បញ្ញត្តហាមក្នុងមជ្ឈិមបទេសមាន ៥ សិក្ខាបទគឺឧបសម្ប-ទាដោយគណៈសង្ឃ មានភិក្ខុជាវិន័យធរជាគម្រប់ ៥ ស្បែកជើង ៤ ជាន់ ស្រង់ទឹកជានិច្ច កម្រាលស្បែក ហៅថា បទេសប្បញ្ញត្តិ ។ ៦ សិក្ខាបទដែលទ្រង់បញ្ញត្តទូទៅទាំងភិក្ខុទាំងភិក្ខុនី ហៅថា សាធារណប្បញ្ញត្តិ ។ ៧ សិក្ខាបទដែលទ្រង់បញ្ញត្តចំពោះតែភិក្ខុ ឬចំពោះតែភិក្ខុនីម្យ៉ាង ហៅថា អសាធារណប្បញ្ញត្តិ ។ ៨ ឯកតោបញ្ញត្តិ មានសេចក្តីដូចអសាធារណប្បញ្ញត្តិ ឧភតោបញ្ញត្តិ មានសេចក្តីដូចសាធារណប្បញ្ញត្តិ ។

កតមា វិបត្តីតិ ។ សីលវិបត្តិ ។ សត្តន្នំ អាបត្តិក្ខ-
ន្ធានំ កតមោ អាបត្តិក្ខន្ធោតិ ។ បារាជិកាបត្តិក្ខន្ធោ ។
ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋា-
តីតិ ។ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច
ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។ ចតុន្នំ អធិករណានំ
កតមំ អធិករណន្តិ ។ អាបត្តាធិករណំ ។ សត្តន្នំ
សមថានំ កតីហិ សមថេហិ សម្មតីតិ ។ ទ្វីហិ
សមថេហិ សម្មតិ សម្មុខាវិនយេន ច បដិញ្ញាតករ-
ណេន ច ។ កោ តត្ថ វិនយោ កោ តត្ថ អភិវិន-
យោតិ ។ បញ្ញត្តិ វិនយោ វិភត្តិ អភិវិនយោ ។ កឹ
តត្ថ បាតិមោក្ខំ កឹ តត្ថ អធិបាតិមោក្ខន្តិ ។ បញ្ញត្តិ
បាតិមោក្ខំ វិភត្តិ អធិបាតិមោក្ខំ ។ កា វិបត្តីតិ ។
អសំវរោ វិបត្តិ ។ កា សម្បត្តីតិ ។ សំវរោ សម្បត្តិ ។
កា បដិបត្តីតិ ។ ន ឯវរូបំ ករិស្សាមីតិ យាវជីវំ អាបា-
ណកោដិកំ សមាទាយ សិក្ខតិ សិក្ខាបទេសុ ។

បឋមបារាជិក ចាត់ជាវិបត្តិអ្វី ។ ចាត់ជាសីលវិបត្តិ ។ បណ្តាកងនៃអាបត្តិទាំង ៧ បឋមបារាជិក ចាត់ចូលក្នុងកងនៃអាបត្តិណា ។ ចាត់ចូលក្នុងកងនៃអាបត្តិបារាជិក ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង បឋមបារាជិកតាំងឡើងដោយសមុដ្ឋានប៉ុន្មានយ៉ាង ។ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាទេ ។ បណ្តាអធិករណ៍ទាំង ៤ យ៉ាង បឋមបារាជិក ចាត់ជាអធិករណ៍ណា ។ ចាត់ជាអាបត្តាធិករណ៍ ។ បណ្តាសមថៈទាំង ៧ យ៉ាង បឋមបារាជិករម្ងាប់ដោយសមថៈប៉ុន្មានយ៉ាង ។ រម្ងាប់ដោយសមថៈពីរយ៉ាង គឺដោយសម្មុខាវិន័យ ១ បដិញ្ញាតករណៈ ១ ។ អ្វីជាវិន័យក្នុងបឋមបារាជិកនោះ អ្វីជាអភិវិន័យក្នុងបឋមបារាជិកនោះ ។ បញ្ញត្តិ ជាវិន័យ វិភត្តិ (បទភាជនៈ) ជាអភិវិន័យក្នុងបឋមបារាជិកនោះ ។ អ្វីជាបាតិមោក្ខក្នុងបឋមបារាជិកនោះ អ្វីជាអធិប្បាតិមោក្ខក្នុងបឋមបារាជិកនោះ ។ បញ្ញត្តិជាបាតិមោក្ខ វិភត្តិ (បទភាជនៈ) ជាអធិប្បាតិមោក្ខ ។ អ្វីជាវិបត្តិ ។ សេចក្តីមិនសង្រួម ជាវិបត្តិ ។ អ្វីជាសម្បត្តិ ។ សេចក្តីសង្រួម ជាសម្បត្តិ ។ អ្វីជាសេចក្តីប្រតិបត្តិ (ក្នុងបឋមបារាជិកនោះ) ។ ភិក្ខុសមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយដរាបអស់ជីវិត មានជីវិតជាទីបំផុតដោយគិតថា អាត្មាអញនឹងមិនធ្វើអំពើមានសភាពយ៉ាងនេះទេ (នេះជាសេចក្តីប្រតិបត្តិ) ។

៤

មហាវិភង្គេ សោឡស មហាវារា បឋមបារាជិកំ

កតិ អត្ថវសេ បដិច្ច ភគវតា បឋមំ បារាជិកំ បញ្ញត្តន្តិ ។ ទស អត្ថវសេ បដិច្ច ភគវតា បឋមំ បារាជិកំ បញ្ញត្តំ សង្ឃសុដ្ឋុតាយ សង្ឃផាសុតាយ ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ បេសលានំ ភិក្ខូនំ ផាសុវិហារាយ ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ សម្បរាយិកានំ អាសវានំ បដិឃាតាយ អប្បសន្នានំ បសាទាយ បសន្នានំ ភិយ្យោភាវាយ សទ្ធម្មដ្ឋិតិយា វិនយានុគ្គហាយ ។ កេ សិក្ខន្តីតិ ។ សេក្ខា ច បុថុជ្ជនកល្យាណកា ច សិក្ខន្តិ ។ កេ សិក្ខិតសិក្ខាតិ ។ អរហន្តោ សិក្ខិតសិក្ខា ។ កត្ថ ឋិតន្តិ ។ សិក្ខាកាមេសុ ឋិតំ ។ កេ ធារេន្តីតិ ។ យេសំ វត្តតិ តេ ធារេន្តិ ។ កស្ស វចនន្តិ ។ ភគវតោ វចនំ អរហតោ សម្មាសម្ពុទ្ធស្ស ។ កេនាភតន្តិ ។ បរម្បរាភតំ[១] ៗ

---
១ ឧ. ម. បរំបរាភតំ ។

បឋមបារាជិក ព្រះមានព្រះភាគ ទ្រង់បញ្ញត្តទុកមក ព្រោះអាស្រ័យអំណាចប្រយោជន៍ប៉ុន្មាន ។ បឋមបារាជិក ព្រះមានព្រះភាគទ្រង់បញ្ញត្តទុកមក ព្រោះអាស្រ័យអំណាចប្រយោជន៍ ១០ យ៉ាង គឺដើម្បីសេចក្តីល្អដល់សង្ឃ ១ ដើម្បីនៅសប្បាយដល់សង្ឃ ១ ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយដែលមិនអៀនខ្មាស ១ ដើម្បីនៅជាសុខស្រួលដល់ភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ ១ ដើម្បីរាំងអាសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន ១ ដើម្បីកំចាត់បង់នូវអាសវធម៌ទាំងឡាយក្នុងបរលោក ១ ដើម្បីញុំាងបុគ្គលទាំងឡាយដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ១ ដើម្បីញុំាងបុគ្គលទាំងឡាយដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើង ១ ដើម្បីតាំងនៅមាំនៃព្រះសទ្ធម្ម ១ ដើម្បីអនុគ្រោះដល់វិន័យ ១ ។ ជនពួកណាតែងសិក្សា ។ ពួកសេក្ខៈនិងពួកកល្យាណបុថុជ្ជនតែងសិក្សា ។ ជនពួកណាដែលមានសិក្ខាសិក្សាហើយ ។ ពួកព្រះអរហន្តមានសិក្ខាសិក្សាហើយ ។ បឋមបារាជិកនោះ ឋិតនៅក្នុងពួកជនណា ។ ឋិតនៅក្នុងពួកសិក្ខាកាមបុគ្គល (អ្នកប្រាថ្នាការសិក្សា) ។ ជនពួកណារមែងទ្រទ្រង់ទុក ។ បឋមបារាជិកប្រព្រឹត្តទៅដល់ជនពួកណា ជនពួកនោះរមែងទ្រទ្រង់ទុក[១] ។ បឋមបារាជិកជាពាក្យរបស់អ្នកណា ។ ជាពាក្យរបស់ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ។ អ្នកណានាំមក ។ ព្រះថេរៈ (ដូចមាននាមតទៅនេះ) នាំត ៗ គ្នាមក ។

---

១ អដ្ឋកថា ថា ពាក្យថាទ្រទ្រង់ទុក គឺចាំស្ទាត់ទាំងបាលីទាំងអដ្ឋកថា នៃបឋមបារាជិក ។

[៣] ឧបាលិ ទាសកោ ចេវ
សោណកោ សិគ្គវោ តថា
មោគ្គលីបុត្តេន បញ្ចមា
ឯតេ ជម្ពុសិរិវ្ហយេ[១] ។
តតោ មហិន្ទោ ឥដ្ដិយោ
ឧត្តិយោ ចេវ សម្ពលោ[២]
ភទ្ទនាមោ ច បណ្ឌិតោ
ឯតេ នាគា មហាបញ្ញា
ជម្ពុទីបា ឥធាគតា
វិនយំ តេ វាចយឹសុ
បិដកំ តម្ពបណ្ណិយា
និកាយេ បញ្ច វាចេសុំ
សត្ត ចេវ បករណេ ។
តតោ អរិដ្ឋោ មេធាវី
តិស្សទត្តោ ច បណ្ឌិតោ
វិសារទោ កាឡសុមនោ

---

១ ជម្ពូសិរិវ្ហយេតិ កត្ថចិ ទិស្សតិ ។ ២ ឱ. ឧត្តិយោ សម្ពលោ តថា ។ ម. ឧដ្ដិយោ សម្បលោ តថា ។

[៣] ព្រះថេរៈឈ្មោះឧបាលិ ១ ទាសកៈ ១ សោណកៈ ១ សិគ្គវៈ ១ និងព្រះមោគ្គលីបុត្ត ១ អង្គទៀត ជាគម្រប់ ៥ ព្រះថេរៈទាំងនេះឋិតនៅក្នុងទ្វីបមានឈ្មោះថា ជម្ពូ ដ៏មានសិរី ។ តអំពីព្រះថេរៈទាំងនោះមក ព្រះមហាមហិន្ទ ១ ព្រះឥដ្ឋិយៈ ១ ព្រះឧត្តិយៈ ១ ព្រះសម្ពលៈ ១ ព្រះភទ្ទនាមជាបណ្ឌិត ១ ព្រះនាគត្ថេរទាំងនេះ មានប្រាជ្ញាច្រើន មកអំពីជម្ពូទ្វីប ហើយបានមកនៅក្នុងលង្កាទ្វីប ព្រះថេរៈទាំងនោះ បានបង្រៀនវិន័យ-បិដក បានបង្រៀននិកាយទាំង ៥ គម្ពីរ ព្រះអភិធម្មទាំង ៧ គម្ពីរ ក្នុងតម្ពបណ្ណិទ្វីប (កោះលង្កា) ។ តអំពីនោះមក (មានព្រះថេរៈច្រើនអង្គទៀតគឺ) ព្រះអរិដ្ឋៈជាអ្នកមានប្រាជ្ញា ១ ព្រះតិស្សទត្តជាបណ្ឌិត ១ ព្រះកាឡសុមនត្ថេរជាអ្នកក្លៀវក្លា ១

**៧**

មហាវិភង្គេ សោឡស មហាវាភា ថេរនាមានិ

ថេរោ ច ធីឃនាមកោ
ធីឃសុមនោ ច បណ្ឌិតោ
បុនរេវ កាឡសុមនោ
នាគត្ថេរោ ច ពុទ្ធរក្ខិតោ
តិស្សត្ថេរោ ច មេធាវី
ទេវត្ថេរោ[១] ច បណ្ឌិតោ
បុនរេវ សុមនោ មេធាវី
វិនយេ ច វិសារទោ
ពហុស្សុតោ ចូឡនាគោ
គជោវ ទុប្បធំសិយោ
ធម្មបាលិតនាមោ ច
រោហណោ សាធុបូជិតោ
តស្ស សិស្សោ មហាបញ្ញោ
ខេមនាមោ តិបេដកី
ទីបេ តារករាជាវ
បញ្ញាយ អតិរោចតិ[២]

---

១ ម. ទេវត្ថេរោ ។ ២ ឱ. ម. អតិរោចថ ។

មហាវិភង្គ មហាវារៈ ១៦ នាមរបស់ព្រះថេរៈទាំងឡាយ

ព្រះទីឃនាមកៈ ១ ព្រះទីឃសុមនៈ ជាបណ្ឌិត ១ ព្រះកាឡសុមនៈ ១ ព្រះនាគត្ថេរ ១ ព្រះពុទ្ធរក្ខិត ១ ព្រះតិស្សត្ថេរជាអ្នកមានប្រាជ្ញា ១ ព្រះទេវត្ថេរជាបណ្ឌិត ១ ព្រះសុមនៈមានប្រាជ្ញាក្លៀវក្លាក្នុងវិន័យ ១ ព្រះចូឡនាគជាពហុស្សូត ១ ព្រះគជត្ថេរជាអ្នកកំចាត់បង់ទោសដ៏អាក្រក់ ១ ព្រះថេរៈឈ្មោះធម្មបាលិត ដែលគេបូជាហើយដោយប្រពៃក្នុងរោហណជនបទ ១ សិស្សរបស់ព្រះធម្មបាលិតនោះឈ្មោះខេមៈ ជាអ្នកមានប្រាជ្ញាច្រើន ទ្រទ្រង់ព្រះត្រៃបិដករុងរឿងដោយបញ្ញាក្នុងទ្វីបដូចព្រះចន្ទ ១ ព្រះថេរៈឈ្មោះ

ឧបតិស្សោ ច មេធាវី
បុស្សទេវោ មហាគណី
បុនទេវ សុមនោ មេធាវី
បុប្ផនាមោ ពហុស្សុតោ
មហាគណី មហាសីវោ
បិដកេ សព្វត្ថ កោវិទោ
បុនទេវ ឧបាលិ មេធាវី
វិនយេ ច វិសារទោ
មហានាគោ មហាបញ្ញោ
សទ្ធម្មវំសកោវិទោ
បុនទេវ អភយោ មេធាវី
បិដកេ សព្វត្ថ កោវិទោ
តិស្សត្ថេរោ ច មេធាវី
វិនយេ ច វិសារទោ
តស្ស សិស្សោ មហាបញ្ញោ
បុស្សនាមោ[១] ពហុស្សុតោ
សាសនំ អនុរក្ខន្តោ

១ ឱ. ម. បុប្ផនាមោ ។

ឧបតិស្សៈជាអ្នកមានប្រាជ្ញា ១ ព្រះបុស្សទេវៈដែលជាមហាធម្មកថិក ១ ព្រះសុមនៈអ្នកមានប្រាជ្ញា ១ ព្រះបុប្ផៈជាពហុស្សូត ១ ព្រះមហាសីវៈជាមហាធម្មកថិកឈ្លាសវៃ ក្នុងបិដកទាំងអស់ ១ ព្រះឧបាលិជាអ្នកមានប្រាជ្ញាក្លៀវក្លាក្នុងវិន័យ ១ ព្រះមហានាគជាអ្នកមានប្រាជ្ញាច្រើនឈ្លាសវៃក្នុងវង្សព្រះសទ្ធម្ម ១ ព្រះអភ័យជាអ្នកមានប្រាជ្ញាឈ្លាសវៃក្នុងបិដកទាំងអស់ ១ ព្រះតិស្សត្ថេរជាអ្នកមានប្រាជ្ញាក្លៀវក្លាក្នុងវិន័យ ១ សិស្សរបស់ព្រះតិស្សត្ថេរនោះ ឈ្មោះបុស្សៈជាអ្នកមានប្រាជ្ញាច្រើន ជាពហុស្សូត ជាអ្នករក្សាព្រះសាសនា

ជម្ពុទីបេ បតិដ្ឋិតោ
ចូឡាភយោ ច មេធាវី
វិនយេ ច វិសារទោ
តិស្សត្ថេរោ ច មេធាវី
សទ្ធម្មវំសកោវិទោ
ចូឡាទេវោ ច មេធាវី
វិនយេ ច វិសារទោ
សីវត្ថេរោ ច មេធាវី
វិនយេ សព្វត្ថ កោវិទោ
ឯតេ នាគា មហាបញ្ញា
វិនយញ្ញូ មគ្គកោវិទា
វិនយំ ទីបេ បកាសេសុំ
បិដកំ តម្ពបណ្ណិយាតិ ។

[៤] យេន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ទុតិយំ បារាជិកំ កត្ថ បញ្ញត្តន្តិ ។ រាជគហេ បញ្ញត្តំ ។ កំ អារព្ភាតិ ។ ធនិយំ កុម្ភការបុត្តំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ធនិយោ កុម្ភការ-

ប្រតិស្ឋានទុកក្នុងជម្ពូទ្វីប ១ ព្រះចូឡាភ័យជាអ្នកមានប្រាជ្ញាក្លៀវក្លាក្នុងវិន័យ ១ ព្រះតិស្សត្ថេរជាអ្នកមានប្រាជ្ញាឈ្លាសវៃក្នុងវង្សព្រះសទ្ធម្ម ១ ព្រះចូឡាទេវៈជាអ្នកមានប្រាជ្ញាក្លៀវក្លាក្នុងវិន័យ ១ ព្រះសីវត្ថេរជាអ្នកមានប្រាជ្ញាឈ្លាសវៃក្នុងវិន័យទាំងអស់ ១ ព្រះនាគត្ថេរទាំងនេះ សុទ្ធតែជាអ្នកមានប្រាជ្ញាច្រើន ចេះវិន័យស្ទាត់ក្នុងមគ្គ បានប្រកាសវិន័យបិដកទុកក្នុងតម្ពបណ្ណិទ្វីប (លង្កាទ្វីប) ។

[៤] សួរថា ទុតិយបារាជិក ដែលព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តក្នុងទីណា ។ ឆ្លើយថា ទុតិយបារាជិក ព្រះអង្គទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវធនិយភិក្ខុជាកូននៃស្មូនឆ្នាំង ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះរឿងរ៉ាវដែលធនិយភិក្ខុជាកូននៃស្មូនឆ្នាំង

បុត្តោ វញ្ញោ ជាវូនិ អធិដ្ឋានិ[១] អាធិយិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ នត្ថិ អនុប្បន្នប្បញ្ញត្តិ[២] ។ ឆន្នំ អាបត្តិសមុដ្ឋានានំ[៣] តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ បេ ។

[៤] តតិយំ ចារាជិកំ កត្ថ បញ្ញត្តន្តិ ។ វេសាលិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ សម្ពហុលេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ សម្ពហុលា ភិក្ខូ អញ្ញមញ្ញំ ជីវិតា វោរោបេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ នត្ថិ អនុប្បន្នប្បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ បេ ។

---

១ ឱ. ម. អទិន្នំ ។ ២ សព្វត្ថ នត្ថិ អនុប្បន្នប្បញ្ញត្តីតិ ន ទិស្សតិ ។ ៣ សព្វត្ថ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតីតិ ទិស្សតិ ។

យកឈើរបស់ព្រះរាជាដែលទ្រង់មិនបានប្រទាន ។ ទុតិយបារាជិកនោះ មានតែបញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ ឯអនុប្បន្នប្បញ្ញត្តិមិនមានឡើយ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង ទុតិយបារាជិកតាំងឡើងដោយសមុដ្ឋាន ៣ យ៉ាង គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចា ១ តាំងឡើងអំពីវាចានិងចិត្ត មិនតាំងឡើងអំពីកាយ ១ តាំងឡើងអំពីកាយ អំពីវាចានិងចិត្ត ១ ។ បេ ។

[៤] សួរថា តតិយបារាជិក ព្រះអង្គទ្រង់បញ្ញត្តក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរវេសាលី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវភិក្ខុទាំងឡាយច្រើនរូប ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលភិក្ខុទាំងឡាយច្រើនរូប ផ្តាច់ជីវិតគ្នានិងគ្នា ។ តតិយបារាជិកនេះ មានតែបញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ ឯអនុប្បន្នប្បញ្ញត្តិមិនមានឡើយ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង តតិយបារាជិកតាំងឡើងដោយសមុដ្ឋាន ៣ យ៉ាង គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចា ១ តាំងឡើងអំពីវាចានិងចិត្ត មិនតាំងឡើងអំពីកាយ ១ តាំងឡើងអំពីកាយ អំពីវាចានិងចិត្ត ១ ។ បេ ។

១១

មហាវិភង្គេ សោឡស មហាវារា ចតុត្ថបារាជិកំ ឧទានគាថា

[៦] ចតុត្ថំ ចារាជិកំ កត្ថ បញ្ញត្តន្តិ ។ វេសាលិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ វគ្គុមុជាតីរិយេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ វគ្គុមុជាតីរិយា ភិក្ខូ គិហីនំ អញ្ញមញ្ញស្ស ឧត្តរិមនុស្សធម្មស្ស វណ្ណំ ភាសឹសុ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ នត្ថិ អនុប្បន្នប្បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ បេ ។

ចត្តារោ បារាជិកា និដ្ឋិតា ។

តស្សុទ្ទានំ

[៧] មេថុនាទិន្នាទានញ្ច
មនុស្សវិគ្គហុត្តរិ
ចារាជិកានិ ចត្តារិ
ឆេជ្ជវត្ថូ អសំសយាតិ ។

[៦] *សួរថា ចតុត្ថបារាជិក ព្រះអង្គបញ្ញត្តក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរវេសាលី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវភិក្ខុទាំងឡាយដែលនៅទៀបឆ្នេរស្ទឹងវគ្គុមុទា ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះរឿងរ៉ាវដែលភិក្ខុទាំងឡាយ អ្នកនៅទៀបឆ្នេរស្ទឹងវគ្គុមុទានាំគ្នាពោលអួតនូវគុណ នៃឧត្តរិមនុស្សធម្មនៃគ្នានិងគ្នា ដល់គ្រហស្ថទាំងឡាយ ។ ចតុត្ថបារាជិកនោះ មានបញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ ឯអនុប្បន្នប្បញ្ញត្តិមិនមានឡើយ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង ចតុត្ថបារាជិកតាំងឡើងដោយសមុដ្ឋាន ៣ យ៉ាង គឺ តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចា ១ តាំងឡើងអំពីវាចានិងចិត្ត មិនតាំងឡើងអំពីកាយ ១ តាំងឡើងអំពីកាយ អំពីវាចានិងចិត្ត ១ ។ បេ ។*

ចប់ បារាជិក ៤ ។

*ឧទ្ទានគឺបញ្ជីរឿងនៃបារាជិកនោះដូច្នេះ*

[៧] *បារាជិក ៤ គឺសេពមេថុន ១ លួចទ្រព្យគេ ១ សម្លាប់*
*មនុស្ស ១ ពោលអួតឧត្តរិមនុស្សធម្ម ១ ជាឆេជ្ជវត្ថុ (វត្ថុជា*
*ហេតុឲ្យដាច់ចាកភិក្ខុភាវៈ) បណ្ឌិតមិនត្រូវសង្ស័យឡើយ ។*

[៨] យន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឧបក្កមិត្វា អសុចឹ មោចេន្តស្ស សង្ឃាទិសេសោ កត្ថ បញ្ញត្តោ ។ កំ អារព្ភ ។ កិស្មឹ វត្ថុស្មឹ ។ អត្ថិ តត្ថ បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តិ សព្វត្ថ បញ្ញត្តិ បទេសប្បញ្ញត្តិ សាធារណប្បញ្ញត្តិ អសាធារណប្បញ្ញត្តិ ឯកតោ បញ្ញត្តិ ឧភតោ បញ្ញត្តិ ។ បញ្ចន្នំ បាតិមោក្ខុទ្ទេសានំ កត្ថោគធំ កត្ថ បរិយាបន្នំ កតេមេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតិ ។ ចតុន្នំ វិបត្តីនំ កតមា វិបត្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតមោ អាបត្តិក្ខន្ធោ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ ចតុន្នំ អធិករណានំ កតមំ អធិករណំ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មតិ ។ កោ តត្ថ វិនយោ កោ តត្ថ អភិវិនយោ កឹ តត្ថ បាតិមោក្ខំ កឹ តត្ថ អធិប្បាតិមោក្ខំ កា វិបត្តិ កា សម្បត្តិ

[៨] សួរថា ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តសង្ឃាទិសេសចំពោះភិក្ខុព្យាយាមបញ្ចេញអសុចិ ក្នុងទីណា ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ បញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ អនុប្បន្នប្បញ្ញត្តិ ១ សព្វត្ថប្បញ្ញត្តិ ១ បទេសប្បញ្ញត្តិ ១ សាធារណប្បញ្ញត្តិ ១ អសាធារណប្បញ្ញត្តិ ១ ឯកតោបញ្ញត្តិ ១ ឧភតោបញ្ញត្តិ ១ មានក្នុងបឋមសង្ឃាទិសេសនោះ ដែរឬទេ ។ បណ្ដាបាតិមោក្ខុទ្ទេសទាំង ៥ យ៉ាង បឋមសង្ឃាទិសេសចាត់ដាក់ចុះក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា មកកាន់ឧទ្ទេសត្រង់ឧទ្ទេសណា ។ បណ្ដាវិបត្តិ ៤ យ៉ាង បឋមសង្ឃាទិសេស ចាត់ជាវិបត្តិអ្វី ។ បណ្ដាកងនៃអាបត្តិទាំង ៧ យ៉ាង បឋមសង្ឃាទិសេសចាត់ចូលក្នុងកងអាបត្តិណា ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង បឋមសង្ឃាទិសេសតាំងឡើងដោយសមុដ្ឋានប៉ុន្មានយ៉ាង ។ បណ្ដាអធិករណ៍ទាំង ៤ យ៉ាង បឋមសង្ឃាទិសេសចាត់ជាអធិករណ៍អ្វី ។ បណ្ដាសមថៈទាំង ៧ យ៉ាង បឋមសង្ឃាទិសេសរម្ងាប់ដោយសមថៈប៉ុន្មានយ៉ាង ។ អ្វីជាវិន័យក្នុងសិក្ខាបទនោះ អ្វីជាអភិវិន័យក្នុងសិក្ខាបទនោះ អ្វីជាបាតិមោក្ខក្នុងសិក្ខាបទនោះ អ្វីជាអធិបាតិមោក្ខក្នុងសិក្ខាបទនោះ អ្វីជាវិបត្តិ អ្វីជាសម្បត្តិ

កា បដិបត្តិ ។ កតិ អត្ថវសេ បដិច្ច ភគវតា ឧបក្កមិត្វា អសុចឹ មោចេន្តស្ស សង្ឃាទិសេសោ បញ្ញត្តោ ។ កេ សិក្ខន្តិ ។ កេ សិក្ខិតសិក្ខា ។ កត្ថ ឋិតំ ។ កេ ធារេន្តិ ។ កស្ស វចនំ ។ កេធាភដន្តិ ។

[៩] យន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឧបក្កមិត្វា អសុចឹ មោចេន្តស្ស សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អាយស្មន្តំ សេយ្យសកំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា សេយ្យសកោ ហត្ថេន ឧបក្កមិត្វា អសុចឹ មោចេសិ តស្មឹ វត្ថុស្មឹ ។ អត្ថិ តត្ថ បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តីតិ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តិ តស្មឹ នត្ថិ ។ សព្វត្ថ បញ្ញត្តិ បទេសប្បញ្ញត្តីតិ ។ សព្វត្ថ បញ្ញត្តិ ។ សាធារណប្បញ្ញត្តិ អសាធារណប្បញ្ញត្តីតិ ។ អសាធារណប្បញ្ញត្តិ ។ ឯកតោ បញ្ញត្តិ ឧភតោ បញ្ញត្តិ ។ ឯកតោ បញ្ញត្តិ ។

សេចក្តីប្រតិបត្តិ (ក្នុងសិក្ខាបទនោះ) ដូចម្តេច ។ ព្រះមានព្រះភាគទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុអ្នកព្យាយាមបញ្ចេញអសុចិ តើព្រោះអាស្រ័យអំណាចប្រយោជន៍ប៉ុន្មានយ៉ាង ។ ជនពួកណា តែងសិក្សា ។ ជនពួកណា មានសិក្ខាសិក្សាហើយ ។ សិក្ខាបទនោះឋិតនៅក្នុងជនពួកណា ។ ជនពួកណាតែងទ្រទ្រង់ទុក ។ សិក្ខាបទនោះជាពាក្យរបស់នរណា ។ នរណានាំមក ។

[៩] សួរថា ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុអ្នកព្យាយាមបញ្ចេញអសុចិ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវសេយ្យសកភិក្ខុមានអាយុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលសេយ្យសកភិក្ខុមានអាយុព្យាយាមបញ្ចេញអសុចិដោយដៃ ។ បញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ អនុប្បន្នប្បញ្ញត្តិ ១ មានក្នុងសិក្ខាបទនោះដែរឬទេ ។ មានតែបញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ ឯអនុប្បន្នប្បញ្ញត្តិមិនមានក្នុងសិក្ខាបទនោះទេ ។ សិក្ខាបទនោះ ជាសព្វត្ថប្បញ្ញត្តិ ឬជាបទេសប្បញ្ញត្តិ ។ ជាសព្វត្ថប្បញ្ញត្តិ ។ សិក្ខាបទនោះជាសាធារណប្បញ្ញត្តិ ឬជាអសាធារណប្បញ្ញត្តិ ។ ជាអសាធារណប្បញ្ញត្តិ ។ សិក្ខាបទនោះ ជាឯកតោបញ្ញត្តិ ឬជាឧភតោបញ្ញត្តិ ។ ជាឯកតោបញ្ញត្តិ ។

បញ្ចន្នំ បាតិមោក្ខុទ្ទេសានំ កត្ថោគធំ កត្ថ បរិយាបន្នន្តិ ។ និទានោគធំ និទានបរិយាបន្នំ ។ កតមេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតីតិ ។ តតិយេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតិ ។ ចតុន្នំ វិបត្តីនំ កតមា វិបត្តីតិ ។ សីលវិបត្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតមោ អាបត្តិក្ខន្ធោតិ ។ សង្ឃាទិសេសាបត្តិក្ខន្ធោ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតីតិ ។ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។ ចតុន្នំ អធិករណានំ កតមំ អធិករណន្តិ ។ អាបត្តាធិករណំ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មតីតិ ។ ទ្វីហិ សមថេហិ សម្មតិ សម្មុខាវិនយេន ច បដិញ្ញាតករណេន ច ។ កោ តត្ថ វិនយោ កោ តត្ថ អភិវិនយោតិ ។ បញ្ញត្តិ វិនយោ វិភត្តិ អភិវិនយោ ។ កឹ តត្ថ បាតិមោក្ខំ កឹ តត្ថ អធិបាតិមោក្ខន្តិ ។ បញ្ញត្តិ បាតិមោក្ខំ វិភត្តិ អធិបាតិមោក្ខំ ។ កា វិបត្តីតិ ។ អសំវរោ

បណ្ដាបាតិមោក្ខុទ្ទេសទាំង ៥ យ៉ាង សិក្ខាបទនោះ ដាក់ចុះក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា ។ ដាក់ចុះក្នុងនិទាន រាប់បញ្ចូលក្នុងនិទាន ។ សិក្ខាបទនោះមកកាន់ឧទ្ទេស ត្រង់ឧទ្ទេសណា ។ មកកាន់ឧទ្ទេស ត្រង់ឧទ្ទេសទី ៣ ។ បណ្ដាវិបត្តិទាំង ៤ សិក្ខាបទនោះចាត់ជាវិបត្តិអ្វី ។ ចាត់ជាសីលវិបត្តិ ។ បណ្ដាកងនៃអាបត្តិទាំង ៧ សិក្ខាបទនោះចាត់ចូលក្នុងកងនៃអាបត្តិណា ។ ចាត់ចូលក្នុងកងនៃអាបត្តិសង្ឃាទិសេស ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះតាំងឡើងដោយសមុដ្ឋានប៉ុន្មានយ៉ាង ។ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាឡើយ ។ បណ្ដាអធិករណ៍ទាំង ៤ សិក្ខាបទនោះចាត់ចូលក្នុងអធិករណ៍ណា ។ ចាត់ចូលក្នុងអាបត្តាធិករណ៍ ។ បណ្ដាសមថៈទាំង ៧ សិក្ខាបទនោះរម្ងាប់ដោយសមថៈប៉ុន្មានយ៉ាង ។ រម្ងាប់ដោយសមថៈពីរយ៉ាង គឺ សម្មុខាវិន័យ ១ បដិញ្ញាតករណៈ ១ ។ អ្វីជាវិន័យក្នុងសិក្ខាបទនោះ អ្វីជាអភិវិន័យក្នុងសិក្ខាបទនោះ ។ បញ្ញត្តិជាវិន័យ វិភត្តិជាអភិវិន័យ ។ អ្វីជាបាតិមោក្ខ ក្នុងសិក្ខាបទនោះ អ្វីជាអធិប្បាតិមោក្ខក្នុងសិក្ខាបទនោះ ។ បញ្ញត្តិជាបាតិមោក្ខ វិភត្តិជាអធិប្បាតិមោក្ខ ។ អ្វីជាវិបត្តិ ។ ការមិនសង្រួម

វិបត្តិ ។ កា សម្បត្តីតិ ។ សំវរោ សម្បត្តិ ។ កា បដិបត្តីតិ ។ ន ឯវរូបំ ករិស្សាមីតិ យាវជីវំ អាចាណកោដិកំ សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ កតិ អត្ថវសេ បដិច្ច ភគវតា ឧបក្កមិត្វា អសុចឹ មោចេន្តស្ស សង្ឃាទិសេសោ បញ្ញត្តោតិ ។ ទស អត្ថវសេ បដិច្ច ភគវតា ឧបក្កមិត្វា អសុចឹ មោចេន្តស្ស សង្ឃាទិសេសោ បញ្ញត្តោ សង្ឃសុដ្ឋុតាយ សង្ឃផាសុតាយ ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ បេសលានំ ភិក្ខូនំ ផាសុវិហារាយ ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ សម្បរាយិកានំ អាសវានំ បដិឃាតាយ អប្បសន្នានំ បសាទាយ បសន្នានំ ភិយ្យោភាវាយ សទ្ធម្មដ្ឋិតិយា វិនយានុគ្គហាយ ។ កេ សិក្ខន្តីតិ ។ សេក្ខា ច បុថុជ្ជនកល្យាណកា ច សិក្ខន្តិ ។ កេ សិក្ខិតសិក្ខាតិ ។ អរហន្តោ សិក្ខិតសិក្ខា ។ កត្ថ ឋិតន្តិ ។

ជាវិបត្តិ ។ អ្វីជាសម្បត្តិ ។ ការសង្រួមជាសម្បត្តិ ។ សេចក្ដីប្រតិបត្តិ (ក្នុងសិក្ខាបទនោះ) ដូចម្ដេច ។ ភិក្ខុសមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ដរាបដល់អស់ជីវិត មានជីវិតជាទីបំផុត ដោយគិតថា អញនឹងមិនធ្វើកម្មយ៉ាងនេះទេ (នេះជាសេចក្ដីប្រតិបត្តិ) ។ ព្រះមានព្រះភាគទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុព្យាយាមបញ្ចេញអសុចិ តើព្រោះអាស្រ័យអំណាចប្រយោជន៍ប៉ុន្មានយ៉ាង ។ ព្រះមានព្រះភាគទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុព្យាយាមបញ្ចេញអសុចិ ព្រោះអាស្រ័យអំណាចប្រយោជន៍ ១០ យ៉ាង គឺដើម្បីសេចក្ដីល្អដល់សង្ឃ ១ ដើម្បីសេចក្ដីសប្បាយដល់សង្ឃ ១ ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយ ដែលមិនមានអៀនខ្មាស ១ ដើម្បីកិរិយានៅជាសុខស្រួល ដល់ភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ ១ ដើម្បីរារាំងនូវអាសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន ១ ដើម្បីកំចាត់បង់នូវអាសវធម៌ទាំងឡាយក្នុងបរលោក ១ ដើម្បីញុំាងជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើង ១ ដើម្បីញុំាងជនទាំងឡាយដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើង ១ ដើម្បីតម្កល់នៅមាំនៃព្រះសទ្ធម្ម ១ ដើម្បីអនុគ្រោះដល់វិន័យ ១ ។ ពួកជនណាតែងសិក្សា ។ សេក្ខបុគ្គលនិងកល្យាណបុថុជ្ជនតែងសិក្សា ។ ជនពួកណាដែលមានសិក្ខាសិក្សាហើយ ។ ព្រះអរហន្តមានសិក្ខាសិក្សាហើយ ។ សិក្ខាបទនោះឋិតនៅក្នុងបុគ្គលពួកណា ។

សិក្ខាកាមេសុ ឋិតំ ។ កេ ជានន្តីតិ ។ យេសំ វត្តតិ តេ ជានន្តិ ។ កស្ស វចនន្តិ ។ ភគវតោ វចនំ អរហតោ សម្មាសម្ពុទ្ធស្ស ។ កេនាភតន្តិ ។ បរម្បរាភតំ ។

ឧបាលិ ទាសកោ ចេវ
សោណកោ សិគ្គវោ តថា
មោគ្គលីបុត្តេន បញ្ចមា
ឯតេ ជម្ពុសិរិវ្ហយេ ។
តតោ មហិន្ទោ ឥដ្ដិយោ
ឧត្តិយោ ចេវ សម្ពលោ ។ បេ ។
ឯតេ នាគា មហាបញ្ញា
វិនយញ្ញូ មគ្គកោវិទា
វិនយំ ទីបេ បកាសេសុំ
បិដកំ តម្ពបណ្ណិយាតិ ។

[១០] យេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន មាតុគ្គាមេន សទ្ធឹ កាយសំសគ្គំ ស-មាបជ្ជន្តស្ស សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ សា-វត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឧទាយឹ

ឋិតនៅក្នុងពួកសិក្ខាកាមបុគ្គល ។ ជនពួកណាតែងទ្រទ្រង់ទុក ។ សិក្ខាបទនោះតែងប្រព្រឹត្តទៅ ដល់ជនពួកណា ជនពួកនោះតែងទ្រទ្រង់ទុក ។ សិក្ខាបទនោះ ជាពាក្យរបស់នរណា ។ ជាពាក្យរបស់ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ។ សិក្ខាបទនោះ លោកអង្គណានាំមក ។ (ព្រះថេរៈដែលមាននាមដូចតទៅនេះ) នាំត ៗ គ្នាមក ។

ព្រះថេរៈឈ្មោះឧបាលិ ១ ទាសកៈ ១ សោណកៈ ១ សិគ្គវៈ ១
ព្រះមោគ្គលីបុត្ត ១ អង្គទៀតជាគម្រប់ ៥ ព្រះថេរៈទាំងនេះ
ឋិតនៅក្នុងទ្វីបមានឈ្មោះថាជម្ពូដ៏មានសិរី ។ តអំពីនោះមក
ព្រះមហិន្ទត្ថេរ ១ ព្រះឥដ្ដិយៈ ១ ព្រះឧត្តិយៈ ១ ព្រះសម្ពលៈ ១
។ បេ ។ ព្រះនាគត្ថេរទាំងនេះ មានប្រាជ្ញាច្រើន ជាអ្នកចេះ
ព្រះវិន័យ ឈ្លាសក្នុងមគ្គ បានប្រកាសវិនយបិដកទុក ក្នុង
តម្ពបណ្ណិទ្វីប ។

[១០] សួរថា ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តសង្ឃាទិសេសចំពោះភិក្ខុដែលស្ទាបអង្អែលកាយមាតុគ្រាមក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធ នូវព្រះឧទាយិ មានអាយុ ។

អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឧទាយិ មាតុគ្គាមេន សទ្ធឹ កាយសំសគ្គំ សមាបជ្ជិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។ បេ ។

[១១] មាតុគ្គាមំ ទុដ្ឋុល្លាហិ វាចាហិ ឱភាសន្តស្ស សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឧទាយឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឧទាយិ មាតុគ្គាមំ ទុដ្ឋុល្លាហិ វាចាហិ ឱភាសិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ បេ ។

[១២] មាតុគ្គាមស្ស សន្តិកេ អត្តកាមចារិយាយ វណ្ណំ ភាសន្តស្ស សង្ឃាទិសេសោ កត្ថ

ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលព្រះឧទាយិមានអាយុ ស្ទាប អង្អែលកាយមាតុគ្រាម ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាងសិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាឡើយ ។ បេ ។

[១១] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុដែលនិយាយចែចង់មាតុគ្រាមក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវព្រះឧទាយិមានអាយុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលព្រះឧទាយិមានអាយុនិយាយចែចង់មាតុគ្រាម ។ សិក្ខាបទនោះមានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះតាំងឡើង ដោយសមុដ្ឋាន ៣ យ៉ាង គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចា ១ តាំងឡើងអំពីវាចានិងចិត្ត មិនតាំងឡើងអំពីកាយ ១ តាំងឡើងអំពីកាយអំពីវាចានិងចិត្ត ។ បេ ។

[១២] សួរថា ព្រះមានព្រះភាគទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុ ដែលនិយាយសរសើរការបម្រើដោយកាម ដើម្បីខ្លួនក្នុងសំណាក់មាតុ-

បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឧទាយឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឧទាយិ មាតុគ្គាមស្ស សន្តិកេ អត្តកាមចារិចរិយាយ វណ្ណំ អភាសិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

[១៣] សញ្ចរិត្តំ សមាបជ្ជន្តស្ស សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឧទាយឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឧទាយិ សញ្ចរិត្តំ សមាបជ្ជិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ សមុដ្ឋាតិ ន វាចតោ ន ចិត្តតោ សិយា វាចតោ សមុដ្ឋាតិ ន កាយតោ ន ចិត្តតោ សិយា កាយតោ ច វាចតោ ច សមុដ្ឋាតិ ន ចិត្តតោ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ បេ ។

គ្រាមក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវ-បុគ្គលណា ។ ទ្រង់ប្រារព្ធនូវព្រះឧទាយិមានអាយុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលព្រះឧទាយិមានអាយុ និយាយសរសើរការបម្រើដោយកាម ដើម្បីខ្លួនក្នុងសំណាក់មាតុគ្រាម ។ សិក្ខាបទនោះមានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះតាំងឡើងដោយសមុដ្ឋាន ៣ យ៉ាង ។ បេ ។

[១៣] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេសចំពោះភិក្ខុដែលប្រព្រឹត្តនិយាយដឹកនាំ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធ នូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវព្រះឧទាយិមានអាយុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលព្រះឧទាយិមានអាយុ និយាយដឹកនាំ ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦ យ៉ាង គឺ តាំងឡើងអំពីកាយ មិនតាំងឡើងអំពីវាចានិងចិត្ត ១ តាំងឡើងអំពីវាចា មិនតាំងឡើងអំពីកាយនិងចិត្ត ១ តាំងឡើងអំពីកាយនិងវាចា មិនតាំងឡើងអំពីចិត្ត ១ តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចា ១ តាំងឡើងអំពីវាចានិងចិត្តមិនតាំងឡើងអំពីកាយ ១ តាំងឡើងអំពីកាយអំពីវាចា និងចិត្ត ១ ។ បេ ។

[១៤] សញ្ញាចិកាយ កុដឹ ការាបេន្តស្ស សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ អាឡវិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អាឡវិកេ[១] ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាឡវិកា ភិក្ខូ សញ្ញាចិកាយ កុដឹ ការាបេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

[១៥] មហល្លកំ វិហារំ ការាបេន្តស្ស សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ កោសម្ពិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឆន្នំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឆន្នោ វិហារវត្ថុំ សោធេន្តោ អញ្ញតរំ ចេតិយរុក្ខំ ឆេទាបេសិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

---

១ ឱ. ម. អាឡវកេ ។

មហាវិភង្គ មហាវារៈ ១៦ សង្ឃាទិសេស ទី ៦-៧

[១៨] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេសចំពោះភិក្ខុដែលឲ្យគេធ្វើកុដិ (មិនមានទាយកជាម្ចាស់របស់) ដោយការសូមគ្រឿងឧបករណ៍របស់គេមកដោយខ្លួនឯង ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរអាឡវី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវភិក្ខុទាំងឡាយដែលនៅក្នុងនគរអាឡវី ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលភិក្ខុទាំងឡាយនៅក្នុងនគរអាឡវី ឲ្យគេធ្វើកុដិ (មិនមានទាយកជាម្ចាស់របស់) ដោយការសូមគ្រឿងឧបករណ៍របស់គេមកដោយខ្លួនឯង ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះតាំងឡើង ដោយសមុដ្ឋានទាំង ៦ យ៉ាង ។ បេ ។

[១៩] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុដែលឲ្យគេធ្វើវិហារធំក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរកោសម្ពី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវព្រះឆន្នៈមានអាយុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលព្រះឆន្នៈមានអាយុ ជម្រះទីវិហារ បានប្រើគេឲ្យកាប់ដើមឈើដែលគេសន្មតថា ជាចេតិយ ១ ដើម ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះតាំងឡើង ដោយសមុដ្ឋានទាំង ៦ យ៉ាង ។ បេ ។

[១៦] ភិក្ខុំ អម្ពុលកោន ចាភជិកោន ជម្មេន អនុទ្ធំ-សេន្តស្ស សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ រាជគហេ បញ្ញត្តោ ។ កំ អារព្ភាតិ ។ មេត្តិយភុម្មជកេ ភិក្ខូ អា-រព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ មេត្តិយភុម្មជកា ភិក្ខូ អាយ-ស្មន្តំ ទព្វំ មល្លបុត្តំ អម្ពុលកោន ចាភជិកោន ជម្មេន អនុទ្ធំសេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិ-សមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

[១៧] ភិក្ខុំ អញ្ញភាគិយស្ស អធិករណស្ស កញ្ចិ ទេសំ លេសមត្តំ ឧបាទាយ ចាភជិកោន ជម្មេន អ-នុទ្ធំសេន្តស្ស សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ រាជគហេ បញ្ញត្តោ ។ កំ អារព្ភាតិ ។ មេត្តិយភុម្មជកេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ មេត្តិយភុម្មជកា ភិក្ខូ អាយស្មន្តំ ទព្វំ មល្លបុត្តំ អញ្ញភាគិយស្ស អធិករណស្ស កញ្ចិ ទេសំ លេសមត្តំ ឧបាទាយ ចាភជិកោន ជម្មេន អនុទ្ធំសេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។

[១៦] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុដែលចោទ (បង្កាច់) ភិក្ខុផងគ្នាដោយអាបត្តិបារាជិកមិនមានមូល ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវមេត្តិយភិក្ខុនិងភុម្មជកភិក្ខុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលមេត្តិយភិក្ខុនិងភុម្មជកភិក្ខុចោទ (បង្កាច់) ព្រះទព្វមល្លបុត្តមានអាយុ ដោយអាបត្តិបារាជិកមិនមានមូល ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះតាំងឡើង ដោយសមុដ្ឋាន ៣ យ៉ាង ។ បេ ។

[១៧] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុដែលចោទ (បង្កាច់) ភិក្ខុផងគ្នាដោយអាបត្តិបារាជិក ព្រោះអាស្រ័យហេតុបន្តិចបន្តួចរបស់អធិករណ៍ ជាចំណែកដទៃមកជាគ្រឿងអាង ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវមេត្តិយភិក្ខុនិងភុម្មជកភិក្ខុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលមេត្តិយភិក្ខុនិងភុម្មជកភិក្ខុចោទ (បង្កាច់) ព្រះទព្វមល្លបុត្តមានអាយុ ដោយអាបត្តិបារាជិក ព្រោះអាស្រ័យហេតុបន្តិចបន្តួចរបស់អធិករណ៍ជាចំណែកដទៃមកជាគ្រឿងអាង ។ សិក្ខាបទនោះមានតែបញ្ញត្តិ ១ ។

ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ បេ ។

[១៨] សង្ឃភេទកស្ស ភិក្ខុនោ យាវតតិយំ សមនុភាសនាយ[១] នប្បដិនិស្សជ្ជន្តស្ស សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ រាជគហេ បញ្ញត្តោ ។ កំ អារព្ភាតិ ។ ទេវទត្តំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ទេវទត្តោ សមគ្គស្ស សង្ឃស្ស ភេទាយ បរក្កមិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ បេ ។

[១៩] ភេទានុវត្តកានំ ភិក្ខូនំ យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជន្តានំ សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ រាជគហេ បញ្ញត្តោ ។ កំ អារព្ភាតិ ។ សម្ពហុលេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ សម្ពហុលា ភិក្ខូ ទេវទត្តស្ស សង្ឃភេទាយ បរក្កមន្តស្ស អនុវត្តកា អហេសុំ[២] តស្មឹ វត្ថុស្មឹ ។

១ សមនុភាសិយមានាយាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ២ ឱ. ម. ឯត្ថន្តរេ វគ្គវាទកាតិ ទិស្សតិ ។

បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ៣ យ៉ាង ។ បេ ។

[១៨] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុអ្នក (ព្យាយាម) បំបែកសង្ឃ ដែលសង្ឃបានសូត្រសមនុភាសនកម្មអស់វារៈ ៣ ដងហើយនៅតែមិនលះបង់ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវភិក្ខុឈ្មោះទេវ-ទត្ត ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលទេវទត្តភិក្ខុព្យាយាមដើម្បីបំបែកសង្ឃដែលព្រមព្រៀងគ្នា ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយវាចាចិត្ត ។ បេ ។

[១៩] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុទាំងឡាយ អ្នកប្រព្រឹត្តតាមនូវភិក្ខុដែល (ព្យាយាម) បំបែកសង្ឃ សង្ឃបានសូត្រសមនុភាសនកម្មអស់វារៈ ៣ ដង នៅតែមិនលះបង់ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវភិក្ខុច្រើនរូប ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលភិក្ខុទាំងឡាយច្រើនរូប ប្រព្រឹត្តតាមទេវទត្តជាអ្នកព្យាយាមដើម្បីបំបែកសង្ឃ ។

ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ បេ ។

[២០] ទុព្ពចស្ស ភិក្ខុនោ យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជន្តស្ស សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ កោសម្ពិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឆន្នំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឆន្នោ ភិក្ខូហិ សហធម្មិកំ វុច្ចមានោ អត្តានំ អវចនីយំ អកាសិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ បេ ។

[២១] កុលទូសកស្ស ភិក្ខុនោ យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជន្តស្ស សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អស្សជិបុនព្វសុកេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អស្សជិបុនព្វសុកា ភិក្ខូ សង្ឃេន

សិក្ខាបទនោះមានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាងសិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយវាចាចិត្ត ។ បេ ។

[២០] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេសចំពោះភិក្ខុអ្នក (រឹងរូស) ប្រដៅបានដោយក្រ សង្ឃបានសូត្រសមនុភាសនកម្មអស់វារៈ ៣ ដង នៅតែមិនលះបង់ ក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងនគរកោសម្ពី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវព្រះឆន្នៈមានអាយុ ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះរឿងរ៉ាវដែលព្រះឆន្នៈមានអាយុ កាលដែលភិក្ខុទាំងឡាយ ពោលទូន្មានប្រកបដោយធម៌ បានធ្វើខ្លួនឲ្យជាអ្នកគឺគេស្ដីប្រដៅមិនបាន ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយវាចាចិត្ត ។ បេ ។

[២១] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុអ្នកប្រទូស្តត្រកូល សង្ឃបានសូត្រសមនុភាសនកម្មអស់វារៈ ៣ ដង នៅតែមិនលះបង់ ក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវអស្សជិភិក្ខុនិងបុនព្វសុកភិក្ខុ ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះរឿងរ៉ាវដែលអស្សជិភិក្ខុនិងបុនព្វសុកភិក្ខុ សង្ឃ

មហាវិភង្គេ សោឡស មហាវារា ឧទ្ទានគាថា

បព្វាជនីយកម្មកតា ភិក្ខូ ឆន្ទគាមិតា ទោសគាមិតា មោហគាមិតា ភយគាមិតា ចាបេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ បេ ។

តេរស សង្ឃាទិសេសា និដ្ឋិតា ។

តស្សុទ្ទានំ

[២២] វិស្សដ្ឋិ កាយសំសគ្គោ[១]
ទុដ្ឋុល្លំ អត្តកាមតំ[២]
សញ្ចរិត្តំ កុដី ចេវ
វិហារោ ច អមូលកំ
កិញ្ចិ លេសញ្ច ភេទោ ច
តថេវ អនុវត្តកា
ទុព្វចំ កុលទូសញ្ច[៣]
សង្ឃាទិសេស[៤]តេរសាតិ ។

---

១ ឱ. ម. កាយសំសគ្គំ ។ ២ ឱ. ម. អត្តកាមញ្ច ។ ៣ កុលទូសន្តិ បាឋោ បញ្ញាយតិ ។ ៤ ឱ. ម. សង្ឃាទិសេសា ។

បានធ្វើបញ្ញាជនីយកម្មហើយ (ត្រឡប់ដេរប្រទេច) ថា ភិក្ខុទាំងឡាយ លុះក្នុងអំណាចសេចក្ដីស្រឡាញ់ លុះក្នុងអំណាចសេចក្ដីស្អប់ លុះក្នុងអំណាចសេចក្ដីលង់ លុះក្នុងអំណាចសេចក្ដីខ្លាច ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយវាចាចិត្ត ។ បេ ។

ចប់ សង្ឃាទិសេស ១៣ ។

ឧទ្ទាន គឺបញ្ជីរឿង នៃសង្ឃាទិសេសនោះដូច្នេះ

[២២] សង្ឃាទិសេសទាំង ១៣ គឺ សុក្កវិស្សដ្ឋិ ១ កាយសំសគ្គៈ ១ ទុដ្ឋុល្លវាចៈ ១ អត្តកាមបារិចរិយៈ ១ សញ្ចរិត្តៈ ១ កុដិការៈ ១ មហល្លកវិហារៈ ១ អមូលកៈ ១ កិញ្ចិទេស (អញ្ញភាគិយៈ) ១ សង្ឃភេទកៈ ១ ភេទានុវត្តកៈ ១ ទុព្វចៈ ១ កុលទូសកៈ ១ ។

[២៣] យន្តេន ភគវតា ជានតា បស្សតា អ-
រហតា សម្មាសម្ពុទ្ធេន បឋមោ អធិយតោ កត្ថ
បញ្ញត្តោ ។ កំ អារព្ភ ។ កិស្មឹ វត្ថុស្មឹ ។ អត្ថិ តត្ថ
បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តិ សព្វត្ថ បញ្ញត្តិ
បទេសប្បញ្ញត្តិ សាធារណប្បញ្ញត្តិ អសាធារណប្បញ្ញត្តិ
ឯកតោ បញ្ញត្តិ ឧភតោ បញ្ញត្តិ ។ បញ្ចន្នំ ចាតិ-
មោក្ខុទ្ទេសានំ កត្ថោគធំ កត្ថ បរិយាបន្នំ កតមេន
ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតិ ។ ចតុន្នំ វិបត្តីនំ កតមា
វិបត្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតមោ អាបត្តិក្ខន្ធោ ។
ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ ស-
មុដ្ឋាតិ ។ ចតុន្នំ អធិករណានំ កតមំ អធិករណំ ។
សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មតិ ។
កោ តត្ថ វិនយោ កោ តត្ថ អភិវិនយោ ។ កឹ
តត្ថ ចាតិមោក្ខំ កឹ តត្ថ អធិប្បាតិមោក្ខំ ។ កា
វិបត្តិ កា សម្បត្តិ កា បដិបត្តិ ។ កតិ អត្ថវសេ
បដិច្ច ភគវតា បឋមោ អធិយតោ បញ្ញត្តោ ។ កេ

[២៣] សួរថា ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តអនិយតៈទី ១ ក្នុងទីណា ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ បញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ អនុប្បន្នប្បញ្ញត្តិ ១ សព្វត្ថប្បញ្ញត្តិ ១ បទេសប្បញ្ញត្តិ ១ សាធារណប្បញ្ញត្តិ ១ អសាធារណប្បញ្ញត្តិ ១ ឯកតោបញ្ញត្តិ ១ ឧភតោបញ្ញត្តិ ១ មានក្នុងអនិយតៈទី ១ នោះដែរឬទេ ។ បណ្ដាបាតិមោក្ខុទ្ទេសទាំង ៥ យ៉ាង សិក្ខាបទនោះ ដាក់ចុះក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា មកកាន់ឧទ្ទេស ត្រង់ឧទ្ទេសណា ។ បណ្ដាវិបត្តិទាំង ៤ យ៉ាង សិក្ខាបទនោះ ចាត់ជាវិបត្តិអ្វី ។ បណ្ដាកងនៃអាបត្តិទាំង ៧ យ៉ាង សិក្ខាបទនោះ ចាត់ចូលក្នុងអាបត្តិកងណា ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានប៉ុន្មានយ៉ាង ។ បណ្ដាអធិករណ៍ទាំង ៤ យ៉ាង សិក្ខាបទនោះ ចាត់ជាអធិករណ៍អ្វី ។ បណ្ដាសមថៈទាំង ៧ យ៉ាង សិក្ខាបទនោះ រម្ងាប់ដោយសមថៈប៉ុន្មានយ៉ាង ។ អ្វីជាវិន័យក្នុងសិក្ខាបទនោះ អ្វីជាអភិវិន័យក្នុងសិក្ខាបទនោះ ។ អ្វីជាបាតិមោក្ខក្នុងសិក្ខាបទនោះ អ្វីជាអធិប្បាតិមោក្ខក្នុងសិក្ខាបទនោះ ។ អ្វីជាវិបត្តិ អ្វីជាសម្បត្តិ សេចក្ដីប្រតិបត្តិ (ក្នុងសិក្ខាបទនោះ) ដូចម្ដេច ។ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តអនិយតៈទី ១ ព្រោះអាស្រ័យអំណាចប្រយោជន៍ប៉ុន្មានយ៉ាង ។ ជនពួក

សិក្ខន្តិ ។ កេ សិក្ខិតសិក្ខា ។ កត្ថ ឋិតំ ។ កេ ធារេន្តិ ។ កស្ស វចនំ ។ កេនាភតន្តិ ។

[២៤] យេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន បឋមោ អនិយតោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឧទាយឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អា-យស្មា ឧទាយិ មាតុគ្គាមេន សទ្ធឹ ឯកោ ឯកាយ រហោ បដិច្ឆន្នេ អាសនេ អលង្កម្មនិយេ និសជ្ជំ កប្បេសិ តស្មឹ វត្ថុស្មឹ ។ អត្ថិ តត្ថ បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តីតិ ។ ឯកា បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្ន-ប្បញ្ញត្តិ តស្មឹ នត្ថិ ។ សព្វត្ថ បញ្ញត្តិ បទេសប្បញ្ញត្តី-តិ ។ សព្វត្ថ បញ្ញត្តិ ។ សាធារណប្បញ្ញត្តិ អសាធារណ-ប្បញ្ញត្តីតិ ។ អសាធារណប្បញ្ញត្តិ ។ ឯកតោ បញ្ញត្តិ ឧភ-តោ បញ្ញត្តីតិ ។ ឯកតោ បញ្ញត្តិ ។ បញ្ចន្នំ ចាតិ-មោក្ខុទ្ទេសានំ កត្ថោគធំ កត្ថ បរិយាបន្នន្តិ ។ និទា-នោគធំ និទានបរិយាបន្នំ ។ កតមេន ឧទ្ទេសេន

ណាតែងសិក្សា ។ ជនពួកណា មានសិក្ខាសិក្សាហើយ ។ សិក្ខាបទនោះ ឋិតនៅក្នុងជនពួកណា ។ ជនពួកណា តែងទ្រទ្រង់ទុក ។ សិក្ខាបទនោះ ជាពាក្យរបស់នរណា ។ សិក្ខាបទនោះ នរណានាំមក ។

[២៤] សួរថា ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តអនិយតៈទី ១ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវព្រះឧទាយិមានអាយុ ។ ព្រោះរឿងរ៉ាវដូចម្តេច ។ ព្រោះរឿងរ៉ាវដែលព្រះឧទាយិមានអាយុ តែម្នាក់ឯង សម្រេចនូវការអង្គុយលើអាសនៈដ៏ស្ងាត់កំបាំងល្មមធ្វើ (សេវនកិច្ចបាន) ជាមួយនឹងមាតុគ្រាមតែម្នាក់ ។ បញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ អនុប្បន្នប្បញ្ញត្តិ ១ ក្នុងអនិយតៈ ទី ១ នោះ មានដែរឬទេ ។ មានតែបញ្ញត្តិ ១ ឯអនុប្បញ្ញត្តិ និងអនុប្បន្នប្បញ្ញត្តិ មិនមានក្នុងសិក្ខាបទនោះទេ ។ សិក្ខាបទនោះ ជាសព្វត្ថប្បញ្ញត្តិ ឬជាបទេសប្បញ្ញត្តិ ។ ជាសព្វត្ថប្បញ្ញត្តិ ។ សិក្ខាបទនោះ ជាសាធារណប្បញ្ញត្តិ ឬជាអសាធារណប្បញ្ញត្តិ ។ ជាអសាធារណប្បញ្ញត្តិ ។ សិក្ខាបទនោះ ជាឯកតោបញ្ញត្តិ ឬជាឧភតោបញ្ញត្តិ ។ ជាឯកតោបញ្ញត្តិ ។ បណ្តាបាតិមោក្ខុទ្ទេសទាំង ៥ យ៉ាង សិក្ខាបទនោះ ដាក់ចុះក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា ។ ដាក់ចុះក្នុងនិទាន រាប់បញ្ចូលក្នុងនិទាន ។ សិក្ខាបទ

ឧទ្ទេសំ អាគច្ឆតីតិ ។ ចតុត្ថេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតិ ។ ចតុន្នំ វិបត្តីនំ កតមា វិបត្តីតិ ។ សិយា សីលវិបត្តិ សិយា អាចារវិបត្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតមោ អាបត្តិក្ខន្ធោតិ ។ សិយា បារាជិកាបត្តិក្ខន្ធោ សិយា សង្ឃាទិសេសាបត្តិក្ខន្ធោ សិយា បាចិត្តិយាបត្តិក្ខន្ធោ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតីតិ ។ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។ ចតុន្នំ អធិករណានំ កតមំ អធិករណន្តិ ។ អាបត្តាធិករណំ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មតីតិ ។ តីហិ សមថេហិ សម្មតិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។ កោ តត្ថ វិនយោ កោ តត្ថ អភិវិនយោតិ ។ បញ្ញត្តិ វិនយោ វិភត្តិ អភិវិនយោ ។ កឹ តត្ថ បាតិមោក្ខំ តត្ថ អធិប្បាតិមោក្ខន្តិ ។ បញ្ញត្តិ បាតិមោក្ខំ វិភត្តិ អធិប្បាតិមោក្ខំ ។ កា វិបត្តីតិ ។ អសំវរោ វិបត្តិ ។ កា សម្បត្តីតិ ។

នោះ មកកាន់ឧទ្ទេស ត្រង់ឧទ្ទេសណា ។ មកកាន់ឧទ្ទេសត្រង់ឧទ្ទេសទី ៤ ។ បណ្តាវិបត្តិទាំង ៤ យ៉ាង សិក្ខាបទនោះ ចាត់ជាវិបត្តិអ្វី ។ សិក្ខាបទនោះ ចាត់ជាសីលវិបត្តិក៏មាន ជាអាចារវិបត្តិក៏មាន ។ បណ្តាកងនៃអាបត្តិទាំង ៧ យ៉ាង សិក្ខាបទនោះ ចាត់ជាកងនៃអាបត្តិណា ។ ចាត់ជាកងនៃអាបត្តិបារាជិកក៏មាន ចាត់ជាកងនៃអាបត្តិសង្ឃាទិសេសក៏មាន ចាត់ជាកងនៃអាបត្តិបាចិត្តិយៈក៏មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានប៉ុន្មានយ៉ាង ។ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាទេ ។ សួរថា បណ្តាអធិករណ៍ទាំង ៤ យ៉ាង សិក្ខាបទនោះ ចាត់ជាអធិករណ៍អ្វី ។ ចាត់ជាអាបត្តាធិករណ៍ ។ បណ្តាសមថៈទាំង ៧ យ៉ាង សិក្ខាបទនោះ រម្ងាប់ដោយសមថៈប៉ុន្មានយ៉ាង ។ រម្ងាប់ដោយសមថៈ ៣ យ៉ាងគឺ ដោយសម្មុខាវិន័យ ១ បដិញ្ញាតករណៈ ១ សម្មុខាវិន័យនិងតិណវត្ថារកៈ ១ ។ អ្វីជាវិន័យក្នុងសិក្ខាបទនោះ អ្វីជាអភិវិន័យក្នុងសិក្ខាបទនោះ ។ បញ្ញត្តិជាវិន័យ វិភត្តិជាអភិវិន័យ ។ អ្វីជាបាតិមោក្ខក្នុងសិក្ខាបទនោះ អ្វីជាអធិប្បាតិមោក្ខក្នុងសិក្ខាបទនោះ ។ បញ្ញត្តិជាបាតិមោក្ខ វិភត្តិជាអធិប្បាតិមោក្ខ ។ អ្វីជាវិបត្តិ ។ សេចក្តីមិនសង្រួមជាវិបត្តិ ។ អ្វីជាសម្បត្តិ ។

២៧

មហាវិភង្គេ សោឡស មហាវារា បឋមោ អនិយតោ

សំវរោ សម្បត្តិ ។ កា បដិបត្តីតិ ។ ន ឯវរូបំ ការិស្សាមីតិ យាវជីវំ អាចាណកោជិកំ សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ កាតិ អត្ថវសេ បដិច្ច ភគវតា បឋមោ អនិយតោ បញ្ញត្តោតិ ។ ទស អត្ថវសេ បដិច្ច ភគវតា បឋមោ អនិយតោ បញ្ញត្តោ សង្ឃសុដ្ឋុតាយ សង្ឃផាសុតាយ ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ បេសលានំ ភិក្ខូនំ ផាសុវិហារាយ ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ សម្បរាយិកានំ អាសវានំ បដិឃាតាយ អប្បសន្នានំ បសាទាយ បសន្នានំ ភិយ្យោភាវាយ សទ្ធម្មដ្ឋិតិយា វិនយានុគ្គហាយ ។ កេ សិក្ខន្តីតិ ។ សេក្ខា ច បុថុជ្ជនកល្យាណកា ច សិក្ខន្តិ ។ កេ សិក្ខិតសិក្ខាតិ ។ អរហន្តោ សិក្ខិតសិក្ខា ។ កត្ថ ឋិតន្តិ ។ សិក្ខាកាមេសុ ឋិតំ ។

មហាវិភង្គ មហាវារៈ ១៦ អនិយតៈ ទី ១

សេចក្ដីសង្រួមជាសម្បត្តិ ។ សេចក្ដីប្រតិបត្តិ (ក្នុងសិក្ខាបទនោះ) ដូចម្ដេច ។ ភិក្ខុសមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ដរាបដល់អស់ជីវិត មានជីវិតជាទីបំផុត ដោយសេចក្ដីកំណត់ក្នុងចិត្តថា អញនឹងមិនធ្វើកម្មមានសភាពយ៉ាងនេះឡើយ (នេះជាសេចក្ដីប្រតិបត្តិ) ។ ព្រះមានព្រះភាគទ្រង់បញ្ញត្តអនិយតៈទី ១ ព្រោះអាស្រ័យអំណាចប្រយោជន៍ប៉ុន្មានយ៉ាង ។ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តអនិយតៈទី ១ ព្រោះអាស្រ័យអំណាចប្រយោជន៍ ១០ យ៉ាង គឺ ដើម្បីល្អដល់សង្ឃ ១ ដើម្បីសេចក្ដីសប្បាយដល់សង្ឃ ១ ដើម្បីសង្កត់សង្កិនបុគ្គលដែលមិនអៀនខ្មាស ១ ដើម្បីនៅជាសុខស្រួលដល់ភិក្ខុដែលមានសីលជាទីស្រឡាញ់ ១ ដើម្បីរាំងរាអាសវៈទាំងឡាយ ដែលកើតឡើងក្នុងបច្ចុប្បន្ន ១ ដើម្បីកំចាត់បង់នូវអាសវៈទាំងឡាយដែលកើតឡើងក្នុងបរលោក ១ ដើម្បីញ៉ាំងបុគ្គលទាំងឡាយដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ១ ដើម្បីញ៉ាំងបុគ្គលទាំងឡាយដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើង ១ ដើម្បីតម្កល់នៅមាំនៃព្រះសទ្ធម្ម ១ ដើម្បីអនុគ្រោះដល់វិន័យ ១ ។ ពួកជនណា តែងសិក្សា ។ ពួកសេក្ខបុគ្គលនិងកល្យាណបុថុជ្ជនតែងសិក្សា ។ ពួកជនណា មានសិក្ខាសិក្សាហើយ ។ ព្រះអរហន្តទាំងឡាយ មានសិក្ខាសិក្សាហើយ ។ សិក្ខាបទនោះ ឋិតនៅក្នុងជនពួកណា ។ ឋិតនៅក្នុងពួកសិក្ខាកាមបុគ្គល ។

កេ ធារេន្តីតិ ។ យេសំ វត្តតិ តេ ធារេន្តិ ។ កស្ស វចនន្តិ ។ ភគវតោ វចនំ អរហតោ សម្មា-សម្ពុទ្ធស្ស ។ កេនាភតន្តិ ។ បរម្បរាភតំ ។

ឧបាលិ ទាសកោ ចេវ
សោណកោ សិគ្គវោ តថា
មោគ្គលីបុត្តេន បញ្ចមា
ឯតេ ជម្ពុសិរិវ្ហយេ ។
តតោ មហិន្ទោ ឥដ្ដិយោ
ឧត្តិយោ ចេវ សម្ពលោ ។ បេ ។
ឯតេ នាគា មហាបញ្ញា
វិនយញ្ញូ មគ្គកោវិទា
វិនយំ ទីបេ បកាសេសុំ
បិដកំ តម្ពបណ្ណិយាតិ ។

[២៩] យន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ទុតិយោ អនិយតោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឧទាយឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឧទាយិ

ជនពួកណា តែងទ្រទ្រង់ទុក ។ សិក្ខាបទនោះ ប្រព្រឹត្តទៅដល់ពួកជនណា ពួកជននោះតែងទ្រទ្រង់ទុក ។ សិក្ខាបទនោះ ជាពាក្យរបស់នរណា ។ ជាពាក្យរបស់ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ។ សិក្ខាបទនោះ នរ-ណានាំមក ។ ព្រះថេរៈទាំងឡាយ (ដូចមាននាមតទៅនេះ) នាំតៗគ្នាមក ។

ព្រះឧបាលិ ១ ព្រះទាសកៈ ១ ព្រះសោណកៈ ១ ព្រះសិគ្គវៈ ១
និងព្រះមោគ្គលីបុត្ត ១អង្គទៀតជាគម្រប់ ៥ ព្រះថេរៈទាំងនេះ
នៅក្នុងទ្វីបមានឈ្មោះថា ជម្ពូ ដ៏មានសិរី ។ តអំពីនោះមក
ព្រះមហិន្ទៈ ១ ព្រះឥដ្ដិយៈ ១ ព្រះឧត្តិយៈ ១ ព្រះសម្ពលៈ ១
។ បេ ។ ព្រះនាគត្ថេរទាំងឡាយ នេះមានបញ្ញាច្រើន ចេះ
ព្រះវិន័យ ស្ទាត់ជំនាញក្នុងមគ្គ បានប្រកាសវិនយបិដកទុក
ក្នុងតម្ពបណ្ណិទ្វីប ។

[២៥] សួរថា ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តអនិយតៈទី ២ ក្នុងទីណា ។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនូវបុគ្គលណា ។ ទ្រង់ប្រារព្ធនូវព្រះឧទាយិមានអាយុ ។ ព្រោះរឿងរ៉ាវដូចម្ដេច ។ ព្រោះ

មាតុគ្គាមេន សទ្ធឹ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេសិ តស្មឹ វត្ថុស្មឹ ។ អត្ថិ តត្ថ បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តីតិ ។ ឯកា បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តិ តស្មឹ នត្ថិ ។ សព្វត្ថ បញ្ញត្តិ បទេស-ប្បញ្ញត្តីតិ ។ សព្វត្ថ បញ្ញត្តិ ។ សាធារណប្បញ្ញត្តិ អសាធារណប្បញ្ញត្តីតិ ។ អសាធារណប្បញ្ញត្តិ ។ ឯក-តោ បញ្ញត្តិ ឧភតោ បញ្ញត្តីតិ ។ ឯកតោ បញ្ញត្តិ ។ បញ្ចន្នំ បាតិមោក្ខុទ្ទេសានំ កត្ថោគធំ កត្ថ បរិយាប-ន្នន្តិ ។ និទានោគធំ និទានបរិយាបន្នំ ។ កតមេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតីតិ ។ ចតុត្ថេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតិ ។ ចតុន្នំ វិបត្តីនំ កតមា វិបត្តីតិ ។ សិយា សីលវិបត្តិ សិយា អាចារវិបត្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតមោ អាបត្តិក្ខន្ធោតិ ។ សិយា សង្ឃាទិសេសាបត្តិក្ខន្ធោ សិយា បាចិត្តិយាបត្តិក្ខន្ធោ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋា-តីតិ ។ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា

រឿងរ៉ាវដែលឧទាយិភិក្ខុមានអាយុ តែម្នាក់ឯង សម្រេចការអង្គុយក្នុងទីកំបាំងជាមួយនឹងមាតុគ្រាមតែម្នាក់ ។ បញ្ញត្តិ ១ អនុប្បញ្ញត្តិ ១ អនុប្បន្នប្បញ្ញត្តិ ១ មានក្នុងសិក្ខាបទនោះដែរឬទេ ។ មានតែបញ្ញត្តិ ១ ឯអនុប្បញ្ញត្តិ និងអនុប្បន្នប្បញ្ញត្តិ មិនមានក្នុងសិក្ខាបទនោះទេ ។ សិក្ខាបទនោះ ជាសព្វត្ថប្បញ្ញត្តិ ឬជាបទេសប្បញ្ញត្តិ ។ ជាសព្វត្ថប្បញ្ញត្តិ ។ សិក្ខាបទនោះ ជាសាធារណប្បញ្ញត្តិ ឬជាអសាធារណប្បញ្ញត្តិ ។ ជាអសាធារណប្បញ្ញត្តិ ។ សិក្ខាបទនោះ ជាឯកតោបញ្ញត្តិ ឬជាឧភតោបញ្ញត្តិ ។ ជាឯកតោបញ្ញត្តិ ។ បណ្តាបាតិមោក្ខុទ្ទេសទាំង ៤ យ៉ាង សិក្ខាបទនោះ ដាក់ចុះក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា ។ ដាក់ចុះក្នុងនិទាន រាប់បញ្ចូលក្នុងនិទាន ។ សិក្ខាបទនោះ មកកាន់ឧទ្ទេស ត្រង់ឧទ្ទេសណា ។ មកកាន់ឧទ្ទេសត្រង់ឧទ្ទេសទី ៤ ។ បណ្តាវិបត្តិទាំង ៤ យ៉ាង សិក្ខាបទនោះចាត់ជាវិបត្តិអ្វី ។ ចាត់ជាសីលវិបត្តិក៏មាន ចាត់ជាអាចារវិបត្តិក៏មាន ។ បណ្តាកងនៃអាបត្តិទាំង ៧ សិក្ខាបទនោះ ចាត់ជាកងនៃអាបត្តិណា ។ ជាកងនៃអាបត្តិសង្ឃាទិសេសក៏មាន ជាកងនៃអាបត្តិបាចិត្តិយៈក៏មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានប៉ុន្មានយ៉ាង ។ តាំងឡើងដោយសមុដ្ឋាន ៣ យ៉ាង

កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ ចតុន្នំ អធិករណានំ កតមំ អធិករណន្តិ ។ អាបត្តាធិករណំ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មតីតិ ។ តីហិ សមថេហិ សម្មតិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។

ទ្វេ អនិយតា និដ្ឋិតា ។

# តស្សុទ្ទានំ

[២៦] អលង្កម្មនិយញ្ចេវ
តថេវ ច ន ហេវ ខោ
អនិយតា សុបញ្ញត្តា
ពុទ្ធសេដ្ឋេន តាទិនាតិ ។

គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចា ១ តាំងឡើងអំពីវាចានិងចិត្ត មិនតាំងឡើងអំពីកាយ ១ តាំងឡើងអំពីកាយអំពីវាចានិងចិត្ត ១ ។ បណ្តាអធិករណ៍ទាំង ៤ យ៉ាង សិក្ខាបទនោះ ចាត់ជាអធិករណ៍ណា ។ ចាត់ជាអាបត្តាធិករណ៍ ។ បណ្តាសមថៈទាំង ៧ យ៉ាង សិក្ខាបទនោះរម្ងាប់ដោយសមថៈប៉ុន្មានយ៉ាង ។ រម្ងាប់ដោយសមថៈ ៣ យ៉ាង គឺដោយសម្មុខាវិន័យ ១ បដិញ្ញាតករណៈ ១ ដោយសម្មុខាវិន័យ និងតិណវត្ថារកៈ ១ ។

ចប់អនិយតៈ ទាំងពីរ ។

# ឧទ្ទាន គឺបញ្ជីរឿងនៃអនិយតៈនោះ ដូច្នេះ

[២៦] អនិយតៈ (ទាំងពីរ) គឺ អលង្កម្មនិយៈ ១ នាលង្កម្មនិយៈ ១ ដែលព្រះពុទ្ធប្រសើរ មានគុណធម៌ដ៏មាំមួន ទ្រង់បញ្ញត្តទុកហើយ ដោយល្អ ។

[២៧] យេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន អតិរេកចីវរំ ទសាហំ អតិក្កាមេន្តស្ស និស្សគ្គិយំ បាចិត្តិយំ កត្ថ បញ្ញត្តន្តិ ។ វេសាលិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ឆព្វគ្គិយេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិយា ភិក្ខូ អតិរេកចីវរំ[១] ធារេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ទ្វីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ ច វាចតោ ច សមុដ្ឋាតិ ន ចិត្តតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ បេ ។

[២៣៧] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរពីខាងក្រោយសម្តែងធម៌ ដល់មនុស្សដែលដើរអំពីមុខ ត្រូវអាបត្តិទុក្កដ ។ បេ ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ មានអនុប្បញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ គឺតាំងឡើងអំពីកាយនិងវាចានិងចិត្ត ។

[២៣៨] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរក្រៅផ្លូវសម្តែងធម៌ ដល់មនុស្សដែលដើរតាមផ្លូវ ត្រូវអាបត្តិទុក្កដ ។ បេ ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ មានអនុប្បញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ គឺតាំងឡើងអំពីកាយនិងវាចានិងចិត្ត ។

[២៣៩] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឈរបន្ទោបង់ឧច្ចារៈឬបស្សាវៈ ត្រូវអាបត្តិទុក្កដ ។ បេ ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ មានអនុប្បញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចា ។

១២៣



[២៤០] អនាទរិយំ បដិច្ច ហរិតេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តស្ស ទុក្កដំ ។ បេ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច ចិត្តតោ ច ស-មុដ្ឋាតិ ន វាចតោ ។

[២៤១] អនាទរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តស្ស ទុក្កដំ កត្ថ បញ្ញត្តន្តិ ។ សា-វត្ថិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ ឆព្វគ្គិយេ ភិក្ខូ អា-រព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឆព្វគ្គិយា ភិក្ខូ ឧទកេ ឧច្ចា-រម្បិ បស្សាវម្បិ ខេឡម្បិ អកំសុ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។

បាទុកាវគ្គោ សត្តមោ ។

បញ្ចសត្តតិ សេក្ខិយា និដ្ឋិតា ។

មហាវិភង្គេ កត្ថបញ្ញត្តិវារំ និដ្ឋិតំ ។

[២៤០] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បន្ទោបង់ឧច្ចារៈក្តី បស្សាវៈក្តី ស្តោះទឹកមាត់ក្តី ដាក់លើ (រុក្ខជាតិដើមឈើ) ដែលមានពណ៌ខៀវស្រស់ ត្រូវអាបត្តិទុក្កដ ។ បេ ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ មានអនុប្បញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចា ។

[២៤១] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បន្ទោបង់ឧច្ចារៈក្តី បស្សាវៈក្តី ស្តោះទឹកមាត់ក្តី ដាក់ក្នុងទឹក ត្រូវអាបត្តិទុក្កដ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងពួកឆព្វគ្គិយភិក្ខុបានបន្ទោបង់ឧច្ចារៈខ្លះ បស្សាវៈខ្លះ ស្តោះទឹកមាត់ខ្លះ ដាក់ក្នុងទឹក ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ មានអនុប្បញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចា ។

ចប់ បាទុកាវគ្គ ទី ៧ ។

សេក្ខិយវត្ត គឺវត្តដែលភិក្ខុត្រូវសិក្សា មាន ៧៥ ចប់តែប៉ុណ្ណោះ ។

ចប់ កត្ថបញ្ញត្តិវារៈ ក្នុងមហាវិភង្គ ។

# តស្សុទ្ទានំ

[២៤២] បរិមណ្ឌលំ បដិច្ឆន្នំ
សុសំវុតោក្ខិត្តចក្ខុដា
ឧក្ខិត្តោជ្ជគ្ឃិកា សទ្ទោ
តយោ ចេវ បចាលនា
ខម្ភំ ឱគុណ្ឋិតោ ចេវ
កុដិ បល្លត្ថិកាយ ច
សក្កច្ចំ បត្តសញ្ញី ច
សមសូបំ សមតិត្តិកំ
សក្កច្ចំ បត្តសញ្ញី ច
សបទានំ សមសូបកំ
ថូបតោ(១) ច បដិច្ឆន្នំ
វិញ្ញត្តុជ្ឈានសញ្ញិនា
ន មហន្តំ មណ្ឌលំ ទ្វារំ

១ ឱ. ម. ថូបកតោ ។

# ឧទ្ទាននៃសេក្ខិយវត្តនោះដូច្នេះ

[២៤២] រឿងភិក្ខុត្រូវស្លៀកដណ្តប់ ឲ្យជាបរិមណ្ឌល ១ រឿងភិក្ខុបិទបាំងកាយ ១ រឿងភិក្ខុសង្រួមឲ្យល្អ ១ រឿងភិក្ខុមានភ្នែកដាក់ចុះ ១ រឿងភិក្ខុសើយចីវរ ១ រឿងភិក្ខុធ្វើសំឡេងខ្លាំង ១ រឿងភិក្ខុគ្រលែងអវយវៈបីយ៉ាង ១ រឿងភិក្ខុស្ទឹមចង្កេះ ១ រឿងភិក្ខុទទូរក្បាល ១ រឿងភិក្ខុចំអើតជើង ១ រឿងភិក្ខុអង្គុយត្របោមក្បាលជង្គង់ ១ រឿងភិក្ខុទទួលបិណ្ឌបាតដោយគោរព ១ រឿងភិក្ខុទទួលបិណ្ឌបាតមានសេចក្តីសំគាល់តែក្នុងបាត្រ ១ រឿងភិក្ខុទទួលបិណ្ឌបាត ឲ្យមានសម្លស្មើគ្នា ១ រឿងភិក្ខុទទួលបិណ្ឌបាត ឲ្យត្រឹមស្មើមាត់បាត្រ ១ រឿងភិក្ខុឆាន់បិណ្ឌបាតដោយគោរព ១ រឿងភិក្ខុឆាន់បិណ្ឌបាតមានសេចក្តីសំគាល់តែក្នុងបាត្រ ១ រឿងភិក្ខុឆាន់បិណ្ឌបាតវាចឲ្យស្មើ ១ រឿងភិក្ខុឆាន់សម្លឲ្យស្មើនឹងបាយ ១ រឿងភិក្ខុឆាន់ច្រមចុះអំពីកំពូលបាយ ១ រឿងភិក្ខុកកាយបាយលុបសម្លម្ហូប ១ រឿងភិក្ខុសុំបិណ្ឌបាត ១ រឿងភិក្ខុសំគាល់គិតនឹងលើកទោស ១ រឿងភិក្ខុមិនធ្វើពំនូតបាយឲ្យធំហួសប្រមាណ ១ រឿងភិក្ខុធ្វើពំនូតបាយឲ្យបរិមណ្ឌល ១ រឿងភិក្ខុហាមាត់ចាំ

១២៤

មហាវិភង្គេ សោឡស មហាវារា សេក្ខិយកណ្ឌោ ឧទ្ទានគាថា

សព្វហត្ថំ ឯ ព្យាហារេ

ឧក្ខេចោ ឆេទនា កណ្ណោ

ជូនំ សិត្តាវកោរកំ

ជិវ្ហានិច្ឆារកាញ្ចេរ

ចបុចបុ សុរុសុរុ

ហត្ថោ បត្តោ ច ឱដ្ឋោ ច

សាមិសំ សិត្ថកេន ច

ឆត្តចាណិស្ស សទ្ធម្មំ

ឯ ទេសេន្តិ តថាគតា

ឯវមេវ ទណ្ឌចាណិស្ស

សត្ថអាវុធចាណិនំ

ចាទុកា ឧចាហនា ចេវ

យានសេយ្យាគតស្ស ច

បល្លត្ថិកានិសិន្នស្ស

វេឋិតោគុណ្ឋិតស្ស ច

ឆមាឌីចាសនេ ហានេ

ពំនូតបាយ ១ រឿងភិក្ខុញាត់ម្រាមដៃទាំងអស់ទៅក្នុងមាត់ ១ រឿងភិក្ខុនិយាយទាំងអាហារនៅក្នុងមាត់ ១ រឿងភិក្ខុបោះដុំបាយបរិភោគ ១ រឿងភិក្ខុខាំកាត់ពំនូតបាយ ១ រឿងភិក្ខុឆាន់អាហារបៀមទុលថ្ពាល់ ១ រឿងភិក្ខុឆាន់រលាស់ដៃ ១ រឿងភិក្ខុឆាន់ឲ្យជ្រុះគ្រាប់បាយ ១ រឿងភិក្ខុលៀនអណ្តាត ១ រឿងភិក្ខុឆាន់ឮសូរចបុចបុ ១ ឮសូរសុរុសុរុ ១ រឿងភិក្ខុឆាន់លិទ្ធដៃ ១ រឿងភិក្ខុឆាន់លិទ្ធបាត្រ ១ រឿងភិក្ខុឆាន់លិទ្ធបបូរមាត់ ១ រឿងភិក្ខុយកដៃដែលប្រឡាក់អាមិសទៅទទួលភាជន៍ទឹក ១ រឿងភិក្ខុចាក់ទឹកលាងបាត្រទាំងគ្រាប់បាយ ១ ព្រះតថាគតទាំងឡាយ មិនបានសម្តែងព្រះសទ្ធម្មដល់មនុស្សដែលមានឆត្រក្នុងដៃ និងមនុស្សដែលមានដំបងក្នុងដៃនិងមនុស្សមានគ្រឿងសស្ត្រា និងអាវុធក្នុងដៃ និងមនុស្សពាក់ទ្រនាប់ជើង ពាក់ស្បែកជើងឋិតនៅលើយាននិងលើដំណេក អង្គុយត្របោមក្បាលជង្គង់ ជួតក្បាល ទទូរក្បាល និងមិនអង្គុយលើផែនដី សម្តែងធម៌ដល់មនុស្សដែលអង្គុយនៅលើអាសនៈ មិនអង្គុយលើអាសនៈទាបសម្តែងធម៌ ដល់មនុស្សដែលអង្គុយលើអាសនៈខ្ពស់ មិនឈរសម្តែងធម៌ ដល់មនុស្សដែលអង្គុយ

បច្ឆតោ ឧប្បជេជ ច
បិតកេន ន កាតព្វំ
ហរិតេ ឧទកម្ហិ ចាតិ ។

តេសំ វគ្គានំ ឧទ្ទានំ

[២៤៣] បរិមណ្ឌលំ ឧជ្ជគ្ឃិ
ខម្ភំ បិណ្ឌំ តថេវ ច
កពឡា សុរុសុរុ ច
ចាទុកេន ច សត្តមាតិ ។

[២៤៤] មេថុនំ ធម្មំ បដិសេវន្តោ កតិ អាបត្តិយោ អាបជ្ជតិ ។ មេថុនំ ធម្មំ បដិសេវន្តោ តិស្សោ អាបត្តិយោ អាបជ្ជតិ ។ អក្ខាយិតេ សរីរេ មេថុនំ ធម្មំ បដិសេវតិ អាបត្តិ ចារាជិកស្ស យេភុយ្យេន ខាយិតេ សរីរេ មេថុនំ ធម្មំ បដិសេវតិ អាបត្តិ ថុល្លច្ចយស្ស វិវដកាតេ(១) មុខេ អច្ឆុបន្តំ អង្គជាតំ បវេសេតិ អាបត្តិ ទុក្កដស្ស មេថុនំ ធម្មំ បដិសេវន្តោ ឥមា តិស្សោ អាបត្តិយោ អាបជ្ជតិ ។

---

១ ឱ. វត្តកតេ ។ ម. វដ្ដកតេ ។

មិនដើរក្រោយ សម្តែងធម៌ដល់មនុស្សដែលដើរមុន មិនដើរក្រៅផ្លូវ សម្តែងធម៌ដល់មនុស្សដែលដើរតាមផ្លូវ រឿងភិក្ខុមិនត្រូវឈរបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ និងមិនត្រូវបន្ទោបង់ឧច្ចារៈ ឬបស្សាវៈលើវត្ថុស្រស់និងទឹក ។

## ឧទ្ទាននៃវគ្គទាំងនោះ ដូច្នេះ

[២៤៣] បរិមណ្ឌលវគ្គ ១ ឧជ្ជគ្ឃិកវគ្គ ១ ខម្ភកតវគ្គ ១ បិណ្ឌបាតវគ្គ ១ កពឡវគ្គ ១ សុរុសុរុវគ្គ ១ បាទុកាវគ្គទីប្រាំពីរ ១ ។

[២៤៤] ភិក្ខុសេពមេថុនធម្ម ត្រូវអាបត្តិប៉ុន្មាន ។ ភិក្ខុសេពមេថុនធម្ម ត្រូវអាបត្តិ ៣ គឺសេពមេថុនធម្ម ចំពោះសរីរៈដែលសត្វមិនទាន់ស៊ី ត្រូវអាបត្តិបារាជិក សេពមេថុនធម្ម ចំពោះសរីរៈដែលសត្វស៊ីហើយដោយច្រើន ត្រូវអាបត្តិថុល្លច្ច័យ បញ្ចូលអង្គជាតទៅក្នុងមាត់ដែលហាតែមិនឲ្យប៉ះ ត្រូវអាបត្តិទុក្កដ ភិក្ខុសេពមេថុនធម្ម ត្រូវអាបត្តិ ៣ នេះឯង ។

១២៧

## មហាវិភង្គេ សោឡស មហាវារា ចត្តារោ បារាជិកា

[២៤៥] អទិន្នំ អាទិយន្តោ កតិ អាបត្តិយោ អាបជ្ជតិ ។ អទិន្នំ អាទិយន្តោ តិស្សោ អាបត្តិយោ អាបជ្ជតិ បញ្ចមាសកំ វា អតិរេកបញ្ចមាសកំ វា អគ្ឃនកំ អទិន្នំ ថេយ្យសង្ខាតំ អាទិយតិ អាបត្តិ បារាជិកស្ស អតិរេកមាសកំ វា ឩនបញ្ចមាសកំ វា អគ្ឃនកំ អទិន្នំ ថេយ្យសង្ខាតំ អាទិយតិ អាបត្តិ ថុល្លច្ចយស្ស មាសកំ វា ឩនមាសកំ វា អគ្ឃនកំ អទិន្នំ ថេយ្យសង្ខាតំ អាទិយតិ អាបត្តិ ទុក្កដស្ស អទិន្នំ អាទិយន្តោ ឥមា តិស្សោ អាបត្តិយោ អាបជ្ជតិ ។

[២៤៦] សញ្ចិច្ច មនុស្សវិគ្គហំ ជីវិតា វោរោបេន្តោ កតិ អាបត្តិយោ អាបជ្ជតិ ។ សញ្ចិច្ច មនុស្សវិគ្គហំ ជីវិតា វោរោបេន្តោ តិស្សោ អាបត្តិយោ អាបជ្ជតិ មនុស្សំ ឱទិស្ស ឱបាតំ ខណតិ បបតិត្វា មរិស្សតីតិ អាបត្តិ ទុក្កដស្ស បបតិតេ ទុក្ខា វេទនា ឧប្បជ្ជតិ អាបត្តិ ថុល្លច្ចយស្ស មរតិ អាបត្តិ បារាជិកស្ស សញ្ចិច្ច មនុស្សវិគ្គហំ ជីវិតា វោរោបេន្តោ ឥមា តិស្សោ អាបត្តិយោ អាបជ្ជតិ ។

[២៤៥] ភិក្ខុកាន់យកទ្រព្យដែលគេមិនឲ្យ ត្រូវអាបត្តិប៉ុន្មាន ។ ភិក្ខុកាន់យកទ្រព្យ ដែលគេមិនឲ្យត្រូវអាបត្តិ ៣ គឺ កាន់យកទ្រព្យដែលគេមិនឲ្យ គួរដល់ថ្ងៃ ៥ មាសកក្តី លើសពី ៥ មាសកក្តី ដោយថេយ្យ-ចិត្ត ត្រូវអាបត្តិបារាជិក កាន់យកទ្រព្យដែលគេមិនឲ្យ គួរដល់ថ្ងៃលើសពី ១ មាសកក្តី ខ្វះពី ៥ មាសកក្តី ដោយថេយ្យចិត្ត ត្រូវអាបត្តិថុល្លច្ច័យ កាន់យកទ្រព្យដែលគេមិនឲ្យ គួរដល់ថ្ងៃ ១ មាសកក្តី ខ្វះពី ១ មាសកក្តី ដោយថេយ្យចិត្ត ត្រូវអាបត្តិទុក្កដ ភិក្ខុកាន់យកទ្រព្យដែលគេមិនឲ្យ ត្រូវអាបត្តិ ៣ នេះឯង ។

[២៤៦] ភិក្ខុក្លែងផ្តាច់បង់រាងកាយ របស់មនុស្សឲ្យធ្លាក់ចុះចាកជីវិតត្រូវអាបត្តិប៉ុន្មាន ។ ភិក្ខុក្លែងផ្តាច់បង់រាងកាយរបស់មនុស្សឲ្យធ្លាក់ចុះចាកជីវិត ត្រូវអាបត្តិ ៣ គឺ ជីករណ្តៅចំពោះមនុស្ស ដោយប៉ុនប៉ងថា អ្នកណានីមួយនឹងធ្លាក់ស្លាប់ដូច្នេះ ត្រូវអាបត្តិទុក្កដ កាលបើមនុស្សនោះធ្លាក់ទៅហើយកើតទុក្ខវេទនាឡើង ត្រូវអាបត្តិថុល្លច្ច័យ (បើ) មនុស្សនោះស្លាប់ ត្រូវអាបត្តិបារាជិក ភិក្ខុក្លែងផ្តាច់បង់ជីវិតរបស់មនុស្ស ត្រូវអាបត្តិ ៣ នេះឯង ។

[២៤៧] អសន្តំ អភូតំ ឧត្តរិមនុស្សធម្មំ ឧល្លបន្តោ កតិ អាបត្តិយោ អាបជ្ជតិ ។ អសន្តំ អភូតំ ឧត្តរិមនុស្សធម្មំ ឧល្លបន្តោ តិស្សោ អាបត្តិយោ អាបជ្ជតិ បាបិច្ឆោ ឥច្ឆាបកតោ អសន្តំ អភូតំ ឧត្តរិមនុស្សធម្មំ ឧល្លបតិ អាបត្តិ បារាជិកស្ស យោ តេ វិហារេ វសតិ សោ ភិក្ខុ អរហាតិ ភណតិ បដិវិជានន្តស្ស អាបត្តិ ថុល្លច្ចយស្ស នប្បដិវិជានន្តស្ស អាបត្តិ ទុក្កដស្ស អសន្តំ អភូតំ ឧត្តរិមនុស្សធម្មំ ឧល្លបន្តោ ឥមា តិស្សោ អាបត្តិយោ អាបជ្ជតិ ។

ចត្តារោ បារាជិកា និដ្ឋិតា ។

[២៤៨] ឧបក្កមិត្វា អសុចឹ មោចេន្តោ កតិ អាបត្តិយោ អាបជ្ជតិ ។ ឧបក្កមិត្វា អសុចឹ មោចេន្តោ តិស្សោ អាបត្តិយោ អាបជ្ជតិ ចេតេតិ ឧបក្កមតិ មុច្ចតិ អាបត្តិ សង្ឃាទិសេសស្ស ចេតេតិ ឧបក្កមតិ ន មុច្ចតិ អាបត្តិ ថុល្លច្ចយស្ស បយោគេ ទុក្កដំ ។

[២៤៧] ភិក្ខុពោលអួតឧត្តរិមនុស្សធម្មដែលមិនមាន ដែលមិនពិត ត្រូវអាបត្តិប៉ុន្មាន ។ ភិក្ខុពោលអួតឧត្តរិមនុស្សធម្ម ដែលមិនមាន ដែលមិនពិត ត្រូវអាបត្តិ ៣ គឺ ភិក្ខុមានសេចក្តីប្រាថ្នាលាមក មានសេចក្តីប្រាថ្នាគ្របសង្កត់ហើយ ពោលអួតឧត្តរិមនុស្សធម្ម ដែលមិនមាន ដែលមិនពិត ត្រូវអាបត្តិបារាជិក ភិក្ខុនិយាយកុហកថា ភិក្ខុណានៅក្នុងវិហាររបស់អ្នក ភិក្ខុនោះជាព្រះអរហន្ត កាលបើអ្នកស្តាប់ដឹងច្បាស់ ត្រូវអាបត្តិថុល្លច្ច័យ បើពុំដឹងច្បាស់ ត្រូវអាបត្តិទុក្កដ ភិក្ខុពោលអួតឧត្តរិ-មនុស្សធម្ម ដែលមិនមាន ដែលមិនពិត ត្រូវអាបត្តិ ៣ នេះឯង ។

ចប់ បារាជិក ៤ ។

[២៤៨] ភិក្ខុព្យាយាមបញ្ចេញអសុចិ ត្រូវអាបត្តិប៉ុន្មាន ។ ភិក្ខុព្យាយាមបញ្ចេញអសុចិ ត្រូវអាបត្តិ ៣ គឺ គិតព្យាយាមទាល់តែអសុចិឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស គិតព្យាយាម តែអសុចិមិនឃ្លាតចេញ ត្រូវអាបត្តិថុល្លច្ច័យ គ្រាន់តែព្យាយាម ត្រូវអាបត្តិទុក្កដ ។

មហាវិភង្គេ សោឡស មហាវារា តេរស សង្ឃាទិសេសា

[២៨៩] មាតុគ្គាមេន សទ្ធឹ កាយសំសគ្គំ សមាបជ្ជន្តោ តិស្សោ អាបត្តិយោ អាបជ្ជតិ កាយេន កាយំ អាមសតិ អាបត្តិ សង្ឃាទិសេសស្ស កាយេន កាយប្បដិពទ្ធំ អាមសតិ អាបត្តិ ថុល្លច្ចយស្ស កាយប្បដិពទ្ធេន កាយប្បដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។

[២៩០] មាតុគ្គាមំ ទុដ្ឋុល្លាហិ វាចាហិ ឱភាសន្តោ តិស្សោ អាបត្តិយោ អាបជ្ជតិ វច្ចមគ្គំ បស្សាវមគ្គំ អាទិស្ស វណ្ណម្បិ ភណតិ អវណ្ណម្បិ ភណតិ អាបត្តិ សង្ឃាទិសេសស្ស វច្ចមគ្គំ បស្សាវមគ្គំ ឋបេត្វា អធក្ខកំ ឧព្ភជានុមណ្ឌលំ អាទិស្ស វណ្ណម្បិ ភណតិ អវណ្ណម្បិ ភណតិ អាបត្តិ ថុល្លច្ចយស្ស កាយប្បដិពទ្ធំ អាទិស្ស វណ្ណម្បិ ភណតិ អវណ្ណម្បិ ភណតិ អាបត្តិ ទុក្កដស្ស ។

[២៩១] អត្តកាមចារិចរិយាយ វណ្ណំ ភាសន្តោ តិស្សោ អាបត្តិយោ អាបជ្ជតិ មាតុគ្គាមស្ស សន្តិកេ អត្តកាមចារិចរិយាយ វណ្ណំ ភាសតិ អាបត្តិ សង្ឃាទិសេសស្ស បណ្ឌកស្ស សន្តិកេ អត្តកាមចារិចរិយាយ

[២៤៩] ភិក្ខុដល់ព្រមនូវកាយសំសគ្គៈ មួយអន្លើដោយមាតុគ្រាម ត្រូវអាបត្តិ ៣ គឺភិក្ខុស្ទាបអង្អែលកាយ (ស្រី) ដោយកាយ (របស់ខ្លួន) ត្រូវអាបត្តិសង្ឃាទិសេស ស្ទាបអង្អែលវត្ថុដែលជាប់ដោយកាយ (ស្រី) ដោយកាយ (របស់ខ្លួន) ត្រូវអាបត្តិថុល្លច្ច័យ ស្ទាបអង្អែលវត្ថុដែលជាប់ដោយកាយ (ស្រី) ដោយវត្ថុជាប់នឹងកាយ (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ ។

[២៥០] ភិក្ខុនិយាយចែចង់មាតុគ្រាមដោយសំដីអាក្រក់ ត្រូវអាបត្តិ ៣ គឺ ភិក្ខុនិយាយសរសើរក្តី និយាយតិះដៀលក្តី ចំពោះវច្ចមគ្គឬបស្សាវមគ្គ ត្រូវអាបត្តិសង្ឃាទិសេស និយាយសរសើរក្តី និយាយតិះដៀលក្តី ចំពោះអវយវៈពីត្រឹមដងកាំបិតចុះមកខាងក្រោម ពីមណ្ឌលជង្គង់ឡើងទៅខាងលើ វៀរលែងតែវច្ចមគ្គនិងបស្សាវមគ្គចេញ ត្រូវអាបត្តិថុល្លច្ច័យ និយាយសរសើរក្តី និយាយតិះដៀលក្តី ចំពោះវត្ថុជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ ។

[២៥១] ភិក្ខុនិយាយសរសើរការបម្រើកាមដើម្បីខ្លួន ត្រូវអាបត្តិ ៣ គឺ និយាយសរសើរការបម្រើកាមដើម្បីខ្លួន ក្នុងសំណាក់មាតុ-គ្រាម ត្រូវអាបត្តិសង្ឃាទិសេស និយាយសរសើរការបម្រើកាមដើម្បីខ្លួន

វណ្ណំ ភាសតិ អាបត្តិ ថុល្លច្ចយស្ស តិរច្ឆានគតស្ស សន្តិកេ អត្តកាមចារិចរិយាយ វណ្ណំ ភាសតិ អាបត្តិ ទុក្កដស្ស ។

[២៨២] សញ្ចរិត្តំ សមាបជ្ជន្តោ តិស្សោ អាបត្តិយោ អាបជ្ជតិ បដិគ្គណ្ហាតិ វីមំសតិ បច្ចាហរតិ អាបត្តិ សង្ឃាទិសេសស្ស បដិគ្គណ្ហាតិ វីមំសតិ ន បច្ចា-ហរតិ អាបត្តិ ថុល្លច្ចយស្ស បដិគ្គណ្ហាតិ ន វីមំសតិ ន បច្ចាហរតិ អាបត្តិ ទុក្កដស្ស ។

[២៨៣] សញ្ញាចិកាយ កុដឹ ការាបេន្តោ តិស្សោ អាបត្តិយោ អាបជ្ជតិ ការាបេតិ បយោគេ ទុក្កដំ ឯ-កបិណ្ឌេ អនាគតេ អាបត្តិ ថុល្លច្ចយស្ស តស្មឹ បិណ្ឌេ អាគតេ អាបត្តិ សង្ឃាទិសេសស្ស ។

[២៨៤] មហល្លកំ វិហារំ ការាបេន្តោ តិស្សោ អាបត្តិយោ អាបជ្ជតិ ការាបេតិ បយោគេ ទុក្កដំ ឯក-បិណ្ឌេ អនាគតេ អាបត្តិ ថុល្លច្ចយស្ស តស្មឹ បិណ្ឌេ អាគតេ អាបត្តិ សង្ឃាទិសេសស្ស ។

ក្នុងសំណាក់បណ្ឌក ត្រូវអាបត្តិថុល្លច្ច័យ និយាយសរសើរការបម្រើកាម ដើម្បីខ្លួនក្នុងសំណាក់តិរច្ឆាន ត្រូវអាបត្តិទុក្កដ ។

[២៥២] ភិក្ខុប្រព្រឹត្តការជើកនាំ (ពាក្យប្រុសស្រី) ត្រូវអាបត្តិ ៣ គឺ ទទួលពាក្យខាង (ប្រុស) ហើយទៅនិយាយល្បងមើល (នឹងស្រី) ហើយត្រឡប់មកប្រាប់ (ខាងប្រុសវិញ) ត្រូវអាបត្តិសង្ឃាទិសេស ទទួលពាក្យហើយ ទៅនិយាយល្បងមើល តែមិនត្រឡប់មកប្រាប់វិញ ត្រូវអាបត្តិថុល្លច្ច័យ ទទួលពាក្យហើយ តែមិនទៅនិយាយល្បងមើល មិនត្រឡប់មកប្រាប់វិញ ត្រូវអាបត្តិទុក្កដ ។

[២៥៣] ភិក្ខុឲ្យគេធ្វើកុដិ ដោយការសូមគ្រឿងឧបករណ៍ពីគេមក ដោយខ្លួនឯង ត្រូវអាបត្តិ ៣ គឺ ឲ្យគេធ្វើត្រូវអាបត្តិទុក្កដ ក្នុងប្រយោគ (ដែលធ្វើ) កាលបើមិនទាន់បូកលាបដុំកំបោរ ឬដីស្អិតមួយដុំនៅឡើយ ត្រូវអាបត្តិថុល្លច្ច័យ កាលបើបានបូកលាបដុំកំបោរ ឬដីស្អិតមួយដុំនោះ ស្រេចហើយ ត្រូវអាបត្តិសង្ឃាទិសេស ។

[២៥៤] ភិក្ខុឲ្យគេធ្វើវិហារធំ ត្រូវអាបត្តិ ៣ គឺ ឲ្យគេធ្វើ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគ (ដែលប្រើគេឲ្យធ្វើ) កាលបើមិនទាន់បូកលាបដុំកំបោរ ឬដីស្អិតមួយដុំ នៅឡើយ ត្រូវអាបត្តិថុល្លច្ច័យ កាលបើបានបូកលាបដុំកំបោរ ឬ ដីស្អិតមួយដុំនោះ ស្រេចហើយ ត្រូវអាបត្តិសង្ឃាទិសេស ។

[២៨៥] ភិក្ខុំ អមូលកេន ចារាជិកេន ជម្មេន អនុទ្ធំសេន្តោ តិស្សោ អាបត្តិយោ អាបជ្ជតិ អនោកាសំ ការាបេត្វា ចាវនាជិប្បាយោ វទេតិ អាបត្តិ សង្ឃាជិសេសេន ទុក្កដស្ស ឱកាសំ ការាបេត្វា អក្កោសាជិប្បាយោ វទេតិ អាបត្តិ ឱមសវាទស្ស ។

[២៨៦] ភិក្ខុំ អញ្ញភាគិយស្ស អជិករណស្ស កិញ្ចិ ទេសំ លេសមត្តំ ឧចាជាយ ចារាជិកេន ជម្មេន អនុទ្ធំសេន្តោ តិស្សោ អាបត្តិយោ អាបជ្ជតិ អនោកាសំ ការាបេត្វា ចាវនាជិប្បាយោ វទេតិ អាបត្តិ សង្ឃាជិសេសេន ទុក្កដស្ស ឱកាសំ ការាបេត្វា អក្កោសាជិប្បាយោ វទេតិ អាបត្តិ ឱមសវាទស្ស ។

[២៨៧] សង្ឃភេទកោ ភិក្ខុ យាវតតិយំ សមនុភាសិយមានោ នប្បដិនិស្សជ្ជន្តោ តិស្សោ អាបត្តិយោ អាបជ្ជតិ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា កម្មវាចាបរិយោសានេ អាបត្តិ សង្ឃាជិសេសស្ស ។

[២៥៥] ភិក្ខុចោទភិក្ខុផងគ្នា ដោយអាបត្តិបារាជិក មិនមានមូល ត្រូវអាបត្តិ ៣ គឺ មិនសូមឱកាសជាមុនសិន ហើយចោទ ដោយមានប្រាថ្នា ដើម្បីឲ្យឃ្លាតចាកព្រហ្មចារ្យ ត្រូវអាបត្តិសង្ឃាទិសេស និង ទុក្កដ ភិក្ខុសូមឱកាសជាមុនហើយទើបចោទ ដោយមានប្រាថ្នានឹងជេរ ត្រូវអាបត្តិបាចិត្តិយៈ ព្រោះពោលពាក្យចាក់ដោត ។

[២៥៦] ភិក្ខុចោទភិក្ខុផងគ្នា ដោយអាបត្តិបារាជិក ព្រោះអាស្រ័យគ្រឿងអាងណាមួយ គ្រាន់តែជាលេសនៃអធិករណ៍ជាចំណែកដទៃ ត្រូវអាបត្តិ ៣ គឺភិក្ខុមិនសូមឱកាស (ជាមុន) ហើយចោទ ដោយមានប្រាថ្នា ដើម្បីឲ្យឃ្លាតចាកព្រហ្មចារ្យ ត្រូវអាបត្តិសង្ឃាទិ-សេស និង ទុក្កដ សូមឱកាស (ជាមុន) ហើយចោទ ដោយមានប្រាថ្នានឹងជេរ ត្រូវអាបត្តិបាចិត្តិយៈ ព្រោះពោលពាក្យចាក់ដោត ។

[២៥៧] ភិក្ខុអ្នកបំបែកសង្ឃ កាលបើសង្ឃបានសូត្រសមនុភា-សនកម្ម អស់វារៈ ៣ ដង ហើយនៅតែមិនលះបង់ ត្រូវអាបត្តិ ៣ គឺ ត្រូវអាបត្តិទុក្កដ ក្នុងខណៈសូត្រញត្តិ (ដំបូង) ត្រូវអាបត្តិថុល្លច្ច័យ ដោយសូត្រកម្មវាចាពីរដង ត្រូវអាបត្តិសង្ឃាទិសេស ក្នុងខណៈសូត្រកម្មវាចាចប់ ។

[២៥៨] ភេទកានុវត្តកា ភិក្ខូ យាវតតិយំ សម-
នុភាសិយមានា នប្បដិនិស្សជ្ជន្តា តិស្សោ អាបត្តិយោ
អាបជ្ជន្តិ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ច-
យា កម្មវាចាបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។

[២៥៩] ទុព្វចោ ភិក្ខុ យាវតតិយំ សមនុភាសិយ-
មានោ នប្បដិនិស្សជ្ជន្តោ តិស្សោ អាបត្តិយោ អាបជ្ជតិ
ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា កម្មវា-
ចាបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។

[២៦០] កុលទូសកោ ភិក្ខុ យាវតតិយំ សមនុ-
ភាសិយមានោ នប្បដិនិស្សជ្ជន្តោ តិស្សោ អាបត្តិយោ
អាបជ្ជតិ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា
កម្មវាចាបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។

តេរស សង្ឃាទិសេសា និដ្ឋិតា ។

[២៥៨] ពួកភិក្ខុអ្នកប្រព្រឹត្តតាមភិក្ខុដែលបំបែកសង្ឃ កាលបើសង្ឃបានសូត្រសមនុភាសនកម្ម អស់វារៈជាគម្រប់ ៣ ដងហើយ នៅតែមិនលះបង់ ត្រូវអាបត្តិ ៣ គឺ ត្រូវអាបត្តិទុក្កដ ក្នុងខណៈសូត្រញត្តិ (ជាដំបូង) ត្រូវអាបត្តិថុល្លច្ច័យ ដោយសូត្រកម្មវាចាពីរដង ត្រូវសង្ឃាទិសេស ក្នុងខណៈសូត្រកម្មវាចាចប់ ។

[២៥៩] ភិក្ខុដែលគេប្រដៅបានដោយក្រ កាលបើសង្ឃបានសូត្រសមនុភាសនកម្ម អស់វារៈជាគម្រប់ ៣ ដងហើយ នៅតែមិនលះបង់ ត្រូវអាបត្តិ ៣ គឺ ត្រូវអាបត្តិទុក្កដ ក្នុងខណៈសូត្រញត្តិ (ជាដំបូង) ត្រូវអាបត្តិថុល្លច្ច័យ ដោយសូត្រកម្មវាចាពីរដង ត្រូវអាបត្តិសង្ឃាទិសេស ក្នុងខណៈសូត្រកម្មវាចាចប់ ។

[២៦០] ភិក្ខុទ្រូស្តត្រកូល កាលបើសង្ឃបានសូត្រសមនុភាសនកម្ម អស់វារៈជាគម្រប់ ៣ ដងហើយ នៅតែមិនលះបង់ ត្រូវអាបត្តិ ៣ គឺ ត្រូវអាបត្តិទុក្កដ ក្នុងខណៈសូត្រញត្តិ (ជាដំបូង) ត្រូវអាបត្តិថុល្លច្ច័យ ដោយសូត្រកម្មវាចាពីរដង ត្រូវអាបត្តិសង្ឃាទិសេស ក្នុងខណៈសូត្រកម្មវាចាចប់ ។

ចប់ សង្ឃាទិសេស ១៣ ។

១៣៣

មហាវិភង្គេ សោឡស មហាវារា និស្សគ្គិយកណ្ឌេ កឋិនវគ្គោ

[២៦១] អតិរេកចីវរំ ទសាហំ អតិក្កាមេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ និស្សគ្គិយំ បាចិត្តិយំ ។

[២៦២] ឯករត្តឹ តិចីវរេន វិប្បវសន្តោ ឯកំ អា-បត្តឹ អាបជ្ជតិ និស្សគ្គិយំ បាចិត្តិយំ ។

[២៦៣] អកាលចីវរំ បដិគ្គហេត្វា មាសំ អតិក្កា-មេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ និស្សគ្គិយំ បាចិត្តិយំ ។

[២៦៤] អញ្ញាតិកាយ ភិក្ខុនិយា បុរាណចីវរំ ធោវាបេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ធោវាបេតិ បយោ-គេ ទុក្កដំ ធោវាបិតេ និស្សគ្គិយំ បាចិត្តិយំ ។

[២៦៥] អញ្ញាតិកាយ ភិក្ខុនិយា ហត្ថតោ ចីវរំ បដិគ្គណ្ហន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ គណ្ហាតិ បយោ-គេ ទុក្កដំ គហិតេ និស្សគ្គិយំ បាចិត្តិយំ ។

[២៦៦] អញ្ញាតកំ គហបតឹ វា គហបតានឹ វា ចីវរំ វិញ្ញាបេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ វិញ្ញាបេតិ បយោ-គេ ទុក្កដំ វិញ្ញាបិតេ និស្សគ្គិយំ បាចិត្តិយំ ។

[២៦១] ភិក្ខុទុកអតិរេកចីវរឲ្យកន្លងហួស ១០ ថ្ងៃទៅ ត្រូវអាបត្តិ ១ គឺ និស្សគ្គិយបាចិត្តិយៈ ។

[២៦២] ភិក្ខុនៅប្រាសចាកត្រៃចីវរ អស់មួយរាត្រី ត្រូវអាបត្តិ ១ គឺ និស្សគ្គិយបាចិត្តិយៈ ។

[២៦៣] ភិក្ខុទទួលអកាលចីវរ ហើយទុកឲ្យកន្លងហួសមួយខែទៅ ត្រូវអាបត្តិ ១ គឺ និស្សគ្គិយបាចិត្តិយៈ ។

[២៦៤] ភិក្ខុប្រើភិក្ខុនីដែលមិនមែនជាញាតិឲ្យលាងចីវរចាស់ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលប្រើឲ្យលាង លុះឲ្យលាងរួចហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

[២៦៥] ភិក្ខុទទួលចីវរអំពីដៃភិក្ខុនី ដែលមិនមែនជាញាតិ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលទទួល លុះទទួលបានមកហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

[២៦៦] ភិក្ខុសូមចីវរនឹងគហបតីក្តី គហបតានីក្តី ដែលមិនមែនជាញាតិ ត្រូវអាបត្តិ ២ គឺភិក្ខុកំពុងសូម ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលសូម លុះសូមបានមកហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

[២៦៧] អញ្ញាតកំ គហបតឹ វា គហបតានឹ វា តន្តវាយេ ចីវរំ វិញ្ញាបេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ វិញ្ញាបេតិ បយោគេ ទុក្កដំ វិញ្ញាបិតេ និស្សគ្គិយំ ចាចិត្តិយំ ។

[២៦៨] បុព្វេ អប្បវារិតោ អញ្ញាតកំ គហបតិកំ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ វិកប្បំ អាបជ្ជតិ បយោគេ ទុក្កដំ វិកប្បំ អាបន្នេ និស្សគ្គិយំ ចាចិត្តិយំ ។

[២៦៩] បុព្វេ អប្បវារិតោ អញ្ញាតកេ គហបតិកេ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ វិកប្បំ អាបជ្ជតិ បយោគេ ទុក្កដំ វិកប្បំ អាបន្នេ និស្សគ្គិយំ ចាចិត្តិយំ ។

[២៧០] អតិរេកតិក្ខត្តុំ ចោទនាយ អតិរេកឆក្ខត្តុំ ឋានេន ចីវរំ អភិនិប្ផាទេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ អភិនិប្ផាទេតិ បយោគេ ទុក្កដំ អភិនិប្ផាទិតេ និស្សគ្គិយំ ចាចិត្តិយំ ។

កឋិនវគ្គោ បឋមោ ។

[២៦៧] ភិក្ខុសូមចីវរនឹងគហបតីក្តី នឹងគហបតានីក្តី ដែលមិនមែនជាញាតិ ឲ្យច្រើនលើសពីស្បង់និងចីពរនោះទៅ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងសូម លុះសូមបានមកហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

[២៦៨] ភិក្ខុដែលគេមិនបានបវារណាទុកជាមុន ហើយចូលទៅរកគហបតី ដែលមិនមែនជាញាតិ ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ (ចង់បានឲ្យល្អហួសហេតុ) ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលដល់នូវកិរិយាកំណត់ក្នុងចីវរ លុះកំណត់ចីវរបានហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

[២៦៩] ភិក្ខុដែលគេមិនបានបវារណាទុកជាមុន ហើយចូលទៅរកគហបតីទាំងឡាយ ដែលមិនមែនជាញាតិ ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលដល់នូវកិរិយាកំណត់ក្នុងចីវរ លុះកំណត់ក្នុងចីវររួចហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

[២៧០] ភិក្ខុឲ្យចីវរសម្រេចបានដោយការតឹងទារឲ្យលើសអំពី ៣ ដង ដោយការឈរឲ្យលើសអំពី ៦ ដង ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឲ្យចីវរសម្រេច កាលបើចីវរសម្រេចហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

ចប់ កឋិនវគ្គ ទី ១ ។

[២៧១] កោសិយមិស្សកំ សន្ថតំ ការាបេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ការាបេតិ បយោគេ ទុក្កដំ ការាបិតេ និស្សគ្គិយំ ចាចិត្តិយំ ។

[២៧២] សុទ្ធកាឡកានំ ឯឡកលោមានំ សន្ថតំ ការាបេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ការាបេតិ បយោគេ ទុក្កដំ ការាបិតេ និស្សគ្គិយំ ចាចិត្តិយំ ។

[២៧៣] អនាទយិត្វា តុលំ ឱទាតានំ តុលំ គោចរិយានំ នវំ សន្ថតំ ការាបេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ការាបេតិ បយោគេ ទុក្កដំ ការាបិតេ និស្សគ្គិយំ ចាចិត្តិយំ ។

[២៧៤] អនុវស្សំ សន្ថតំ ការាបេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ការាបេតិ បយោគេ ទុក្កដំ ការាបិតេ និស្សគ្គិយំ ចាចិត្តិយំ ។

[២៧៥] អនាទយិត្វា បុរាណសន្ថតស្ស សាមន្តា សុគតវិទត្ថឹ នវំ និសីទនសន្ថតំ ការាបេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ការាបេតិ បយោគេ ទុក្កដំ ការាបិតេ និស្សគ្គិយំ ចាចិត្តិយំ ។

[២៧១] ភិក្ខុឲ្យគេធ្វើសន្ថ័ត លាយដោយសូត្រ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឲ្យគេធ្វើ លុះឲ្យគេធ្វើស្រេចហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

[២៧២] ភិក្ខុឲ្យគេធ្វើសន្ថ័ត ដោយរោមចៀម មានពណ៌ខ្មៅសុទ្ធ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឲ្យគេធ្វើ លុះឲ្យគេធ្វើស្រេចហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

[២៧៣] ភិក្ខុធ្វើសន្ថ័តថ្មី មិនលាយរោមចៀមស ទម្ងន់មួយជញ្ជីង រោមចៀមក្រហម ទម្ងន់មួយជញ្ជីង ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឲ្យគេធ្វើ លុះឲ្យគេធ្វើរួចហើយ ត្រូវនិស្សគ្គិយបា-ចិត្តិយៈ ។

[២៧៤] ភិក្ខុឲ្យគេធ្វើសន្ថ័តរាល់ ៗ ឆ្នាំ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឲ្យគេធ្វើ លុះឲ្យគេធ្វើរួចហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

[២៧៥] ភិក្ខុឲ្យគេធ្វើសន្ថ័តសម្រាប់អង្គុយថ្មី មិនលាយសន្ថ័តចាស់មួយចំអាមព្រះសុគត ដោយជុំវិញ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលប្រើឲ្យគេធ្វើ លុះប្រើឲ្យគេធ្វើរួចហើយ ត្រូវនិស្ស-គ្គិយបាចិត្តិយៈ ។

[២៧៦] ឯឡកលោមានិ បដិគ្គហេត្វា តិយោជនំ អតិក្កាមេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ បឋមំ បាទំ តិយោជនំ អតិក្កាមេតិ អាបត្តិ ទុក្កដស្ស ទុតិយំ បាទំ អតិក្កាមេតិ និស្សគ្គិយំ បាចិត្តិយំ ។

[២៧៧] អញ្ញាតិកាយ ភិក្ខុនិយា ឯឡកលោ-មានិ ធោវាបេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ធោវាបេតិ បយោគេ ទុក្កដំ ធោវាបិតេ និស្សគ្គិយំ បាចិត្តិយំ ។

[២៧៨] រូបិយំ បដិគ្គណ្ហន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ គណ្ហាតិ បយោគេ ទុក្កដំ គហិតេ និស្សគ្គិយំ បាចិត្តិយំ ។

[២៧៩] នានប្បការកំ រូបិយសំវោហារំ សមាប-ជ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ សមាបជ្ជតិ បយោគេ ទុក្កដំ សមាបន្នេ និស្សគ្គិយំ បាចិត្តិយំ ។

[២៨០] នានប្បការកំ កយវិក្កយំ សមាបជ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ សមាបជ្ជតិ បយោគេ ទុក្កដំ សមាបន្នេ និស្សគ្គិយំ បាចិត្តិយំ ។

កោសិយវគ្គោ ទុតិយោ ។

[២៧៦] ភិក្ខុទទួលរោមចៀម ហើយនាំយកឲ្យកន្លងហួស ៣ យោជន៍ទៅ ត្រូវអាបត្តិ ២ គឺ ឈានជំហានដំបូងឲ្យកន្លងហួស ៣ យោជន៍ទៅ ត្រូវអាបត្តិទុក្កដ ឈានជំហានទី ២ ឲ្យកន្លងហួសទៅ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

[២៧៧] ភិក្ខុប្រើភិក្ខុនីដែលមិនមែនជាញាតិ ឲ្យលាងរោមចៀម ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលប្រើឲ្យគេលាង លុះប្រើឲ្យគេលាងរួចហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

[២៧៨] ភិក្ខុទទួលរូបិយៈ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលទទួល លុះទទួលរួចហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

[២៧៩] ភិក្ខុប្រព្រឹត្តទិញដូរដោយរូបិយៈ មានប្រការផ្សេង ៗ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលប្រព្រឹត្ត (ការលក់ដូរ) លុះប្រព្រឹត្តរួចហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

[២៨០] ភិក្ខុប្រព្រឹត្តទិញដូររបស់មានប្រការផ្សេង ៗ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលខ្លួនប្រព្រឹត្ត លុះប្រព្រឹត្តរួចហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

ចប់ កោសិយវគ្គ ទី ២ ។

## ១៣៧

មហាវិភង្គេ សោឡស មហាវារា និស្សគ្គិយកណ្ឌោ បត្តវគ្គោ

[២៨១] អតិរេកបត្តំ ទសាហំ អតិក្កាមេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ និស្សគ្គិយំ បាចិត្តិយំ ។

[២៨២] ឩនបញ្ចពន្ធនេន បត្តេន អញ្ញំ នវំ បត្តំ ចេតាបេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ចេតាបេតិ បយោគេ ទុក្កដំ ចេតាបិតេ និស្សគ្គិយំ បាចិត្តិយំ ។

[២៨៣] ភេសជ្ជានិ បដិគ្គហេត្វា សត្តាហំ អតិក្កាមេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ និស្សគ្គិយំ បាចិត្តិយំ ។

[២៨៤] អតិរេកមាសេ សេសេ គិម្ហានំ[១] វស្សិកសាដិកចីវរំ បរិយេសន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ បរិយេសតិ បយោគេ ទុក្កដំ បរិយិដ្ឋេ និស្សគ្គិយំ បាចិត្តិយំ ។

[២៨៥] ភិក្ខុស្ស សាមំ ចីវរំ ទត្វា កុបិតោ អនត្តមនោ អច្ឆិន្ទន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ អច្ឆិន្ទតិ បយោគេ ទុក្កដំ អច្ឆិន្នេ និស្សគ្គិយំ បាចិត្តិយំ ។

[២៨៦] សាមំ សុត្តំ វិញ្ញាបេត្វា តន្តវាយេហិ ចីវរំ វាយាបេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ វាយាបេតិ បយោគេ ទុក្កដំ វាយាបិតេ និស្សគ្គិយំ បាចិត្តិយំ ។

---

១ ឱ. ម. គិម្ហានេ ។

[២៨១] ភិក្ខុទុកអតិរេកបាត្រ ឲ្យកន្លងហួស ១០ ថ្ងៃទៅ ត្រូវអាបត្តិ ១ គឺ និស្សគ្គិយបាចិត្តិយៈ ។

[២៨២] ភិក្ខុមានបាត្រ មានចំណាធមិនទាន់ដល់ ៥ អន្ទើ ហើយសូមបាត្រថ្មីដទៃទៀត ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលសូម លុះសូមបានមកហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

[២៨៣] ភិក្ខុទទួលភេសជ្ជៈទាំងឡាយហើយ ទុកឲ្យកន្លងហួស ៧ ថ្ងៃទៅ ត្រូវអាបត្តិ ១ គឺ និស្សគ្គិយបាចិត្តិយៈ ។

[២៨៤] ភិក្ខុស្វែងរកវស្សិកសាដិកចីវរ សម្រាប់ងូតទឹកភ្លៀង ក្នុងកាលដ៏លើសអំពីខែខាងចុងនៃរដូវក្តៅ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលស្វែងរក លុះស្វែងរកបានមកហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

[២៨៥] ភិក្ខុឲ្យចីវរដល់ភិក្ខុផងគ្នា ដោយខ្លួនឯងហើយក្រោធអាក់អន់ចិត្ត ក៏ដណ្តើមយកវិញ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលដណ្តើម លុះដណ្តើមបានមកហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

[២៨៦] ភិក្ខុសូមអំបោះដោយខ្លួនឯង យកមកឲ្យជាងតម្បាញត្បាញចីវរ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលប្រើគេឲ្យត្បាញ លុះប្រើគេឲ្យត្បាញរួចហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

[២៨៧] បុព្វេ អប្បវារិតោ អញ្ញាតកស្ស គហបតិកស្ស តន្តវាយេ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ វិកប្បំ អាបជ្ជតិ បយោគេ ទុក្កដំ វិកប្បំ អាបន្នេ និស្សគ្គិយំ បាចិត្តិយំ ។

[២៨៨] អច្ចេកចីវរំ បដិគ្គហេត្វា ចីវរកាលសមយំ អតិក្កាមេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ និស្សគ្គិយំ បាចិត្តិយំ ។

[២៨៩] តិណ្ណំ ចីវរានំ អញ្ញតរំ ចីវរំ អន្តរឃរេ និក្ខិបិត្វា អតិរេកឆារត្តំ វិប្បវសន្តោ ឯកំ អាបត្តឹ អាបជ្ជតិ និស្សគ្គិយំ បាចិត្តិយំ ។

[២៩០] ជានំ សង្ឃិកំ លាភំ បរិណតំ អត្តនោ បរិណាមេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ បរិណាមេតិ បយោគេ ទុក្កដំ បរិណាមិតេ និស្សគ្គិយំ បាចិត្តិយំ ។

បត្តវគ្គោ តតិយោ ។

តឹស និស្សគ្គិយា បាចិត្តិយា និដ្ឋិតា ។

[២៨៧] ភិក្ខុដែលគេមិនបានបវារណាទុកជាមុន ហើយចូលទៅរកជាង៍តម្បាញរបស់គហបតីមិនមែនជាញាតិ ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំណត់ លុះកំណត់រួចហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

[២៨៨] ភិក្ខុទទួលអច្ចេកចីវរទុកឲ្យកន្លងហួសសម័យ នៃចីវរកាលទៅ ត្រូវអាបត្តិ ១ គឺនិស្សគ្គិយបាចិត្តិយៈ ។

[២៨៩] បណ្ដាចីវរទាំង ៣ ភិក្ខុទុកចីវរណាមួយ ក្នុងចន្លោះផ្ទះ ហើយនៅប្រាសចាកលើស ៦ រាត្រីទៅ ត្រូវអាបត្តិ ១ គឺនិស្សគ្គិយ-បាចិត្តិយៈ ។

[២៩០] ភិក្ខុដឹងថា លាភរបស់សង្ឃដែលគេបង្អោនទៅ (ដើម្បីសង្ឃ) ត្រឡប់បង្អោនមក ដើម្បីខ្លួនវិញ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលបង្អោនមក លុះបង្អោនបានមកហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ ។

ចប់ បត្តវគ្គ ទី ៣ ។

ចប់ និស្សគ្គិយបាចិត្តិយៈ ៣០ ។

១៣៩

មហាវិភង្គេ សោឡស មហាវារា បាចិត្តិយកណ្ឌេ មុសាវាទវគ្គោ

[២៩១] សម្បជានមុសា ភាសន្តោ កតិ អាបត្តិ-យោ អាបជ្ជតិ ។ សម្បជានមុសា ភាសន្តោ បញ្ច អា-បត្តិយោ អាបជ្ជតិ ចាបិច្ឆោ ឥច្ឆាបកតោ អសន្តំ អភូ-តំ ឧត្តរិមនុស្សធម្មំ ឧល្លបតិ អាបត្តិ ចារាជិកស្ស ភិក្ខុំ អមូលកេន ចារាជិកេន ធម្មេន អនុទ្ធំសេតិ អាបត្តិ សង្ឃាទិសេសស្ស យោ តេ វិហារេ វសតិ សោ ភិក្ខុ អរហាតិ ភណតិ បដិវិជានន្តស្ស អាបត្តិ ថុល្ល-ច្ចយស្ស នប្បដិវិជានន្តស្ស អាបត្តិ ទុក្កដស្ស សម្ប-ជានមុសាវាទេ ចាចិត្តិយំ សម្បជានមុសា ភាសន្តោ ឥមា បញ្ច អាបត្តិយោ អាបជ្ជតិ ។

[២៩២] ឱមសន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ឧប-សម្បន្នំ ឱមសតិ អាបត្តិ ចាចិត្តិយស្ស អនុបសម្បន្នំ ឱមសតិ អាបត្តិ ទុក្កដស្ស ។

[២៩៣] បេសុញ្ញំ ឧបសំហរន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ឧបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ អាបត្តិ ចាចិត្តិយស្ស អនុបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ អាបត្តិ ទុក្កដស្ស ។

[២៩១] ភិក្ខុពោលពាក្យកុហកដោយដឹងខ្លួន ត្រូវអាបត្តិប៉ុន្មាន ។ ភិក្ខុពោលពាក្យកុហក ដោយដឹងខ្លួន ត្រូវអាបត្តិ ៥ គឺ ភិក្ខុមានសេចក្តីប្រាថ្នាលាមក មានសេចក្តីប្រាថ្នាគ្របសង្កត់ហើយ ពោលអួតឧត្តរិមនុស្សធម្ម ដែលមិនមាន ដែលមិនពិត ត្រូវអាបត្តិបារាជិក ភិក្ខុចោទភិក្ខុផងគ្នា ដោយអាបត្តិបារាជិកមិនមានមូល ត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុពន្យល់គេថា ភិក្ខុណានៅក្នុងវិហាររបស់អ្នក ភិក្ខុនោះជាព្រះអរហន្ត បើគេដឹងច្បាស់ ត្រូវអាបត្តិថុល្លច្ច័យ បើគេមិនដឹងច្បាស់ ត្រូវអាបត្តិទុក្កដ និយាយកុហក (តាមធម្មតា) ត្រូវអាបត្តិបាចិត្តិយៈ ព្រោះពោលសម្បជានមុសាវាទ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ត្រូវអាបត្តិទាំង ៥ នេះឯង ។

[២៩២] ភិក្ខុពោលពាក្យចាក់ដោត ត្រូវអាបត្តិ ២ គឺ ពោលចាក់ដោតឧបសម្បន្ន ត្រូវអាបត្តិបាចិត្តិយៈ ពោលចាក់ដោតអនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។

[២៩៣] ភិក្ខុបង្កពាក្យញុះញង់ ត្រូវអាបត្តិ ២ គឺ ភិក្ខុបង្កពាក្យញុះញង់ ដល់ឧបសម្បន្នផងគ្នា ត្រូវអាបត្តិបាចិត្តិយៈ បង្កពាក្យញុះញង់ដល់អនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។

[២៩៤] អនុបសម្បន្នំ បទសោ ធម្មំ វាចេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ វាចេតិ បយោគេ ទុក្កដំ បទេ បទេ អាបត្តិ បាចិត្តិយស្ស ។

[២៩៥] អនុបសម្បន្នេន ឧត្តរិទ្វិរត្តតិរត្តំ សហសេយ្យំ កប្បេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ និបជ្ជតិ បយោគេ ទុក្កដំ និបន្នេ អាបត្តិ បាចិត្តិយស្ស ។

[២៩៦] មាតុគ្គាមេន សហសេយ្យំ កប្បេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ និបជ្ជតិ បយោគេ ទុក្កដំ និបន្នេ អាបត្តិ បាចិត្តិយស្ស ។

[២៩៧] មាតុគ្គាមស្ស ឧត្តរិឆប្បញ្ចវាចាហិ ធម្មំ ទេសេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ទេសេតិ បយោគេ ទុក្កដំ បទេ បទេ អាបត្តិ បាចិត្តិយស្ស ។

[២៩៨] អនុបសម្បន្នស្ស ឧត្តរិមនុស្សធម្មំ ភូតំ អារោចេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ អារោចេតិ ប-យោគេ ទុក្កដំ អារោចិតេ អាបត្តិ បាចិត្តិយស្ស ។

[២៩៤] ភិក្ខុបង្រៀនធម៌ជាបទ ចំពោះអនុបសម្បន្ន ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលបង្រៀន ត្រូវអាបត្តិបាចិត្តិយៈ គ្រប់ ៗ បទ ។

[២៩៥] ភិក្ខុសម្រេចការដេក ជាមួយនឹងអនុបសម្បន្ន លើស ២-៣ រាត្រីឡើងទៅ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលប្រាសដេក លុះដេកស៊ប់ហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[២៩៦] ភិក្ខុសម្រេចការដេកជាមួយនឹងមាតុគ្រាម ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលប្រាសដេក លុះដេកស៊ប់ហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[២៩៧] ភិក្ខុសម្ដែងធម៌ដល់មាតុគ្រាម ដោយវាចាលើសអំពី ៥-៦ ម៉ាត់ឡើងទៅ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងសម្ដែង ត្រូវអាបត្តិបាចិត្តិយៈ រាល់ ៗ បទ ។

[២៩៨] ភិក្ខុប្រាប់ឧត្តរិមនុស្សធម្ម ដែលមានពិតប្រាកដ ដល់អនុបសម្បន្ន ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងប្រាប់ លុះប្រាប់រួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

១៤១

មហាវិភង្គេ សោឡស មហាវារា បាចិត្តិយកណ្ឌោ ភូតគាមវគ្គោ

[២៩៩] ភិក្ខុស្ស ទុដ្ឋុល្លំ អាបត្តឹ អនុបសម្បន្នស្ស អារោចេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ អារោចេតិ ប-យោគេ ទុក្កដំ អារោចិតេ អាបត្តិ ចាចិត្តិយស្ស ។

[៣០០] បឋវឹ ខណន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ខណតិ បយោគេ ទុក្កដំ បហារេ បហារេ អាបត្តិ ចាចិត្តិយស្ស ។

មុសាវាទវគ្គោ បឋមោ ។

[៣០១] ភូតគាមំ ចាតេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ចាតេតិ បយោគេ ទុក្កដំ បហារេ បហារេ អាបត្តិ ចាចិត្តិយស្ស ។

[៣០២] អញ្ញេនញ្ញំ បដិចរន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ អនារោបិតេ អញ្ញវាទកោ អញ្ញេនញ្ញំ បដិច-រតិ អាបត្តិ ទុក្កដស្ស អារោបិតេ អញ្ញវាទកោ អញ្ញេ-នញ្ញំ បដិចរតិ អាបត្តិ ចាចិត្តិយស្ស ។

[២៩៩] ភិក្ខុប្រាប់ទុដ្ឋុល្លាបត្តិរបស់ភិក្ខុផង់គ្នា ដល់អនុបសម្បន្ន ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងប្រាប់ លុះប្រាប់រួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣០០] ភិក្ខុជីកដីត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគ (ដែលផ្គង់នឹងជីក) ត្រូវអាបត្តិបាចិត្តិយៈ គ្រប់ ៗ វារៈដែលជីក ។

ចប់ មុសាវាទវគ្គ ទី ១ ។

[៣០១] ភិក្ខុធ្វើភូតគាមឲ្យឃ្លាតចាកទី ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគ (ដែលផ្គង់នឹងធ្វើឲ្យឃ្លាតចាកទី) ត្រូវអាបត្តិ-បាចិត្តិយៈ គ្រប់ ៗ វារៈដែលប្រហារ ។

[៣០២] ភិក្ខុពោលបិទបាំងពាក្យដទៃ ដោយពាក្យដទៃ ត្រូវអាបត្តិ ២ គឺ កាលបើអញ្ញវាទកកម្ម ដែលសង្ឃមិនទាន់លើកឡើងទេ ភិក្ខុពោលបិទបាំងពាក្យដទៃ ដោយពាក្យដទៃ ត្រូវអាបត្តិទុក្កដ កាលបើអញ្ញវាទកកម្ម ដែលសង្ឃបានលើកឡើងហើយ ភិក្ខុនៅតែពោលបិទបាំងពាក្យដទៃ ដោយពាក្យដទៃ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣០៣] ភិក្ខុំ ឧជ្ឈាបេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ឧជ្ឈាបេតិ បយោគេ ទុក្កដំ ឧជ្ឈាបិតេ អាបត្តិ បាចិត្តិយស្ស ។

[៣០៤] សង្ឃិកំ មញ្ចំ វា បីឋំ វា ភិសឹ វា កោច្ឆំ វា អជ្ឈោកាសេ សន្ថរិត្វា អនុទ្ធរិត្វា អនាបុច្ឆា បក្កមន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ បឋមំ បាទំ លេឌ្ឌុ-បាតំ អតិក្កាមេតិ អាបត្តិ ទុក្កដស្ស ទុតិយំ បាទំ អតិក្កាមេតិ អាបត្តិ បាចិត្តិយស្ស ។

[៣០៥] សង្ឃិកេ វិហារេ សេយ្យំ សន្ថរិត្វា អនុ-ទ្ធរិត្វា អនាបុច្ឆា បក្កមន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ បឋមំ បាទំ បរិក្ខេបំ អតិក្កាមេតិ អាបត្តិ ទុក្កដស្ស ទុតិយំ បាទំ អតិក្កាមេតិ អាបត្តិ បាចិត្តិយស្ស ។

[៣០៦] សង្ឃិកេ វិហារេ ជានំ បុព្វុបគតំ ភិក្ខុំ អនុប្បខជ្ជ សេយ្យំ កប្បេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ និបជ្ជតិ បយោគេ ទុក្កដំ និបន្នេ អាបត្តិ បាចិត្តិយស្ស ។

[៣០៣] ភិក្ខុឲ្យភិក្ខុដទៃពោលទោសភិក្ខុផងគ្នា ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឲ្យគេពោលទោស លុះឲ្យគេពោលទោសហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣០៤] ភិក្ខុលាគ្រែក្តី តាំងក្តី ពូកក្តី កៅអីក្តី ជារបស់សង្ឃ ទុកក្នុងទីវាល មិនសាយកមកទុកវិញ ទាំងមិនបានប្រាប់ (អ្នកឯទៀតឲ្យសាយកមកទុកវិញ) ហើយចៀសចេញទៅ ត្រូវអាបត្តិ ២ គឺឈានជំហានជាដំបូង ឲ្យកន្ទងហួសលេឌ្ឌុបាត ត្រូវអាបត្តិទុក្កដ ឈានជំហានទី ២ ឲ្យកន្ទងហួសទៅ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣០៥] ភិក្ខុក្រាលកម្រាលសម្រាប់ដេក ក្នុងវិហាររបស់សង្ឃ ហើយមិនសាយកមកទុកវិញ ទាំងមិនបានប្រាប់ (អ្នកឯទៀតឲ្យសាយកមកទុកវិញ) ហើយចៀសចេញទៅ ត្រូវអាបត្តិ ២ គឺ ឈានជំហានជាដំបូង ឲ្យកន្ទងផុតរបងទៅ ត្រូវអាបត្តិទុក្កដ ឈានជំហាន ទី ២ ឲ្យកន្ទងហួសទៅ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣០៦] ភិក្ខុដឹងថា មានភិក្ខុផងគ្នាចូលទៅមុន ក្នុងវិហារជារបស់សង្ឃ ហើយចូលជ្រៀតប្រៀតទៅ សម្រេចការដេក ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបដេក លុះដេកស៊ប់ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣០៧] ភិក្ខុំ កុបិតោ អនត្តមនោ សង្ឃិកា វិហារា និក្កឌ្ឍន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ និក្កឌ្ឍតិ បយោគេ ទុក្កដំ និក្កឌ្ឍិតេ អាបត្តិ ចាចិត្តិយស្ស ។

[៣០៨] សង្ឃិកេ វិហារេ ឧបរិ វេហាសកុដិយា អាហច្ចចាទកំ មញ្ចំ វា បីឋំ វា អភិនិសីទន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ អភិនិសីទតិ បយោគេ ទុក្កដំ អភិនិសិន្នេ អាបត្តិ ចាចិត្តិយស្ស ។

[៣០៩] ទ្វិត្តិបរិយាយេ អធិដ្ឋហិត្វា តទុត្តរឹ អធិដ្ឋ-ហន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ អធិដ្ឋេតិ បយោគេ ទុក្កដំ អធិដ្ឋិតេ អាបត្តិ ចាចិត្តិយស្ស ។

[៣១០] ជានំ សប្បាណកំ ឧទកំ តិណំ វា មត្តិកំ វា សិញ្ចន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ សិញ្ចតិ បយោគេ ទុក្កដំ សិញ្ចិតេ អាបត្តិ ចាចិត្តិយស្ស ។

ភូតគាមវគ្គោ ទុតិយោ ។

[៣០៧] ភិក្ខុក្រោធអាក់អន់ចិត្ត ក៏ទង់ទាញភិក្ខុផង់គ្នាចាកវិហារជារបស់សង្ឃ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបទង់ទាញ លុះទង់ទាញ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣០៨] ភិក្ខុអង្គុយសង្កត់គ្រែក្តី តាំងក្តី ដែលមានជើងគ្រាន់តែផ្គុំទុក ឰដ៏ថ្នាក់ខាងលើ ក្នុងវិហាររបស់សង្ឃ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងអង្គុយសង្កត់ លុះអង្គុយសង្កត់ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣០៩] ភិក្ខុធ្វើការប្រក់បានត្រឹមតែ២-៣ ជាន់ កាលបើប្រក់ឲ្យលើសអំពីកំណត់នោះទៅ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងប្រក់ លុះប្រក់ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣១០] ភិក្ខុដឹងថា ទឹកមានសត្វហើយ ស្រោចស្មៅក្តី ដីក្តី ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងស្រោច លុះស្រោច ត្រូវអាបត្តិបាចិត្តិយៈ ។

ចប់ ភូតគាមវគ្គ ទី ២ ។

[៣១១] អសម្មតោ ភិក្ខុនិយោ ឱវទន្តោ ទ្វេ អា-
បត្តិយោ អាបជ្ជតិ ឱវទតិ បយោគេ ទុក្កដំ ឱវទិតេ អាបត្តិ បាចិត្តិយស្ស ។

[៣១២] អត្ថង្គតេ សុរិយេ ភិក្ខុនិយោ ឱវទន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ឱវទតិ បយោគេ ទុក្កដំ ឱវទិតេ អាបត្តិ បាចិត្តិយស្ស ។

[៣១៣] ភិក្ខុនូបស្សយំ ឧបសង្កមិត្វា ភិក្ខុនិយោ ឱវទន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ឱវទតិ បយោគេ ទុក្កដំ ឱវទិតេ អាបត្តិ បាចិត្តិយស្ស ។

[៣១៤] អាមិសហេតុ ភិក្ខូ ភិក្ខុនិយោ ឱវទន្តីតិ ភណន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ភណតិ បយោគេ ទុក្កដំ ភណិតេ អាបត្តិ បាចិត្តិយស្ស ។

[៣១៥] អញ្ញាតិកាយ ភិក្ខុនិយា ចីវរំ ទេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ទេតិ បយោគេ ទុក្កដំ ទិន្នេ អាបត្តិ បាចិត្តិយស្ស ។

[៣១១] ភិក្ខុដែលសង្ឃមិនបានសន្មត ហើយទៅទូន្មានភិក្ខុនី ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលទូន្មាន លុះទូន្មាន ត្រូវអាបត្តិបាចិត្តិយៈ ។

[៣១២] ភិក្ខុទូន្មានពួកភិក្ខុនី ក្នុងវេលាព្រះអាទិត្យអស្តង្គត ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងទូន្មាន លុះទូន្មាន ត្រូវអាបត្តិបាចិត្តិយៈ ។

[៣១៣] ភិក្ខុចូលទៅកាន់សំណាក់ភិក្ខុនី ហើយទូន្មានពួកភិក្ខុនី ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងទូន្មាន លុះទូន្មាន ត្រូវអាបត្តិបាចិត្តិយៈ ។

[៣១៤] ភិក្ខុនិយាយថា ភិក្ខុទាំងឡាយទូន្មានពួកភិក្ខុនី ព្រោះហេតុតែអាមិសៈ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងនិយាយ លុះនិយាយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣១៥] ភិក្ខុឲ្យចីវរដល់ភិក្ខុនី ដែលមិនមែនជាញាតិ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងឲ្យ លុះឲ្យ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣១៦] អញ្ញាតិកាយ ភិក្ខុនិយា ចីវរំ សិព្វេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ សិព្វេតិ បយោគេ ទុក្កដំ អារាបថេ អារាបថេ អាបត្តិ ចាចិត្តិយស្ស ។

[៣១៧] ភិក្ខុនិយា សទ្ធឹ សំវិធាយ ឯកទ្ធានមគ្គំ បដិបជ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ បដិបជ្ជតិ បយោគេ ទុក្កដំ បដិបន្នេ អាបត្តិ ចាចិត្តិយស្ស ។

[៣១៨] ភិក្ខុនិយា សទ្ធឹ សំវិធាយ ឯកំ នាវំ អភិរូហន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ អភិរូហតិ បយោគេ ទុក្កដំ អភិរូឡ្ហេ អាបត្តិ ចាចិត្តិយស្ស ។

[៣១៩] ជានំ ភិក្ខុនីបរិចាចិតំ បិណ្ឌចាតំ ភុញ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ ចាចិត្តិយស្ស ។

[៣២០] ភិក្ខុនិយា សទ្ធឹ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ និសីទតិ បយោគេ ទុក្កដំ និសិន្នេ អាបត្តិ ចាចិត្តិយស្ស ។

ឱវាទវគ្គោ តតិយោ ។

[៣១៦] ភិក្ខុដេរចីវរឲ្យភិក្ខុនី ដែលមិនមែនជាញាតិ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគ ដែលរៀបនឹងដេរ ត្រូវអាបត្តិបាចិត្តិយៈ គ្រប់ ៗ ថ្នេរ ដែលដេរ ។

[៣១៧] ភិក្ខុបបួលភិក្ខុនីដើរទៅ កាន់ផ្លូវឆ្ងាយមួយជាមួយគ្នា ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងដើរទៅ លុះដើរទៅ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣១៨] ភិក្ខុបបួលភិក្ខុនីឡើងជិះទូកមួយជាមួយគ្នា ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងឡើងជិះ លុះឡើងជិះ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣១៩] ភិក្ខុដឹងហើយឆាន់បិណ្ឌបាតដែលភិក្ខុនីចាត់ចែង ត្រូវអាបត្តិ ២ គឺ ភិក្ខុទទួល ដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ គ្រប់ ៗ វារៈដែលលេបចូលទៅ ។

[៣២០] ភិក្ខុមួយរូបសម្រេចការអង្គុយ ក្នុងទីកំបាំង ជាមួយនឹងភិក្ខុនីតែមួយរូប ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងអង្គុយ លុះអង្គុយ ត្រូវអាបត្តិបាចិត្តិយៈ ។

ចប់ ឱវាទវគ្គទី ៣ ។

[៣២១] តទុត្តរឹ អាវសថបិណ្ឌំ ភុញ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាចិត្តិយស្ស ។

[៣២២] គណភោជនំ ភុញ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាចិត្តិយស្ស ។

[៣២៣] បរម្បរភោជនំ ភុញ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាចិត្តិយស្ស ។

[៣២៤] ទ្វិត្តិបត្តបូរេ បូវេ បដិគ្គហេត្វា តទុត្តរឹ បដិគ្គណ្ហន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ បដិគ្គណ្ហាតិ បយោគេ ទុក្កដំ បដិគ្គហិតេ អាបត្តិ បាចិត្តិយស្ស ។

[៣២៥] ភុត្តាវី បវារិតោ អនតិរិត្តំ ខាទនីយំ វា ភោជនីយំ វា ភុញ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាចិត្តិយស្ស ។

[៣២១] ភិក្ខុឆាន់បិណ្ឌបាតក្នុងផ្ទះសំណាក់ ឬរោងឆាន់ ឲ្យលើស អំពីម្តងទៅ ត្រូវអាបត្តិ ២ គឺ ភិក្ខុទទួលដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ គ្រប់ ៗ វារៈ ដែលលេប ចូលទៅ ។

[៣២២] ភិក្ខុឆាន់គណភោជន ត្រូវអាបត្តិ ២ គឺ ភិក្ខុទទួល ដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិ បាចិត្តិយៈ គ្រប់ ៗ វារៈដែលលេបចូលទៅ ។

[៣២៣] ភិក្ខុឆាន់បរម្បរភោជន ត្រូវអាបត្តិ ២ គឺ ភិក្ខុទទួលដោយ គិតថា អាត្មាអញនឹងឆាន់ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ គ្រប់ៗ វារៈដែលលេចចូលទៅ ។

[៣២៤] ភិក្ខុទទួលនំបានត្រឹម ២-៣ បាត្រ កាលបើទទួលឲ្យលើស ពីនោះទៅ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀប នឹងទទួល លុះទទួល ត្រូវអាបត្តិបាចិត្តិយៈ ។

[៣២៥] ភិក្ខុឆាន់រួចហើយ ហាមភត្តហើយ បែរទៅឆាន់ខាទ- នីយៈ ឬភោជនីយៈ ដែលជាអនតិរិត្តៈ ត្រូវអាបត្តិ ២ គឺ ភិក្ខុទទួល ដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិ បាចិត្តិយៈ គ្រប់ ៗ វារៈដែលលេបចូលទៅ ។

១៤៧

មហាវិភង្គេ សោឡស មហាវារា បាចិត្តិយកណ្ឌេ ភោជនវគ្គោ

[៣២៦] ភិក្ខុំ ភុត្តាវឹ បវារិតំ អនតិរិត្តេន ខាទនីយេន វា ភោជនីយេន វា អភិហដ្ឋុំ បវារេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ តស្ស វចនេន ខាទិស្សាមិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ភោជនបរិយោសានេ អាបត្តិ បាចិត្តិយស្ស ។

[៣២៧] វិកាលេ ខាទនីយំ វា ភោជនីយំ វា ភុញ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាចិត្តិយស្ស ។

[៣២៨] សន្និធិការកំ ខាទនីយំ វា ភោជនីយំ វា ភុញ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាចិត្តិយស្ស ។

[៣២៩] បណីតភោជនានិ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាចិត្តិយស្ស ។

[៣២៦] ភិក្ខុបវារណាបង្ខំភិក្ខុផងគ្នាដែលឆាន់រួចហើយ ហាមភត្ត ហើយ ដោយខាទនីយៈ ឬភោជនីយៈ ដែលជាអនតិរិត្តៈ ត្រូវអាបត្តិ ២ គឺ ភិក្ខុទទួលដោយគិតថា អាត្មាអញនឹងទំពាស៊ីនឹងឆាន់ តាមពាក្យ របស់ភិក្ខុនោះ ដូច្នេះ ត្រូវអាបត្តិទុក្កដ លុះឆាន់រួចស្រេចហើយ ត្រូវ អាបត្តិបាចិត្តិយៈ ។

[៣២៧] ភិក្ខុឆាន់ខាទនីយៈ ឬភោជនីយៈ ក្នុងវេលាវិកាល ត្រូវ អាបត្តិ ២ គឺ ភិក្ខុទទួល ដោយគិតថា អាត្មាអញនឹងឆាន់ដូច្នេះ ត្រូវ អាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ គ្រប់ៗ វារៈដែលលេបចូលទៅ ។

[៣២៨] ភិក្ខុឆាន់ខាទនីយៈ ឬភោជនីយៈ ដែលខ្លួនធ្វើឲ្យជាសន្និធិ ត្រូវអាបត្តិ ២ គឺ ភិក្ខុទទួលដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ គ្រប់ ៗ វារៈដែលលេបចូលទៅ ។

[៣២៩] ភិក្ខុសូមបណីតភោជន ដើម្បីប្រយោជន៍ដល់ខ្លួនឯង មក ឆាន់ ត្រូវអាបត្តិ ២ គឺ ភិក្ខុទទួល ដោយគិតថា អាត្មាអញនឹង ឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ គ្រប់ ៗ វារៈដែល លេបចូលទៅ ។

[៣៣០] អជិន្នំ មុខទ្វារំ អាហារំ អាហរន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ កុញ្ចិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាចិត្តិយស្ស ។

ភោជនវគ្គោ ចតុត្ថោ ។

[៣៣១] អចេលកស្ស វា បរិព្វាជកស្ស វា បរិព្វាជិកាយ វា សហត្ថា ខាទនីយំ វា ភោជនីយំ វា ទេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ទេតិ បយោគេ ទុក្កដំ ទិន្នេ អាបត្តិ បាចិត្តិយស្ស ។

[៣៣២] ភិក្ខុំ ឯហាវុសោ គាមំ វា និគមំ វា បិណ្ឌាយ បវិសិស្សាមាតិ តស្ស ទាបេត្វា វា អទាបេត្វា វា ឧយ្យោជេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ឧយ្យោជេតិ បយោគេ ទុក្កដំ ឧយ្យោជិតេ អាបត្តិ បាចិត្តិយស្ស ។

[៣៣៣] សភោជនេ កុលេ អនុប្បខជ្ជ និសជ្ជំ កប្បេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ និសីទតិ បយោគេ ទុក្កដំ និសិន្នេ អាបត្តិ បាចិត្តិយស្ស ។

[៣៣០] ភិក្ខុលេបអាហារ ដែលគេមិនបានប្រគេន ឲ្យចូលតាមមុខទ្វារ ត្រូវអាបត្តិ ២ គឺ ភិក្ខុទទួល ដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ គ្រប់ ៗ វារៈដែលលេបចូលទៅ ។

ចប់ ភោជនវគ្គ ទី ៤ ។

[៣៣១] ភិក្ខុឲ្យខាទនីយៈ ឬភោជនីយៈ ដល់អចេលកក៏ក្តី បរិព្វាជកក្តី បរិព្វាជិកាក្តី ដោយដៃខ្លួនឯង ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងឲ្យ លុះឲ្យ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៣២] ភិក្ខុនិយាយនឹងភិក្ខុផងគ្នាថា ម្នាលអាវុសោ លោកចូរមក យើងនឹងចូលទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត (លុះថាដូច្នេះហើយ) ក៏ឲ្យគេឲ្យ ឬមិនឲ្យគេឲ្យ (អ្វី ៗ) ដល់ភិក្ខុនោះ ហើយបញ្ជូនឲ្យត្រឡប់មកវិញ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងបញ្ជូនឲ្យត្រឡប់វិញ លុះបញ្ជូនឲ្យត្រឡប់វិញ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៣៣] ភិក្ខុចូលទៅអង្គុយក្នុង (ផ្ទះ) នៃត្រកូលដែលមានជនតែពីរនាក់ (គឺស្វាមីនិងភរិយា) ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងអង្គុយ លុះអង្គុយហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

១៤៩



[៣៣៤] មាតុគ្គាមេន សទ្ធឹ រហោ បដិច្ឆន្នេ អាសនេ និសជ្ជំ កប្បេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ និសីទតិ បយោគេ ទុក្កដំ និសិន្នេ អាបត្តិ ចាចិត្តិយស្ស ។

[៣៣៥] មាតុគ្គាមេន សទ្ធឹ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ និសីទតិ បយោគេ ទុក្កដំ និសិន្នេ អាបត្តិ ចាចិត្តិយស្ស ។

[៣៣៦] និមន្តិតោ សភត្តោ សមានោ បុរេភត្តំ វា បច្ឆាភត្តំ វា សន្តំ ភិក្ខុំ អនាបុច្ឆា កុលេសុ ចារិត្តំ អាបជ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ បឋមំ បាទំ ឧម្មារំ អតិក្កាមេតិ អាបត្តិ ទុក្កដស្ស ទុតិយំ បាទំ អតិក្កាមេតិ អាបត្តិ ចាចិត្តិយស្ស ។

[៣៣៧] តទុត្តរឹ ភេសជ្ជំ វិញ្ញាបេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ វិញ្ញាបេតិ បយោគេ ទុក្កដំ វិញ្ញាបិតេ អាបត្តិ ចាចិត្តិយស្ស ។

[៣៣៤] ភិក្ខុសម្រេចការអង្គុយលើអាសនៈ ជាទីស្ងាត់កំបាំងភ្នែក ជាមួយនឹងមាតុគ្រាម ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងអង្គុយ លុះអង្គុយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៣៥] ភិក្ខុមួយរូបសម្រេចការអង្គុយ ក្នុងទីស្ងាត់ (កំបាំងត្រចៀក) ជាមួយនឹងមាតុគ្រាមតែម្នាក់ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងអង្គុយ លុះអង្គុយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៣៦] ភិក្ខុអ្នកទទួលនិមន្តគេហើយ ឈ្មោះថា ជាអ្នកមានភត្តហើយ មិនលាភិក្ខុផងគ្នា ដែលមាននៅ ហើយចៀសចេញទៅក្នុងត្រកូលទាំងឡាយ (ឯទៀត) ក្នុងកាលមុនភត្តក្តី ក្រោយភត្តក្តី ត្រូវអាបត្តិ ២ គឺ ឈានជំហានទី ១ កន្លងហួសធរណីទ្វារទៅ ត្រូវអាបត្តិទុក្កដ ឈានជំហានទី ២ ឲ្យកន្លងហួសទៅ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៣៧] ភិក្ខុសូមភេសជ្ជៈឲ្យលើសកំណត់ខែ ដែលគេបវារណា ត្រូវអាបត្តិ ២ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលសូម លុះសូមបានមក ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៣៨] ឧយ្យុត្តំ សេនំ ទស្សនាយ គច្ឆន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ គច្ឆតិ អាបត្តិ ទុក្កដស្ស យត្ថ ឋិតោ បស្សតិ អាបត្តិ បាចិត្តិយស្ស ។

[៣៣៩] អតិរេកតិរត្តំ សេនាយ វសន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ វសតិ បយោគេ ទុក្កដំ វសិតេ អាបត្តិ បាចិត្តិយស្ស ។

[៣៤០] ឧយ្យោធិកំ គច្ឆន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ គច្ឆតិ អាបត្តិ ទុក្កដស្ស យត្ថ ឋិតោ បស្សតិ អាបត្តិ បាចិត្តិយស្ស ។

អចេលកវគ្គោ បញ្ចមោ ។

[៣៤១] មជ្ជំ បិវន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ បិវិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាចិត្តិយស្ស ។

[៣៤២] ភិក្ខុំ អង្គុលិបតោទកេន ហាសេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ហាសេតិ បយោគេ ទុក្កដំ ហាសិតេ អាបត្តិ បាចិត្តិយស្ស ។

[៣៣៨] ភិក្ខុទៅដើម្បីមើលកងទ័ពដែលលើកចេញទៅ ត្រូវអាបត្តិ ២ គឺ ដើរចេញទៅ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ ក្នុងទីដែលឈរមើល ។

[៣៣៩] ភិក្ខុទៅនៅក្នុងកងទ័ពឲ្យលើសជាង ៣ រាត្រីទៅ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងនៅ លុះនៅ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៤០] ភិក្ខុទៅកាន់ទីដែលគេត្រួតពល ត្រូវអាបត្តិ ២ គឺដើរចេញទៅ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ ក្នុងទីដែលឈរមើល ។

ចប់ អចេលកវគ្គ ទី ៥ ។

[៣៤១] ភិក្ខុផឹកទឹកស្រវឹង ត្រូវអាបត្តិ ២ គឺ ភិក្ខុទទួលដោយគិតថា អាត្មាអញនឹងផឹក ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ គ្រប់ ៗ ប្រយោគដែលផឹកលេបចូលទៅ ។

[៣៤២] ភិក្ខុធ្វើភិក្ខុផងគ្នា ឲ្យសើចដោយជន្ទួញគឺម្រាមដៃ (ចាក់ក្រឡេក) ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលធ្វើឲ្យគេសើច លុះគេសើច ត្រូវអាបត្តិបាចិត្តិយៈ ។

មហាវិភង្គេ សោឡស មហាវារា បាចិត្តិយកណ្ឌេ សុរាមេរយវគ្គោ

[៣៤៣] ឧទកេ ហសធម្មេ ហសធម្មសញ្ញី កីឡតិ អាបត្តិ បាចិត្តិយស្ស ។

[៣៤៣] ឧទកេ កីឡន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ហេដ្ឋាគោប្ផកេ ឧទកេ កីឡតិ អាបត្តិ ទុក្កដស្ស ឧបរិគោប្ផកេ ឧទកេ កីឡតិ អាបត្តិ បាចិត្តិយស្ស ។

[៣៤៤] អនាទរិយំ ករោន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ករោតិ បយោគេ ទុក្កដំ កតេ អាបត្តិ បាចិត្តិយស្ស ។

[៣៤៥] ភិក្ខុំ ភឹសាបេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ភឹសាបេតិ បយោគេ ទុក្កដំ ភឹសាបិតេ អាបត្តិ បាចិត្តិយស្ស ។

[៣៤៦] ជោតឹ សមាទហិត្វា វិសិព្វេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ សមាទហាតិ បយោគេ ទុក្កដំ សមាទហិតេ អាបត្តិ បាចិត្តិយស្ស ។

[៣៤៧] ឱរេនឌ្ឍមាសំ ន្ហាយន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ន្ហាយតិ បយោគេ ទុក្កដំ ន្ហានបរិយោសានេ អាបត្តិ បាចិត្តិយស្ស ។

[៣៤៣] ភិក្ខុលេងទឹក ត្រូវអាបត្តិ ២ គឺ ភិក្ខុលេងទឹករាក់ក្រោមក្នែកគោរ ត្រូវអាបត្តិទុក្កដ ភិក្ខុលេងទឹកជ្រៅ លើក្នែកគោរ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៤៤] ភិក្ខុធ្វើសេចក្ដីមិនអើពើ (នឹងបុគ្គលអ្នកសម្ដែងធម៌ ឬធម៌) ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងធ្វើសេចក្ដីមិនអើពើ លុះធ្វើសេចក្ដីមិនអើពើ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៤៥] ភិក្ខុបន្ទាចភិក្ខុផងគ្នា ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលរៀបនឹងបន្ទាច លុះបន្ទាចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៤៦] ភិក្ខុបង្កាត់ភ្លើងអាំង ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលកំពុងបង្កាត់ លុះបង្កាត់ស្រេចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៤៧] មិនទាន់ដល់កន្ទះខែ ភិក្ខុ (អ្នកនៅក្នុងមជ្ឈិមបទេស) ងូតទឹក ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលងូត លុះងូតរួចហើយ ត្រូវអាបត្តិបាត្តិបាចិត្តិយៈ ។

[៣៤៨] អជានយិត្វា តិណ្ណំ ទុព្វណ្ណករណានំ អញ្ញតរំ ទុព្វណ្ណករណំ នវំ ចីវរំ បរិភុញ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ បរិភុញ្ជតិ បយោគេ ទុក្កដំ បរិភុត្តេ អាបត្តិ បាចិត្តិយស្ស ។

[៣៤៩] ភិក្ខុស្ស វា ភិក្ខុនិយា វា សិក្ខមានាយ វា សាមណេរស្ស វា សាមណេរិយា វា សាមំ ចីវរំ វិកប្បេត្វា អបច្ចុទ្ធារកំ បរិភុញ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ បរិភុញ្ជតិ បយោគេ ទុក្កដំ បរិភុត្តេ អាបត្តិ បាចិត្តិយស្ស ។

[៣៥០] ភិក្ខុស្ស បត្តំ វា ចីវរំ វា និសីទនំ វា សូ-ចិឃរំ វា កាយពន្ធនំ វា អបនិធេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ អបនិធេតិ បយោគេ ទុក្កដំ អបនិហិតេ អា-បត្តិ បាចិត្តិយស្ស ។

សុរាមេរយវគ្គោ ឆដ្ឋោ ។

[៣៤៨] ភិក្ខុមិនកាន់យកវត្ថុសម្រាប់ធ្វើពណ៌ឲ្យខូច ៣ យ៉ាង វត្ថុសម្រាប់ធ្វើពណ៌ឲ្យខូចឯណានីមួយ ក៏ប្រើប្រាស់ចីវរថ្មី ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងប្រើប្រាស់ លុះប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៤៩] ភិក្ខុវិកប្បចីវររបស់ខ្លួន ដល់ភិក្ខុក្តី ភិក្ខុនីក្តី សិក្ខមានាក្តី សាមណេរក្តី សាមណេរីក្តី មិនបានដកវិកប្បជាមុន ហើយប្រើប្រាស់ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងប្រើប្រាស់ លុះប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៥០] ភិក្ខុលាក់បាត្រក្តី ចីវរក្តី និសីទនៈក្តី បំពង់ម្ជុលក្តី វត្ថពន្ធចង្កេះក្តី របស់ភិក្ខុផងគ្នា ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងលាក់ លុះលាក់រួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

ចប់ សុរាមេរយវគ្គ ទី ៦ ។

១៤៣

## មហាវិភង្គេ សោឡស មហាវារា បាចិត្តិយកណ្ឌេ សប្បាណកវគ្គោ

[៣៤១] សញ្ចិច្ច បាណំ ជីវិតា វោរោបេន្តោ កតិ អាបត្តិយោ អាបជ្ជតិ ។ សញ្ចិច្ច បាណំ ជីវិតា វោរោបេន្តោ ចតស្សោ អាបត្តិយោ អាបជ្ជតិ អនោទិស្ស ឱបាតំ ខណតិ យោ កោចិ បបតិត្វា មរិស្សតីតិ អាបត្តិ ទុក្កដស្ស មនុស្សោ តស្មឹ បបតិត្វា មរតិ អាបត្តិ បារាជិកស្ស យក្ខោ វា បេតោ វា តិរច្ឆានគតមនុស្សវិគ្គហោ វា តស្មឹ បបតិត្វា មរតិ អាបត្តិ ថុល្លច្ចយស្ស តិរច្ឆានគតោ តស្មឹ បបតិត្វា មរតិ អាបត្តិ បាចិត្តិយស្ស សញ្ចិច្ច បាណំ ជីវិតា វោរោបេន្តោ ឥមា ចតស្សោ អាបត្តិយោ អាបជ្ជតិ ។

[៣៤២] ជានំ សប្បាណកំ ឧទកំ បរិភុញ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ បរិភុញ្ជតិ បយោគេ ទុក្កដំ បរិភុត្តេ អាបត្តិ បាចិត្តិយស្ស ។

[៣៤៣] ជានំ យថាធម្មំ នីហតាធិករណំ បុនក្កម្មាយ ឧក្កោដេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ឧក្កោដេតិ បយោគេ ទុក្កដំ ឧក្កោដិតេ អាបត្តិ បាចិត្តិយស្ស ។

[៣៥១] ភិក្ខុក្លែងផ្តាច់បង់សត្វ ឲ្យឃ្លាតចាកជីវិត ត្រូវអាបត្តិប៉ុន្មាន ។ ភិក្ខុក្លែងផ្តាច់បង់សត្វឲ្យឃ្លាតចាកជីវិត ត្រូវអាបត្តិ ៤ គឺ ភិក្ខុជីករណ្តៅមិនចំពោះ (សត្វឬមនុស្ស) ដោយគិតថា អ្នកណាមួយនឹងធ្លាក់ស្លាប់ ដូច្នេះ ត្រូវអាបត្តិទុក្កដ មនុស្សធ្លាក់ក្នុងរណ្តៅនោះហើយស្លាប់ ត្រូវអាបត្តិបារាជិក យក្សក្តី ប្រេតក្តី តិរច្ឆានមានរាងកាយដូចមនុស្សក្តី ធ្លាក់ក្នុងរណ្តៅនោះស្លាប់ ត្រូវអាបត្តិថុល្លច្ច័យ តិរច្ឆានធ្លាក់ក្នុងរណ្តៅនោះស្លាប់ ត្រូវអាបត្តិបាចិត្តិយៈ ភិក្ខុក្លែងផ្តាច់បង់សត្វឲ្យឃ្លាតចាកជីវិត ត្រូវអាបត្តិ ៤ នេះឯង ។

[៣៥២] ភិក្ខុដឹងថា ទឹកមានសត្វហើយប្រើប្រាស់ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងប្រើប្រាស់ លុះប្រើប្រាស់ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៥៣] ភិក្ខុដឹងថា អធិករណ៍ដែលសង្ឃឲ្យរម្ងាប់សមគួរតាមធម៌ហើយ សើរើដើម្បីធ្វើជាថ្មីទៀត ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលសើរើ លុះសើរើរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៥៤] ភិក្ខុស្ស ជានំ ទុដ្ឋុល្លំ អាបត្តឹ បដិច្ឆាទេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ បាចិត្តិយំ ។

[៣៥៥] ជានំ ឩនវីសតិវស្សំ បុគ្គលំ ឧបសម្បាទេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ឧបសម្បាទេតិ បយោគេ ទុក្កដំ ឧបសម្បាទិតេ អាបត្តិ បាចិត្តិយស្ស ។

[៣៥៦] ជានំ ថេយ្យសត្ថេន សទ្ធឹ សំវិធាយ ឯកទ្ធានមគ្គំ បដិបជ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ បដិបជ្ជតិ បយោគេ ទុក្កដំ បដិបន្នេ អាបត្តិ បាចិត្តិយស្ស ។

[៣៥៧] មាតុគ្គាមេន សទ្ធឹ សំវិធាយ ឯកទ្ធានមគ្គំ បដិបជ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ បដិបជ្ជតិ បយោគេ ទុក្កដំ បដិបន្នេ អាបត្តិ បាចិត្តិយស្ស ។

[៣៥៨] បាបិកាយ ទិដ្ឋិយា យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ញត្តិយា ទុក្កដំ កម្មវាចាបរិយោសានេ អាបត្តិ បាចិត្តិយស្ស ។

[៣៥៤] ភិក្ខុដឹងហើយបិទបាំងទុដ្ឋុល្លាបត្តិ របស់ភិក្ខុផងគ្នា ត្រូវអាបត្តិ ១ គឺ បាចិត្តិយៈ ។

[៣៥៥] ភិក្ខុដឹងថា បុគ្គលមានឆ្នាំខ្វះពី ២០ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឲ្យឧបសម្បទា លុះឲ្យឧបសម្បទាហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៥៦] ភិក្ខុដឹងហើយបបួលដើរផ្លូវឆ្ងាយមួយជាមួយគ្នា នឹងពួកឈ្មួញដែលគេចវាងឲ្យរួចពន្ធ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងដើរ លុះដើរទៅ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៥៧] ភិក្ខុបបួលដើរផ្លូវឆ្ងាយមួយជាមួយនឹងមាតុគ្រាម ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងដើរ លុះដើរទៅ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៥៨] ភិក្ខុមានទិដ្ឋិអាក្រក់ ដែលសង្ឃបានសូត្រសមនុភាសនកម្មអស់វារៈ ៣ ដងហើយ នៅតែមិនលះបង់ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងខណៈសូត្រញត្តិ លុះចប់កម្មវាចា ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៥៩] ជានំ តថាវាទិនា ភិក្ខុនា អកដានុធម្មេន តំ ទិដ្ឋឹ អប្បដិនិស្សដ្ឋេន សទ្ធឹ សម្ភុញ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ សម្ភុញ្ជតិ បយោគេ ទុក្កដំ សម្ភុត្តេ អាបត្តិ បាចិត្តិយស្ស ។

[៣៦០] ជានំ តថានាសិតំ សមណុទ្ទេសំ ឧបលាបេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ឧបលាបេតិ បយោគេ ទុក្កដំ ឧបលាបិតេ អាបត្តិ បាចិត្តិយស្ស ។

សប្បាណកវគ្គោ សត្តមោ ។

[៣៦១] ភិក្ខុ[១] ភិក្ខូហិ សហធម្មិកំ វុច្ចមានោ ន តាវាហំ អាវុសោ ឯតស្មឹ សិក្ខាបទេ សិក្ខិស្សាមិ យាវ នញ្ញំ ភិក្ខុំ ព្យត្តំ វិនយធរំ បរិបុច្ឆាមីតិ ភណន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ភណតិ បយោគេ ទុក្កដំ ភណិតេ អាបត្តិ បាចិត្តិយស្ស ។

១ ឱ. ម. ភិក្ខូតិ បទំ នត្ថិ ។

[៣៥៩] ភិក្ខុដឹងហើយបរិភោគរួមជាមួយគ្នា នឹងភិក្ខុដែលពោលដូច្នោះ ជាអ្នកមិនធ្វើតាមធម៌ ជាអ្នកមិនលះទិដ្ឋិនោះចេញ ត្រូវអាត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងបរិភោគរួម លុះបរិភោគរួម ត្រូវអាបត្តិបាចិត្តយៈ ។

[៣៦០] ភិក្ខុដឹងថា សាមណេរ ដែលភិក្ខុឯទៀត ឲ្យវិនាសទៅដូច្នោះ ហើយទៅប្រលោមយកមក ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងប្រលោម លុះនិយាយប្រលោមហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

ចប់ សប្បាណកវគ្គ ទី ៧ ។

[៣៦១] ភិក្ខុដែលភិក្ខុទាំងឡាយពោលដាស់តឿន ប្រកបដោយធម៌ហើយនិយាយ (នឹងភិក្ខុទាំងឡាយ) យ៉ាងនេះវិញថា ម្នាលអាវុសោ ខ្ញុំមិនទាន់សិក្សាសិក្ខាបទនុ៎ះនៅឡើយ ព្រោះខ្ញុំមិនទាន់បានសាកសួរភិក្ខុដទៃជាអ្នកឈ្លាស ជាអ្នកទ្រទ្រង់វិន័យ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងនិយាយ លុះនិយាយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៦២] វិជយំ វិវណ្ណេន្តោ ទ្វេ អាបត្តិយោ អា-បជ្ជតិ វិវណ្ណេតិ បយោគេ ទុក្កដំ វិវណ្ណិតេ អាបត្តិ ចាចិត្តិយស្ស ។

[៣៦៣] មោហេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ អនារោបិតេ មោហេ មោហេតិ អាបត្តិ ទុក្កដស្ស អារោបិតេ មោហេ មោហេតិ អាបត្តិ ចាចិត្តិយស្ស ។

[៣៦៤] ភិក្ខុស្ស កុបិតោ អនត្តមនោ បហារំ ទេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ បហរតិ បយោគេ ទុក្កដំ បហដេ អាបត្តិ ចាចិត្តិយស្ស ។

[៣៦៥] ភិក្ខុស្ស កុបិតោ អនត្តមនោ តលសត្តិ-កំ ឧគ្គិរន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ឧគ្គិរតិ បយោគេ ទុក្កដំ ឧគ្គិរិតេ អាបត្តិ ចាចិត្តិយស្ស ។

[៣៦៦] ភិក្ខុំ អមូលកេន សង្ឃាទិសេសេន អនុទ្ធំសេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ អនុទ្ធំសេតិ បយោគេ ទុក្កដំ អនុទ្ធំសិតេ អាបត្តិ ចាចិត្តិយស្ស ។

[៣៦២] ភិក្ខុពោលបង្អាប់វិន័យ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងពោលបង្អាប់ លុះពោលបង្អាប់ហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៦៣] ភិក្ខុក្លែងធ្វើជាវង្វេង (ក្លែងពើធ្វើជាមិនដឹង) ត្រូវអាបត្តិ ២ គឺ កាលបើមោហារោបនកម្ម សង្ឃមិនទាន់សូត្រប្រកាសទេ ភិក្ខុក្លែងធ្វើជាវង្វេង ត្រូវអាបត្តិទុក្កដ កាលបើមោហារោបនកម្ម សង្ឃបានសូត្រប្រកាសហើយ នៅតែក្លែងធ្វើជាវង្វេង ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៦៤] ភិក្ខុក្រោធអាក់អន់ចិត្ត ឲ្យប្រហារភិក្ខុផងគ្នា ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងប្រហារ លុះប្រហារហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៦៥] ភិក្ខុក្រោធអាក់អន់ចិត្ត ង៉ាជន្ទលំពែងគឺបាតដៃ ដល់ភិក្ខុផងគ្នា ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងង៉ាជន្ទ លុះង៉ាជន្ទ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៦៦] ភិក្ខុចោទភិក្ខុផងគ្នា ដោយអាបត្តិសង្ឃាទិសេស មិនមានមូល ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងចោទ លុះចោទ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៦៧] ភិក្ខុស្ស សញ្ចិច្ច កុក្កុច្ចំ ឧបទហន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ឧបទហតិ បយោគេ ទុក្កដំ ឧបទហិតេ អាបត្តិ បាចិត្តិយស្ស ។

[៣៦៨] ភិក្ខូនំ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ ឧបស្សុតឹ តិដ្ឋន្តោ ទ្វេ អាបត្តិយោ អា-បជ្ជតិ សោស្សាមីតិ គច្ឆតិ អាបត្តិ ទុក្កដស្ស យត្ថ ឋិតោ សុណាតិ អាបត្តិ បាចិត្តិយស្ស ។

[៣៦៩] ធម្មិកានំ កម្មានំ ឆន្ទំ ទត្វា បច្ឆា ខីយនធម្មំ អាបជ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ខីយ-តិ បយោគេ ទុក្កដំ ខីយិតេ អាបត្តិ បាចិត្តិយស្ស ។

[៣៧០] សង្ឃេ វិនិច្ឆយកថាយ វត្តមានាយ ឆន្ទំ អទត្វា ឧដ្ឋាយាសនា បក្កមន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ បរិសាយ ហត្ថបាសំ អវិជហន្តស្ស អាបត្តិ ទុក្កដស្ស វិជហិតេ អាបត្តិ បាចិត្តិយស្ស ។

[៣៦៧] ភិក្ខុក្លែងបង្កសេចក្តីវង្វេស ឲ្យកើតឡើងដល់ភិក្ខុផងគ្នា ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងបង្កហេតុ លុះបង្ក (ហេតុនោះ) ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៦៨] កាលបើភិក្ខុទាំងឡាយ កំពុងប្រកួតប្រកាន់ ឈ្លោះទាស់ទែងគ្នា ភិក្ខុឈរអែបចាំស្តាប់ ត្រូវអាបត្តិ ២ គឺ ភិក្ខុទៅដោយគិតថា អញនឹងចាំស្តាប់ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ ក្នុងទីដែលឈរស្តាប់ ។

[៣៦៩] ភិក្ខុបានឲ្យឆន្ទៈ ចំពោះកម្មទាំងឡាយ ដែលប្រកបដោយធម៌ លុះមកខាងក្រោយ ត្រឡប់តិះដៀលវិញ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងតិះដៀល លុះតិះដៀល ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៧០] កាលបើពាក្យវិនិច្ឆ័យ កំពុងប្រព្រឹត្តទៅក្នុងជំនុំសង្ឃ ភិក្ខុមិនឲ្យឆន្ទៈ ហើយស្រាប់តែក្រោកចាកអាសនៈចៀសចេញទៅ ត្រូវអាបត្តិ ២ គឺ កាលបើមិនទាន់លះបង់ហត្ថបាសបរិស័ទទៅទេ ត្រូវអាបត្តិទុក្កដ លុះលះ (ហត្ថបាស) ចេញទៅហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៧១] សមកេ្កន សង្ឃេន ចីវរំ ឧត្វា បច្ឆា វីយនជម្មំ អាបជ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ វីយតិ បយោគេ ទុក្កដំ វីយិតេ អាបត្តិ ចាចិត្តិយស្ស ។

[៣៧២] ជានំ សង្ឃិកំ លាភំ បរិណតំ បុគ្គ-លស្ស បរិណាមេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ បរិ-ណាមេតិ បយោគេ ទុក្កដំ បរិណាមិតេ អាបត្តិ ចា-ចិត្តិយស្ស ។

សហាធម្មិកវគ្គោ អដ្ឋមោ ។

[៣៧៣] បុព្វេ អប្បដិសំវិទិតោ រញ្ញោ អន្តេបុរំ បវិសន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ បឋមំ ចាទំ ឧម្មារំ អតិក្កាមេតិ អាបត្តិ ទុក្កដស្ស ទុតិយំ ចាទំ អតិក្កាមេតិ អាបត្តិ ចាចិត្តិយស្ស ។

[៣៧៤] រតនំ ឧគ្គណ្ហន្តោ ទ្វេ អាបត្តិយោ អា-បជ្ជតិ គណ្ហាតិ បយោគេ ទុក្កដំ គហិតេ អាបត្តិ ចាចិត្តិយស្ស ។

[៣៧១] សង្ឃព្រមព្រៀងគ្នាឲ្យចីវរ (ដល់ភិក្ខុ) ហើយភិក្ខុណាមួយ ត្រឡប់តិះដៀលជាខាងក្រោយ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងតិះដៀល លុះតិះដៀល ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៧២] ភិក្ខុដឹងថា លាភជារបស់សង្ឃ គេបង្អោនទៅដើម្បីសង្ឃរួចហើយ ត្រឡប់បង្អោនមកដើម្បីបុគ្គលវិញ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងបង្អោនទៅ លុះបង្អោនទៅ ត្រូវអាបត្តិបាចិត្តិយៈ ។

ចប់ សហធម្មិកវគ្គ ទី ៨ ។

[៣៧៣] ភិក្ខុដែលមិនទាន់បានទូលស្នើព្រះបរមក្សត្រ ឲ្យទ្រង់ជ្រាបជាមុនទេ ហើយស្រាប់តែចូលទៅកាន់ខាងក្នុងព្រះរាជដំណាក់ ត្រូវអាបត្តិ ២ គឺ ឈានជំហានទី ១ ឲ្យកន្លងធរណីទ្វារទៅ ត្រូវអាបត្តិទុក្កដ ឈានជំហានទី ២ ឲ្យកន្លងហួសទៅ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៧៤] ភិក្ខុរើសយករតនវត្ថុ (គ្រឿងប្រើប្រាស់របស់គ្រហស្ថ) ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងរើសយក លុះរើសយក ត្រូវអាបត្តិបាចិត្តិយៈ ។

១៥៩

មហាវិភង្គេ សោឡស មហាវារា បាចិត្តិយកណ្ឌោ រាជវគ្គោ

[៣៧៥] សន្តំ ភិក្ខុំ អនាបុច្ឆា វិកាលេ គាមំ បវិសន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ បឋមំ បាទំ បរិក្ខេបំ បវិសន្តោ អតិក្កាមេតិ អាបត្តិ ទុក្កដស្ស ទុតិយំ បាទំ អតិក្កាមេតិ អាបត្តិ បាចិត្តិយស្ស ។

[៣៧៦] អដ្ឋិមយំ វា ទន្តមយំ វា វិសាណមយំ វា សូចិឃរំ ការាបេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ការាបេតិ បយោគេ ទុក្កដំ ការាបិតេ អាបត្តិ បាចិត្តិយស្ស ។

[៣៧៧] បមាណាតិក្កន្តំ មញ្ចំ វា បីឋំ វា ការាបេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ការាបេតិ បយោគេ ទុក្កដំ ការាបិតេ អាបត្តិ បាចិត្តិយស្ស ។

[៣៧៨] មញ្ចំ វា បីឋំ វា តូលោនទ្ធំ ការាបេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ការាបេតិ បយោគេ ទុក្កដំ ការាបិតេ អាបត្តិ បាចិត្តិយស្ស ។

[៣៧៩] បមាណាតិក្កន្តំ និសីទនំ ការាបេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ការាបេតិ បយោគេ ទុក្កដំ ការាបិតេ អាបត្តិ បាចិត្តិយស្ស ។

[៣៧៥] ភិក្ខុមិនលាភិក្ខុផងគ្នាដែលមាននៅ ចូលទៅកាន់ស្រុកក្នុងវេលាវិកាល ត្រូវអាបត្តិ ២ គឺ ឈានជំហានទី ១ ឲ្យកន្ទងហួសរបងទៅ ត្រូវអាបត្តិទុក្កដ ឈានជំហានទី ២ ឲ្យកន្លងទៅ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៧៦] ភិក្ខុឲ្យគេធ្វើបំពង់ម្ជុលនឹងឆ្អឹងក្តី ភ្លុកក្តី ស្នែងក្តី ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងឲ្យគេធ្វើ លុះឲ្យគេធ្វើហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៧៧] ភិក្ខុឲ្យគេធ្វើគ្រែក្តី តាំងក្តី ឲ្យកន្ទងហួសប្រមាណ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងឲ្យគេធ្វើ លុះឲ្យគេធ្វើរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៧៨] ភិក្ខុឲ្យគេធ្វើគ្រែក្តី តាំងក្តី ញាត់ដោយសំឡី[១] ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងឲ្យគេធ្វើ លុះឲ្យគេធ្វើរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៧៩] ភិក្ខុឲ្យគេធ្វើនិសីទនៈ ឲ្យកន្ទងហួសប្រមាណ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងឲ្យគេធ្វើ លុះឲ្យគេធ្វើរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

---

១ មើលក្នុងមហាវិភង្គភាគទី ៤ ត្រង់រតនវគ្គ សិក្ខាបទទី ៦ បព្វៈ ៣៧៨ ទំព័រ ៣៩០ ។

[៣៨០] បមាណាតិក្កន្តំ កណ្ឌុប្បដិច្ឆាទឹ ការា-បេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ការាបេតិ បយោគេ ទុក្កដំ ការាបិតេ អាបត្តិ ឆាចិត្តិយស្ស ។

[៣៨១] បមាណាតិក្កន្តំ វស្សិកសាដិកំ ការា-បេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ការាបេតិ បយោគេ ទុក្កដំ ការាបិតេ អាបត្តិ ឆាចិត្តិយស្ស ។

[៣៨២] សុគតចីវរប្បមាណំ ចីវរំ ការាបេន្តោ កតិ អាបត្តិយោ អាបជ្ជតិ ។ សុគតចីវរប្បមាណំ ចី-វរំ ការាបេន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ការាបេតិ បយោគេ ទុក្កដំ ការាបិតេ អាបត្តិ ឆាចិត្តិយស្ស សុគតចីវរប្បមាណំ ចីវរំ ការាបេន្តោ ឥមា ទ្វេ អា-បត្តិយោ អាបជ្ជតិ ។

រាជវគ្គោ នវមោ ។

ខុទ្ទកា និដ្ឋិតា ។

[៣៨០] ភិក្ខុឲ្យគេធ្វើសំពត់សម្រាប់គ្របកមឬដំបៅ ឲ្យកន្លងហួសប្រមាណ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងឲ្យគេធ្វើ លុះឲ្យគេធ្វើរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៨១] ភិក្ខុឲ្យគេធ្វើសំពត់សម្រាប់ងូតទឹកភ្លៀង ឲ្យកន្លងហួសប្រមាណ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងឲ្យគេធ្វើ លុះឲ្យគេធ្វើរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ។

[៣៨២] ភិក្ខុឲ្យគេធ្វើចីវរ ប៉ុនចីវរព្រះសុគត ត្រូវអាបត្តិប៉ុន្មាន ។ ភិក្ខុឲ្យគេធ្វើចីវរ ប៉ុនចីវរព្រះសុគត ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងឲ្យគេធ្វើ លុះឲ្យគេធ្វើរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ភិក្ខុឲ្យគេធ្វើចីវរ ប៉ុនចីវរព្រះសុគត ត្រូវអាបត្តិ ២ នេះឯង ។

ចប់ រាជវគ្គ ទី ៩ ។

ចប់ ពួកខុទ្ទកសិក្ខាបទ ។

[៣៨៣] អញ្ញាតិកាយ ភិក្ខុនិយា អន្តរឃរំ បវិដ្ឋាយ ហត្ថតោ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ភុញ្ជន្តោ កតិ អាបត្តិយោ អាបជ្ជតិ ។ អញ្ញាតិកាយ ភិក្ខុនិយា អន្តរឃរំ បវិដ្ឋាយ ហត្ថតោ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ភុញ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ភុញ្ជិស្សាមីតិ បដិ-គ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាដិទេសនីយស្ស អញ្ញាតិកាយ ភិក្ខុនិយា អន្តរឃរំ បវិដ្ឋាយ ហត្ថតោ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ភុញ្ជន្តោ ឥមា ទ្វេ អាបត្តិយោ អាបជ្ជតិ ។

[៣៨៤] ភិក្ខុនិយា វោសាសន្តិយា ន និវារេត្វា ភុញ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោ-ហារេ អាបត្តិ បាដិទេសនីយស្ស ។

[៣៨៣] ភិក្ខុទទួលខាទនីយៈក្តី ភោជនីយៈក្តី ដោយដៃខ្លួនឯង អំពីដៃភិក្ខុនី មិនមែនជាញាតិដែលចូលទៅកាន់ចន្លោះផ្ទះ យកមកឆាន់ ត្រូវអាបត្តិប៉ុន្មាន ។ ភិក្ខុទទួលខាទនីយៈក្តី ភោជនីយៈក្តី ដោយដៃខ្លួនឯង អំពីដៃភិក្ខុនី មិនមែនជាញាតិដែលចូលទៅកាន់ចន្លោះផ្ទះ យកមកឆាន់ ត្រូវអាបត្តិ ២ គឺ ភិក្ខុទទួល ដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាដិទេសនីយៈគ្រប់ ៗ វារៈដែលលេបចូលទៅ ភិក្ខុទទួលខាទនីយៈក្តី ភោជនីយៈក្តី ដោយដៃខ្លួនឯង អំពីដៃភិក្ខុនី មិនមែនជាញាតិ ដែលចូលទៅកាន់ចន្លោះផ្ទះ យកមកឆាន់ ត្រូវអាបត្តិ ២ នេះឯង ។

[៣៨៤] ភិក្ខុមិនហាមឃាត់ភិក្ខុនីដែលបង្គាប់ (ទាយកឲ្យប្រគេនរបស់នេះ របស់នោះ) ត្រូវអាបត្តិ ២ គឺ ភិក្ខុទទួល ដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាដិទេសនីយៈគ្រប់ ៗ វារៈដែលលេបចូលទៅ ។

[៣៨៥] សេក្ខសម្មតេសុ កុលេសុ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ភុញ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាដិទេសនីយស្ស ។

[៣៨៦] អារញ្ញកេសុ សេនាសនេសុ បុព្វេ អប្បដិសំវិទិតំ ខាទនីយំ វា ភោជនីយំ វា អជ្ឈារាមេ សហត្ថា បដិគ្គហេត្វា ភុញ្ជន្តោ កតិ អាបត្តិយោ អាបជ្ជតិ ។ អារញ្ញកេសុ សេនាសនេសុ បុព្វេ អប្បដិសំវិទិតំ ខាទនីយំ វា ភោជនីយំ វា អជ្ឈារាមេ សហត្ថា បដិគ្គហេត្វា ភុញ្ជន្តោ ទ្វេ អាបត្តិយោ អាបជ្ជតិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាដិទេសនីយស្ស អារញ្ញកេសុ សេនាសនេសុ បុព្វេ អប្បដិសំវិទិតំ ខាទនីយំ វា ភោជនីយំ វា អជ្ឈារាមេ សហត្ថា បដិគ្គហេត្វា ភុញ្ជន្តោ ឥមា ទ្វេ អាបត្តិយោ អាបជ្ជតិ ។

ចត្តារោ បាដិទេសនីយា និដ្ឋិតា ។

[៣៨៥] ភិក្ខុទទួលខាទនីយៈក្តី ភោជនីយៈក្តី ក្នុងត្រកូលដែលសង្ឃសន្មតថាជាសេក្ខត្រកូល ដោយដៃខ្លួនឯងមកឆាន់ ត្រូវអាបត្តិ ២ គឺ ភិក្ខុទទួលដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវបាដិទេសនីយៈ គ្រប់ ៗ វារៈដែលលេបចូលទៅ ។

[៣៨៦] ភិក្ខុ (នៅ) ក្នុងសេនាសនៈ ដែលតាំងនៅក្នុងព្រៃហើយទទួលខាទនីយៈក្តី ភោជនីយៈក្តី ដែលគេមិនបានឲ្យដំណឹងមកជាមុនដោយដៃខ្លួនឯង យកមកឆាន់ខាងក្នុងអារាម ត្រូវអាបត្តិប៉ុន្មាន ។ ភិក្ខុ (នៅ) ក្នុងសេនាសនៈ ដែលតាំងនៅក្នុងព្រៃ ហើយទទួលខាទនីយៈក្តី ភោជនីយៈក្តី ដែលគេមិនបានឲ្យដំណឹងមកជាមុនដោយដៃខ្លួនឯង យកមកឆាន់ខាងក្នុងអារាម ត្រូវអាបត្តិ ២ គឺ ភិក្ខុទទួលដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាដិទេសនីយៈគ្រប់ ៗ វារៈដែលលេបចូលទៅ ភិក្ខុ (នៅ) ក្នុងសេនាសនៈ ដែលតាំងនៅក្នុងព្រៃទទួលខាទនីយៈក្តី ភោជនីយៈក្តី ដែលគេមិនបានឲ្យដំណឹងមកជាមុនដោយដៃខ្លួនឯង យកមកឆាន់ខាងក្នុងអារាម ត្រូវអាបត្តិ ២ នេះឯង ។

ចប់ បាដិទេសនីយៈ ៤ ។

[៣៨៧] អជានវិយំ បដិច្ច បុរតោ វា បច្ឆតោ វា ឱលម្ពេន្តោ និវាសេន្តោ កាតិ អាបត្តិយោ អាបជ្ជតិ ។ អជានវិយំ បដិច្ច បុរតោ វា បច្ឆតោ វា ឱលម្ពេន្តោ និវាសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ អជានវិយំ បដិច្ច បុរតោ វា បច្ឆតោ វា ឱលម្ពេន្តោ និវាសេន្តោ ឥមំ ឯកំ អាបត្តឹ អាបជ្ជតិ ។

[៣៨៨] អជានវិយំ បដិច្ច បុរតោ វា បច្ឆតោ វា ឱលម្ពេន្តោ ចារុបេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៣៨៩] អជានវិយំ បដិច្ច កាយំ វិវរិត្វា អន្តរឃរេ គច្ឆន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៣៩០] អជានវិយំ បដិច្ច កាយំ វិវរិត្វា អន្តរឃរេ និសីទន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៣៩១] អជានវិយំ បដិច្ច ហត្ថំ វា ចាទំ វា កីឡាបេន្តោ អន្តរឃរេ គច្ឆន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៣៩២] អជានវិយំ បដិច្ច ហត្ថំ វា ចាទំ វា កីឡាបេន្តោ អន្តរឃរេ និសីទន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៣៨៧] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ស្លៀកស្បង់ស្ទុយមុខ ឬស្ទុយក្រោយ ត្រូវអាបត្តិប៉ុន្មាន ។ ភិក្ខុ អាស្រ័យសេចក្តីមិនអើពើ ស្លៀកស្បង់ស្ទុយមុខ ឬស្ទុយក្រោយ ត្រូវអាបត្តិ ១ គឺ ទុក្កដ ភិក្ខុ អាស្រ័យសេចក្តីមិនអើពើ ស្លៀកស្បង់ស្ទុយមុខ ឬស្ទុយក្រោយ ត្រូវអាបត្តិ ១ នេះឯង ។

[៣៨៨] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឃ្លុំចីពរឲ្យស្ទុយមុខ ឬស្ទុយក្រោយ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៣៨៩] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បើកកាយដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៣៩០] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បើកកាយអង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៣៩១] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរគ្រវាសដៃឬជើងទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៣៩២] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ អង្គុយគ្រវាសដៃឬជើងក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៣៩៣] អជាតរិយំ បដិច្ច តហំ តហំ ឱលោកេន្តោ អន្តរឃរេ គច្ឆន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៣៩៤] អជាតរិយំ បដិច្ច តហំ តហំ ឱលោកេ-ន្តោ អន្តរឃរេ និសីទន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៣៩៥] អជាតរិយំ បដិច្ច ឧក្ខិត្តកាយ អន្តរឃរេ គច្ឆន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៣៩៦] អជាតរិយំ បដិច្ច ឧក្ខិត្តកាយ អន្តរឃរេ និសីទន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

បឋមោ វគ្គោ[១] ។

[៣៩៧] អជាតរិយំ បដិច្ច ឧជ្ជគ្ឃិកាយ អន្តរ-ឃរេ គច្ឆន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៣៩៨] អជាតរិយំ បដិច្ច ឧជ្ជគ្ឃិកាយ អន្តរ-ឃរេ និសីទន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៣៩៩] អជាតរិយំ បដិច្ច ឧច្ចាសទ្ទំ មហាសទ្ទំ ករោន្តោ អន្តរឃរេ គច្ឆន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

---

១ ឱ. ម. បរិមណ្ឌលវគ្គោ បឋមោ ។

[៣៩៣] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ដើរផ្ងាកមើលពីសពាស ទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៣៩៤] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ អង្គុយផ្ងាកមើលពីសពាស ក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៣៩៥] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ សើយចីវរដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៣៩៦] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ សើយចីវរអង្គុយក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

ចប់ វគ្គទី ១ ។

[៣៩៧] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ដើរទៅក្នុងចន្លោះផ្ទះដោយសំណើចខ្លាំង ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៣៩៨] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ អង្គុយក្នុងចន្លោះផ្ទះដោយសំណើចខ្លាំង ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៣៩៩] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ធ្វើសំឡេងហ៊ោ សំឡេងខ្លាំង ដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤០០] អជានរិយំ បដិច្ច ឧច្ចាសន្ទំ មហាសន្ទំ កាហេន្តោ អន្តរឃរេ និសីទន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤០១] អជានរិយំ បដិច្ច កាយប្បចាលកំ អន្តរឃរេ គច្ឆន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤០២] អជានរិយំ បដិច្ច កាយប្បចាលកំ អន្តរឃរេ គច្ឆន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤០៣] អជានរិយំ បដិច្ច ពាហុប្បចាលកំ អន្តរឃរេ និសីទន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤០៤] អជានរិយំ បដិច្ច ពាហុប្បចាលកំ អន្តរឃរេ និសីទន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤០៥] អជានរិយំ បដិច្ច សីសប្បចាលកំ អន្តរឃរេ គច្ឆន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤០៦] អជានរិយំ បដិច្ច សីសប្បចាលកំ អន្តរឃរេ និសីទន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

ទុតិយោ វគ្គោ[១] ។

---

១ ឱ. ម. ឧជ្ជគ្ឃិកវគ្គោ ទុតិយោ ។

[៤០០] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ធ្វើសំឡេងហ៊ោ សំឡេងខ្លាំង អង្គុយក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤០១] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ដើរគ្រលែងកាយទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤០២] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ អង្គុយគ្រលែងកាយក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤០៣] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ដើរគ្រវាសដៃទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤០៤] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ អង្គុយគ្រវាសដៃក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤០៥] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ដើរធ្វើក្បាលងើកងោកទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤០៦] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ អង្គុយធ្វើក្បាលងើកងោកក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

ចប់ វគ្គទី ២ ។

[៤០៧] អនាទរិយំ បដិច្ច ខម្ភកតោ អន្តរឃរេ គច្ឆន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤០៨] អនាទរិយំ បដិច្ច ខម្ភកតោ អន្តរឃរេ និសីទន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤០៩] អនាទរិយំ បដិច្ច ឱគុណ្ឋិតោ អន្តរឃរេ គច្ឆន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤១០] អនាទរិយំ បដិច្ច ឱគុណ្ឋិតោ អន្តរឃរេ និសីទន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤១១] អនាទរិយំ បដិច្ច ឧក្កុដិកាយ អន្តរឃរេ គច្ឆន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤១២] អនាទរិយំ បដិច្ច បល្លត្ថិកាយ អន្តរឃរេ និសីទន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤១៣] អនាទរិយំ បដិច្ច អសក្កច្ចំ បិណ្ឌបាតំ បដិគ្គណ្ហន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤១៤] អនាទរិយំ បដិច្ច តហំ តហំ ឱលោកេន្តោ បិណ្ឌបាតំ បដិគ្គណ្ហន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤០៧] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ដើរស្ទីមចង្កេះទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤០៨] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ អង្គុយស្ទីមចង្កេះក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤០៩] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ដើរទទូរក្បាលទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤១០] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ អង្គុយទទូរក្បាលក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤១១] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ដើរបំអើតជើងទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤១២] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ អង្គុយត្របោមក្បាលជង្គង់ក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤១៣] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ទទួលបិណ្ឌបាតដោយមិនគោរព ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤១៤] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ងាកមើលពីសពាសទទួលបិណ្ឌបាត ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

មហាវិភង្គេ សោឡស មហាវារា សេក្ខិយកណ្ឌេ ចតុត្ថោ វគ្គោ

[៤១៥] អជានវិយំ បជិច្ច សូបញ្ជោវ ពហុំ បជិគ្គ-ណ្ហាវេ្តា ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤១៦] អជានវិយំ បជិច្ច ថូបីកតំ បិណ្ឌបាតំ បជិគ្គណ្ហាវេ្តា ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

តតិយោ វគ្គោ[១] ។

[៤១៧] អជានវិយំ បជិច្ច អសក្កច្ចំ បិណ្ឌបាតំ កុញ្ជវេ្តា ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤១៨] អជានវិយំ បជិច្ច តហំ តហំ ឱលោកេវេ្តា បិណ្ឌបាតំ កុញ្ជវេ្តា ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤១៩] អជានវិយំ បជិច្ច តហំ តហំ ឱមសិត្វា បិណ្ឌបាតំ កុញ្ជវេ្តា ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤២០] អជានវិយំ បជិច្ច សូបញ្ជោវ ពហុំ កុញ្ជវេ្តា ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤២១] អជានវិយំ បជិច្ច ថូបតោ ឱមទ្ទិត្វា បិណ្ឌ-បាតំ កុញ្ជវេ្តា ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

---

១ ឱ. ម. ខម្ពកតវគ្គោ តតិយោ ។

[៦១៥] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ទទួលសម្លច្រើន (ជាងបាយ) ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៦១៦] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ទទួលបិណ្ឌបាតឲ្យកំពុងហួសពីកណ្តាប់បាត្រទៅ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

ចប់ វគ្គទី ៣ ។

[៦១៧] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឆាន់បិណ្ឌបាតដោយមិនគោរព ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៦១៨] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឆាន់បិណ្ឌបាតងាកមើលពីសពាស ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៦១៩] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ កកាយ (បាយ) ត្រង់ទីនោះ ៗ ឆាន់បិណ្ឌបាត ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៦២០] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឆាន់សម្លច្រើន (ជាងបាយ) ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៦២១] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ច្រូមចុះអំពីកំពូលបាយឆាន់បិណ្ឌបាត ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤២២] អនាទរិយំ បដិច្ច សូបំ វា ព្យញ្ជនំ វា ឱននេន បដិច្ឆាទេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤២៣] អនាទរិយំ បដិច្ច សូបំ វា ឱទនំ វា អគិលានោ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤២៤] អនាទរិយំ បដិច្ច ឧជ្ឈានសញ្ញី បរេសំ បត្តំ ឱលោកេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤២៥] អនាទរិយំ បដិច្ច មហន្តំ កពឡំ ករោន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤២៦] អនាទរិយំ បដិច្ច ទីឃំ អាលោបំ ករោន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

ចតុត្ថោ វគ្គោ[១] ។

[៤២៧] អនាទរិយំ បដិច្ច អនាហដេ កពឡេ មុខទ្វារំ វិវរន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤២៨] អនាទរិយំ បដិច្ច ភុញ្ជន្តោ សព្វំ ហត្ថំ មុខេ បក្ខិបន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

---

១ ឱ. ម. បិណ្ឌបាតវគ្គោ ចតុត្ថោ ។

[៤២២] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ កកាយបាយលុបសម្ល ឬម្ហូបក្រៀម ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤២៣] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ខ្លួនមិនឈឺ សូមសម្ល ឬបាយ ដើម្បីជាប្រយោជន៍ដល់ខ្លួនឯងឆាន់ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤២៤] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ មានសេចក្ដីសំគាល់ដើម្បីលើកទោស ហើយសំឡឹងមើលបាត្រពួកភិក្ខុដទៃ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤២៥] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ធ្វើពំនូតបាយឲ្យធំ (ពេក) ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤២៦] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ធ្វើពំនូតបាយ ឲ្យវែង (ពេក) ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

ចប់ វគ្គទី ៤ ។

[៤២៧] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ កាលដែលពំនូតបាយមិនទាន់ដល់មាត់ ហាមាត់ចាំ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤២៨] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ឆាន់ញាត់ម្រាមដៃទាំងអស់ទៅក្នុងមាត់ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤២៩] អជានរិយំ បដិច្ច សកាពទ្បេង មុខេង ព្យាហរន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៣០] អជានរិយំ បដិច្ច បិណ្ឌុក្ខេបកំ ភុញ្ជន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៣១] អជានរិយំ បដិច្ច កាពឡាវច្ឆេទកំ ភុញ្ជន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៣២] អជានរិយំ បដិច្ច អវគណ្ឌកាការកំ ភុញ្ជន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៣៣] អជានរិយំ បដិច្ច ហត្ថនិទ្ធូនកំ ភុញ្ជន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៣៤] អជានរិយំ បដិច្ច សិត្ថាវកាការកំ ភុញ្ជន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៣៥] អជានរិយំ បដិច្ច ជិវ្ហានិច្ឆារកំ ភុញ្ជន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៣៦] អជានរិយំ បដិច្ច ចបុចបុការកំ ភុញ្ជន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

បញ្ចមោ វគ្គោ[១] ។

១ ឱ. ម. កពឡវគ្គោ បញ្ចមោ ។

[៤២៩] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ និយាយទាំងពំនូតបាយនៅក្នុងមាត់ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៣០] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ឆាន់បោះដុំបាយ (ទៅក្នុងមាត់) ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៣១] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ឆាន់ខាំកាត់ពំនូតបាយ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៣២] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ឆាន់បៀមពំនូតបាយឲ្យទុលថ្ពាល់ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៣៣] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ឆាន់រលាស់ដៃបណ្ដើរ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៣៤] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ឆាន់ធ្វើគ្រាប់បាយឲ្យជ្រុះរោយរាយ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៣៥] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ឆាន់លៀនអណ្ដាត ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៣៦] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ឆាន់ឮសូរផ្ចប់ ៗ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

ចប់ វគ្គទី ៥ ។

[៤៣៧] អជានន្តិយំ បដិច្ច សុរុសុរុការកំ ភុញ្ជន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៣៨] អជានន្តិយំ បដិច្ច ហត្ថនិល្លេហកំ ភុញ្ជន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៣៩] អជានន្តិយំ បដិច្ច បត្តនិល្លេហកំ ភុញ្ជន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៤០] អជានន្តិយំ បដិច្ច ឱដ្ឋនិល្លេហកំ ភុញ្ជន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៤១] អជានន្តិយំ បដិច្ច សាមិសេន ហត្ថេន បានីយថាលកំ បដិគ្គណ្ហន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៤២] អជានន្តិយំ បដិច្ច សសិត្ថកំ បត្តធោវនំ អន្តរឃរេ ឆឌ្ឌេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៤៣] អជានន្តិយំ បដិច្ច ឆត្តបាណិស្ស ធម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៣៧] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ធាន់ព្ទសូរគ្រូក ៗ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៣៨] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ធាន់លិទ្ធដៃ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៣៩] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ធាន់លិទ្ធបាត្រ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៤០] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ធាន់លិទ្ធបបូរមាត់ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៤១] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ មានដៃប្រឡាក់ដោយអាមិស: ទទួលផ្តិលទឹក ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៤២] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ ចាក់ទឹកលាងបាត្រ ទាំងគ្រាប់បាយ ចោលក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៤៣] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ សម្ដែងធម៌ដល់មនុស្សមានឆត្រក្នុងដៃ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

មហាវិភង្គេ សោឡស មហាវារា សេខិយកណ្ឌោ សត្តមោ វគ្គោ

[៥៥៤] អជានរិយំ បដិច្ច ទណ្ឌាចាណិស្ស ធម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៥៥៥] អជានរិយំ បដិច្ច សត្ថបាណិស្ស ធម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៥៥៦] អជានរិយំ បដិច្ច អាវុធបាណិស្ស ធម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

ឆដ្ឋោ វគ្គោ[១] ។

[៥៥៧] អជានរិយំ បដិច្ច បាទុការូឡ្ហស្ស ធម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៥៥៨] អជានរិយំ បដិច្ច ឧបាហនារូឡ្ហស្ស ធម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៥៥៩] អជានរិយំ បដិច្ច យានគតស្ស ធម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៥៩០] អជានរិយំ បដិច្ច សយនគតស្ស ធម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

---

១ ឱ. ម. សុរុសុរុវគ្គោ ឆដ្ឋោ ។

[៤៤៤] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ សម្ដែងធម៌ ដល់មនុស្ស មានដំបងក្នុងដៃ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៤៥] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ សម្ដែងធម៌ដល់មនុស្ស មានគ្រឿងសស្ត្រាក្នុងដៃ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៤៦] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ សម្ដែងធម៌ ដល់មនុស្ស មានគ្រឿងអាវុធក្នុងដៃ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

ចប់ វគ្គទី ៦ ។

[៤៤៧] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ សម្ដែងធម៌ដល់មនុស្ស ពាក់ទ្រនាប់ជើង ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៤៨] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ សម្ដែងធម៌ ដល់មនុស្ស ពាក់ស្បែកជើង ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៤៩] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ សម្ដែងធម៌ ដល់មនុស្ស ដែលនៅលើយាន ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៥០] ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ សម្ដែងធម៌ ដល់មនុស្ស ដែលនៅលើដំណេក ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៩១] អជានវិយំ បជិច្ច បល្វត្ថិកាយ និសិន្នស្ស ធម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៩២] អជានវិយំ បជិច្ច វេឋិតសីសស្ស ធម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៩៣] អជានវិយំ បជិច្ច ឱគុណ្ឋិតសីសស្ស ធម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៩៤] អជានវិយំ បជិច្ច ឆមាយំ និសីទិត្វា អាសនេ និសិន្នស្ស ធម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៩៥] អជានវិយំ បជិច្ច នីចេ អាសនេ និសីទិត្វា ឧច្ចេ អាសនេ និសិន្នស្ស ធម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៩៦] អជានវិយំ បជិច្ច ឋិតោ និសិន្នស្ស ធម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៩៧] អជានវិយំ បជិច្ច បច្ឆតោ គច្ឆន្តោ បុរ-តោ គច្ឆន្តស្ស ធម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៩១] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ ដល់មនុស្ស ដែលអង្គុយត្របោមក្បាលជង្គង់ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៩២] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ ដល់មនុស្ស ដែលជួតក្បាល ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៩៣] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ ដល់មនុស្ស ដែលទទូរក្បាល ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៩៤] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ អង្គុយលើផែនដី សម្តែងធម៌ ដល់មនុស្សដែលអង្គុយលើអាសនៈ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៩៥] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ អង្គុយលើអាសនៈទាប សម្តែងធម៌ ដល់មនុស្សដែលអង្គុយលើអាសនៈខ្ពស់ ត្រូវអាបត្តិ ១ គឺទុក្កដ ។

[៤៩៦] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឈរសម្តែងធម៌ ដល់មនុស្សដែលអង្គុយ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

[៤៩៧] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរពីខាងក្រោយ សំដែងធម៌ ដល់មនុស្សដែលដើរពីខាងមុខ ត្រូវអាបត្តិ ១ គឺ ទុក្កដ ។

មហាវិភង្គេ សោឡស មហាវារា សេក្ខិយកណ្ឌេ សត្តមោ វគ្គោ

[៤៥៨] អជានន្តិយំ បដិច្ច ឧប្បថេន គច្ឆន្តោ បថេន គច្ឆន្តស្ស ធម្មំ ទេសេន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៥៩] អជានន្តិយំ បដិច្ច ឋិតោ ឧច្ចារំ វា បស្សាវំ វា ករោន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៦០] អជានន្តិយំ បដិច្ច ហរិតេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។

[៤៦១] អជានន្តិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តោ កតិ អាបត្តិយោ អាបជ្ជតិ ។ អជានន្តិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ អជានន្តិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តោ ឥមំ ឯកំ អាបត្តឹ អាបជ្ជតិ ។

សត្តមោ វគ្គោ[១] ។

បញ្ចសត្តតិ សេក្ខិយា និដ្ឋិតា[២] ។

កតាបត្តិវារំ និដ្ឋិតំ ទុតិយំ ។

---

១ ម. បាទុកវគ្គោ សត្តមោ ។ ២ សេក្ខិយា និដ្ឋិតា ។

[៤៥៨] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរក្រៅផ្លូវ សម្តែងធម៌ដល់មនុស្សដែលដើរតាមផ្លូវ ត្រូវអាបត្តិ ១ គឺទុក្កដ ។

[៤៥៩] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឈរបន្ទោឧច្ចារៈ ឬបស្សាវៈ ត្រូវអាបត្តិ ១ គឺទុក្កដ ។

[៤៦០] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ដាក់លើវត្ថុខៀវស្រស់ ត្រូវអាបត្តិ ១ គឺទុក្កដ ។

[៤៦១] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក ត្រូវអាបត្តិប៉ុន្មាន ។ ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក ត្រូវអាបត្តិ ១ គឺទុក្កដ ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក ត្រូវអាបត្តិ ១ នេះឯង ។

ចប់ វគ្គទី ៧ ។

ចប់ ពួកសេក្ខិយវត្ត ៧៥ ។

ចប់ កតាបត្តិវារៈទី ២ ។

[៤៦២] មេថុនំ ធម្មំ បដិសេវន្តស្ស អាបត្តិយោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ មេថុនំ ធម្មំ បដិសេវន្តស្ស អាបត្តិយោ ចតុន្នំ វិបត្តីនំ ទ្វេ វិបត្តិយោ ភជន្តិ សិយា សីលវិបត្តឹ សិយា អាចារវិបត្តឹ ។ បេ ។ អជានវិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តស្ស អាបត្តិ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជតិ ។ អជានវិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តស្ស អាបត្តិ ចតុន្នំ វិបត្តីនំ ឯកំ វិបត្តឹ ភជតិ អាចារវិបត្តឹ ។

វិបត្តិវារំ និដ្ឋិតំ តតិយំ ។

[៤៦៣] មេថុនំ ធម្មំ បដិសេវន្តស្ស អាបត្តិយោ សត្តន្នំ អាបត្តិក្ខន្ធានំ កតីហិ អាបត្តិក្ខន្ធេហិ សង្គហិ-តា ។ មេថុនំ ធម្មំ បដិសេវន្តស្ស អាបត្តិយោ សត្តន្នំ អាបត្តិក្ខន្ធានំ តីហិ អាបត្តិក្ខន្ធេហិ សង្គហិតា សិ-យា បារាជិកាបត្តិក្ខន្ធេន សិយា ថុល្លច្ចយាបត្តិក្ខន្ធេ-ន សិយា ទុក្កដាបត្តិក្ខន្ធេន ។ បេ ។ អជានវិយំ

[៤៦២] បណ្តាវិបត្តិទាំង ៤ អាបត្តិរបស់ភិក្ខុ ដែលសេពមេ-ថុនធម្ម រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន ។ បណ្តាវិបត្តិទាំង ៤ អាបត្តិរបស់ភិក្ខុដែលសេពមេថុនធម្ម រាប់បញ្ចូលក្នុងវិបត្តិ ២ គឺសីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន ។ បេ ។ បណ្តាវិបត្តិទាំង ៤ អាបត្តិរបស់ភិក្ខុដែលអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក រាប់បញ្ចូល ក្នុងវិបត្តិប៉ុន្មាន ។ បណ្តាវិបត្តិទាំង ៤ អាបត្តិរបស់ភិក្ខុដែលអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក រាប់បញ្ចូល ក្នុងវិបត្តិ ១ គឺ អាចារវិបត្តិ ។

ចប់ វិបត្តិវារៈ ទី ៣ ។

[៤៦៣] បណ្តាកងនៃអាបត្តិទាំង ៧ អាបត្តិរបស់ភិក្ខុដែលសេពមេថុនធម្ម លោកសង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន ។ បណ្តាកងនៃអាបត្តិទាំង ៧ អាបត្តិរបស់ភិក្ខុ ដែលសេពមេថុនធម្ម លោកសង្គ្រោះដោយកងនៃអាបត្តិ ៣ កង គឺ កងនៃបារាជិកាបត្តិក៏មាន កងនៃថុល្លច្ចយាបត្តិក៏មាន កងនៃទុក្កដាបត្តិក៏មាន ។ បេ ។ បណ្តាកងនៃអាបត្តិ

បដិច្ច ឧតកោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា កាហេន្តស្ស អាបត្តិ សត្តន្នំ អាបត្តិក្ខន្ធានំ កតីហិ អាបត្តិក្ខន្ធេហិ សង្គហិតា ។ អជានវិយំ បដិច្ច ឧតកោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា កាហេន្តស្ស អាបត្តិ សត្តន្នំ អាបត្តិក្ខន្ធានំ ឯកេន អាបត្តិក្ខន្ធេន សង្គហិតា ទុក្កដាបត្តិក្ខន្ធេន ។

សង្គហិតវារំ និដ្ឋិតំ ចតុត្ថំ ។

[៤៦៤] មេថុនំ ធម្មំ បដិសេវន្តស្ស អាបត្តិយោ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ ។ មេថុនំ ធម្មំ បដិសេវន្តស្ស អាបត្តិយោ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋហន្តិ កាយតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន វាចតោ ។ បេ ។ អជានវិយំ បដិច្ច ឧតកោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា កាហេន្តស្ស អាបត្តិ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ អជានវិយំ បដិច្ច

ទាំង ៧ អាបត្តិរបស់ភិក្ខុ ដែលអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក លោកសង្គ្រោះដោយកង នៃអាបត្តិប៉ុន្មាន ។ បណ្តាកងនៃអាបត្តិទាំង ៧ អាបត្តិរបស់ភិក្ខុដែលអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក លោកសង្គ្រោះដោយកងនៃអាបត្តិ ១ គឺទុក្កដាបត្តិ ។

ចប់ សង្គហិតវារៈ ទី ៤ ។

[៤៦៤] បណ្តាសមុដ្ឋាន នៃអាបត្តិទាំង ៦ អាបត្តិរបស់ភិក្ខុដែលសេពមេថុនធម្ម តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិរបស់ភិក្ខុដែលសេពមេថុនធម្ម តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាឡើយ ។ បេ ។ បណ្តាសមុដ្ឋាន នៃអាបត្តិទាំង ៦ អាបត្តិរបស់ភិក្ខុដែលអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ បណ្តាសមុដ្ឋាន នៃអាបត្តិទាំង ៦ អាបត្តិរបស់ភិក្ខុ ដែលអាស្រ័យសេចក្តីមិនអើពើ

ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តស្ស អាបត្តិ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។

សមុដ្ឋានវារំ និដ្ឋិតំ បញ្ចមំ ។

[៤៦៥] មេថុនំ ធម្មំ បដិសេវន្តស្ស អាបត្តិយោ ចតុន្នំ អធិករណានំ កតមំ អធិករណំ ។ មេថុនំ ធម្មំ បដិសេវន្តស្ស អាបត្តិយោ ចតុន្នំ អធិករណានំ អាបត្តា-ធិករណំ ។ បេ ។ អជានរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តស្ស អាបត្តិ ចតុន្នំ អធិ-ករណានំ កតមំ អធិករណំ ។ អជានរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តស្ស អាបត្តិ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។

អធិករណវារំ និដ្ឋិតំ ឆដ្ឋំ ។

[៤៦៦] មេថុនំ ធម្មំ បដិសេវន្តស្ស អាបត្តិយោ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មន្តិ ។ មេថុនំ

បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក តាំងឡើងដោយសមុដ្ឋាន ១ គឺ តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាឡើយ ។

ចប់ សមុដ្ឋានវារៈ ទី ៥ ។

[៤៦៥] បណ្តាអធិករណ៍ ទាំង ៤ អាបត្តិរបស់ភិក្ខុ ដែលសេពមេថុនធម្ម ចាត់ជាអធិករណ៍ណា ។ បណ្តាអធិករណ៍ទាំង ៤ អាបត្តិរបស់ភិក្ខុដែលសេពមេថុនធម្ម ចាត់ជាអាបត្តាធិករណ៍ ។ បេ ។ បណ្តាអធិករណ៍ទាំង ៤ អាបត្តិរបស់ភិក្ខុ ដែលអាស្រ័យសេចក្តីមិនអើ-ពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក ចាត់ជាអធិករណ៍ណា ។ បណ្តាអធិករណ៍ទាំង ៤ អាបត្តិរបស់ភិក្ខុ ដែលអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក ចាត់ជាអាបត្តាធិករណ៍ ។

ចប់ អធិករណវារៈ ទី ៦ ។

[៤៦៦] បណ្តាសមថៈទាំង ៧ អាបត្តិរបស់ភិក្ខុ ដែលសេពមេថុនធម្ម រម្ងាប់ដោយសមថៈប៉ុន្មាន ។ បណ្តាសមថៈទាំង ៧

១៧៧



ធម្មំ បដិសេវន្តស្ស អាបត្តិយោ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មន្តិ សិយា សម្មុខាវិនយេន ច បដិញ្ញាត-ការណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។ បេ ។ អនាទរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តស្ស អាបត្តិ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មតិ ។ អនាទរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តស្ស អាបត្តិ សត្តន្នំ សម-ថានំ តីហិ សមថេហិ សម្មតិ សិយា សម្មុខាវិនយេន ច បដិញ្ញាតការណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។

សមថវារំ និដ្ឋិតំ សត្តមំ ។

អាបត្តិរបស់ភិក្ខុ ដែលសេពមេថុនធម្ម រម្ងាប់ដោយសមថៈ ៣ គឺ សម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មានខ្លះ សម្មុខាវិន័យនិងតិណវត្ថារកៈក៏មានខ្លះ[១] ។ បេ ។ បណ្ដាសមថៈទាំង ៧ អាបត្តិរបស់ភិក្ខុដែលអាស្រ័យសេចក្ដីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក រម្ងាប់ដោយសមថៈប៉ុន្មាន ។ បណ្ដាសមថៈទាំង ៧ អាបត្តិរបស់ភិក្ខុដែលអាស្រ័យសេចក្ដីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក រម្ងាប់ដោយសមថៈ ៣ គឺ សម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មានខ្លះ សម្មុខាវិន័យនិងតិណវត្ថារកៈក៏មានខ្លះ ។

ចប់ សមថវារៈ ទី ៧ ។

---

១ ក្នុងទីនេះ បើនិយាយតាមឈ្មោះសមថៈ ឃើញថា ៣ តែបើនិយាយតាមសេចក្ដីរួមនៅតែ ២ វិញ ដូចសេចក្ដីដែលប្រែហើយនេះ ។ ព្រោះក្នុងសុមង្គលវិលាសិនីអដ្ឋកថាទីឃនិកាយ ត្រង់សង្គីតិសូត្រ ពន្យល់ថា អាបត្តាធិករណ៍ រម្ងាប់ដោយសម្មុខាវិន័យតែម្យ៉ាងមិនបានទេ ដូចយ៉ាងភិក្ខុសម្ដែងលហុកាបត្តិក្នុងសំណាក់ភិក្ខុ ១ រូប ឬកណ្ដាលជំនុំសង្ឃ ឬគណៈ ក្នុងកាលណា ទើបហៅថា អាបត្តាធិករណ៍រម្ងាប់ដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈ ក្នុងកាលនោះ ។ ព្រោះហេតុដូច្នោះ បានជាលោកពោលថា អាបត្តាធិករណ៍តែងរម្ងាប់ដោយន័យ ២ យ៉ាង គឺដោយសម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មានខ្លះ ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មានខ្លះ ដោយប្រការដូច្នេះ ។

[៦៦៧] មេថុនំ ធម្មំ បដិសេវន្តោ កតិ អាបត្តិយោ អាបជ្ជតិ ។ មេថុនំ ធម្មំ បដិសេវន្តោ តិស្សោ អាបត្តិយោ អាបជ្ជតិ អក្ខាយិតេ សរីរេ មេថុនំ ធម្មំ បដិសេវតិ អាបត្តិ បារាជិកស្ស យេភុយ្យេន ខាយិតេ សរីរេ មេថុនំ ធម្មំ បដិសេវតិ អាបត្តិ ថុល្លច្ចយស្ស វិវដកតេ មុខេ អច្ឆុបន្តំ អង្គជាតំ បវេសេតិ អាបត្តិ ទុក្កដស្ស មេថុនំ ធម្មំ បដិសេវន្តោ ឥមា តិស្សោ អាបត្តិយោ អាបជ្ជតិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតីហិ អាបត្តិក្ខន្ធេហិ សង្គហិតា ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ ។ ចតុន្នំ អធិករណានំ កតមំ អធិករណំ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មន្តិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ ទ្វេ វិបត្តិយោ ភជន្តិ សិយា សីលវិបត្តឹ សិយា អាចារវិបត្តឹ ។ សត្តន្នំ អាបត្តិក្ខន្ធានំ តីហិ អាបត្តិក្ខន្ធេហិ សង្គហិតា សិយា បារាជិកាបត្តិក្ខន្ធេន សិយា ថុល្លច្ចយាបត្តិក្ខន្ធេន សិយា ទុក្កដាបត្តិក្ខន្ធេន ។

[៤៦៧] ភិក្ខុសេពមេថុនធម្ម ត្រូវអាបត្តិប៉ុន្មាន ។ ភិក្ខុសេពមេថុនធម្ម ត្រូវអាបត្តិ ៣ គឺ សេពមេថុនធម្មនឹងសរីរៈ ដែលសត្វមិនទាន់ទំពាស៊ី ត្រូវអាបត្តិបារាជិក សេពមេថុនធម្មនឹងសរីរៈដែលសត្វទំពា-ស៊ីហើយដោយច្រើន ត្រូវអាបត្តិថុល្លច្ច័យ បញ្ចូលអង្គជាតទៅក្នុងទ្វារមាត់ដែលហា តែមិនឲ្យប៉ះពាល់ ត្រូវអាបត្តិទុក្កដ ភិក្ខុសេពមេថុនធម្ម ត្រូវអាបត្តិ ៣ នេះឯង ។ បណ្តាវិបត្តិទាំង ៤ អាបត្តិទាំងនោះរាប់បញ្ចូល ក្នុងវិបត្តិណា ។ បណ្តាកងនៃអាបត្តិទាំង ៧ លោកសង្គ្រោះ ដោយកងនៃអាបត្តិប៉ុន្មាន ។ បណ្តាសមុដ្ឋាន នៃអាបត្តិទាំង ៦ អាបត្តិទាំងនោះ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ បណ្តាអធិករណ៍ទាំង ៤ អាបត្តិទាំងនោះ ចាត់ចូលក្នុងអធិករណ៍ណា ។ បណ្តាសមថៈទាំង ៧ អាបត្តិទាំងនោះ រម្ងាប់ដោយសមថៈប៉ុន្មាន ។ បណ្តាវិបត្តិទាំង ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ ២ គឺសីល-វិបត្តិក៏មាន អាចារវិបត្តិក៏មាន ។ បណ្តាកងនៃអាបត្តិទាំង ៧ អាបត្តិទាំងនោះ លោកសង្គ្រោះ ដោយកងនៃអាបត្តិ ៣ គឺ កងនៃបារាជិកាបត្តិក៏មាន កងនៃថុល្លច្ចយាបត្តិក៏មាន កងនៃទុក្កដាបត្តិក៏មាន ។

១៧៩

មហាវិភង្គេ សោឡស មហាវារា សមុច្ចយវារំ

ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋហន្តិ កាយតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន វាចតោ ។ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មន្តិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។ បេ ។ អនាទរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តោ កតិ អាបត្តិយោ អាបជ្ជតិ ។ អនាទរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តោ ឯកំ អាបត្តឹ អាបជ្ជតិ ទុក្កដំ ។ អនាទរិយំ បដិច្ច ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោន្តោ ឥមំ ឯកំ អាបត្តឹ អាបជ្ជតិ ។ សា អាបត្តិ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជតិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតីហិ អាបត្តិក្ខន្ធេហិ សង្គហិតា ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ ចតុន្នំ អធិករណានំ កតមំ អធិករណំ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មតិ ។

បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិទាំងនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាឡើយ ។ បណ្តាអធិករណ៍ទាំង ២ អាបត្តិទាំងនោះ ចាត់ជាអាបត្តាធិករណ៍ ។ បណ្តាសមថៈទាំង ៤ អាបត្តិទាំងនោះ រម្ងាប់ដោយសមថៈ ៣ គឺសម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មានខ្លះ សម្មុខាវិន័យនិងតិណវត្ថារកៈក៏មានខ្លះ ។ បេ ។ ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក ត្រូវអាបត្តិប៉ុន្មាន ។ ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក ត្រូវអាបត្តិ ១ គឺទុក្កដ ។ ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក ត្រូវអាបត្តិ ១ នេះឯង ។ បណ្តាវិបត្តិទាំង ៤ អាបត្តិនោះ រាប់បញ្ចូល ក្នុងវិបត្តិប៉ុន្មាន ។ បណ្តាកងនៃអាបត្តិទាំង ៧ អាបត្តិនោះ លោកសង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ បណ្តាអធិករណ៍ទាំង ៤ អាបត្តិនោះ ចាត់ជាអធិករណ៍ណា ។ បណ្តាសមថៈទាំង ៧ អាបត្តិនោះ រម្ងាប់ដោយសមថៈប៉ុន្មាន ។

សា អាបត្តិ ចតុន្នំ វិបត្តីនំ ឯកំ វិបត្តឹ ភជតិ អាចារវិបត្តឹ ។ សត្តន្នំ អាបត្តិក្ខន្ធានំ ឯកេន អាបត្តិក្ខន្ធេន សង្គហិតា ទុក្កដាបត្តិក្ខន្ធេន ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មតិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។

សមុច្ចយវារំ និដ្ឋិតំ អដ្ឋមំ ។

ឥមេ អដ្ឋ វារា សជ្ឈាយមគ្គេន លិខិតា ។

# តស្សុទ្ទានំ

[៤៦៨] កត្ថ បញ្ញត្តិ កតី ច

វិបត្តិសង្គហេន ច

សមុដ្ឋានាធិករណា

សមថោ ច សមុច្ចយោតិ ។

បណ្ដាវិបត្តិទាំង ៤ អាបត្តិនោះ រាប់បញ្ចូល ក្នុងវិបត្តិ ១ គឺ អាចារៈវិបត្តិ ។ បណ្ដាកងនៃអាបត្តិទាំង ៧ អាបត្តិនោះ លោកសង្គ្រោះដោយកងនៃអាបត្តិ ១ គឺកងនៃទុក្កដាបត្តិ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាឡើយ ។ បណ្ដាអធិករណ៍ទាំង ៤ អាបត្តិនោះ ចាត់ជាអាបត្តាធិករណ៍ ។ បណ្ដាសមថៈទាំង ៧ អាបត្តិនោះ រម្ងាប់ដោយសមថៈ ៣ គឺ សម្មុខាវិន័យ និងបដិញ្ញាតករណៈ ក៏មានខ្លះ សម្មុខាវិន័យនិងតិណវត្ថារកៈ ក៏មានខ្លះ ។

ចប់ សមុច្ចយវារៈ ទី ៨ ។

វារៈទាំង ៨ ប្រការនេះ លោកកត់ត្រាទុកសម្រាប់ស្វាធ្យាយ ។

# ឧទ្ទាន គឺបញ្ជីរឿងនៃមហាវារៈនោះដូច្នេះ

[៤៦៨] រឿងព្រះមានព្រះភាគ (ទ្រង់បញ្ញត្តសិក្ខាបទនោះ ៗ) ក្នុងទីណា ១ រឿងបញ្ញត្តិទាំង ៩ យ៉ាង ១ រឿងព្រះមានព្រះភាគ ទ្រង់បញ្ញត្តវិន័យ ព្រោះអាស្រ័យប្រយោជន៍ប៉ុន្មានយ៉ាង ១ រឿងសង្គ្រោះអាបត្តិចូលនឹងវិបត្តិ ១ សមុដ្ឋាននិងអធិករណ៍ ១ សមថៈ ១ សមុច្ចយៈ (ការរួបរួម) ១ ។

[៤៦៩] យេន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន មេថុនំ ធម្មំ បដិសេវេនប្បច្ចយា បារាជិកំ កត្ថ បញ្ញត្តំ ។ កំ អារព្ភ ។ កិស្មឹ វត្ថុស្មឹ ។ បេ ។ កោជាភជន្តិ ។ យេន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន មេថុនំ ធម្មំ បដិសេវេនប្បច្ចយា បារាជិកំ កត្ថ បញ្ញត្តន្តិ ។ វេសាលិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ សុទិន្នំ កលន្ទបុត្តំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ សុទិន្នោ កលន្ទបុត្តោ បុរាណទុតិយិកាយ មេថុនំ ធម្មំ បដិសេវិ តស្មឹ វត្ថុស្មឹ ។ អត្ថិ តត្ថ បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តីតិ ។ ឯកា បញ្ញត្តិ ទ្វេ អនុប្បញ្ញត្តិយោ អនុប្បន្នប្បញ្ញត្តិ តស្មឹ នត្ថិ ។ សព្វត្ថប្បញ្ញត្តិ បទេសប្បញ្ញត្តីតិ ។ សព្វត្ថប្បញ្ញត្តិ ។ សាធារណប្បញ្ញត្តិ អសាធារណប្បញ្ញត្តីតិ ។

[៤៦៩] បារាជិកសិក្ខាបទណា ដែលព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប (នូវកាលដែលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍ទាំង ១០) ទ្រង់បញ្ញត្ត ព្រោះបច្ច័យ គឺសេពមេថុនធម្ម បារាជិកសិក្ខាបទនោះ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ព្រោះរឿងដូចម្តេច ។ បេ ។ សិក្ខាបទនោះ បុគ្គលណាបាននាំមក ។ បារាជិកសិក្ខាបទណា ដែលព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប (នូវកាលដែលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍ទាំង ១០) ទ្រង់បញ្ញត្ត ព្រោះបច្ច័យ គឺសេពមេថុនធម្ម បារាជិកសិក្ខាបទនោះ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងក្រុងវេសាលី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងសុទិន្នភិក្ខុ ជាកូននៃកលន្ទសេដ្ឋី ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងដែលសុទិន្នភិក្ខុ ជាកូននៃកលន្ទសេដ្ឋី សេពមេថុនធម្មនឹងស្រីជាប្រពន្ធពីដើម ។ ក្នុងសិក្ខាបទនោះ មានបញ្ញត្តិ អនុប្បញ្ញត្តិ និងអនុប្បន្នប្បញ្ញត្តិឬទេ ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ មានអនុប្បញ្ញត្តិ ២ ឯអនុប្បន្នប្បញ្ញត្តិ មិនមានក្នុងសិក្ខាបទនោះឡើយ ។ សិក្ខាបទនោះ ជាសព្វត្ថប្បញ្ញត្តិ ឬជាបទេសប្បញ្ញត្តិ ។ សិក្ខាបទនោះជា សព្វត្ថប្បញ្ញត្តិ ។ សិក្ខាបទនោះ ជាសាធារណប្បញ្ញត្តិ ឬជាអសាធារណប្បញ្ញត្តិ ។

សាធារណបញ្ញត្តិ ។ ឯកតោ បញ្ញត្តិ ឧភតោ បញ្ញត្តីតិ ។ ឧភតោ បញ្ញត្តិ ។ បញ្ចន្នំ បាតិមោក្ខុទ្ទេសានំ កត្ថោគធំ កត្ថ បរិយាបន្នន្តិ ។ និទានោគធំ និទានបរិយាបន្នំ ។ កតមេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតីតិ ។ ទុតិយេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតិ ។ ចតុន្នំ វិបត្តីនំ កតមា វិបត្តីតិ ។ សីលវិបត្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតមោ អាបត្តិក្ខន្ធោតិ ។ បារាជិកាបត្តិក្ខន្ធោ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតីតិ ។ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។ បេ ។ កេនាភតន្តិ ។ បរម្បរាភតំ ។

ឧបាលិ ទាសកោ ចេវ
សោណកោ សិគ្គវោ តថា
មោគ្គលិបុត្តេន បញ្ចមា
ឯតេ ជម្ពុសិរិវ្ហយេ[១] ។
តតោ មហិន្ទោ ឥដ្ដិយោ
ឧត្តិយោ ចេវ សម្ពលោ ។ បេ ។

---
១ ជម្ពូសិរិវ្ហយេតិបិ បាឋោ ។

សិក្ខាបទនោះ ជាសាធារណបញ្ញត្តិ ។ សិក្ខាបទនោះ ជាឯកតោបញ្ញត្តិ ឬ ជាឧភតោបញ្ញត្តិ ។ សិក្ខាបទនោះ ជាឧភតោបញ្ញត្តិ ។ បណ្តាបាតិមោក្ខុទ្ទេសទាំង ៥ សិក្ខាបទនោះ ចាត់ចូលក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា ។ សិក្ខាបទនោះ ចាត់ចូលក្នុងនិទាន រាប់បញ្ចូលក្នុងនិទាន ។ សិក្ខាបទនោះ មកកាន់ឧទ្ទេស ត្រង់ឧទ្ទេសទីប៉ុន្មាន ។ សិក្ខាបទនោះ មកកាន់ឧទ្ទេសត្រង់ឧទ្ទេសទី ២ ។ បណ្តាវិបត្តិទាំង ៤ សិក្ខាបទនោះ ជាវិបត្តិអ្វី ។ សិក្ខាបទនោះ ជាសីលវិបត្តិ ។ បណ្តាកងនៃអាបត្តិទាំង ៧ សិក្ខាបទនោះ ជាកងនៃអាបត្តិអ្វី ។ សិក្ខាបទនោះ ជាកងនៃអាបត្តិបារាជិក ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាឡើយ ។ បេ ។ សិក្ខាបទនោះ បុគ្គលណា បាននាំមក ។ ព្រះថេរៈទាំងឡាយ ដូចមានឈ្មោះខាងក្រោមបាននាំត ៗ គ្នាមក ។

គឺព្រះថេរៈឈ្មោះឧបាលិ ១ ទាសកៈ ១ សោណកៈ ១ សិគ្គវៈ ១
និងព្រះមោគ្គលិបុត្តជាគម្រប់ ៥ អង្គ ១ ឯព្រះថេរៈទាំងនេះ នៅ
ក្នុងទ្វីបឈ្មោះជម្ពូដ៏មានសិរី ។ តពីនោះមកព្រះអរហន្តទាំង-
ឡាយ គឺព្រះថេរៈឈ្មោះមហិន្ទ ១ ឥដ្ឋិយៈ ១ ឧត្តិយៈ ១ សម្ពលៈ ១

។ បេ ។

មហាវិភង្គេ សោឡស មហាវារា កត្ថបញ្ញត្តិវារំ

ឯតេ ឆាតា មហាបញ្ញា
វិនយញ្ញូ មគ្គកោវិទា
វិនយំ ទីបេ បកាសេសុំ
បិដកំ តម្ពបណ្ណិយាតិ ។

[៤៧០] យន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន អទិន្នំ អទិយនប្បច្ចយា ទារាជិកំ កត្ថ បញ្ញត្តន្តិ ។ រាជគហេ បញ្ញត្តំ ។ កំ អារព្ភាតិ ។ ធនិយំ កុម្ភការបុត្តំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ ធនិយោ កុម្ភការបុត្តោ រញ្ញោ ទារូនិ អទិន្នានិ អាទិយិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។

ព្រះនាគត្ថេរទាំងនេះ លោកមានប្រាជ្ញាច្រើន ស្គាល់ច្បាស់ នូវព្រះវិន័យ លោកឈ្លាសក្នុងមគ្គ បាននាំគ្នាប្រកាស នូវព្រះវិនយបិដក ទុកក្នុងតម្ពបណ្ណិទ្វីប គឺកោះលង្កា ។

[៤៧០] បារាជិកសិក្ខាបទណា ដែលព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប (នូវកាលដែលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍ទាំង ១០) ហើយទ្រង់បញ្ញត្ត ព្រោះបច្ច័យ គឺកាន់យកនូវទ្រព្យដែលគេមិនបានឲ្យ បារាជិក-សិក្ខាបទនោះ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងធនិយភិក្ខុ ជាកូននៃស្មូនឆ្នាំង ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងដែលធនិយភិក្ខុ ជាកូននៃស្មូនឆ្នាំង យកឈើព្រះរាជទ្រព្យ ដែលគេមិនបានឲ្យ ។ សិក្ខាបទនោះមានបញ្ញត្តិ ១ មានអនុប្បញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ៣ គឺ តាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចានិងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយនិងវាចានិងចិត្តក៏មាន ។

[៤៧១] សញ្ចិច្ច មនុស្សវិគ្គហំ ជីវិតា វោរោបនប្បច្ចយា ធារាជិកំ កត្ថ បញ្ញត្តន្តិ ។ វេសាលិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ សម្ពហុលេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ សម្ពហុលេ ភិក្ខូ អញ្ញមញ្ញំ ជីវិតា វោរោបេសុំ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។

[៤៧២] អសន្តំ អភូតំ ឧត្តរិមនុស្សធម្មំ ឧល្លបនប្បច្ចយា ធារាជិកំ កត្ថ បញ្ញត្តន្តិ ។ វេសាលិយា បញ្ញត្តំ ។ កំ អារព្ភាតិ ។ វគ្គុមុទាតីរិយេ ភិក្ខូ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ វគ្គុមុទាតីរិយា ភិក្ខូ គិហីនំ អញ្ញមញ្ញស្ស ឧត្តរិមនុស្សធម្មស្ស វណ្ណំ ភាសឹសុ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ ច

[៤៧១] បារាជិកសិក្ខាបទ ដែលទ្រង់បញ្ញត្ត ព្រោះបច្ច័យ គឺក្លែងធ្វើរាងកាយមនុស្សឲ្យធ្លាក់ចុះចាកជីវិត ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងនគរវេសាលី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងភិក្ខុច្រើនរូប ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងដែលភិក្ខុច្រើនរូបញ៉ាំងគ្នានឹងគ្នាឲ្យធ្លាក់ចុះចាកជីវិត ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ មានអនុប្បញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ៣ គឺ តាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចានិងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយនិងវាចានិងចិត្តក៏មាន ។

[៤៧២] បារាជិកសិក្ខាបទ ដែលទ្រង់បញ្ញត្ត ព្រោះបច្ច័យ គឺពោលអួតឧត្តរិមនុស្សធម្ម ដែលមិនមាន មិនពិត ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងនគរវេសាលី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងភិក្ខុទាំងឡាយ ដែលនៅប្រេបឆ្នេរស្ទឹងវគ្គុមុទា ។ ព្រោះរឿងដូចម្តេច ។ ព្រោះរឿងដែលពួកភិក្ខុនៅប្រេបឆ្នេរស្ទឹងវគ្គុមុទា ពោលសរសើរគុណឧត្តរិមនុស្សធម្មនៃគ្នានឹងគ្នាដល់ពួកគ្រហស្ថ ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ មានអនុប្បញ្ញត្តិ ១ ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ៣ គឺ តាំងឡើងអំពីកាយនិង

ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។

[៤៧៣] យន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឧបក្កមិត្វា អសុចឹ មោចនប្បច្ចយា សង្ឃាទិសេសោ កត្ថ បញ្ញត្តោ ។ កំ អារព្ភ ។ កិស្មឹ វត្ថុស្មឹ ។ បេ ។ កេនាភជន្តិ ។ យន្តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឧបក្កមិត្វា អសុចឹ មោចនប្បច្ចយា សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អាយស្មន្តំ សេយ្យសកំ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា សេយ្យសកោ ឧបក្កមិត្វា អសុចឹ មោចេសិ តស្មឹ វត្ថុស្មឹ ។ អត្ថិ តត្ថ បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្ន-

ចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចានិងចិត្ត មិនបាន តាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយនិងវាចានិងចិត្តក៏មាន ។

[៤៧៣] សង្ឃាទិសេសសិក្ខាបទណា ដែលព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប (នូវកាលដែលគួរនឹងបញ្ញត្ត សិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍ ១០ យ៉ាង) ទ្រង់ បញ្ញត្ត ព្រោះបច្ច័យ គឺព្យាយាមញ៉ាំងអសុចិឲ្យឃ្លាតចេញ សង្ឃាទិសេស-សិក្ខាបទនោះ ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ព្រោះរឿងដូចម្តេច ។ បេ ។ សិក្ខាបទនោះ បុគ្គលណាបាននាំមក ។ សង្ឃាទិសេសសិក្ខាបទណា ដែលព្រះមានព្រះភាគ ជាអរហន្តសម្មា-សម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប (នូវកាលដែលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ ឃើញ (នូវអំណាចនៃប្រយោជន៍ ១០ យ៉ាង) ទ្រង់បញ្ញត្ត ព្រោះបច្ច័យ គឺ ព្យាយាមញ៉ាំងអសុចិឲ្យឃ្លាតចេញ សង្ឃាទិសេសសិក្ខាបទនោះ ទ្រង់ បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គល ណា ។ ទ្រង់ប្រារព្ធនឹងព្រះសេយ្យសកៈមានអាយុ ។ ព្រោះរឿងដូច ម្តេច ។ ព្រោះរឿងព្រះសេយ្យសកៈមានអាយុ ព្យាយាមញ៉ាំងអសុចិឲ្យ ឃ្លាតចេញ ។ ក្នុងសិក្ខាបទនោះ មានបញ្ញត្តិ អនុប្បញ្ញត្តិ និងអនុប្បន្ន-

ប្បញ្ញត្តីតិ ។ ឯកា បញ្ញត្តិ ឯកា អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តិ តស្មឹ នត្ថិ ។ សព្វត្ថប្បញ្ញត្តិ បទេសប្បញ្ញត្តីតិ ។ សព្វត្ថប្បញ្ញត្តិ ។ សាធារណប្បញ្ញត្តិ អសាធារណប្បញ្ញត្តីតិ ។ អសាធាណប្បញ្ញត្តិ ។ ឯកតោ បញ្ញត្តិ ឧភតោ បញ្ញត្តីតិ ។ ឯកតោ បញ្ញត្តិ ។ បញ្ចន្នំ ចាតិមោក្ខុទ្ទេសានំ កត្ថោគធំ កត្ថ បរិយាបន្នន្តិ ។ និទានោគធំ និទានបរិយាបន្នំ ។ កតមេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតីតិ ។ តតិយេន ឧទ្ទេសេន ឧទ្ទេសំ អាគច្ឆតិ ។ ចតុន្នំ វិបត្តីនំ កតមា វិបត្តីតិ ។ សីលវិបត្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតមោ អាបត្តិក្ខន្ធោតិ ។ សង្ឃាទិសេសាបត្តិក្ខន្ធោ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។ បេ ។ កេនាភតន្តិ ។ បរម្បរាភតំ ។

ឧបាលិ ទាសកោ ចេវ

សោណកោ សិគ្គវោ តថា

មោគ្គលិបុត្តេន បញ្ចមា

ប្បញ្ញត្តិ ដែរឬទេ ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ មានអនុប្បញ្ញត្តិ ១ ឯអនុប្បន្នប្បញ្ញត្តិ មិនមានក្នុងសិក្ខាបទនោះឡើយ ។ សិក្ខាបទនោះ ជាសព្វត្ថប្បញ្ញត្តិ ឬជាបទេសប្បញ្ញត្តិ ។ ជាសព្វត្ថប្បញ្ញត្តិ ។ សិក្ខាបទនោះ ជាសាធារណប្បញ្ញត្តិ ឬជាអសាធារណប្បញ្ញត្តិ ។ ជាអសាធារណ-ប្បញ្ញត្តិ ។ សិក្ខាបទនោះ ជាឯកតោបញ្ញត្តិ ឬជាឧភតោបញ្ញត្តិ ។ ជាឯក-តោបញ្ញត្តិ ។ បណ្តាបាតិមោក្ខុទ្ទេសទាំង ៥ សិក្ខាបទនោះ ចាត់ចូលក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា ។ ចាត់ចូលក្នុងនិទាន រាប់បញ្ចូលក្នុងនិទាន ។ សិក្ខាបទនោះ មកកាន់ឧទ្ទេស ត្រង់ឧទ្ទេសទីប៉ុន្មាន ។ មកកាន់ឧទ្ទេសត្រង់ឧទ្ទេសទី ៣ ។ បណ្តាវិបត្តិទាំង ៤ សិក្ខាបទនោះ ជាវិបត្តិអ្វី ។ ជាសីលវិបត្តិ ។ បណ្តាកងអាបត្តិទាំង ៧ សិក្ខាបទនោះ ជាកងនៃអាបត្តិអ្វី ។ ជាកងនៃអាបត្តិសង្ឃាទិសេស ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ តាំងឡើងដោយសមុដ្ឋាន ១ គឺ តាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាឡើយ ។ បេ ។ សិក្ខាបទនោះ បុគ្គលណាបាននាំមក ។ ព្រះថេរៈទាំងឡាយ ដូចមាននាមខាងក្រោម បាននាំត ៗ គ្នាមក ។

គឺព្រះថេរៈឈ្មោះឧបាលិ ១ ទាសកៈ ១ សោណកៈ ១ សិគ្គវៈ ១
និងព្រះមោគ្គលិបុត្តជាគម្រប់ ៥ អង្គ ១ ព្រះថេរៈទាំងនេះ ឋិត

ឯតេ ជម្ពុសិរិវ្ហយេ ។
តតោ មហិន្ទោ ឥដ្ដិយោ
ឧត្តិយោ ចេវ សម្ពលោ
។ បេ ។
ឯតេ នាគា មហាបញ្ញា
វិនយញ្ញូ មគ្គកោវិទា
វិនយំ ទីបេ បកាសេសុំ
បិដកំ តម្ពបណ្ណិយាតិ ។

[៤៧៤] មាតុគ្គាមេន សទ្ធឹ កាយសំសគ្គំ សមាបជ្ជនប្បច្ចយា សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឧទាយឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឧទាយិ មាតុគ្គាមេន សទ្ធឹ កាយសំសគ្គំ សមាបជ្ជិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ ។

នៅក្នុងទ្វីបឈ្មោះជម្ពូដ៏មានសិរី ។ តអំពីនោះ មកមានព្រះអរហន្តទាំងឡាយទៀតគឺ ព្រះថេរៈឈ្មោះមហិន្ទ ១ ឥដ្ដិយៈ ១ ឧត្តិយៈ ១ សម្ពលៈ ១

។ បេ ។

ព្រះនាគត្ថេរទាំងនេះ មានប្រាជ្ញាច្រើន ចេះដឹងនូវព្រះវិន័យ ឈ្លាសក្នុងមគ្គ នាំគ្នាប្រកាសព្រះវិនយបិដក ទុកក្នុងតម្ពបណ្ណិទ្វីប ។

[៤៧៤] សង្ឃាទិសេសសិក្ខាបទ ដែលទ្រង់បញ្ញត្ត ព្រោះបច្ច័យគឺដល់នូវកាយសំសគ្គៈជាមួយនឹងមាតុគ្រាម (ប៉ះពាល់កាយមាតុគ្រាមជាដើម) ទ្រង់បញ្ញត្តក្នុងទីណា ។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងព្រះឧទាយិមានអាយុ ។ ព្រោះរឿងដូចម្ដេច ។ ព្រោះរឿងព្រះឧទាយិមានអាយុ ដល់នូវកាយសំសគ្គៈជាមួយនឹងមាតុគ្រាម ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាឡើយ ។

[៤៧៥] មាតុគ្គាមំ ទុដ្ឋុល្លាហិ វាចាហិ ឱភាសនប្បច្ចយា សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឧទាយឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឧទាយិ មាតុគ្គាមំ ទុដ្ឋុល្លាហិ វាចាហិ ឱភាសិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។

[៤៧៦] មាតុគ្គាមស្ស សន្តិកេ អត្តកាមចារិចរិយាយ វណ្ណំ ភាសនប្បច្ចយា សង្ឃាទិសេសោ កត្ថ បញ្ញត្តោតិ ។ សាវត្ថិយា បញ្ញត្តោ ។ កំ អារព្ភាតិ ។ អាយស្មន្តំ ឧទាយឹ អារព្ភ ។ កិស្មឹ វត្ថុស្មិន្តិ ។ អាយស្មា ឧទាយិ មាតុគ្គាមស្ស សន្តិកេ អត្តកាមចារិចរិយាយ វណ្ណំ អភាសិ តស្មឹ វត្ថុស្មឹ ។ ឯកា បញ្ញត្តិ ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋាតិ ។

[៨១៦] ភិក្ខុនីនៅច្រឡូកច្រឡំ (ដោយគ្រហស្ថ) ត្រូវអាបត្តិ ៣ ព្រោះបច្ច័យនៃកិរិយាមិនលះ (អំពើនោះៗ) ក្នុងវេលាដែលសង្ឃសូត្រសមនុភាសនកម្មចប់ ជាគម្រប់ ៣ ដង គឺចប់ញត្តិ ត្រូវអាបត្តិទុក្កដ ចប់កម្មវាចាពីរលើក ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ចប់កម្មវាចាសព្វគ្រប់ ត្រូវអាបត្តិសង្ឃាទិសេស ។

[៨១៧] ភិក្ខុនីបញ្ជូនភិក្ខុនីផងគ្នា ដោយពាក្យថា នែលោកម្ចាស់ទាំងឡាយ ចូរលោកម្ចាស់ទាំងឡាយនៅច្រឡូកច្រឡំ (ដោយគ្រហស្ថ) ចុះ កុំនៅបែកខ្ញែកពីគ្នាឡើយ ដូច្នេះ ត្រូវអាបត្តិ ៣ ព្រោះបច្ច័យនៃ

អាបជ្ជតិ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្ល-ច្ចយា កម្មវាចាបរិយោសានេ អាបត្តិ សង្ឃាទិសេ-សស្ស ។

សង្ឃាទិសេសា និដ្ឋិតា[១] ។

។ បេ ។

[៨១៨] ឆដ្ឋី វិញ្ញាបេត្វា កុញ្ចនប្បច្ចយា កតិ អាបត្តិយោ អាបជ្ជតិ ។ ឆដ្ឋី វិញ្ញាបេត្វា កុញ្ចនប្បច្ចយា ទ្វេ អាបត្តិយោ អាបជ្ជតិ កុញ្ចិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាចិត្តិយស្ស ឆដ្ឋី វិញ្ញាបេត្វា កុញ្ចនប្បច្ចយា ឥមា ទ្វេ អាបត្តិយោ អាបជ្ជតិ ។

កតិអាបត្តិវារំ និដ្ឋិតំ ទុតិយំ ។

[៨១៩] កាយសំសគ្គំ សាទិយនប្បច្ចយា អាបត្តិ-យោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ កាយ-សំសគ្គំ សាទិយនប្បច្ចយា អាបត្តិយោ ចតុន្នំ វិបត្តីនំ

១ ឱ. ម. ទសសង្ឃាទិសេសា និដ្ឋិតា ។

កិរិយាមិនលះ (អំពើនោះ ៗ) ក្នុងវេលាដែលសង្ឃសូត្រសមនុភាសនកម្ម ចប់ជាគម្រប់ ៣ ដង គឺចប់ញត្តិ ត្រូវអាបត្តិទុក្កដ ចប់កម្មវាចាពីរលើក ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ចប់កម្មវាចាសព្វគ្រប់ ត្រូវអាបត្តិសង្ឃា-ទិសេស ។

ចប់ សង្ឃាទិសេស ។

។ បេ ។

[៨១៨] ភិក្ខុនីត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ ។ ភិក្ខុនីត្រូវអាបត្តិ ២ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ គឺកំពុងទទួលដោយគិតថា អាត្មាអញនឹងឆាន់ដូច្នេះ ត្រូវអាបត្តិទុក្កដ (លុះទទួលហើយឆាន់) ត្រូវអាបត្តិបាដិទេសនីយៈគ្រប់ ៗ វារៈដែលលេបចូលទៅ ភិក្ខុនីត្រូវអាបត្តិ ២ នេះ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ ។

ចប់ កតិអាបត្តិវារៈ ជាគម្រប់ ២ ។

[៨១៩] អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្ដីត្រេកអរនឹងការប៉ះពាល់កាយ បណ្ដាវិបត្តិទាំង ៤ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្ដីត្រេកអរនឹងការប៉ះពាល់កាយ បណ្ដាវិបត្តិ

ទ្វេ វិបត្តិយោ ភជន្តិ សិយា សីលវិបត្តឹ សិយា អាចារវិបត្តឹ ។ បេ ។ ឆដ្ឋំ វិញ្ញាបេត្វា ភុញ្ជនប្បច្ចយា អាបត្តិយោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ ឆដ្ឋំ វិញ្ញាបេត្វា ភុញ្ជនប្បច្ចយា អាបត្តិយោ ចតុន្នំ វិបត្តីនំ ឯកំ វិបត្តឹ ភជន្តិ អាចារវិបត្តឹ ។

វិបត្តិវារំ និដ្ឋិតំ តតិយំ ។

[៨២០] កាយសំសគ្គំ សាទិយនប្បច្ចយា អាបត្តិយោ សត្តន្នំ អាបត្តិក្ខន្ធានំ កតីហិ អាបត្តិក្ខន្ធេហិ សង្គហិតា ។ កាយសំសគ្គំ សាទិយនប្បច្ចយា អាបត្តិយោ សត្តន្នំ អាបត្តិក្ខន្ធានំ បញ្ចហិ អាបត្តិក្ខន្ធេហិ សង្គហិតា សិយា បារាជិកាបត្តិក្ខន្ធេន សិយា សង្ឃាទិសេសាបត្តិក្ខន្ធេន សិយា ថុល្លច្ចយាបត្តិក្ខន្ធេន សិយា បាចិត្តិយាបត្តិក្ខន្ធេន សិយា ទុក្កដាបត្តិក្ខន្ធេន ។ បេ ។ ឆដ្ឋំ វិញ្ញាបេត្វា ភុញ្ជនប្បច្ចយា អាបត្តិយោ សត្តន្នំ អាបត្តិក្ខន្ធានំ កតីហិ អាបត្តិក្ខន្ធេហិ សង្គហិតា ។ ឆដ្ឋំ វិញ្ញាបេត្វា ភុញ្ជនប្បច្ចយា អាបត្តិយោ

ទាំង ៤ រាប់បញ្ចូលក្នុងវិបត្តិ ២ គឺសីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន ។ បេ ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃកិរិយាសូមនូវទឹកដោះជូរ យកមកឆាន់ បណ្តាវិបត្តិទាំង ៤ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ បណ្តាវិបត្តិទាំង ៤ រាប់បញ្ចូលក្នុងវិបត្តិ ១ គឺអាចារវិបត្តិ ។

ចប់ វិបត្តិវារៈ ជាគម្រប់ ៣ ។

[៨២០] អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្តីត្រេកអរនឹងការប៉ះពាល់កាយ បណ្តាកងនៃអាបត្តិទាំង ៧ លោកសង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្តីត្រេកអរនឹងការប៉ះពាល់កាយ បណ្តាកងនៃអាបត្តិទាំង ៧ លោកសង្គ្រោះដោយកងនៃអាបត្តិ ៥ គឺកងនៃអាបត្តិបារាជិកក៏មាន កងនៃអាបត្តិសង្ឃាទិសេសក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន ។ បេ ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ បណ្តាកងនៃអាបត្តិទាំង ៧ លោកសង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរ

សត្តន្នំ អាបត្តិក្ខន្ធានំ ទ្វីហិ អាបត្តិក្ខន្ធេហិ សង្គហិតា សិយា ថាដិទេសនីយាបត្តិក្ខន្ធេន សិយា ទុក្កដាបត្តិក្ខន្ធេន ។

សង្គហវារំ និដ្ឋិតំ ចតុត្ថំ ។

[៨២១] កាយសំសគ្គំ សាទិយនប្បច្ចយា អាបត្តិយោ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ ។ កាយសំសគ្គំ សាទិយនប្បច្ចយា អាបត្តិយោ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋហន្តិ កាយតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន វាចតោ ។ បេ ។ ឧជ្ឈំ វិញ្ញាបេត្វា កុញ្ជនប្បច្ចយា អាបត្តិយោ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ ។ ឧជ្ឈំ វិញ្ញាបេត្វា កុញ្ជនប្បច្ចយា អាបត្តិយោ ឆន្នំ អាបត្តិសមុដ្ឋានានំ ចតូហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ សិយា កាយតោ សមុដ្ឋហន្តិ ន វាចតោ ន ចិត្តតោ សិយា កាយតោ ច វាចតោ ច

យកមកឆាន់ បណ្តាកងនៃអាបត្តិទាំង ៧ លោកសង្គ្រោះដោយកងនៃអាបត្តិ ២ គឺកងនៃអាបត្តិបាដិទេសនីយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន ។

ចប់ សង្គហវារៈ ជាគម្រប់ ៤ ។

[៨២១] អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្តីត្រេកអរ នឹងការប៉ះពាល់កាយ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្តីត្រេកអរនឹងការប៉ះពាល់កាយ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាឡើយ ។ បេ ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ អាបត្តិទាំង-ឡាយ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋាន ៤ គឺតាំងឡើងអំពីកាយមិនតាំងឡើងអំពីវាចា មិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយវាចា

សមុដ្ឋហន្តិ ន ចិត្តតោ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន វាចតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ។

សមុដ្ឋានវារំ និដ្ឋិតំ បញ្ចមំ ។

[៨២២] កាយសំសគ្គំ សាទិយនប្បច្ចយា អាបត្តិយោ ចតុន្នំ អធិករណានំ កតមំ អធិករណំ ។ កាយសំសគ្គំ សាទិយនប្បច្ចយា អាបត្តិយោ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។ បេ ។ ឧព្ភិំ វិញ្ញាបេត្វា ភុញ្ជនប្បច្ចយា អាបត្តិយោ ចតុន្នំ អធិករណានំ កតមំ អធិករណំ ។ ឧព្ភិំ វិញ្ញាបេត្វា ភុញ្ជនប្បច្ចយា អាបត្តិយោ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។

អធិករណវារំ និដ្ឋិតំ ឆដ្ឋំ ។

[៨២៣] កាយសំសគ្គំ សាទិយនប្បច្ចយា អាបត្តិយោ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មន្តិ ។ កាយសំសគ្គំ សាទិយនប្បច្ចយា អាបត្តិយោ សត្តន្នំ

មិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីកាយវាចានិងចិត្តក៏មាន ។

ចប់ សមុដ្ឋានវារៈ ជាគម្រប់ ៥ ។

[៨២២] អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្តីត្រេកអរនឹងការប៉ះពាល់កាយ បណ្តាអធិករណ៍ទាំង ៤ ចាត់ជាអធិករណ៍ណា ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្តីត្រេកអរនឹងការប៉ះពាល់កាយ បណ្តាអធិ-ករណ៍ទាំង ៤ ចាត់ជាអាបត្តាធិករណ៍ ។ បេ ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ បណ្តាអធិករណ៍ទាំង ៤ ចាត់ជាអធិករណ៍ណា ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ បណ្តាអធិករណ៍ទាំង ៤ ចាត់ជាអាបត្តាធិករណ៍ ។

ចប់ អធិករណវារៈ ជាគម្រប់ ៦ ។

[៨២៣] អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្តីត្រេកអរនឹងការប៉ះពាល់កាយ បណ្តាសមថៈទាំង ៧ រម្ងាប់ដោយសមថៈប៉ុន្មាន ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្តីត្រេកអរនឹងការប៉ះពាល់កាយ បណ្តា

សមថានំ តីហិ សមថេហិ សម្មន្តិ សិយា សម្មុខាវិន-
យេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិន-
យេន ច តិណវត្ថារកេន ច ។ បេ ។ ឧជឹ វិញ្ញាបេត្វា
កុញ្ចនប្បច្ចយា អាបត្តិយោ សត្តន្នំ សមថានំ កតីហិ
សមថេហិ សម្មន្តិ ។ ឧជឹ វិញ្ញាបេត្វា កុញ្ចនប្បច្ចយា
អាបត្តិយោ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មន្តិ
សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច
សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។

សមថវារំ និដ្ឋិតំ សត្តមំ ។

[៨២៤] កាយសំសគ្គំ សាទិយនប្បច្ចយា កតិ
អាបត្តិយោ អាបជ្ជតិ ។ កាយសំសគ្គំ សាទិយនប្បច្ច-
យា បញ្ច អាបត្តិយោ អាបជ្ជតិ អវស្សុតា ភិក្ខុនី អវ-
ស្សុតស្ស បុរិសបុគ្គលស្ស អធក្ខកំ ឧព្ភជានុមណ្ឌលំ
គហណំ សាទិយតិ អាបត្តិ ចារាជិកស្ស ភិក្ខុ
កាយេន កាយំ អាមសតិ អាបត្តិ សង្ឃាទិសេសស្ស

សមថៈទាំង ៧ តែងរម្ងាប់ដោយសមថៈ ៣ គឺដោយសម្មុខាវិន័យនិង បដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន ។ បេ ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ បណ្ដាសមថៈទាំង ៧ រម្ងាប់ដោយសមថៈប៉ុន្មាន ។ ពួកអាបត្តិ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ បណ្ដាសមថៈទាំង ៧ តែងរម្ងាប់ដោយសមថៈ ៣ គឺដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន ។

ចប់ សមថវារៈ ជាគម្រប់ ៧ ។

[៨២៤] ភិក្ខុ ឬភិក្ខុនី ត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យនៃសេចក្ដីត្រេកអរនិងការប៉ះពាល់កាយ ។ ភិក្ខុ ភិក្ខុនី ត្រូវអាបត្តិ ៥ ព្រោះបច្ច័យនៃសេចក្ដីត្រេកអរនិងការប៉ះពាល់កាយ គឺភិក្ខុនីមានតម្រេកត្រេកអរនិងការចាប់ពាល់ (នូវសរីរប្រទេស) របស់បុរសបុគ្គលដែលមានតម្រេកដែរ តាំងពីខាងក្រោមដងកាំបិតចុះមក ដល់ខាងលើមណ្ឌលជង្គង់ ត្រូវអាបត្តិបារាជិក ភិក្ខុចាប់ពាល់កាយ (ស្ត្រី) ដោយកាយរបស់ (ខ្លួន) ត្រូវអាបត្តិ

៣៤១



កាយេន កាយប្បដិពទ្ធំ អាមសតិ អាបត្តិ ថុល្លច្ចយស្ស កាយប្បដិពទ្ធេន កាយប្បដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស អង្គុលិបតោទកេ បាចិត្តិយំ កាយសំសគ្គំ សាទិយនប្បច្ចយា ឥមា បញ្ច អាបត្តិយោ អាបជ្ជតិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតីហិ អាបត្តិក្ខន្ធេហិ សង្គហិតា ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ ។ ចតុន្នំ អធិករណានំ កតមំ អធិករណំ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មន្តិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ ទ្វេ វិបត្តិយោ ភជន្តិ សិយា សីលវិបត្តឹ សិយា អាចារវិបត្តឹ ។ សត្តន្នំ អាបត្តិក្ខន្ធានំ បញ្ចហិ អាបត្តិក្ខន្ធេហិ សង្គហិតា សិយា បារាជិកាបត្តិក្ខន្ធេន សិយា សង្ឃាទិសេសាបត្តិក្ខន្ធេន សិយា ថុល្លច្ចយាបត្តិក្ខន្ធេន សិយា បាចិត្តិយាបត្តិក្ខន្ធេន សិយា ទុក្កដាបត្តិក្ខន្ធេន ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋហន្តិ កាយតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន វាចតោ ។ ចតុន្នំ អធិករណានំ

សង្ឃាទិសេស ភិក្ខុចាប់ពាល់វត្ថុដែលជាប់នឹងកាយ (ស្ត្រី) ដោយកាយរបស់ (ខ្លួន) ត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុចាប់ពាល់វត្ថុដែលជាប់នឹងកាយ (ស្ត្រី) ដោយវត្ថុដែលជាប់នឹងកាយ (ខ្លួន) ត្រូវអាបត្តិទុក្កដ ភិក្ខុចាក់ក្រឡេកភិក្ខុផងគ្នា ដោយម្រាមដៃ ត្រូវអាបត្តិបាចិត្តិយៈ ភិក្ខុឬភិក្ខុនីត្រូវអាបត្តិទាំង ៥ នេះ ព្រោះបច្ច័យនៃសេចក្តីត្រេកអរនិងការប៉ះពាល់កាយ ។ ពួកអាបត្តិទាំងនោះ បណ្តាវិបត្តិទាំង ៤ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន ។ បណ្តាកងនៃអាបត្តិទាំង ៧ អាបត្តិទាំងនោះ លោកសង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ បណ្តាអធិករណ៍ទាំង ៤ ចាត់ជាអធិករណ៍ណា ។ បណ្តាសមថៈទាំង ៧ រម្ងាប់ដោយសមថៈប៉ុន្មាន ។ អាបត្តិទាំងនោះ បណ្តាវិបត្តិទាំង ៤ រាប់បញ្ចូលក្នុងវិបត្តិ ២ គឺសីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន ។ បណ្តាកងនៃអាបត្តិទាំង ៧ អាបត្តិទាំងនោះ លោកសង្គ្រោះដោយកងនៃអាបត្តិ ៥ គឺកងនៃអាបត្តិបារាជិកក៏មាន កងនៃអាបត្តិសង្ឃាទិសេសក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិទាំងនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាឡើយ ។ បណ្តាអធិករណ៍ទាំង ៤

អាបត្តាធិករណំ ។ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មន្តិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។ បេ ។

[៨២៨] ឧជឹ វិញ្ញាបេត្វា កុញ្ជរប្បច្ចយា កតិ អាបត្តិយោ អាបជ្ជតិ ។ ឧជឹ វិញ្ញាបេត្វា កុញ្ជរប្បច្ចយា ទ្វេ អាបត្តិយោ អាបជ្ជតិ កុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ ថាជិនេសជីយស្ស ឧជឹ វិញ្ញាបេត្វា កុញ្ជរប្បច្ចយា ឥមា ទ្វេ អាបត្តិយោ អាបជ្ជតិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតីហិ អាបត្តិក្ខន្ធេហិ សង្គហិតា ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ ។ ចតុន្នំ អធិករណានំ កតមំ អធិករណំ ។ សត្តន្នំ សមថានំ

ចាត់ជាអាបត្តាធិករណ៍ ។ បណ្តាសមថៈទាំង ៧ តែងរម្ងាប់ដោយសមថៈ ៣ គឺដោយសម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន ។ បេ ។

[៨២៥] ភិក្ខុនីត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ ។ ភិក្ខុនីត្រូវអាបត្តិ ២ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ គឺកំពុងទទួលប្រគេនដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ (លុះទទួលហើយឆាន់) ត្រូវអាបត្តិបាដិទេសនីយៈ គ្រប់ ៗ វារៈដែលលេបចូលទៅ ភិក្ខុនីត្រូវអាបត្តិទាំង ២ នេះ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ ។ អាបត្តិទាំងនោះ បណ្តាវិបត្តិទាំង ៤ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន ។ បណ្តាកងនៃអាបត្តិទាំង ៧ អាបត្តិទាំងនោះ លោកសង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ បណ្តាអធិករណ៍ទាំង ៤ ចាត់ជាអធិករណ៍ណា ។ បណ្តាសមថៈទាំង ៧ រម្ងាប់

កតីហិ សមថេហិ សម្មន្តិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ ឯកំ វិបត្តឹ ភជន្តិ អាចារវិបត្តឹ ។ សត្តន្នំ អាបត្តិក្ខន្ធានំ ទ្វីហិ អាបត្តិក្ខន្ធេហិ សង្គហិតា សិយា ថុល្លច្ចយាបត្តិក្ខន្ធេន សិយា ទុក្កដាបត្តិក្ខន្ធេន ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ចតូហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ សិយា កាយតោ សមុដ្ឋហន្តិ ន វាចតោ ន ចិត្តតោ សិយា កាយតោ ច វាចតោ ច សមុដ្ឋហន្តិ ន ចិត្តតោ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន វាចតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ។ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មន្តិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ចាតិ ។

សមុច្ចយវារំ និដ្ឋិតំ អដ្ឋមំ ។

អដ្ឋ បច្ចយវារា និដ្ឋិតា ។

ភិក្ខុនីវិភង្គេ សោឡស មហាវារា និដ្ឋិតា ។

ដោយសមថៈប៉ុន្មាន ។ ពួកអាបត្តិទាំងនោះ បណ្តាវិបត្តិទាំង ៤ រាប់បញ្ចូលក្នុងវិបត្តិ ១ គឺអាចារវិបត្តិ ។ បណ្តាអាបត្តិទាំង ៧ កង លោកសង្គ្រោះដោយកងនៃអាបត្តិ ២ គឺកងនៃអាបត្តិបាដិទេសនីយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋាន ៤ គឺតាំងឡើងអំពីកាយ មិនតាំងឡើងអំពីវាចា និងមិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយអំពីវាចា មិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយអំពីចិត្ត មិនតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីកាយវាចា និងចិត្តក៏មាន ។ បណ្តាអធិករណ៍ទាំង ៤ ចាត់ជាអាបត្តាធិករណ៍ ។ បណ្តាសមថៈទាំង ៧ តែងរម្ងាប់ដោយសមថៈ ៣ គឺដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន ។

ចប់ សមុច្ចយវារៈជាគម្រប់ ៨ ។

ចប់ បច្ចយវារៈទាំង ៨ ។

ចប់ មហាវារៈ ១៦ ក្នុងភិក្ខុនីវិភង្គ ។

# សមុដ្ឋានសីសសង្ខេបំ

[៨២៦] អនិច្ចា សព្វសង្ខារា[១]

ទុក្ខានត្តា ច សង្ខតា

និព្វានញ្ចេវ បណ្ណត្តិ

អនត្តា ឥតិ និច្ឆយា ។

ពុទ្ធចន្ទេ អនុប្បន្នេ

ពុទ្ធាទិច្ចេ អនុគ្គតេ

តេសំ សភាគធម្មានំ

នាមមត្តំ ន ញាយតិ[២] ។

១ ឱ. ម. សព្វេ សង្ខារា ។ ២ ឱ. ម. ន នាយតិ ។

# សមុដ្ឋានសីសសង្ខេប

[៨២៦] *សង្ខារទាំងពួងទាំងឡាយ ដែលបច្ច័យតាក់តែងហើយ ជារបស់មិនទៀងផង ជាទុក្ខផង ជាអនត្តាផង ។ និព្វាន និងបញ្ញត្តិ ក៏លោកវិនិច្ឆ័យថា ជាអនត្តាធម៌ដែរ[១] កាលព្រះពុទ្ធដូចជាព្រះចន្ទមិនទាន់កើតឡើង កាលព្រះពុទ្ធដូចជាព្រះអាទិត្យមិនទាន់បានត្រាស់នៅឡើយ នាមបញ្ញត្តិរបស់សភាគធម៌[២] ទាំងឡាយនោះ ក៏មិនមានអ្នកណាអាចដឹងបាន ។*

---

១ អត្តា ប្រែថា ខ្លួន ថា ចិត្ត ឬថា សភាវៈតែងប្រព្រឹត្តទៅក្នុងអំណាចនៃខ្លួន ។ អនត្តា ប្រែថា សភាវៈមិនមែនខ្លួន មិនមែនចិត្ត មិនប្រព្រឹត្តទៅក្នុងអំណាចនៃខ្លួន ។ យើងបានពិនិត្យមើលត្រង់បទដែលថា អនត្តានោះច្រើនគម្ពីរបានចូលចិត្តដោយច្បាស់លាស់ថា ធម៌ទាំងអស់គឺ អាយតនៈ ១២ ឬ ខន្ធ ៥ ប្រការសុទ្ធតែជាអនត្តាគ្រប់ចំណែក សូម្បីព្រះនិព្វានដែលជាធម៌យ៉ាងឯក ក៏គង់បានឈ្មោះថាជា អនត្តា ដែរ តែធម៌ទាំងអស់ក្រៅចាកព្រះនិព្វាននោះ នៅមានខន្ធ ៥ ជាហេតុ ជាបច្ច័យឲ្យកើតទៀត ព្រោះធម៌ទាំងនោះ ជាសសង្ខារនៅឡើយ ។ ឯព្រះនិព្វានជាអនត្តាដែរ ជាធម៌មិនមានហេតុ មិនមានបច្ច័យ ជាកម្លាំងឲ្យកើតឡើយ ។ ព្រោះព្រះនិព្វាននេះ ជាវិសង្ខារទៅហើយ ព្រះនិព្វាននោះ ពិតមែនតែជាគុណជាតិមិនត្រូវកើតទៀត តែមិនមែនជាឋានសូន្យទទេនោះទេ គឺព្រះនិព្វាននៅមានអាយតនៈមួយ ឬមានហេតុម្យ៉ាង គឺអរហត្តផលញ្ញាណនោះឯង សមដូចពុទ្ធភាសិតថា អត្ថិ ភិក្ខវេ តទាយតនំ ។ ២ សំដៅយកសង្ខតធម៌គឺមានបច្ច័យប្រជុំតាក់តែងបាន ជាធម៌មានចំណែកស្មើដោយអាការមានមិនទៀងជាដើម ។

ទុក្ករំ    វីរិជំ    កត្វា
បូរយិត្វាន    ចារមី
ឧបជ្ជន្តិ    មហាវីរា
ចក្ខុភូតា    សព្រហ្មកេ
តេ    ទេសយន្តិ    សទ្ធម្មំ
ទុក្ខហានឹ    សុខាវហំ    ។
អង្គីរសោ    សក្យមុនិ
សព្វភូតានុកម្បកោ
សព្វសត្តុត្តមោ    សីហោ
បិដកេ    តីណិ    ទេសយិ
សុត្តន្តំ    អភិជម្មញ្ច(១)
វិនយញ្ច    មហាគុណំ    ។
ឯវំ    នីយតិ    សទ្ធម្មោ
វិនយោ    យទិ    តិដ្ឋតិ
ឧភតោ    ច    វិភង្គានិ
ខន្ធកា    យា    ច    មាតិកា

១  ឱ.  ម.  សុត្តន្តមភិធម្មញ្ច  ។

សមុដ្ឋានសីសសង្ខេប សមុដ្ឋានកថា

ព្រះសម្មាសម្ពុទ្ធទាំងឡាយ ជាមហាវីរៈ ទ្រង់ធ្វើនូវទុក្ករកិរិយា មានប្រការផ្សេង ៗ បានបំពេញនូវបារមីទាំងឡាយ ព្រះអង្គមានចក្ខុកើតហើយ បានត្រាស់ដឹងឡើង ព្រះអង្គទ្រង់សម្ដែង នូវព្រះសទ្ធម្មដែលសម្រាប់បំផ្លាញ នូវកងទុក្ខ ហើយនាំមកនូវសេចក្ដីសុខ ចំពោះសត្វលោកព្រមទាំងព្រហ្មលោក ។ ព្រះអង្គីរសសម្មាសម្ពុទ្ធ ជាសក្យមុនី ព្រះអង្គមានសេចក្ដីអនុគ្រោះសព្វសត្វ ឧត្តមជាងសព្វសត្វ ជាសីហៈ (របស់នរជន) ទ្រង់សម្ដែងនូវពុទ្ធវចនៈទាំង ៣ ក្នុងបិដកគឺព្រះវិន័យ ព្រះសូត្រ ព្រះអភិធម្ម ដែលជាពាក្យមានគុណធំ ។ បើព្រះវិន័យ ឋិតនៅហើយ ព្រះសទ្ធម្មក៏ប្រព្រឹត្តទៅបាន យ៉ាងនេះ ឧភតោវិភង្គ ខន្ធកវិន័យ និងមាតិកា ដែល

មាលា សុត្តកុណោនេវ
បរិវារេន គន្ថិតា ។
តស្សេវ បរិវារស្ស
សមុដ្ឋានំ និយតោ កតំ
សម្ភេទនិទានញ្ចញ្ញំ
សុត្តេ ទិស្សន្តិ ឧបរិ
តស្មា សិក្ខេ បរិវារំ
ធម្មកាមោ សុបេសលោតិ ។
វិភង្គេ ទ្វីសុ បញ្ញត្តំ
ឧទ្ទិសន្តិ ឧបោសថេ
បវក្ខាមិ សមុដ្ឋានំ
យថាញាយំ សុណាថ មេ ។
បារាជិកំ យំ បឋមំ
ទុតិយញ្ច តតោ បរំ
សញ្ចរិត្តានុភាសញ្ច
អតិរេកញ្ច ចីវរំ
លោមានិ បទសោធម្មោ

សង្គីតិកាចារ្យចងក្រងហើយ ដោយបរិវារៈ បីដូចជាកម្រងផ្កា ដែលគេក្រង ដោយចេសនុ៎ះឯង ។ សមុដ្ឋាននៃបរិវារៈនុ៎ះឯង ជាសមុដ្ឋានដែលអ្នកប្រាជ្ញធ្វើឲ្យទៀងទាត់ គឺធ្វើមិនឲ្យលាយច្រឡំ ដោយសមុដ្ឋានឯទៀត សម្ភេទផង និទានផង សមុដ្ឋានដទៃផង មានប្រាកដមកក្នុងសូត្រ ដូចសម្ដែងមកហើយខាងដើម ព្រោះហេតុនោះ ភិក្ខុដែលមានសីលជាទីស្រឡាញ់ ជាអ្នកប្រាថ្នាធម៌ គប្បីសិក្សានូវបរិវារៈ (ទៀតចុះ) ។ សិក្ខាបទណា ដែលទ្រង់បញ្ញត្តហើយក្នុងវិភង្គទាំងពីរ ដែលពួកភិក្ខុ និងភិក្ខុនីតែងសម្ដែងគ្រប់ថ្ងៃឧបោសថ ខ្ញុំនឹងពោលនូវសមុដ្ឋាន (នៃសិក្ខា-បទនោះ) តាមសមគួរដល់សេចក្ដីចេះដឹង អ្នកទាំងឡាយចូរប្រុងស្ដាប់ពាក្យរបស់ខ្ញុំ ។ សិក្ខាបទទាំងឡាយ ១៣ គឺបឋម-បារាជិកសិក្ខាបទ ១ ទុតិយបារាជិកសិក្ខាបទ ១ តទៅមុខទៀត គឺសញ្ចរិត្តសិក្ខាបទ ១ សមនុភាសនសិក្ខាបទ ១ អតិរេកចីវរ-សិក្ខាបទ ១ ឯឡកលោមសិក្ខាបទ ១ បទសោធម្មសិក្ខាបទ ១

ភូតសំវិធានេន ច
ថេយ្យទេសនចោរិញ្ច
អននុញ្ញាយ តេរស ។
តេរសេតេ សមុដ្ឋាន-
នយា វិញ្ញូហិ ចិន្តិតា
ឯកេកស្មឹ សមុដ្ឋានេ
សទិសា ឥធ ទិស្សរេ
[៨២៧] មេថុនំ សុក្កសំសគ្គោ
អនិយតា បឋមិកា
បុព្វូបបរិចាចិតា
រហោ ភិក្ខុនិយា សហ
សភោជនេ រហោ ទ្វេ ច
អង្គុលិ ឧទកេ ហាសំ
បហារេ ឧគ្គិរេ ចេវ
តេបញ្ញាសា ច សេក្ខិយា
អធក្ខគាមាវស្សុតា[១]

១ ឱ. អធក្ខកំ គាមាវស្សុតា ។

ភូតារោចនសិក្ខាបទ ១ សំវិធានសិក្ខាបទ ១ ថេយ្យសត្ថ-សិក្ខាបទ ១ ធម្មទេសនាសិក្ខាបទ ១ ចោរីវុដ្ឋាបនសិក្ខាបទ ១ អននុញ្ញាតសិក្ខាបទ ១ ។ សិក្ខាបទទាំង ១៣ នេះ មានន័យរបស់សមុដ្ឋាន ដែលអ្នកប្រាជ្ញទាំងឡាយ បានគិតហើយថា ក្នុងសមុដ្ឋាននៃសិក្ខាបទមួយ ៗ ក្នុងវិភង្គទាំងពីរនេះ មានសមុដ្ឋានប្រហែល ៗ គ្នាទាំងអស់ ។

[៨២៧] មេថុនសិក្ខាបទ ១ សុក្កវិស្សដ្ឋិសិក្ខាបទ ១ កាយ-សំសគ្គសិក្ខាបទ ១ បឋមានីយតសិក្ខាបទ ១ បុព្វូបគត-សិក្ខាបទ[១] ១ បរិបាចិតសិក្ខាបទ ១ រហោនិសជ្ជសិក្ខា-បទ[២] ១ សភោជនសិក្ខាបទ ១ រហោនិសជ្ជសិក្ខាបទ[៣] ទាំង ២ អង្គុលិបតោទកសិក្ខាបទ ១ ឧទកេហាសធម្មសិក្ខាបទ ១ បហារទានសិក្ខាបទ ១ ឧគ្គិរណសិក្ខាបទ[៤] ១ សេក្ខិយ ៥៣ អជក្ខសិក្ខាបទ ១ គាមន្តរគមនសិក្ខាបទ ១ អវស្សុតខាទនីយ-

---

១ គឺអនុប្បខជ្ជសិក្ខាបទ ក្នុងភូតគាមវគ្គសិក្ខាបទទី ៦ ។ ២ គឺភិក្ខុអង្គុយក្នុងទីកំបាំងជាមួយនឹងភិក្ខុនី ។ ៣ គឺបឋមរហោនិសជ្ជ ១ ទុតិយរហោនិសជ្ជ ១ (អចេលកវគ្គ សិក្ខាបទទី ៤-៥) ។ ៤ គឺតលសត្តិកសិក្ខាបទ ។

តលមជ្ឈញ្ច សុទ្ធិកា
វស្សំ វុត្ថា ច ឱវាទំ
ជានុពន្ធេ បវត្តិនី
ឆសត្តតិ ឥមេ សិក្ខា
កាយមានសិកា កតា
សព្វេ ឯកសមុដ្ឋានា
បឋមំ បារាជិកំ យថា ។

បឋមបារាជិកសមុដ្ឋានំ និដ្ឋិតំ ។

[៨២៨] អធិដ្ឋំ វិក្កហុត្តរី[១]
ទុដ្ឋុល្លា អត្តកាមិនំ
អមូលា អញ្ញភាគិយា
អនិយតា ទុតិយិកា
អច្ឆិន្ទេ បរិណាមនេ
មុសា ឱមសបេសុណា
ទុដ្ឋុល្លា បឋវីខណេ

១ ម. វិគ្គហុត្តរិ ។

គហនសិក្ខាបទ[១] ១ តលឃាដកសិក្ខាបទ ១ ជតុមដ្ឋកសិក្ខាបទ ១ ឧទកសុទ្ធិកសិក្ខាបទ ១ វស្សវុត្ថានសិក្ខាបទ ១ ឱវាទគមនសិក្ខាបទ ១ វុដ្ឋាបិតបវត្តននានុពន្ធសិក្ខាបទ ១ រួមត្រូវជា ៧៦ សិក្ខាបទទាំងអស់នេះ សុទ្ធតែមានសមុដ្ឋានមួយ គឺ តាំងឡើងអំពីកាយចិត្ត ដូចបឋមបារាជិកសិក្ខាបទដែរ ។

ចប់ បឋមបារាជិកសមុដ្ឋាន ។

[៨២៨] អទិន្នាទានសិក្ខាបទ ១ មនុស្សវិគ្គហសិក្ខាបទ ១ ឧត្តរិមនុស្សធម្មសិក្ខាបទ ១ ទុដ្ឋុល្លវាចសិក្ខាបទ ១ អត្តកាមបារិចរិយសិក្ខាបទ ១ អមូលកសិក្ខាបទ ១ អញ្ញភាគិយសិក្ខាបទ ១ ទុតិយានិយតសិក្ខាបទ ១ ចីវរច្ឆិន្ទនសិក្ខាបទ ១ បរិណាមនសិក្ខាបទ ១ មុសាវាទសិក្ខាបទ ១ ឱមសវាទសិក្ខាបទ ១ បេសុញ្ញសិក្ខាបទ ១ ទុដ្ឋុល្លារោចនសិក្ខាបទ ១ បឋវីខណនសិក្ខាបទ ១

១ គឺខាទនីយគហណសិក្ខាបទ ។

សមុដ្ឋានសីសសង្ខេបំ ទុតិយបារាជិកសមុដ្ឋានំ

ភូតំ អញ្ញាយ ឧល្លបេ

និក្កឌ្ឍនំ សិញ្ចនញ្ច

អាមិសហេតុ ភុត្តាវី

ឯហិ អនាទរិ ភឹសា

អបនិធេ ច ជីវិតំ

ជានំ សប្បាណកំ កម្មំ

ឩនសំវាសនាសនា

សហធម្មិកវិលេខា

មោហោ អមូលកេន ច

កុក្កុច្ចំ ធម្មិកំ[១] ទត្វា

បរិណាមេយ្យ បុគ្គលេ

កិន្តេ អកាលអច្ឆិន្នេ

ទុត្តហិ និរយេន ច

គណំ វិភង្គំ ទុព្វលំ

១ ម. កុក្កុច្ចធម្មិកំ ។

ភូតគាមសិក្ខាបទ ១ អញ្ញវាទកសិក្ខាបទ ១ ឧជ្ឈាបនកសិក្ខាបទ ១ និកឌ្ឍនសិក្ខាបទ ១ សិញ្ចនសិក្ខាបទ[១] ១ អាមិសហេតុសិក្ខាបទ ១ កុត្តាវីសិក្ខាបទ[២] ១ ឯហិសិក្ខាបទ[៣] ១ អនាទរិយសិក្ខាបទ ១ ភឹសាបនសិក្ខាបទ ១ អបនិធានសិក្ខាបទ ១ ជីវិតាវោរោបនសិក្ខាបទ[៤] ១ សប្បាណកសិក្ខាបទ ១ កម្មឧក្កោដនសិក្ខាបទ ១ ឩនវីសតិវស្សសិក្ខាបទ ១ សំវាសសិក្ខាបទ[៥] ១ នាសិតកសាមណេរសម្ភោគសិក្ខាបទ[៦] ១ សហធម្មិកសិក្ខាបទ ១ វិលេខនសិក្ខាបទ ១ មោហនកសិក្ខាបទ ១ អមូលកសិក្ខាបទ[៧] ១ កុក្កុច្ចឧបទហនសិក្ខាបទ[៨] ១ ធម្មិកសិក្ខាបទ[៩] ១ ចីវរំទត្វាខិយ្យនធម្មសិក្ខាបទ[១០] ១ បុគ្គលបរិណាមនសិក្ខាបទ ១ កិន្តេសិក្ខាបទ[១១] ១ អកាលចីវរសិក្ខាបទ (ភាជាបនៈ) ១ អច្ឆិន្នសិក្ខាបទ ១ ទុគ្គហិតសិក្ខាបទ (ឧជ្ឈាបនកៈ) ១ និរយសិក្ខាបទ (អភិសបន) ១ គណាចីវរលាភសិក្ខាបទ ១ ចីវរវិភង្គសិក្ខាបទ ១ ទុព្វលចីវរសិក្ខាបទ ១

---

១ គឺសប្បាណកសិក្ខាបទទី ១០ ក្នុងភូតគាមវគ្គ ។ ២ គឺទុតិយបវារណាសិក្ខាបទ ។ ៣ គឺឧយ្យោជនសិក្ខាបទ ។ ៤ គឺសញ្ចិច្ចបាណសិក្ខាបទ ។ ៥ គឺឧក្ខិត្តសម្ភោគសិក្ខាបទ ។ ៦ គឺកណ្ដកសិក្ខាបទ ។ ៧ គឺអមូលកសិក្ខាបទទី ៦ ក្នុងសហធម្មិកវគ្គ ។ ៨ គឺសញ្ចិច្ចសិក្ខាបទ ។ ៩ គឺកម្មប្បដិពាហនសិក្ខាបទ ។ ១០ គឺខិយ្យធម្មសិក្ខាបទ ។ ១១ មានក្នុងភិក្ខុនីវិភង្គ ។

កឋិនផាសុបស្សយំ
អក្កោសចណ្ឌី មច្ឆរី
កត្តិនី ច ចាយន្តិយា
ទ្វេ វស្សា សិក្ខា សង្ឃេន
តយោ ចេវ គិហិគតា
កុមារីភូតា តិស្សោ ច
ឩនទ្វាទសសម្មតា
អលង្ការ សោកាវស្សំ
ឆន្ទា អនុវស្សា ច ទ្វេ
សិក្ខាបទា សត្តតីមេ
សមុដ្ឋានា តិកា កតា
កាយចិត្តេន ន វាចា
វាចាចិត្តា ន កាយិកា
តីហិ ទ្វារេហិ ជាយន្តិ
ចារាជិកំ ទុតិយំ យថា

ទុតិយបារាជិកសមុដ្ឋានំ និដ្ឋិតំ ។

កឋិនផាសុកសិក្ខាបទ ១ ឧបស្សយសិក្ខាបទ ១ អក្កោសនសិក្ខាបទ ១ ចណ្ឌីកតាសិក្ខាបទ ១ កុលមច្ឆរីសិក្ខាបទ ១ គព្ភិនីវុដ្ឋាបនសិក្ខាបទ ១ បាយន្តីវុដ្ឋាបនសិក្ខាបទ ១ ទ្វេវស្សាអសិក្ខិតសិក្ខមានាសិក្ខាបទ ១ សិក្ខិតសិក្ខាសង្ឃេនអសម្មតាសិក្ខាបទ ១ គិហិគតាសិក្ខាបទ[១] មាន ៣ កុមារីភូតាសិក្ខាបទ[២] មាន ៣ ឩនទ្វាទសវស្សាវុដ្ឋាបនសិក្ខាបទ ១ អសម្មតវុដ្ឋាបនសិក្ខាបទ ១ អលន្តាវសិក្ខាបទ ១ សោកាវស្សាសិក្ខាបទ ១ បារិវាសិកច្ឆន្ទទានសិក្ខាបទ ១ អនុវស្សសិក្ខាបទ ១ ឯកវស្សទ្វេវុដ្ឋាបនសិក្ខាបទ ១ រួមទាំងអស់ត្រូវជា ៧០ សិក្ខាបទ សិក្ខាបទទាំងនេះ សុទ្ធតែមានសមុដ្ឋាន ៣ ។ គឺកើតឡើងអំពីកាយចិត្ត មិនកើតឡើងអំពីវាចា ១ កើតឡើងអំពីវាចានិងចិត្តមិនកើតឡើងអំពីកាយ ១ កើតឡើងអំពីទ្វារទាំង ៣ គឺកាយវាចាចិត្ត ១ ដូចក្នុងទុតិយបារាជិកសិក្ខាបទ ។

ចប់ ទុតិយបារាជិកសមុដ្ឋាន ។

---

១ គឺឩនទ្វាទសវស្សាគិហិគតា ១ បរិបុណ្ណទ្វាទសវស្សាអសិក្ខិតសិក្ខាគិហិគតា ១ ទ្វេវស្សានិសិក្ខិតាសង្ឃេនអសម្មតាគិហិគតា ១ ។ ២ គឺចែកដូចគ្នានឹងគិហិគតាសិក្ខាបទ ។

៣៤១

សមុដ្ឋានសីសសង្ខេបំ សញ្ចរិត្តសមុដ្ឋានំ

[៨២៩] សញ្ចរិ កុដិ វិហារោ
ទោវចស្ស បដិត្តហោ
វិញ្ញត្តុត្តរិ អភិហដ្ឋុំ
ឧភិន្នំ ទូតកោន ច
កោសិយា សុទ្ធទ្វេភាគា
ឆព្វស្សានិ និសីទនំ
វិញ្ចន្តិ រូបិកា ចេវ
ឧភោ នានប្បការកា
ឩនពន្ធនវស្សិកា
សុត្តំ វិកប្បនេន ច
ទ្វារទានសិព្វិនី ច
បូវបច្ចយជោតិ ច
រតនំ សូចិ មញ្ចោ ច
តូលំ និសីទនកណ្ឌុ ច

## សមុដ្ឋានសីសសង្ខេប សញ្ចរិត្តសមុដ្ឋាន

[៨២៩] សញ្ចរិត្តសិក្ខាបទ ១ កុដិការសិក្ខាបទ ១ វិហារសិក្ខាបទ (មហល្លកៈ) ១ ចីវរធោវនសិក្ខាបទ ១ ចីវរប្បដិគ្គហណសិក្ខាបទ ១ អញ្ញាតកវិញ្ញត្តិសិក្ខាបទ ១ តទុត្តរិអភិហដ្ឋសិក្ខាបទ[១] ១ ឧបក្ខដសិក្ខាបទ ២ (គឺបឋមឧបក្ខដៈ ១ ទុតិយឧបក្ខដៈ ១) ទូតសិក្ខាបទ[២] ១ កោសិយសិក្ខាបទ ១ សុទ្ធកាឡកសិក្ខាបទ ១ ទ្វេភាគសិក្ខាបទ ១ ឆព្វស្សសិក្ខាបទ ៦ និសីទនសន្ថតសិក្ខាបទ ១ រិញ្ចន្តិសិក្ខាបទ[៣] ១ រូបិយសិក្ខាបទ ១ នានប្បការកសិក្ខាបទ ២ (គឺរូបិយសំវោហារសិក្ខាបទ ១ កយវិក្កយសិក្ខាបទ ១) ឩនបញ្ចពន្ធនសិក្ខាបទ ១ វស្សិកសាដិកសិក្ខាបទ ១ សុត្តវិញ្ញត្តិសិក្ខាបទ ១ វិកប្បនសិក្ខាបទ[៤] ១ ទ្វារសិក្ខាបទ[៥] ១ ចីវរទានសិក្ខាបទ ១ ចីវរសិព្វនសិក្ខាបទ ១ បូវសិក្ខាបទ[៦] ១ បច្ចយសិក្ខាបទ[៧] ១ ជោតិសមាទហនសិក្ខាបទ ១ រតនសិក្ខាបទ ១ សុចិឃរសិក្ខាបទ ១ មញ្ចសិក្ខាបទ ១ តូលោនទ្ធសិក្ខាបទ ១ និសីទនសិក្ខាបទ ១ កណ្ឌុបដិច្ឆាទិសិក្ខាបទ ១

---

១ គួរហៅថា តទុត្តរិសិក្ខាបទប៉ុណ្ណោះ ។ ២ គឺរាជសិក្ខាបទ ។ ៣ គឺឯឡកលោមធោវាបនសិក្ខាបទ ។ ៤ គឺមហាបេសការសិក្ខាបទ ។ ៥ គឺមហាល្លកសិក្ខាបទ ទី ៩ ក្នុងភូតគាមវគ្គ ។ ៦ គឺកាណមាតាសិក្ខាបទ ។ ៧ គឺមហានាមសិក្ខាបទ ។

វេស្សេកា ច សុគតេន
វិញ្ញត្តិ អញ្ញចេតាបនា
ទ្វេ សង្ឃិកា មហាជនិកា
ទ្វេ បុគ្គលា លហុកា គរុ
ទ្វេ វិឃាសា សាដិកា ច
សមណាចីវរេន ច
សមបញ្ញាសិមេ ធម្មា
ឆហិ ឋានេហិ ជាយរេ
កាយតោ ន វាចាចិត្តា
វាចតោ ន កាយមនា
កាយវាចា ន ចិត្តតោ[១]
កាយចិត្តា ន វាចតោ[២]
វាចាចិត្តា ន កាយេន
តីហិ ឋានេហិ[៣] ជាយរេ
ឆសមុដ្ឋានិកា ចេតេ[៤]
សញ្ចរិត្តេន សាទិសា ។

សញ្ចរិត្តសមុដ្ឋានំ និដ្ឋិតំ ។

១ ឱ. ម. ន ច ចិត្តា ។ ២ ន វាចិកា ។ ៣ ទ្វារេហិ ។ ៤ ឱ. ម. ឯតេ ។

វស្សិកសាដិកាសិក្ខាបទ ១ សុគតចីវរសិក្ខាបទ[១] ១ វិញ្ញត្តិសិក្ខាបទ ១ អញ្ញចេតាបនសិក្ខាបទ ១ សង្ឃិកចីវរសិក្ខាបទ ២ មហាជនិកសិក្ខាបទ ១ បុគ្គលបរិណាមនសិក្ខាបទ ២ លហុបាបុរណសិក្ខាបទ ១ គរុបាបុរណសិក្ខាបទ ១ វិឃាសាសិក្ខាបទ ២ ឧទកសាដិកាសិក្ខាបទ ១ សមណចីវរទានសិក្ខាបទ ១ រួមទាំងអស់ត្រូវជាសិក្ខាបទ ៥០ គត់ សិក្ខាបទទាំងនេះ សុទ្ធតែមានសមុដ្ឋានប្រាំមួយ ៗ គឺកើតឡើងអំពីកាយ មិនកើតឡើងអំពីវាចានិងចិត្ត ១ កើតឡើងអំពីវាចា មិនកើតឡើងអំពីកាយនិងចិត្ត ១ កើតឡើងអំពីកាយនិងវាចា មិនកើតឡើងអំពីចិត្ត ១ កើតឡើងអំពីកាយនិងចិត្ត មិនកើតឡើងអំពីវាចា ១ កើតឡើងអំពីវាចានិងចិត្ត មិនកើតឡើងអំពីកាយ ១ កើតឡើងអំពីទ្វារទាំង ៣ គឺកាយវាចានិងចិត្ត ១ សិក្ខាបទទាំងនេះសុទ្ធតែមានសមុដ្ឋាន ៦ ដូចគ្នានឹងសញ្ចរិត្តសិក្ខាបទដែរ ។

ចប់ សញ្ចរិត្តសមុដ្ឋាន ។

---

១ គឺ នន្ទត្ថេរសិក្ខាបទ ។

សមុដ្ឋានសីសសង្ខេបំ សមនុភាសនសមុដ្ឋានំ

[៨៣០] ភេជានុវត្តទុព្វច
ទូសទុដ្ឋុល្លទិដ្ឋិ ច
ឆន្ទំ ឧជ្ជគ្ឃិកា ទ្វេ ច
ទ្វេ ច សទ្ធា ន ព្យាហរេ
ឆមា នីចាសនេ ឋានំ
បច្ឆតោ ឧប្បថេន ច
វជ្ជានុវត្តិ គហណា
ឱសារេ បច្ចាចិក្ខនា
កិស្មឹ សំសដ្ឋា ទ្វេ វធី
វិសិព្វេ ទុក្ខិតាយ ច
បុន សំសដ្ឋា ន វូបសមេ
អារាមញ្ច បវារណា
អន្វឌ្ឍមាសំ សហជីវិនី
ទ្វេ ចីវរំ អនុពន្ធនា
សត្តតឹស ឥមេ ធម្មា

សមុដ្ឋានសីសសង្ខេប សមនុភាសនសមុដ្ឋាន

[៨៣០] សង្ឃភេទសិក្ខាបទ ១ ភេទានុវត្តកសិក្ខាបទ ១ ទុព្វចជាតិកសិក្ខាបទ ១ កុលទូសកសិក្ខាបទ ១ ទុដ្ឋុល្លប្បដិច្ឆាទនសិក្ខាបទ ១ ទិដ្ឋិអប្បដិនិស្សជ្ជនសិក្ខាបទ ១ ឆន្ទំអទត្វាគមនសិក្ខាបទ ១ ឧជ្ឈគ្ឃិកសិក្ខាបទ ២ អប្បសទ្ទសិក្ខាបទ ២ នព្យាហរណសិក្ខាបទ ១ ឆមាយសិក្ខាបទ ១ នីចាសនសិក្ខាបទ ១ ឋានសិក្ខាបទ ១ បច្ឆតោសិក្ខាបទ ១ ឧប្បថេនសិក្ខាបទ ១ វជ្ជប្បដិច្ឆាទនសិក្ខាបទ ១ ឧក្ខិត្តានុវត្តនសិក្ខាបទ ១ ហត្ថគ្គហណសិក្ខាបទ ១ ឱសារណសិក្ខាបទ ១ បច្ចាចិក្ខនាសិក្ខាបទ ១ កិស្មិញ្ចិអធិករណេបច្ចាគតាសិក្ខាបទ ១ សំសដ្ឋសិក្ខាបទ[១] ១ វធិសិក្ខាបទ ២ វិសិព្វនសិក្ខាបទ ១ ទុក្ខិតាសហជីវិនីសិក្ខាបទ ១ សំសដ្ឋាសិក្ខាបទ[២] មួយទៀត ១ នវូបសមនសិក្ខាបទ ១ អារាមសិក្ខាបទ ១ ឧភតោសង្ឃបវារណាសិក្ខាបទ ១ អន្វឌ្ឍមាសសិក្ខាបទ ១ សហជីវិនីសិក្ខាបទ[៣] ២ ចីវរទានសិក្ខាបទ ១ អនុពន្ធនសិក្ខាបទ ១ រួមទាំងអស់ត្រូវជា ៣៧ សិក្ខាបទ សិក្ខាបទទាំងអស់នេះ

១ គឺ ភិក្ខុនិយាសំសដ្ឋសិក្ខាបទ ។ ២ គឺ គិហិសំសដ្ឋសិក្ខាបទ ។ ៣ សហជីវិនីនានុគ្គហណសិក្ខាបទ ១ សហជីវិនីនវុបកាសនសិក្ខាបទ ១ ។

កាយវាចាយ ចិត្តតោ
សព្វេ ឯកសមុដ្ឋានា
សមនុភាសនា យថា ។
សមនុភាសនសមុដ្ឋានំ និដ្ឋិតំ ។

[៨៣១] ឧព្ភតំ កឋិនំ តីណិ
បឋមំ បត្តភេសជ្ជំ
អច្ចេកញ្ចាបិ[១] សាសង្កំ
បក្កមន្តេន វា ទុវេ
ឧបស្សយំ បរម្បរា
អនតិរិត្តំ និមន្តនា
វិកប្បំ រញ្ញោ វិកាលេ
វោសាសារញ្ញកេន ច
ឧស្សយា[២] សន្និចយញ្ច
បុរេ បច្ឆា វិកាលេ ច
បញ្ចាហិកា សង្កមនី

១ ឱ. អច្ចេកំ វាបិ ។ ២ ឱ. ម. ឧស្សយា ។

សុទ្ធតែមានសមុដ្ឋានមួយ ៗ គឺកើតឡើងអំពីកាយវាចានិងចិត្ត ដូចក្នុងសមនុភាសនសិក្ខាបទដែរ[១] ។

ចប់ សមនុភាសនសមុដ្ឋាន ។

[៨៣១] ឧព្ភតកឋិនសិក្ខាបទ[២] ៣ បឋមបត្តសិក្ខាបទ ១ ភេសជ្ជសិក្ខាបទ ១ អច្ចេកចីវរសិក្ខាបទ ១ សាសង្កសិក្ខាបទ ១ បក្កមន្តសិក្ខាបទ[៣] ២ ភិក្ខុនូបស្សយសិក្ខាបទ ១ បរម្បរភោជនសិក្ខាបទ ១ អនតិរិត្តសិក្ខាបទ[៤] ១ និមន្តនសិក្ខាបទ[៥] ១ វិកប្បនសិក្ខាបទ ១ រាជសិក្ខាបទ[៦] វិកាលេគាមប្បវេសនសិក្ខាបទ ១ វោសាសសិក្ខាបទ ១ អារញ្ញិកសិក្ខាបទ ១ ឧសូយវាទិកសិក្ខាបទ ១ បត្តសន្និចយសិក្ខាបទ ១ បុរេភត្តសិក្ខាបទ ១ បច្ឆាភត្តសិក្ខាបទ ១ វិកាលេឧបសង្កមនសិក្ខាបទ ១ បញ្ចាហិកធារណសិក្ខាបទ ១ ចីវរសង្កមនីយ-

---

១ សង្ឃាទិសេសសិក្ខាបទ ៤ គឺតាំងពីសង្ឃភេទដល់កុលទូសកៈ ឈ្មោះថា សមនុភាសនា ឬហៅថា យាវតតិយកា ។ ២ ឧព្ភតកឋិនសិក្ខាបទ ៣ នោះ គឺបឋមកឋិន ១ ទុតិយកឋិន ១ តតិយកឋិន ១ ។ ៣ បក្កមនសិក្ខាបទ ២ នោះ គឺបឋមសេនាសនៈ ១ ទុតិយសេនាសនៈ ១ ។ ៤ គឺបឋមបវារណា ។ ៥ គឺទុតិយបវារណា ។ ៦ គឺអន្តេបុរសិក្ខាបទ ។ ៧ អាវាសថសិក្ខាបទ ២ នោះ គឺអាវាសថចីវរានិស្សជ្ជនសិក្ខាបទ ១ អាវាសថចីវរបក្កមនៈ ១ ។

សមុដ្ឋានសីសសង្ខេបំ ឯឡកលោមសមុដ្ឋានំ

ទ្វេបិ(១) អាវសថេន ច
បសាខេ អាសនេ ចេវ
តឹសឯកូនកា ឥមេ
កាយវាចា ន ចិត្តតោ(២)
តីហិ ទ្វារេហិ ជាយរេ
ទ្វិសមុដ្ឋានិកា សព្វេ
កឋិនេន សហា សមា ។

កឋិនសមុដ្ឋានំ និដ្ឋិតំ ។

[៨៣២] ឯឡកលោមា ទ្វេ សេយ្យា
អាហច្ចបិណ្ឌភោជនំ
គណវិកាលេ សន្និធិ
ទន្តបោណនចេលកា
ឧយ្យុត្តំ វសេ(៣) ឧយ្យោធិ
សុរា ឱរេន ន្ហាយនា

១ ឱ. ម. ទ្វេ ។ ឱ. ន ច ចិត្តា ។ ៣ ឱ. សេនំ ។

សិក្ខាបទ ១ អាវសថ[១]សិក្ខាបទ ២ បសាខសិក្ខាបទ ១ អាសននិសីទនសិក្ខាបទ ១ រួមទាំងអស់ត្រូវជា ២៩ សិក្ខាបទ សិក្ខាបទទាំងអស់នេះ សុទ្ធតែមានសមុដ្ឋានពីរ ៗ គឺកើតឡើង អំពីកាយនិងវាចា មិនកើតឡើងអំពីចិត្ត ១ កើតឡើងអំពីទ្វារ ទាំង ៣ គឺកាយវាចានិងចិត្ត ១ ដូចកឋិនសិក្ខាបទដែរ ។

ចប់ កឋិនសមុដ្ឋាន ។

[៨៣២] ឯឡកលោមសិក្ខាបទ ១ សហសេយ្យសិក្ខាបទ[២] ២ អាហច្ចនសិក្ខាបទ[៣] ១ អាវសថបិណ្ឌភោជនសិក្ខាបទ ១ គណភោជនសិក្ខាបទ ១ វិកាលភោជនសិក្ខាបទ ១ សន្និធិការសិក្ខាបទ ១ ទន្តបោណសិក្ខាបទ ១ អចេលកសិក្ខាបទ ១ ឧយ្យុត្តសិក្ខាបទ ១ សេនាវាសសិក្ខាបទ ១ ឧយ្យោធិកសិក្ខាបទ ១ សុរាបានសិក្ខាបទ ១ ឱរេនឌ្ឍមាសនហានសិក្ខាបទ ១

---

១ អាវសថសិក្ខាបទ ២ នោះ គឺអាវាសថចីវរានិស្សជ្ជនសិក្ខាបទ ១ អាវាសថចីវរបក្កមនៈ ១ ។
២ បឋមសហសេយ្យសិក្ខាបទ ១ ទុតិយសហសេយ្យសិក្ខាបទ ១ ។ ៣ វេហាសកុដិសិក្ខាបទ ។

ទុព្វណ្ណោ ទ្វេ ទេសនិកា

លសុណុត្តិដ្ឋេ នច្ចនា

ឆ្ឌានំ អត្ថរណំ[១] សេយ្យា

អន្តោរដ្ឋេ តថា ពហិ

អន្តោវស្សំ ចិត្តាគារំ

អាសន្ទិ សុត្តកន្តនា

វេយ្យាវច្ចំ សហត្ថា ច

អភិក្ខុកាវាសេន ច

ឆត្តំ យានញ្ច សង្ឃាណី

អលង្ការំ គន្ធវាសិតំ

ភិក្ខុនី សិក្ខមានា ច

សាមណេរី គិហិនិយា

អសង្កច្ឆិកា[២]អាបត្តី

១ ឱ. ម. ន្ទានមត្ថរណំ ។ ២ ម. អសង្កច្ចិកា ។

ទុព្វណ្ណករណសិក្ខាបទ ១ បាដិទេសនីយសិក្ខាបទ ២ លសុ-
ណសិក្ខាបទ ១ ឧតិដ្ឋសិក្ខាបទ ១ នច្ចនសិក្ខាបទ ១ ។ នហាន-
សិក្ខាបទ ១ អត្ថរណតុវដ្តសិក្ខាបទ ១ ឯកសេយ្យតុវដ្តសិក្ខា-
បទ ១ អន្តោរដ្ឋេសាសង្កសិក្ខាបទ ១ ពហិរដ្ឋេសាសង្កសិក្ខា-
បទ ១ អន្តោវស្សសិក្ខាបទ ១ ចិត្តាគារសិក្ខាបទ ១ អាសន្ទិ-
បរិភុញ្ជនសិក្ខាបទ ១ សុត្តកន្តនសិក្ខាបទ ១ គិហិវេយ្យាវច្ច-
ករណសិក្ខាបទ ១ សហត្ថាទានសិក្ខាបទ ១ អភិក្ខុកាវាស-
សិក្ខាបទ ១ ឆត្តធារណសិក្ខាបទ ១ យានសិក្ខាបទ ១ សង្ឃា-
ណីធារណសិក្ខាបទ ១ អលង្ការធារណសិក្ខាបទ ១ គន្ធនហាន-
សិក្ខាបទ ១ វាសិតនហានសិក្ខាបទ ១ ភិក្ខុនីឧម្មទ្ទាបនសិក្ខាបទ ១
សិក្ខមានាឧម្មទ្ទាបនសិក្ខាបទ ១ សាមណេរីឧម្មទ្ទាបនសិក្ខា-
បទ ១ គិហិនីឧម្មទ្ទាបនសិក្ខាបទ ១ អសង្កច្ចិកាបត្តិសិក្ខាបទ ១

### សមុដ្ឋានសីសសង្ខេបំ បទសោធម្មសមុដ្ឋានំ

ចត្តារីសា ចតុត្តិ
កាយេន ន វាចាចិត្តេន
កាយចិត្តេន ន វាចតោ
ទ្វិសមុដ្ឋានិកា សព្វេ
សមា ឯឡកលោមកា ។

ឯឡកលោមសមុដ្ឋានំ និដ្ឋិតំ ។

[៨៣៣] បញ្ញត្រ អសម្មតា
តថា អត្ថង្គតេន ច
តិរច្ឆានវិជ្ជា ទ្វេ វុត្តា
អនោកាសេ ច បុច្ឆនា
សត្តសិក្ខាបទា ឯតេ
វាចា ន កាយចិត្តតោ[១]
វាចាចិត្តេន ជាយន្តិ
ន តុ កាយេន ជាយរេ
ទ្វិសមុដ្ឋានិកា សព្វេ
បទសោធម្មសាទិសា ។

បទសោធម្មសមុដ្ឋានំ និដ្ឋិតំ ។

---

១ ម. វាចា ន កាយចិត្តកា ។

រួមទាំងអស់ត្រូវជា ៤៤ សិក្ខាបទ សិក្ខាបទទាំងអស់នេះ សុទ្ធតែមានសមុដ្ឋានពីរ ៗ គឺកើតឡើងអំពីកាយ មិនកើតឡើងអំពីវាចានិងចិត្ត ១ កើតឡើងអំពីកាយនិងចិត្ត មិនកើតឡើងអំពីវាចា ១ ដូចឯឡកលោមសិក្ខាបទដែរ ។

ចប់ ឯឡកលោមសមុដ្ឋាន ។

[៨៣៣] បទសោធម្មសិក្ខាបទ ១ ធម្មទេសនាសិក្ខាបទ ១ អសម្មតោភិក្ខុនោវាទសិក្ខាបទ ១ អត្ថង្គតសិក្ខាបទ ១ តិរច្ឆានវិជ្ជាសិក្ខាបទ ២[១] អនោកាសបុច្ឆនសិក្ខាបទ ១ រួមទាំងអស់ត្រូវជា ៧ សិក្ខាបទ សិក្ខាបទទាំងអស់នេះ សុទ្ធតែមានសមុដ្ឋានពីរ ៗ គឺកើតឡើងអំពីវាចា មិនកើតឡើងអំពីកាយនិងចិត្ត ១ កើតឡើងអំពីវាចានិងចិត្ត មិនកើតឡើងអំពីកាយ ១ ដូចបទសោធម្មសិក្ខាបទដែរ ។

ចប់ បទសោធម្មសមុដ្ឋាន ។

---

១ តិរច្ឆានវិជ្ជា ២ នោះ គឺតិរច្ឆានវិជ្ជាបរិយាបុនសិក្ខាបទ ១ តិរច្ឆានវិជ្ជាវាចនសិក្ខាប ១ ។

[៨៣៤] អដ្ឋានជាវំ បណីតំ
មាតុគ្គាមេន សង្ឃិរេ[១]
ជញ្ញំ និមន្តិតា ចេវ
អដ្ឋ ច ចាជិនេសជី
សិក្ខា បណ្ណាសោ ឯតេ
កាយា ន វាចា ន មនា
កាយវាចាយ ជាយន្តិ
ន តេ ចិត្តេន ជាយរេ
កាយចិត្តេន ជាយន្តិ
ន តេ ជាយន្តិ វាចតោ
កាយវាចាយ[២] ចិត្តេន
សមុដ្ឋានា ចតុព្វិជា
បញ្ញត្តា ពុទ្ធញាណេន
អដ្ឋានេន សមា នយា[៣]

អទ្ធានសមុដ្ឋានំ និដ្ឋិតំ ។

១ ម. សង្ខរេ ។ ២ ម. កាយវាចាហិ ។ ៣ ឱ. សហា សមា ។ ម. សហា សមា ។

[៨៣៤] អទ្ធានគមនសិក្ខាបទ[១] ១ នាវាភិរូហនសិក្ខាបទ ១ បណីតភោជនសិក្ខាបទ ១ មាតុគ្គាមសំវិធានសិក្ខាបទ ១ លោមសំហរណសិក្ខាបទ ១ ធញ្ញវិញ្ញាបនសិក្ខាបទ ១ និមន្ត-នសិក្ខាបទ ១ បាដិទេសនីយសិក្ខាបទ ៨ រួមទាំងអស់ត្រូវជា ១៥ សិក្ខាបទ សិក្ខាបទទាំងអស់នេះ ព្រះពុទ្ធទ្រង់ញាណ បានបញ្ញត្តហើយដោយសមុដ្ឋានបួន ។ គឺកើតឡើងអំពីកាយ មិនកើតឡើងអំពីវាចា ទាំងមិនកើតឡើងអំពីចិត្ត ១ កើត ឡើងអំពីកាយនិងវាចា មិនកើតឡើងអំពីចិត្ត ១ កើតឡើង អំពីកាយនិងចិត្ត មិនកើតឡើងអំពីវាចា ១ កើតឡើងអំពី កាយវាចានិងចិត្ត ១ មានទំនងដូចអទ្ធានគមនសិក្ខាបទដែរ ។

ចប់ អទ្ធានសមុដ្ឋាន ។

---

១ គឺសំវិធានសិក្ខាបទ ។

[៨៣៥] ថេយ្យសត្ថំ ឧបស្សុតិំ
សូបវិញ្ញាបនេន ច
រត្តិ ឆន្ទញ្ច ឱកាសំ
ឯតេ ព្យូហេន សត្តមា
កាយចិត្តេន ជាយន្តិ
ន តេ ជាយន្តិ វាចតោ
តីហិ ទ្វារេហិ ជាយន្តិ
ទ្វិសមុដ្ឋានិកា ឥមេ
ថេយ្យសត្ថសមុដ្ឋានា
ទេសិតាទិច្ចពន្ធុនា ។

ថេយ្យសត្ថសមុដ្ឋានំ និដ្ឋិតំ ។

[៨៣៦] ឆត្តចាណិស្ស សទ្ធម្មំ
ន ទេសន្តិ តថាគតា
តថេវ[១] ទណ្ឌចាណិស្ស
សត្ថអាវុធចាណិនំ
ចាទុកុចាហនា យានំ
សេយ្យា បល្លត្ថិកាយ ច

១ ឱ. ម. ឯវមេវ ។

សមុដ្ឋានសីសសង្ខេប ថេយ្យសត្ថសមុដ្ឋាន និងធម្មទេសនាសមុដ្ឋាន

[៨៣៥] ថេយ្យសត្ថសិក្ខាបទ ១ ឧបស្សុតិសិក្ខាបទ ១ សូប-វិញ្ញាបនសិក្ខាបទ ១ រត្តន្ធការសិក្ខាបទ ១ បដិច្ឆន្នសិក្ខាបទ ១ អជ្ឈោកាសសិក្ខាបទ ១ ព្យូហសិក្ខាបទ ១ សិក្ខាបទទាំងអស់នេះ រួមគ្នាត្រូវជា ៧ សិក្ខាបទទាំងនោះ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់សម្ដែងហើយថា មានសមុដ្ឋានពីរ ៗ គឺកើតឡើងអំពីកាយនិងចិត្ត មិនកើតឡើងអំពីវាចា ១ កើតឡើងអំពីទ្វារទាំង ៣ គឺកាយវាចាចិត្ត ១ ដូចសមុដ្ឋានរបស់ថេយ្យសត្ថ-សិក្ខាបទដែរ ។

ចប់ ថេយ្យសត្ថសមុដ្ឋាន ។

[៨៣៦] ព្រះតថាគតទាំងឡាយ មិនសម្ដែងនូវព្រះសទ្ធម្មដល់បុគ្គល (មិនមានជម្ងឺ) មានឆត្រក្នុងដៃ ១ មានឈើច្រត់ក្នុងដៃ ១ មានសស្ត្រាក្នុងដៃ ១ មានអាវុធក្នុងដៃ ១ ពាក់ទ្រនាប់ជើងឈើឬស្មៅ ១ ពាក់ទ្រនាប់ជើងស្បែក ១ នៅលើយាន ១ នៅលើដំណេក ១ អង្គុយត្របោមក្បាលជង្គង់ ១

វេបិតោកុណ្ឌិតោ ចេវ
ឯកាទសសមុដ្ឋកា
វាចាចិត្តេន ជាយន្តិ
ន តេ ជាយន្តិ កាយតោ
សព្វេ ឯកសមុដ្ឋានា
សមកា ធម្មទេសនា[១] ។

ធម្មទេសនាសមុដ្ឋានំ និដ្ឋិតំ ។

[៨៣៧] ភូតំ កាយេន ជាយតិ
ន វាចាយ ន ចិត្តតោ
វាចតោ ច សមុដ្ឋាតិ
ន កាយា ន ច ចិត្តតោ
កាយវាចាយ ជាយតិ
ន ច[២] ជាយតិ ចិត្តតោ
ភូតារោចនកា ធម្មា
តីហិ ឋានេហិ ជាយតិ ។

ភូតារោចនសមុដ្ឋានំ និដ្ឋិតំ ។

១ ឱ. ម. ធម្មទេសនេ ។ ឱ. ម. តុ ។

ជួតឈ្នួតក្បាល ១ ទទូរក្បាល ១ (រឿងទាំងនេះរួមគ្នាជា) សិក្ខាបទ ១១ គត់ សិក្ខាបទទាំងអស់នោះ សុទ្ធតែមានសមុដ្ឋានមួយ ៗ គឺកើតឡើងអំពីវាចានិងចិត្ត មិនកើតឡើងអំពីកាយទេ ដូចធម្មទេសនាសិក្ខាបទដែរ ។

ចប់ ធម្មទេសនាសមុដ្ឋាន ។

[៨៣៧] ភូតសិក្ខាបទ ឈ្មោះថា ភូតារោចនសិក្ខាបទ កើតឡើងអំពីសមុដ្ឋាន ៣ គឺកើតឡើងអំពីកាយ មិនកើតឡើងអំពីវាចា មិនកើតឡើងអំពីចិត្ត ១ កើតឡើងអំពីវាចា មិនកើតឡើងអំពីកាយ ទាំងមិនកើតឡើងអំពីចិត្ត ១ កើតឡើងអំពីកាយនិងវាចា មិនកើតឡើងអំពីចិត្ត ១ ។

ចប់ ភូតារោចនសមុដ្ឋាន ។

សមុដ្ឋានសីសសង្ខេបំ ចោរីវុដ្ឋាបនសមុដ្ឋានំ អននុញ្ញាតសមុដ្ឋានំ

[៨៣៨] ចោរី វាចាយ ចិត្តេន
ន តំ ជាយតិ កាយតោ
ជាយតិ តីហិ ទ្វារេហិ
ចោរីវុដ្ឋាបនំ ឥទំ
អកតំ ទ្វិសមុដ្ឋានំ
ធម្មរាជេន ឋបិតំ[១] ។

ចោរីវុដ្ឋាបនសមុដ្ឋានំ និដ្ឋិតំ ។

[៨៣៩] អននុញ្ញាតំ វាចាយ
ន កាយា ន ច ចិត្តតោ
ជាយតិ កាយវាចាយ
ន តំ ជាយតិ ចិត្តតោ
ជាយតិ វាចាចិត្តេន
ន តំ ជាយតិ កាយតោ
ជាយតិ តីហិ ឋានេហិ[២]
អកតំ ចតុដ្ឋានិកំ ។

អននុញ្ញាតសមុដ្ឋានំ និដ្ឋិតំ ។

---

១ ឱ. ម. ភាសិតំ ។ ២ ឱ. ម. ទ្វារេហិ ។

សមុដ្ឋានសីសសង្ខេប ចោរីវុដ្ឋាបនសមុដ្ឋាននិងអននុញ្ញាតសមុដ្ឋាន

[៣៨៨] ចោរីវុដ្ឋាបនសិក្ខាបទ កើតឡើងអំពីវាចានិងចិត្ត សិក្ខាបទនោះ មិនកើតឡើងអំពីកាយ ១ (ម្យ៉ាងទៀត) ចោរី-វុដ្ឋាបនសិក្ខាបទកើតឡើងអំពីទ្វារទាំង ៣ គឺកាយវាចានិង ចិត្ត ១ សិក្ខាបទនេះ ព្រះសម្មាសម្ពុទ្ធ ជាធម្មរាជទ្រង់សម្តែង ហើយថា មានសមុដ្ឋានពីរនិងជាអកិរិយា (ត្រូវអាបត្តិព្រោះ មិនធ្វើ គឺមិនបានប្រាប់គេជាមុនហើយបំបួស) ។

ចប់ ចោរីវុដ្ឋាបនសមុដ្ឋាន ។

[៨៣៩] អននុញ្ញាតសិក្ខាបទមានសមុដ្ឋាន ៤ ជាអកិរិយា គឺកើតឡើងអំពីវាចា មិនកើតឡើងអំពីកាយ ទាំងមិនកើតឡើង អំពីចិត្ត ១ សិក្ខាបទនោះ កើតឡើងអំពីកាយនិងវាចា មិន កើតឡើងអំពីចិត្ត ១ សិក្ខាបទនោះ កើតឡើងអំពីវាចានិងចិត្ត មិនកើតឡើងអំពីកាយ ១ កើតឡើងអំពីសមុដ្ឋានទាំង ៣ គឺ កាយវាចានិងចិត្ត ១ ។

ចប់ អននុញ្ញាតសមុដ្ឋាន ។

[៨៤០] សមុដ្ឋានំ ហិ សង្ខេបំ
ឧស តីណិ សុទេសិតំ
អសម្មោហាករណដ្ឋានំ[១]
នេត្តិធម្មានុលោមិកំ
ធារយន្តោ ឥមំ វិញ្ញូ
សមុដ្ឋានេ ន មុយ្ហតីតិ ។

សមុដ្ឋានសីសសង្ខេបំ និដ្ឋិតំ ។

---

១ ឱ. អសម្មោហករណំ ឋានំ ។ ម. អសម្មោហករំ ឋានំ ។

[៨៤០] សេចក្តីថា សមុដ្ឋានសង្ខេបទាំង ១៣ (នេះ) ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងប្រពៃហើយ ដើម្បីធ្វើមិនឲ្យភាន់ច្រឡំ សមគួរដល់វិន័យនិងបាលីនិងធម៌ បណ្ឌិតអ្នកទ្រទ្រង់វិន័យនេះ កុំភាន់ច្រឡំក្នុងសមុដ្ឋានឡើយ ។

ចប់ សមុដ្ឋានសីសសង្ខេប ។

# កតិបុច្ឆាវារំ

[៨៤១] កតិ អាបត្តិយោ ។ កតិ អាបត្តិក្ខន្ធា ។ កតិ វិនីតវត្ថូនិ ។ កតិ អគារវា ។ កតិ គារវា ។ កតិ វិនីតវត្ថូនិ ។ កតិ វិបត្តិយោ ។ កតិ អាបត្តិសមុដ្ឋានា ។ កតិ វិវាទមូលានិ ។ កតិ អនុវាទមូលានិ ។ កតិ សារាណីយា ធម្មា ។ កតិ ភេទករវត្ថូនិ ។ កតិ អធិករណានិ ។ កតិ សមថា ។

[៨៤២] បញ្ច អាបត្តិយោ ។ បញ្ច អាបត្តិក្ខន្ធា ។ បញ្ច វិនីតវត្ថូនិ ។ សត្ត អាបត្តិយោ ។ សត្ត អាបត្តិក្ខន្ធា ។ សត្ត វិនីតវត្ថូនិ ។ ឆ អគារវា ។ ឆ គារវា ។ ឆ វិនីតវត្ថូនិ ។ ចតស្សោ វិបត្តិយោ ។ ឆ អាបត្តិសមុដ្ឋានា ។ ឆ វិវាទមូលានិ ។ ឆ អនុវាទមូលានិ ។

# កតិបុច្ឆាវារៈ

[៨៤១] សួរថា អាបត្តិ មានប៉ុន្មាន ។ កង៏នៃអាបត្តិ មានប៉ុន្មាន ។ វិនីតវត្ថុ មានប៉ុន្មាន ។ សេចក្តីមិនគោរព មានប៉ុន្មាន ។ សេចក្តីគោរព មានប៉ុន្មាន ។ វិនីតវត្ថុ មានប៉ុន្មាន ។ វិបត្តិមានប៉ុន្មាន ។ សមុដ្ឋាននៃអាបត្តិ មានប៉ុន្មាន ។ មូលនៃវិវាទ មានប៉ុន្មាន ។ មូលនៃអនុវាទ មានប៉ុន្មាន ។ សារាណីយធម៌ មានប៉ុន្មាន ។ ភេទករវត្ថុ (រឿងដែលធ្វើឲ្យបែកគ្នា) មានប៉ុន្មាន ។ អធិករណ៍ មានប៉ុន្មាន ។ សមថៈ មានប៉ុន្មាន ។

[៨៤២] ឆ្លើយថា អាបត្តិមាន ៥ ។ កង៏នៃអាបត្តិមាន ៥ ។ វិនីវត្ថុមាន ៥ ។ អាបត្តិមាន ៧ ។ កង៏នៃអាបត្តិមាន ៧ ។ វិនីតវត្ថុមាន ៧ ។ សេចក្តីមិនគោរពមាន ៦ ។ សេចក្តីគោរពមាន ៦ ។ វិនីតវត្ថុមាន ៦ ។ វិបត្តិមាន ៤ ។ សមុដ្ឋាននៃអាបត្តិមាន ៦ ។ មូលនៃវិវាទមាន ៦ ។ មូលនៃអនុវាទ

ឆ សារាណីយា ធម្មា ។ អដ្ឋារស ភេទករវត្ថូនិ ។ ចត្តារិ អធិករណានិ ។ សត្ត សមថា ។

[៨៤៣] តត្ថ កតមា បញ្ច អាបត្តិយោ ។ បារាជិកាបត្តិ សង្ឃាទិសេសាបត្តិ បាចិត្តិយាបត្តិ បដិទេសនីយាបត្តិ ទុក្កដាបត្តិ ។ ឥមា បញ្ច អាបត្តិយោ ។

[៨៤៤] តត្ថ កតមេ បញ្ច អាបត្តិក្ខន្ធា ។ បារាជិកាបត្តិក្ខន្ធោ សង្ឃាទិសេសាបត្តិក្ខន្ធោ បាចិត្តិយាបត្តិក្ខន្ធោ បាដិទេសនីយាបត្តិក្ខន្ធោ ទុក្កដាបត្តិក្ខន្ធោ ។ ឥមេ បញ្ច អាបត្តិក្ខន្ធា ។

[៨៤៥] តត្ថ កតមានិ បញ្ច វិនីតវត្ថូនិ ។ បញ្ចហិ អាបត្តិក្ខន្ធេហិ អារតិ វិរតិ បដិវិរតិ វេរមណី អកិរិយា អករណំ អនជ្ឈាបត្តិ វេលាអនតិក្កមោ សេតុឃាតោ ។ ឥមានិ បញ្ច វិនីតវត្ថូនិ ។

មាន ៦ ។ សាកណីយធម៌មាន ៦ ។ ភេទករវត្ថុមាន ១៨ ។ អធិករណ៍មាន ៤ ។ សមថៈមាន ៧ ។

[៨៤៣] អាបត្តិ ៥ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ ។ (អាបត្តិ៥) គឺអាបត្តិបារាជិក ១ អាបត្តិសង្ឃាទិសេស ១ អាបត្តិបាចិត្តិយៈ ១ អាបត្តិបាដិទេសនីយៈ ១ អាបត្តិទុក្កដ ១ ។ នេះ ជាអាបត្តិ ៥ ។

[៨៤៤] កងនៃអាបត្តិទាំង ៥ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ ។ (កងនៃអាបត្តិ ៥) គឺកងនៃអាបត្តិបារាជិក ១ កងនៃអាបត្តិសង្ឃា-ទិសេស ១ កងនៃអាបត្តិបាចិត្តិយៈ ១ កងនៃអាបត្តិបាដិទេសនីយៈ ១ កងនៃអាបត្តិទុក្កដ ១ ។ នេះ ជាកងនៃអាបត្តិ ៥ ។

[៨៤៥] វិនីតវត្ថុមាន ៥ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ ។ (វិនីតវត្ថុ ៥) គឺកិរិយាវៀរឲ្យឆ្ងាយ វៀរឲ្យស្រឡះ វៀរចំពោះ ចៀសវាងចាកកងនៃអាបត្តិទាំង ៥ គឺថា កិរិយាមិនធ្វើ មិនបង្កើត (នូវកងអាបត្តិ) មិនឲ្យត្រូវអាបត្តិ មិនកន្លងនូវដែន (នៃអាបត្តិ) សម្ងាប់បង់នូវកងនៃអាបត្តិ ។ នេះ ជាវិនីតវត្ថុ ៥ ។

កតិបុច្ឆាវារំ សត្ត អាបត្តិយោ សត្ត វិនីតវត្ថូនិ

[៨៤៦] តត្ថ កតមា សត្ត អាបត្តិយោ ។ បារាជិកាបត្តិ សង្ឃាទិសេសាបត្តិ ថុល្លច្ចយាបត្តិ បាចិត្តិយាបត្តិ បាដិទេសនីយាបត្តិ ទុក្កដាបត្តិ ទុព្ភាសិតាបត្តិ ។ ឥមា សត្ត អាបត្តិយោ ។

[៨៤៧] តត្ថ កតមេ សត្ត អាបត្តិក្ខន្ធា ។ បារាជិកាបត្តិក្ខន្ធោ សង្ឃាទិសេសាបត្តិក្ខន្ធោ ថុល្លច្ចយាបត្តិក្ខន្ធោ បាចិត្តិយាបត្តិក្ខន្ធោ បាដិទេសនីយាបត្តិក្ខន្ធោ ទុក្កដាបត្តិក្ខន្ធោ ទុព្ភាសិតាបត្តិក្ខន្ធោ ។ ឥមេ សត្ត អាបត្តិក្ខន្ធា ។

[៨៤៨] តត្ថ កតមានិ សត្ត វិនីតវត្ថូនិ ។ សត្តហិ អាបត្តិក្ខន្ធេហិ អារតិ វិរតិ បដិវិរតិ វេរមណី អកិរិយា អករណំ អនជ្ឈាបត្តិ វេលាអនតិក្កមោ សេតុឃាតោ ។ ឥមានិ សត្ត វិនីតវត្ថូនិ ។

កតិបុច្ឆាវារៈ អាបត្តិ ៧ វិនីតវត្ថុ ៨

[៨៤៦] អាបត្តិ ៧ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ ។ អាបត្តិ ៧ គឺអាបត្តិបារាជិក ១ អាបត្តិសង្ឃាទិសេស ១ អាបត្តិថុល្លច្ច័យ ១ អាបត្តិបាចិត្តិយៈ ១ អាបត្តិបាដិទេសនីយៈ ១ អាបត្តិទុក្កដ ១ អាបត្តិទុព្ភាសិត ១ ។ នេះ ជាអាបត្តិ ៧ ។

[៨៤៧] កងនៃអាបត្តិ ៧ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ ។ (កងនៃអាបត្តិ ៧) គឺកងនៃអាបត្តិបារាជិក ១ កងនៃអាបត្តិសង្ឃាទិ-សេស ១ កងនៃអាបត្តិថុល្លច្ច័យ ១ កងនៃអាបត្តិបាចិត្តិយៈ ១ កងនៃអាបត្តិបាដិទេសនីយៈ ១ កងនៃអាបត្តិទុក្កដ ១ កងនៃអាបត្តិទុព្ភាសិត ១ ។ នេះ ជាកងនៃអាបត្តិ ៧ ។

[៨៤៨] វិនីតវត្ថុ មាន ៧ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ ។ (វិនីតវត្ថុមាន ៧) គឺកិរិយាវៀរឲ្យឆ្ងាយ វៀរឲ្យស្រឡះ វៀរចំពោះ ចៀសវាងចាកកងនៃអាបត្តិទាំង ៧ គឺជាកិរិយាមិនធ្វើ មិនបង្កើត (នូវកងនៃអាបត្តិ) មិនឲ្យត្រូវអាបត្តិ មិនកន្លងនូវដែន (នៃអាបត្តិ) សម្រាប់បង់នូវកងនៃអាបត្តិ ។ នេះ ជាវិនីតវត្ថុ ៧ ។

[៨៤៩] តត្ថ កតមេ ឆ អគារវា ។ ពុទ្ធេ អគារវោ ធម្មេ អគារវោ សង្ឃេ អគារវោ សិក្ខាយ អគារវោ អប្បមាទេ អគារវោ បដិសន្ថារេ អគារវោ ។ ឥមេ ឆ អគារវា ។

[៨៥០] តត្ថ កតមេ ឆ គារវា ។ ពុទ្ធេ គារវោ ធម្មេ គារវោ សង្ឃេ គារវោ សិក្ខាយ គារវោ អប្បមាទេ គារវោ បដិសន្ថារេ គារវោ ។ ឥមេ ឆ គារវា ។

[៨៥១] តត្ថ កតមានិ ឆ វិនីតវត្ថូនិ ។ ឆហិ អគារវេហិ អារតិ វិរតិ បដិវិរតិ វេរមណី អកិរិយា អករណំ អនជ្ឈាបត្តិ វេលាអនតិក្កមោ សេតុឃាតោ ។ ឥមានិ ឆ វិនីតវត្ថូនិ ។

[៨៤៩] សេចក្តីមិនគោរព ៦ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ ។ (សេចក្តីមិនគោរព ៦) គឺ ការមិនគោរពព្រះពុទ្ធ ១ មិនគោរពព្រះធម៌ ១ មិនគោរពព្រះសង្ឃ ១ មិនគោរពសិក្ខា ១ មិនគោរពសេចក្តីមិនប្រមាទ ១ មិនគោរពការបដិសន្ថារៈ ១ ។ នេះ ជាសេចក្តីមិនគោរព ៦ ។

[៨៥០] សេចក្តីគោរព ៦ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ ។ (សេចក្តីគោរព ៦) គឺការគោរពព្រះពុទ្ធ ១ គោរពព្រះធម៌ ១ គោរពព្រះសង្ឃ ១ គោរពសិក្ខា ១ គោរពសេចក្តីមិនប្រមាទ ១ គោរពក្នុងការបដិសន្ថារៈ ១ ។ នេះ ជាសេចក្តីគោរព ៦ យ៉ាង ។

[៨៥១] វិនីតវត្ថុ ៦ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ ។ (វិនីតវត្ថុ ៦) គឺកិរិយាវៀរឲ្យឆ្ងាយ វៀរឲ្យស្រឡះ វៀរចំពោះ ចៀសវាងចាកសេចក្តីមិនគោរពទាំង ៦ គឺថា កិរិយាមិនធ្វើ មិនបង្កើត (នូវសេចក្តីមិនគោរព) មិនឲ្យត្រូវ មិនកន្លងដែន (នៃសេចក្តីមិនគោរព) សម្រាប់បង់នូវអគារវៈ ។ នេះ ជាវិនីតវត្ថុ ៦ ។

### កតិបុច្ឆាវារំ ចតស្សោ វិបត្តិយោ ឆ អាបត្តិសមុដ្ឋានា

[៨៤២] តត្ថ កតមា ចតស្សោ វិបត្តិយោ ។ សីលវិបត្តិ អាចារវិបត្តិ ទិដ្ឋិវិបត្តិ អាជីវវិបត្តិ ។ ឥមា ចតស្សោ វិបត្តិយោ ។

[៨៤៣] តត្ថ កតមេ ឆ អាបត្តិសមុដ្ឋានា ។ អត្ថាបត្តិ កាយតោ សមុដ្ឋាតិ ន វាចតោ ន ចិត្តតោ អត្ថាបត្តិ វាចតោ សមុដ្ឋាតិ ន កាយតោ ន ចិត្តតោ អត្ថាបត្តិ កាយតោ ច វាចតោ ច សមុដ្ឋាតិ ន ចិត្តតោ អត្ថាបត្តិ កាយតោ ច ចិត្តតោ ច សមុដ្ឋាតិ ន វាចតោ អត្ថាបត្តិ វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ន កាយតោ អត្ថាបត្តិ កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ ឥមេ ឆ អាបត្តិសមុដ្ឋានា ។

[៨៤៤] តត្ថ កតមានិ ឆ វិវាទមូលានិ ។ ឥធ ភិក្ខុ កោធនោ ហោតិ ឧបនាហី យោ សោ ភិក្ខុ កោធនោ ហោតិ ឧបនាហី សោ សត្ថរិបិ អគារវោ វិហរតិ អប្បដិស្សោ ធម្មេបិ អគារវោ វិហរតិ អប្បដិស្សោ សង្ឃេបិ អគារវោ វិហរតិ អប្បដិស្សោ សិក្ខាយបិ ន បរិបូរការី ហោតិ ។ យោ សោ ភិក្ខុ

## កតិបុច្ឆាវារៈ វិបត្តិ ៤ សមុដ្ឋាននៃអាបត្តិ ៦

[៨៥២] វិបត្តិ ៤ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ ។ វិបត្តិ ៤ គឺ សីលវិបត្តិ ១ អាចារវិបត្តិ ១ ទិដ្ឋិវិបត្តិ ១ អាជីវវិបត្តិ ១ ។ នេះ ជាវិបត្តិ ៤ ។

[៨៥៣] សមុដ្ឋាននៃអាបត្តិ ៦ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ ។ (សមុដ្ឋាននៃអាបត្តិ ៦) គឺអាបត្តិកើតឡើងអំពីកាយ មិនកើតឡើងអំពីវាចា មិនកើតឡើងអំពីចិត្ត ១ អាបត្តិកើតឡើងអំពីវាចា មិនកើតឡើងអំពីកាយ មិនកើតឡើងអំពីចិត្ត ១ អាបត្តិកើតឡើងអំពីកាយផង អំពីវាចាផង មិនកើតឡើងអំពីចិត្ត ១ អាបត្តិកើតឡើងអំពីកាយផង អំពីចិត្តផង មិនកើតឡើងអំពីវាចា ១ អាបត្តិកើតឡើងអំពីវាចាផង អំពីចិត្តផង មិនកើតឡើងអំពីកាយ ១ អាបត្តិកើតឡើងអំពីកាយផង អំពីវាចាផង អំពីចិត្តផង ១ ។ នេះ ជាសមុដ្ឋាននៃអាបត្តិទាំង ៦ ។

[៨៥៤] មូលនៃវិវាទ ៦ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ ។ (មូលនៃវិវាទទាំង ៦) គឺភិក្ខុក្នុងសាសនានេះ ជាអ្នកក្រោធ ចងនូវសេចក្តីក្រោធទុក ភិក្ខុណា ជាអ្នកក្រោធ ចងនូវសេចក្តីក្រោធទុក ភិក្ខុនោះឈ្មោះថា មិនគោរព មិនឱនលំទោន ក្នុងព្រះសាស្តាផង មិនគោរព មិនឱនលំទោន ក្នុងព្រះធម៌ផង មិនគោរព មិនឱនលំទោនក្នុងព្រះសង្ឃផង មិនធ្វើឲ្យបរិបូណ៌ក្នុងសិក្ខាផង ។ ភិក្ខុណា

សត្ថរិបិ អគារវោ វិហរតិ អប្បដិស្សោ ធម្មេបិ ។ បេ ។ សង្ឃេបិ ។ បេ ។ សិក្ខាយបិ ន បរិបូរការី ហោតិ សោ សង្ឃេ វិវាទំ ជនេតិ ។ យោ សោ ហោតិ វិវាទោ ពហុជនាហិតាយ ពហុជនាសុខាយ ពហុនោ ជ-នស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានំ ។ ឯវរូបញ្ចេ តុម្ហេ វិវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា ស-មនុបស្សេយ្យាថ តត្ថ តុម្ហេ តស្សេវ បាបកស្ស វិវាទ-មូលស្ស បហានាយ វាយមេយ្យាថ ឯវរូបញ្ចេ តុម្ហេ វិវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា ន សមនុបស្សេ-យ្យាថ តត្រ តុម្ហេ តស្សេវ បាបកស្ស វិវាទមូលស្ស អាយតឹ អនវស្សវាយ បដិបជ្ជេយ្យាថ ។ ឯវមេតស្ស បាបកស្ស វិវាទមូលស្ស បហានំ ហោតិ ឯវមេតស្ស

មិនគោរព មិនឱនលំទោនក្នុងព្រះសាស្តាផង ក្នុងព្រះធម៌ផង ។ បេ ។ ក្នុងព្រះសង្ឃផង ។ បេ ។ មិនធ្វើឲ្យបរិបូណ៌ក្នុងសិក្ខាផង ភិក្ខុនោះឈ្មោះថា ជាអ្នកញុំាងវិវាទឲ្យកើតឡើងក្នុងសង្ឃ ។ វិវាទណា ប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន ដើម្បីសេចក្តីមិនចម្រើនដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដល់ទេវតានិងមនុស្សទាំងឡាយ ។ បើអ្នកទាំងឡាយ ពិចារណាឃើញនូវមូលនៃវិវាទមានសភាពយ៉ាងនេះ ក្នុងសន្តាននៃខ្លួន ឬក្នុងបរិស័ទនៃខ្លួនក្តី ក្នុងសន្តាននៃបុគ្គលដទៃ ឬក្នុងបរិស័ទនៃបុគ្គលដទៃក្តី អ្នកទាំងឡាយ ត្រូវព្យាយាមលះបង់ នូវមូលនៃវិវាទដ៏លាមកនោះឯងក្នុងសន្តាននៃខ្លួន និងសន្តាននៃបុគ្គលដទៃ ក្នុងបរិស័ទនៃខ្លួន ឬក្នុងបរិស័ទនៃបុគ្គលដទៃនោះចេញ បើអ្នកទាំងឡាយ មិនបានពិចារណាឃើញនូវមូលនៃវិវាទមានសភាពយ៉ាងនេះ ក្នុងសន្តាននៃខ្លួន ឬក្នុងបរិស័ទនៃខ្លួនក្តី ក្នុងសន្តានបុគ្គលដទៃ ឬក្នុងបរិស័ទនៃបុគ្គលដទៃក្តី អ្នកទាំងឡាយ ត្រូវប្រតិបត្តិ ដើម្បីកុំឲ្យមូលនៃវិវាទដ៏លាមកនោះឯងប្រព្រឹត្តទៅក្នុងអនាគតទៀតបាន ក្នុងសន្តាននៃខ្លួន និងសន្តាននៃបុគ្គលដទៃ ក្នុងបរិស័ទនៃខ្លួននិងបរិស័ទនៃបុគ្គលដទៃនោះ ។ ការលះបង់នូវមូលនៃវិវាទដ៏លាមកនោះ រមែងមានដោយប្រការយ៉ាងនេះ ការ

ចាបកស្ស វិវាទមូលស្ស អាយតឹ អនវស្សវាយ ហោតិ ។ បុន ចបរំ ភិក្ខុ មក្ខី ហោតិ បលាសី ។ បេ ។ ឥស្សុកី ហោតិ មច្ឆរី សឋោ ហោតិ មាយាវី ចាបិច្ឆោ ហោតិ មិច្ឆាទិដ្ឋិ សន្ទិដ្ឋិបរាមាសី ហោតិ អាធានគ្គាហី ទុប្បដិនិស្សគ្គី យោ សោ ភិក្ខុ សន្ទិដ្ឋិបរាមាសី ហោតិ អាធានគ្គាហី ទុប្បដិនិស្សគ្គី សោ សត្ថរិបិ អគារវោ វិហរតិ អប្បដិស្សោ ធម្មេបិ អគារវោ វិហរតិ អប្បដិស្សោ សង្ឃេបិ អគារវោ វិហរតិ អប្បដិស្សោ សិក្ខាយបិ ន បរិបូរិការី ហោតិ ។ យោ សោ ភិក្ខុ សត្ថរិបិ អគារវោ វិហរតិ អប្បដិ-ស្សោ ធម្មេបិ ។ បេ ។ សង្ឃេបិ ។ បេ ។ សិក្ខាយបិ ន បរិបូរិការី ហោតិ សោ សង្ឃេ វិវាទំ ជនេតិ ។ យោ សោ ហោតិ វិវាទោ ពហុជនាហិតាយ ពហុ-ជនាសុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានំ ។ ឯវរូបញ្ចេ តុម្ហេ វិវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា សមនុបស្សេយ្យាថ តត្រ

ដែលមិនឲ្យមូលនៃវិវាទដ៏លាមកនោះ ប្រព្រឹត្តទៅក្នុងអនាគតទៀត រមែងមានដោយប្រការយ៉ាងនេះ ។ ពាក្យខាងមុខនៅមានទៀត ភិក្ខុជាអ្នកលុបគុណគេ ជាអ្នកលើកខ្លួន (ប្រណាំងវាសនា) ។ បេ ។ ជាអ្នកប្រណែន ជាអ្នកកំណាញ់ ជាអ្នកអួតអាង លាក់ពុត ជាអ្នកមានសេចក្តីប្រាថ្នាលាមក មានទិដ្ឋិអាក្រក់ ជាអ្នកប្រកាន់តាមសេចក្តីយល់របស់ខ្លួន ទាំងប្រកាន់មាំ លះបង់បានដោយកម្រ ភិក្ខុណា ជាអ្នកប្រកាន់តាមសេចក្តីយល់របស់ខ្លួន ទាំងប្រកាន់មាំ លះបង់បានដោយកម្រ ភិក្ខុនោះឈ្មោះថា មិនគោរព មិនឱនលំទោន ក្នុងព្រះសាស្តាផង មិនគោរព មិនឱនលំទោនក្នុងព្រះធម៌ផង មិនគោរព មិនឱនលំទោន ក្នុងព្រះសង្ឃផង មិនធ្វើឲ្យបរិបូណ៌ក្នុងសិក្ខាផង ។ ភិក្ខុណា មិនគោរព មិនឱនលំទោន ក្នុងព្រះសាស្តាផង ក្នុងព្រះធម៌ផង ។ បេ ។ ក្នុងព្រះសង្ឃផង ។ បេ ។ មិនធ្វើឲ្យបរិបូណ៌ក្នុងសិក្ខាផង ភិក្ខុនោះឈ្មោះថា ញុំាងវិវាទឲ្យកើតឡើងក្នុងសង្ឃ ។ វិវាទណា ប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន ដើម្បីសេចក្តីមិនចំរើនដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដល់ទេវតានិងមនុស្សទាំងឡាយ ។ បើអ្នកទាំងឡាយ ពិចារណាឃើញនូវមូលនៃវិវាទមានសភាពយ៉ាងនេះ ក្នុងសន្តាននៃខ្លួន ឬក្នុងបរិស័ទនៃខ្លួនក្តី ក្នុងសន្តាននៃបុគ្គលដទៃ

តុម្ហេ តស្សេវ បាបកស្ស វិវាទមូលស្ស បហានាយ វាយមេយ្យាថ ឯវរូបញ្ចេ តុម្ហេ វិវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា ន សមនុបស្សេយ្យាថ តត្រ តុម្ហេ តស្សេវ បាបកស្ស វិវាទមូលស្ស អាយតឹ អនវស្ស-វាយ បដិបជ្ជេយ្យាថ ។ ឯវមេតស្ស បាបកស្ស វិវាទមូលស្ស បហានំ ហោតិ ឯវមេតស្ស បាបកស្ស វិវាទមូលស្ស អាយតឹ អនវស្សវោ ហោតិ ។ ឥមានិ ឆ វិវាទមូលានិ ។

[៨៥៥] តត្ថ កតមានិ ឆ អនុវាទមូលានិ ។ ឥធ ភិក្ខុ កោធនោ ហោតិ ឧបនាហី យោ សោ ភិក្ខុ កោធនោ ហោតិ ឧបនាហី សោ សត្ថរិបិ អគា-រវោ វិហរតិ អប្បដិស្សោ ធម្មេបិ អគារវោ វិហរតិ អប្ប-ដិស្សោ សង្ឃេបិ អគារវោ វិហរតិ អប្បដិស្សោ សិក្ខា-យបិ ន បរិបូរិការី ហោតិ ។ យោ សោ ភិក្ខុ សត្ថរិបិ

ឬក្នុងបរិស័ទនៃបុគ្គលដទៃក្តី អ្នកទាំងឡាយ ត្រូវព្យាយាមលះបង់នូវមូលនៃវិវាទដ៏លាមកនោះឯង ក្នុងសន្តាននៃខ្លួននិងសន្តាននៃបុគ្គលដទៃ ក្នុងបរិស័ទនៃខ្លួននិងបរិស័ទនៃបុគ្គលដទៃនោះចេញ បើអ្នកទាំងឡាយមិនបានពិចារណាឃើញនូវមូលនៃវិវាទមានសភាពយ៉ាងនេះ ក្នុងសន្តាននៃខ្លួន ឬក្នុងបរិស័ទនៃខ្លួនក្តី ក្នុងសន្តាននៃបុគ្គលដទៃ ឬ ក្នុងបរិស័ទនៃបុគ្គលដទៃក្តី អ្នកទាំងឡាយ ត្រូវប្រតិបត្តិ ដើម្បីកុំឲ្យមូលនៃវិវាទដ៏លាមកនោះឯងប្រព្រឹត្តតទៅក្នុងអនាគតទៀតបាន ក្នុងសន្តាននៃខ្លួននិងសន្តាននៃបុគ្គលដទៃ ក្នុងបរិស័ទនៃខ្លួននិងបរិស័ទនៃបុគ្គលដទៃនោះ ។ ការលះបង់នូវមូលនៃវិវាទដ៏លាមកនុ៎ះ រមែងមានដោយប្រការយ៉ាងនេះ ការដែលមិនឲ្យមូលនៃវិវាទដ៏លាមកនុ៎ះ ប្រព្រឹត្តទៅក្នុងអនាគតទៀតបាន រមែងបានដោយប្រការយ៉ាងនេះ ។ នេះ ជាមូលនៃវិវាទ ៦ ។

[៨៥៥] មូលនៃអនុវាទ ៦ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ ។ (មូលនៃអនុវាទ ៦ គឺ) ភិក្ខុក្នុងសាសនានេះ ជាអ្នកក្រោធ ចងនូវសេចក្តីក្រោធទុក ភិក្ខុណា ជាអ្នកក្រោធ ចងនូវសេចក្តីក្រោធទុក ភិក្ខុនោះឈ្មោះថា មិនគោរព មិនឱនលំទោន ក្នុងព្រះសាស្តាផង មិនគោរព មិនឱនលំទោន ក្នុងព្រះធម៌ផង មិនគោរព មិនឱនលំទោនក្នុងព្រះសង្ឃផង មិនធ្វើឲ្យបរិបូណ៌ក្នុងសិក្ខាផង ។ ភិក្ខុណា

៣៧១



អគារវោ វិហរតិ អប្បដិស្សោ ធម្មេបិ ។ បេ ។ សង្ឃេបិ ។ បេ ។ សិក្ខាយបិ ន បរិបូរការី ហោតិ សោ សង្ឃេ អនុវាទំ ជនេតិ ។ យោ សោ ហោតិ អនុវាទោ ពហុជនាហិតាយ ពហុជនាសុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានំ ។ ឯវរូបញ្ចេ តុម្ហេ អនុវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា សមនុបស្សេយ្យាថ តត្រ តុម្ហេ តស្សេវ បាបកស្ស អនុវាទមូលស្ស បហានាយ វាយមេយ្យាថ ឯវរូបញ្ចេ តុម្ហេ អនុវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា ន សមនុបស្សេយ្យាថ តត្រ តុម្ហេ តស្សេវ បាបកស្ស អនុវាទមូលស្ស អាយតឹ អនវស្សវាយ បដិបជ្ជេយ្យាថ ។ ឯវមេតស្ស បាបកស្ស អនុវាទមូលស្ស បហានំ ហោតិ ឯវមេតស្ស បាបកស្ស

ជាអ្នកមិនគោរព មិនឱនលំទោនក្នុងព្រះសាស្តាផង ក្នុងព្រះធម៌ផង ។ បេ ។ ក្នុងព្រះសង្ឃផង ។ បេ ។ មិនធ្វើឲ្យបរិបូណ៌ក្នុងសិក្ខាផង ភិក្ខុនោះឈ្មោះថា ញុំាំងអនុវាទឲ្យកើតឡើងក្នុងសង្ឃ ។ អនុវាទណា ប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន ដើម្បីមិនមែនជាសេចក្តីចំរើនដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខដល់ទេវតានិងមនុស្សទាំងឡាយ ។ បើអ្នកទាំងឡាយ ពិចារណានូវមូលនៃអនុវាទមានសភាពយ៉ាងនេះ ក្នុងសន្តាននៃខ្លួន ក្នុងបរិស័ទនៃខ្លួនក្តី ក្នុងសន្តាននៃបុគ្គលដទៃ ឬក្នុងបរិស័ទនៃបុគ្គលដទៃក្តី អ្នកទាំងឡាយ ត្រូវព្យាយាមដើម្បីលះបង់នូវមូលនៃអនុ-វាទដ៏លាមកនោះឯង ក្នុងសន្តាននៃខ្លួន និងសន្តាននៃបុគ្គលដទៃ ក្នុងបរិស័ទនៃខ្លួន និងបរិស័ទនៃបុគ្គលដទៃនោះចេញ បើអ្នកទាំងឡាយមិនពិចារណាឃើញនូវមូលនៃអនុវាទមានសភាពយ៉ាងនេះ ក្នុងសន្តាននៃខ្លួន ឬក្នុងបរិស័ទនៃខ្លួនក្តី ក្នុងសន្តាននៃបុគ្គលដទៃ ឬក្នុងបរិស័ទនៃបុគ្គលដទៃក្តី អ្នកទាំងឡាយ ត្រូវប្រតិបត្តិដើម្បីកុំឲ្យមូលនៃអនុវាទដ៏លាមកនោះឯង ប្រព្រឹត្តទៅក្នុងអនាគតទៀតបាន ក្នុងសន្តាននៃខ្លួននិងសន្តាននៃបុគ្គលដទៃ ក្នុងបរិស័ទនៃខ្លួននិងបរិស័ទនៃបុគ្គលដទៃនោះ ។ ការលះ-បង់នូវមូលនៃអនុវាទដ៏លាមកនុ៎ះ រមែងមានដោយប្រការយ៉ាងនេះ ការ

អនុវាទមូលស្ស អាយតឹ អនវស្សវោ ហោតិ ។ បុន
ចបរំ ភិក្ខុ មក្ខី ហោតិ បឡាសី ។ បេ ។ ឥស្សុកី
ហោតិ មច្ឆរី សឋោ ហោតិ មាយាវី បាបិច្ឆោ ហោតិ
មិច្ឆាទិដ្ឋិ សន្ទិដ្ឋិបរាមាសី ហោតិ អាធានគ្គាហី ទុប្ប-
ដិនិស្សគ្គី ។ យោ សោ ភិក្ខុ សន្ទិដ្ឋិបរាមាសី ហោតិ
អាធានគ្គាហី ទុប្បដិនិស្សគ្គី សោ សត្ថរិបិ អគារវោ
វិហរតិ អប្បដិស្សោ ធម្មេបិ អគារវោ វិហរតិ អប្បដិស្សោ
សង្ឃេបិ អគារវោ វិហរតិ អប្បដិស្សោ សិក្ខាយបិ ន
បរិបូរការី ហោតិ ។ យោ សោ ភិក្ខុ សត្ថរិបិ អគា-
រវោ វិហរតិ អប្បដិស្សោ ធម្មេបិ ។ បេ ។ សង្ឃេបិ
។ បេ ។ សិក្ខាយបិ ន បរិបូរការី ហោតិ សោ សង្ឃេ
អនុវាទំ ជនេតិ ។ យោ សោ ហោតិ អនុវាទោ ពហុជ-
នាហិតាយ ពហុជនាសុខាយ ពហុនោ ជនស្ស អនត្ថា-
យ អហិតាយ ទុក្ខាយ ទេវមនុស្សានំ ។ ឯវរូបញ្ចេ

ដែលមិនឲ្យមូលនៃអនុវាទដ៏លាមកនោះ ប្រព្រឹត្តទៅក្នុងអនាគតទៀតបាន រមែងមានដោយប្រការយ៉ាងនេះ ។ មានពាក្យតទៅទៀតថា ភិក្ខុជាអ្នកលុបគុណគេ ជាអ្នកលើកខ្លួន ។ បេ ។ ជាអ្នកច្រណែន ជាអ្នកកំណាញ់ ជាអ្នកអួតអាង ជាអ្នកលាក់ពុត ជាអ្នកមានប្រាថ្នាលាមក មានទិដ្ឋិអាក្រក់ ជាអ្នកប្រកាន់តាមសេចក្តីយល់របស់ខ្លួន និងប្រកាន់មាំ លះបង់បានដោយកម្រ ។ ភិក្ខុណា ដែលប្រកាន់តាមសេចក្តីយល់ របស់ខ្លួន ប្រកាន់មាំ លះបង់បានដោយកម្រ ភិក្ខុនោះឈ្មោះថា មិនគោរព មិនឱនលំទោនក្នុងព្រះសាស្តាផង មិនគោរព មិនឱនលំទោន ក្នុងព្រះធម៌ផង មិនគោរព មិនឱនលំទោនក្នុងព្រះសង្ឃផង មិនធ្វើឲ្យបរិបូណ៌ក្នុងសិក្ខាផង ។ បេ ។ ភិក្ខុណា មិនគោរព មិនឱនលំទោនក្នុងព្រះសាស្តាផង ក្នុងព្រះធម៌ផង ។ បេ ។ ក្នុងព្រះសង្ឃផង ។ បេ ។ មិនធ្វើឲ្យបរិបូណ៌ក្នុងសិក្ខាផង ភិក្ខុនោះឈ្មោះថា ញ៉ាំងអនុវាទឲ្យកើតឡើងក្នុងសង្ឃ ។ អនុវាទណា ប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន ដើម្បីមិនចំរើនដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដល់ទេវតានិងមនុស្សទាំងឡាយ ។ បើអ្នកទាំងឡាយ

តុម្ហេ អនុវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា សមនុបស្សេយ្យាថ តត្រ តុម្ហេ តស្សេវ បាបកស្ស អនុវាទមូលស្ស បហានាយ វាយមេយ្យាថ ឯវរូបញ្ចេ តុម្ហេ អនុវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា ន សមនុបស្សេយ្យាថ តត្រ តុម្ហេ តស្សេវ បាបកស្ស អនុវាទមូលស្ស អាយតឹ អនវស្សវាយ បដិបជ្ជេយ្យាថ ។ ឯវមេតស្ស បាបកស្ស អនុវាទមូលស្ស បហានំ ហោតិ ឯវមេតស្ស បាបកស្ស អនុវាទមូលស្ស អាយតឹ អនវស្សវោ ហោតិ ។ ឥមានិ ឆ អនុវាទមូលានិ ។

[៨៤៦] តត្ថ កតមេ ឆ សារាណីយា ធម្មា ។ ឥធ ភិក្ខុនោ មេត្តំ កាយកម្មំ បច្ចុបដ្ឋិតំ ហោតិ សព្រហ្មចារីសុ អាវិ ចេវ រហោ ច អយម្បិ ធម្មោ

ពិចារណាឃើញ នូវមូលនៃអនុវាទមានសភាពយ៉ាងនេះ ក្នុងសន្តាននៃខ្លួន ឬក្នុងបរិស័ទនៃខ្លួនក្តី ក្នុងសន្តាននៃបុគ្គលដទៃ ឬក្នុងបរិស័ទនៃបុគ្គលដទៃក្តី អ្នកទាំងឡាយ ត្រូវព្យាយាមលះបង់នូវមូលនៃអនុវាទដ៏លាមកនោះឯង ក្នុងសន្តាននៃខ្លួន និងសន្តាននៃបុគ្គលដទៃ ក្នុងបរិស័ទនៃខ្លួននិងបរិស័ទនៃបុគ្គលដទៃនោះចេញ បើអ្នកទាំងឡាយ មិនពិចារណាឃើញ នូវមូលនៃអនុវាទមានសភាពយ៉ាងនេះ ក្នុងសន្តាននៃខ្លួន ឬក្នុងបរិស័ទនៃខ្លួនក្តី ក្នុងសន្តាននៃបុគ្គលដទៃ ឬក្នុងបរិស័ទនៃបុគ្គលដទៃក្តី អ្នកទាំងឡាយត្រូវប្រតិបត្តិ ដើម្បីកុំឲ្យមូលនៃអនុវាទដ៏លាមកនោះឯង ប្រព្រឹត្តទៅក្នុងអនាគតបាន ក្នុងសន្តាននៃខ្លួននិងសន្តាននៃបុគ្គលដទៃ ក្នុងបរិស័ទនៃខ្លួននិងបរិស័ទនៃបុគ្គលដទៃនោះ ។ ការលះបង់នូវមូលនៃអនុវាទដ៏លាមកនុ៎ះ រមែងមានដោយប្រការយ៉ាងនេះ ការដែលមិនឲ្យមូលនៃអនុវាទដ៏លាមកនុ៎ះ ប្រព្រឹត្តទៅក្នុងអនាគតបាន រមែងមានដោយប្រការយ៉ាងនេះ ។ នេះ ជាមូលនៃអនុវាទ ៦ យ៉ាង ។

[៨៥៦] សារាណីយធម៌ ៦ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ ។ (សារាណីយធម៌ ៦ គឺ) ភិក្ខុក្នុងសាសនានេះ បានតាំងកាយកម្មប្រកបដោយមេត្តា ក្នុងពួកសព្រហ្មចារីបុគ្គល ទាំងក្នុងទីចំពោះមុខទាំងក្នុងទីកំបាំងមុខ ធម៌នេះឯង ឈ្មោះថា ជាធម៌ដែលបុគ្គលគប្បីរលឹក

សារាណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខុនោ មេត្តំ វចីកម្មំ បច្ចុបដ្ឋិតំ ហោតិ ស-ព្រហ្មចារីសុ អាវិ ចេវ រហោ ច អយម្បិ ធម្មោ សារាណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខុនោ មេត្តំ មនោកម្មំ បច្ចុបដ្ឋិតំ ហោតិ សព្រហ្មចារីសុ អាវិ ចេវ រហោ ច អយម្បិ ធម្មោ សារាណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខុ យេ តេ លាភា ធម្មិកា ធម្មលទ្ធា អន្តមសោ បត្តបរិយាបន្នមត្តម្បិ តថារូបេហិ លាភេហិ អប្បដិវិ-ភត្តភោគី ហោតិ សីលវន្តេហិ សព្រហ្មចារីហិ សាធា-

ឈ្មោះថា ធ្វើនូវសេចក្ដីស្រឡាញ់ ឈ្មោះថា ធ្វើនូវសេចក្ដីគោរព ដល់សព្រហ្មចារីបុគ្គល ប្រព្រឹត្តទៅដើម្បីសេចក្ដីសង្គ្រោះ ដើម្បីមិនវិវាទ ដើម្បីព្រមព្រៀង ដើម្បីសេចក្ដីស្ងប់ស្ងាត់ ។ មានពាក្យតទៅទៀតថា ភិក្ខុ (ក្នុងសាសនានេះ) បានតាំងវចីកម្មប្រកបដោយមេត្តា ក្នុងពួកសព្រហ្មចារីបុគ្គល ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ ធម៌នេះឯង ឈ្មោះថា ជាធម៌ដែលបុគ្គលគប្បីរលឹក ឈ្មោះថា ធ្វើនូវសេចក្ដីស្រឡាញ់ ឈ្មោះថា ធ្វើនូវសេចក្ដីគោរពដល់សព្រហ្មចារីបុគ្គល ប្រព្រឹត្តទៅដើម្បីសេចក្ដីសង្គ្រោះ ដើម្បីសេចក្ដីមិនវិវាទ ដើម្បីព្រមព្រៀង ដើម្បីសេចក្ដីស្ងប់ស្ងាត់ ។ មានពាក្យតទៅទៀតថា ភិក្ខុ (ក្នុងសាសនានេះ) បានតាំងមនោកម្មប្រកបដោយមេត្តា ក្នុងពួកសព្រហ្មចារីបុគ្គល ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ ធម៌នេះឯង ឈ្មោះថា ជាធម៌ដែលបុគ្គលគប្បីរលឹក ឈ្មោះថា ធ្វើនូវសេចក្ដីស្រឡាញ់ ឈ្មោះថា ធ្វើនូវសេចក្ដីគោរពដល់សព្រហ្មចារីបុគ្គល ប្រព្រឹត្តទៅដើម្បីសេចក្ដីសង្គ្រោះ ដើម្បីសេចក្ដីមិនវិវាទ ដើម្បីព្រមព្រៀង ដើម្បីសេចក្ដីស្ងប់ស្ងាត់ ។ មានពាក្យតទៅទៀតថា លាភណា ដែលប្រកបដោយធម៌ បានមកដោយធម៌ ដោយហោចទៅ សូម្បីគ្រាន់តែអាហារបិណ្ឌបាត ភិក្ខុអ្នកមិនទាន់បានបរិភោគ ទាំងមិនទាន់បានចែកលាភដូច្នោះនៅឡើយ ជាអ្នកបរិភោគសាធារណៈ

រណោភោតី អយម្បិ ធម្មោ សារាណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខុ យានិ តានិ សីលានិ អខណ្ឌានិ អច្ឆិទ្ទានិ អសពលានិ អកម្មាសានិ ភុជិស្សានិ វិញ្ញុបសត្ថានិ អបរាមដ្ឋានិ សមាធិសំវត្តនិកានិ តថារូបេសុ សីលេសុ សីលសាមញ្ញគតោ វិហរតិ សព្រហ្មចារីហិ អាវិ ចេវ រហោ ច អយម្បិ ធម្មោ សារាណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខុ យាយំ ទិដ្ឋិ អរិយា និយ្យានិកា និយ្យាតិ តក្ករស្ស សម្មាទុក្ខក្ខយាយ តថារូបាយ ទិដ្ឋិយា

(ជាមួយ) នឹងសព្រហ្មចារីបុគ្គល អ្នកមានសីលទាំងឡាយ ធម៌នេះឯង ឈ្មោះថា ជាធម៌ដែលបុគ្គលគប្បីរលឹក ឈ្មោះថា ធ្វើនូវសេចក្តីស្រឡាញ់ ឈ្មោះថា ធ្វើនូវសេចក្តីគោរព ដល់សព្រហ្មចារីបុគ្គល ប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនវិវាទ ដើម្បីព្រមព្រៀង ដើម្បីសេចក្តីស្ងប់ស្ងាត់ ។ មានពាក្យតទៅទៀតថា សីលណា ដែលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុះ ជាសីលល្អ ជាសីលដែលអ្នកប្រាជ្ញតែងសរសើរ ជាសីលដែលតណ្ហានិងទិដ្ឋិមិនបានប៉ះពាល់ ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ[១] ភិក្ខុជាអ្នកមានសីលស្មើគ្នា ក្នុងសីលទាំងឡាយ មានសភាពដូច្នោះ ជាមួយនឹងសព្រហ្មចារីបុគ្គល ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ ធម៌នេះឯង ឈ្មោះថា ជាធម៌ដែលបុគ្គលគប្បីរលឹក ឈ្មោះថា ធ្វើនូវសេចក្តីស្រឡាញ់ ឈ្មោះថាធ្វើនូវសេចក្តីគោរពដល់សព្រហ្មចារីបុគ្គល ប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនវិវាទ ដើម្បីព្រមព្រៀង ដើម្បីសេចក្តីស្ងប់ស្ងាត់ ។ ពាក្យតទៅទៀតថា ទិដ្ឋិណា ដ៏ប្រសើរ ជាទីនាំសត្វចេញចាកវដ្តទុក្ខ របស់បុគ្គលអ្នកធ្វើយ៉ាងនោះ ដើម្បីជាទីអស់ទៅនៃកងទុក្ខដោយប្រពៃ ភិក្ខុប្រកបដោយសេចក្តី

---

១ អដ្ឋកថា ថាប្រព្រឹត្តទៅដើម្បីឧបចារសមាធិនិងអប្បនាសមាធិ ។

និជ្ជិសាមញ្ញគតោ វិហរតិ សព្រហ្មចារីហិ អាវិ ចេវ រហោ ច អយម្បិ ធម្មោ សារាណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ ឥមេ ឆ សារាណីយា ធម្មា ។

[៨៤៧] តត្ថ កតមានិ អដ្ឋារស ភេទករវត្ថូនិ ។ ឥធ ភិក្ខុ អធម្មំ ធម្មោតិ ទីបេតិ ធម្មំ អធម្មោតិ ទីបេតិ អវិនយំ វិនយោតិ ទីបេតិ វិនយំ អវិនយោតិ ទីបេតិ អភាសិតំ អលបិតំ តថាគតេន ភាសិតំ លបិតំ តថាគតេនាតិ ទីបេតិ ភាសិតំ លបិតំ តថាគតេន អភាសិតំ អលបិតំ តថាគតេនាតិ ទីបេតិ អនាចិណ្ណំ តថាគតេន អាចិណ្ណំ តថាគតេនាតិ ទីបេតិ អាចិណ្ណំ តថាគតេន អនាចិណ្ណំ តថាគតេនាតិ ទីបេតិ អប្បញ្ញត្តំ តថាគតេន បញ្ញត្តំ តថាគតេនាតិ ទីបេតិ បញ្ញត្តំ តថាគតេន

យល់ឃើញស្មើគ្នា ដោយទិដ្ឋិមានសភាពដូច្នោះ (ជាមួយ) នឹងសព្រហ្មចារីបុគ្គល ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ ធម៌នេះឯង ឈ្មោះថា ជាធម៌ដែលបុគ្គលគប្បីរលឹក ឈ្មោះថា ធ្វើនូវសេចក្តីស្រឡាញ់ ឈ្មោះថា ធ្វើនូវសេចក្តីគោរពដល់សព្រហ្មចារីបុគ្គល ប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនវិវាទ ដើម្បីព្រមព្រៀង ដើម្បីសេចក្តីស្ងប់ស្ងាត់ ។ នេះ ជាសារាណីយធម៌ ៦ ។

[៨៥៧] ភេទករវត្ថុ ១៨ ដែលមកក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ ។ (ភេទករវត្ថុ ១៨ នោះគឺ) ភិក្ខុក្នុងសាសនានេះ សម្តែងនូវសភាវៈមិនមែនធម៌ថា ជាធម៌ ១ សម្តែងនូវធម៌ ថា មិនមែនធម៌ ១ សម្តែងនូវសភាវៈមិនមែនវិន័យ ថា ជាវិន័យ ១ សម្តែងនូវវិន័យថា មិនមែនវិន័យ ១ សម្តែងនូវធម្មវិន័យ ដែលតថាគត មិនបានសម្តែង មិនបានពោល ថា តថាគតបានសម្តែងបានពោល ១ សម្តែងនូវធម្មវិន័យដែលតថាគតបានសម្តែងបានពោល ថា តថាគតមិនបានសម្តែង មិនបានពោល ១ សម្តែងនូវវត្តដែលតថាគត មិនបានសន្សំមកហើយ ថា ជាវត្តដែលតថាគតបានសន្សំមក ១ សម្តែងនូវវត្តដែលតថាគតបានសន្សំមកហើយ ថា ជាវត្តដែលតថាគត មិនបានសន្សំមកហើយ ១ សម្តែងនូវសិក្ខាបទដែលតថាគត មិនបានបញ្ញត្ត ថា តថាគតបានបញ្ញត្ត ១ សម្តែងនូវសិក្ខាបទដែលតថាគត

៣៧៧

កតិបុច្ឆាវារំ អដ្ឋារសភេទករវត្ថូនិ

អប្បញ្ញត្តំ តថាគតេនាតិ ជីវេតិ អាបត្តី អនាបត្តីតិ ជីវេតិ អនាបត្តី អាបត្តីតិ ជីវេតិ លហុកំ អាបត្តី គរុកាតិ អាបត្តីតិ ជីវេតិ គរុកំ អាបត្តី លហុកា អាបត្តីតិ ជីវេតិ សាវសេសំ អាបត្តី អនវសេសា អាបត្តីតិ ជីវេតិ អនវសេសំ អាបត្តី សាវសេសា អាបត្តីតិ ជីវេតិ ទុដ្ឋុល្លំ អាបត្តី អទុដ្ឋុល្លា អាបត្តីតិ ជីវេតិ អទុដ្ឋុល្លំ អាបត្តី ទុដ្ឋុល្លា អាបត្តីតិ ជីវេតិ ។ ឥមានិ អដ្ឋារស ភេទករវត្ថូនិ ។

[៨៤៨] តត្ថ កតមានិ ចត្តារិ អធិករណានិ ។ វិវាទាធិករណំ អនុវាទាធិករណំ អាបត្តាធិករណំ កិច្ចាធិករណំ ។ ឥមានិ ចត្តារិ អធិករណានិ ។

[៨៤៩] តត្ថ កតមេ សត្ត សមថា ។ សម្មុខាវិនយោ សតិវិនយោ អមូឡ្ហវិនយោ បដិញ្ញាតករណំ យេភុយ្យសិកា តស្សបាបិយសិកា[១] តិណវត្ថារកោ ។ ឥមេ សត្ត សមថា ។

កតិបុច្ឆាវារំ និដ្ឋិតំ ។

---

១ ឱ. តស្សបាបិយ្យសិកា ។

កតិបុច្ឆាវារៈ ភេទករវត្ថុ ១៨ យ៉ាង

បានបញ្ញត្ត ថា តថាគតមិនបានបញ្ញត្ត ១ សម្តែងនូវអាបត្តិ ថាជាអនាបត្តិ ១ សម្តែងនូវអនាបត្តិ ថា ជាអាបត្តិ ១ សម្តែងនូវលហុកាបត្តិ ថា ជាគរុកាបត្តិ ១ សម្តែងនូវគរុកាបត្តិ ថា ជាលហុកាបត្តិ ១ សម្តែងនូវសាវសេសាបត្តិ ថា ជាអនវសេសាបត្តិ ១ សម្តែងនូវអនវសេសាបត្តិ ថា ជាសាវសេសាបត្តិ ១ សម្តែងនូវទុដ្ឋុល្លាបត្តិ ថា ជាអទុដ្ឋុល្លាបត្តិ ១ សម្តែងនូវអទុដ្ឋុល្លាបត្តិ ថា ជាទុដ្ឋុល្លាបត្តិ ១ ។ នេះ ជាភេទករវត្ថុ ១៨ ។

[៨៥៨] អធិករណ៍ ៤ ដែលមកក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ ។ (អធិករណ៍ ៤ នោះ គឺ) វិវាទាធិករណ៍ ១ អនុវាទាធិករណ៍ ១ អាបត្តាធិករណ៍ ១ កិច្ចាធិករណ៍ ១ ។ នេះ ជាអធិករណ៍ ៤ ។

[៨៥៩] សមថៈ ៧ ដែលមកក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ ។ (សមថៈ ៧ នោះគឺ) សម្មុខាវិន័យ ១ សតិវិន័យ ១ អមូឡ្ហវិន័យ ១ បដិញ្ញាតករណៈ ១ យេភុយ្យសិកា ១ តស្សបាបិយសិកា ១ តិណវត្ថារកៈ ១ ។ នេះ ជាសមថៈ ៧ ។

ចប់ កតិបុច្ឆាវារៈ ។

# តស្សុទ្ទានំ

[៨៦០] អាបត្តិ អាបត្តិក្ខន្ធា

វិនីតា សត្តធា បុន

វិនីតាការណា ចេវ

ការណា មូលមេវ ច

បុន វិនីតា វិបត្តិ

សមុដ្ឋានវិវាទនា[១]

អនុវាទា សារណីយំ

ភេទាធិករណេន ច ។

សត្តេវ សមថា វុត្តា

បទា សត្តរសា[២] ឥមេតិ ។

---

១ ឱ. សមុដ្ឋានំ វិវាទនា ។ ២ ឱ. សត្តរស ។

# ឧទ្ទាននៃកតិបុច្ឆាវារៈនោះដូច្នេះ

[៨៦០] និយាយពីអាបត្តិ ១ កងនៃអាបត្តិ ១ វត្ថុដែលព្រះអង្គទ្រង់វិនិច្ឆ័យហើយ ១ អាបត្តិ ៧ យ៉ាង ១ និងកងនៃអាបត្តិ ៧ ទៀត ១ វត្ថុដែលព្រះអង្គទ្រង់វិនិច្ឆ័យហើយ ៧ ទៀត ១ អគារវៈ ១ គារវៈជាមូល ១ វត្ថុដែលព្រះអង្គទ្រង់វិនិច្ឆ័យហើយ ៦ ទៀត ១ វិបត្តិ ១ សមុដ្ឋាន (នៃអាបត្តិ) ១ វិវាទមូល ១ អនុវាទមូល ១ សារាណីយធម៌ ១ ភេទករវត្ថុ ១ អធិករណ៍ ១ ។ សមថៈ ៧ ដែលលោកពោលហើយ រួមជាបទ ១៧ នេះឯង ។

# វីសតិ វារា

[៨៦១] បឋមេន អាបត្តិសមុដ្ឋានេន បារាជិកំ អាបជ្ជេយ្យាតិ ។ ន ហីតិ វត្តព្វំ ។ សង្ឃាទិសេសំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ ថុល្លច្ចយំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ បាចិត្តិយំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ បាដិទេសនីយំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ ទុក្កដំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ ទុព្ភាសិតំ អាបជ្ជេយ្យាតិ ។ ន ហីតិ វត្តព្វំ ។

[៨៦២] ទុតិយេន អាបត្តិសមុដ្ឋានេន បារាជិកំ អាបជ្ជេយ្យាតិ ។ ន ហីតិ វត្តព្វំ ។ សង្ឃាទិសេសំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ ថុល្លច្ចយំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ បាចិត្តិយំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ បាដិទេសនីយំ អាបជ្ជេយ្យាតិ ។ ន ហីតិ វត្តព្វំ ។ ទុក្កដំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ ទុព្ភាសិតំ អាបជ្ជេយ្យាតិ ។ ន ហីតិ វត្តព្វំ ។

# វីសតិវារៈ

[៨៦១] ភិក្ខុត្រូវអាបត្តិបារាជិក ដោយសមុដ្ឋាននៃអាបត្តិ ជាបឋមដែរឬទេ ។ មិនត្រូវទេ ។ ត្រូវអាបត្តិសង្ឃាទិសេស (ដោយសមុដ្ឋាននៃអាបត្តិជាបឋម) ឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិថុល្លច្ច័យឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិបាចិត្តិយៈឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិបាដិទេសនីយៈឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិទុក្កដឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិទុព្ភាសិត (ដោយសមុដ្ឋាននៃអាបត្តិជាបឋម) ឬទេ ។ មិនត្រូវទេ ។

[៨៦២] ភិក្ខុត្រូវអាបត្តិបារាជិក ដោយសមុដ្ឋាននៃអាបត្តិទី ២ ឬទេ ។ មិនត្រូវទេ ។ ត្រូវអាបត្តិសង្ឃាទិសេសឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិថុល្លច្ច័យឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិបាចិត្តិយៈឬទេ ។ មានត្រូវដែរ ត្រូវអាបត្តិបាដិទេសនីយៈឬទេ ។ មិនត្រូវទេ ។ ត្រូវអាបត្តិទុក្កដឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិទុព្ភាសិតឬទេ ។ មិនត្រូវទេ ។

[៨៦៣] តតិយេន អាបត្តិសមុដ្ឋានេន ចាតុមាសិកំ អាបជ្ជេយ្យាតិ ។ ន ហីតិ វត្តព្វំ ។ សង្ឃាទិសេសំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ ថុល្លច្ចយំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ បាចិត្តិយំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ បាដិទេសនីយំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ ទុក្កដំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ ទុព្ភាសិតំ អាបជ្ជេយ្យាតិ ។ ន ហីតិ វត្តព្វំ ។

[៨៦៤] ចតុត្ថេន អាបត្តិសមុដ្ឋានេន ចាតុមាសិកំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ សង្ឃាទិសេសំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ ថុល្លច្ចយំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ បាចិត្តិយំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ បាដិទេសនីយំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ ទុក្កដំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ ទុព្ភាសិតំ អាបជ្ជេយ្យាតិ ។ ន ហីតិ វត្តព្វំ ។

[៨៦៣] ភិក្ខុត្រូវអាបត្តិបារាជិក ដោយសមុដ្ឋាននៃអាបត្តិទី ៣ ឬទេ ។ មិនត្រូវទេ ។ ត្រូវអាបត្តិសង្ឃាទិសេសឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិថុល្លច្ច័យឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិបាចិត្តិយៈឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិបាដិទេសនីយៈឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិទុក្កដឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិទុព្ភាសិតឬទេ ។ មិនត្រូវទេ ។

[៨៦៤] ភិក្ខុត្រូវអាបត្តិបារាជិក ដោយសមុដ្ឋាននៃអាបត្តិទី ៤ ឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិសង្ឃាទិសេសឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិថុល្លច្ច័យឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិបាចិត្តិយៈឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិបាដិទេសនីយៈឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិទុក្កដឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិទុព្ភាសិតឬទេ ។ មិនត្រូវទេ ។

## វីសតិ វារា ឆអាបត្តិសមុដ្ឋានវារំ

[៨៦៥] បញ្ចមេន អាបត្តិសមុដ្ឋានេន ចាតុក្កំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ សង្ឃាទិសេសំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ ថុល្លច្ចយំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ បាចិត្តិយំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ បាដិទេសនីយំ អាបជ្ជេយ្យាតិ ។ ន ហីតិ វត្តព្វំ ។ ទុក្កដំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ ទុព្ភាសិតំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។

[៨៦៦] ឆដ្ឋេន អាបត្តិសមុដ្ឋានេន ចាតុក្កំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ សង្ឃាទិសេសំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ ថុល្លច្ចយំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ បាចិត្តិយំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ បាដិទេសនីយំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ ទុក្កដំ អាបជ្ជេយ្យាតិ ។ សិយាតិ វត្តព្វំ ។ ទុព្ភាសិតំ អាបជ្ជេយ្យាតិ ។ ន ហីតិ វត្តព្វំ ។

ឆអាបត្តិសមុដ្ឋានវារំ និដ្ឋិតំ បឋមំ ។

វីសតិវារៈ វារៈសមុដ្ឋាននៃអាបត្តិ ៦

[៨៦៥] ភិក្ខុត្រូវអាបត្តិបារាជិក ដោយសមុដ្ឋាននៃអាបត្តិទី ៥ ឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិសង្ឃាទិសេសឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិថុល្លច្ច័យឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិបាចិត្តិយៈឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិបាដិទេសនីយៈឬទេ ។ មិនត្រូវទេ ។ ត្រូវអាបត្តិទុក្កដឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិទុព្ភាសិតឬទេ ។ មានត្រូវដែរ ។

[៨៦៦] ភិក្ខុត្រូវអាបត្តិបារាជិក ដោយសមុដ្ឋាននៃអាបត្តិទី ៦ ឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិសង្ឃាទិសេសឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិថុល្លច្ច័យឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិបាចិត្តិយៈឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិបាដិទេសនីយៈឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិទុក្កដឬទេ ។ មានត្រូវដែរ ។ ត្រូវអាបត្តិទុព្ភាសិតឬទេ ។ មិនត្រូវទេ ។

ចប់ វារៈនៃអាបត្តិសមុដ្ឋាន ៦ ជាបឋម ។

[៨៦៧] បឋមេន អាបត្តិសមុដ្ឋានេន កតិ អាបត្តិយោ អាបជ្ជតិ ។ បឋមេន អាបត្តិសមុដ្ឋានេន បញ្ច អាបត្តិយោ អាបជ្ជតិ ភិក្ខុ កប្បិយសញ្ញី សញ្ញាចិកាយ កុដឹ ករោតិ អទេសិតវត្ថុកំ បមាណាតិក្កន្តំ សារម្ភំ អបរិក្កមនំ បយោគេ ទុក្កដំ ឯកបិណ្ឌេ អនាគតេ អាបត្តិ ថុល្លច្ចយស្ស តស្មឹ បិណ្ឌេ អាគតេ អាបត្តិ សង្ឃាទិសេសស្ស ។ ភិក្ខុ កប្បិយសញ្ញី វិកាលេ ភោជនំ ភុញ្ជតិ អាបត្តិ បាចិត្តិយស្ស ។ ភិក្ខុ កប្បិយសញ្ញី អញ្ញាតិកាយ ភិក្ខុនិយា អន្តរឃរំ បវិដ្ឋាយ ហត្ថតោ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ភុញ្ជតិ អាបត្តិ បាដិទេសនីយស្ស ។ បឋមេន អាបត្តិសមុដ្ឋានេន ឥមា បញ្ច អាបត្តិយោ អាបជ្ជតិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតីហិ អាបត្តិក្ខន្ធេហិ សង្គហិតា ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ ។ ចតុន្នំ អធិករណានំ កតមំ អធិករណំ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មន្តិ ។

[៨៦៧] ភិក្ខុត្រូវអាបត្តិប៉ុន្មានយ៉ាង ដោយសមុដ្ឋាននៃអាបត្តិទី ១ ។ ត្រូវអាបត្តិ ៥ ដោយសមុដ្ឋាននៃអាបត្តិទី ១ គឺភិក្ខុសំគាល់ថា គួរហើយ ធ្វើកុដិដោយការសូមគេមកដោយខ្លួនឯង តែឥតមានសង្ឃសម្តែងទីឲ្យ ធ្វើឲ្យហួសប្រមាណ មានហេតុទាស់ មិនមានទីឧបចារៈ ត្រូវអាបត្តិទុក្កដរាល់ប្រយោគ កាលនៅតែបាយអបូកមួយដុំនឹងហើយ ត្រូវអាបត្តិថុល្លច្ច័យ កាលបើបូកបាយអមួយដុំនោះហើយស្រេច ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុសំគាល់ថា គួរ ហើយបរិភោគភោជនីយាហារក្នុងវេលាវិកាល ត្រូវអាបត្តិបាចិត្តិយៈ ។ ភិក្ខុសំគាល់ថា គួរ ហើយទទួលខាទនីយៈ ឬភោជនីយាហារអំពីដៃភិក្ខុនី មិនមែនជាញាតិ ដែលចូលទៅកាន់ចន្លោះផ្ទះដោយដៃខ្លួនឯង យកមកបរិភោគត្រូវអាបត្តិបាដិទេសនីយៈ ។ ភិក្ខុត្រូវអាបត្តិទាំង ៥ នេះ ដោយសមុដ្ឋាននៃអាបត្តិទី ១ ។ បណ្តាវិបត្តិទាំង ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន ។ បណ្តាកងនៃអាបត្តិទាំង ៧ លោកសង្គ្រោះ ដោយកងនៃអាបត្តិប៉ុន្មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិ ៦ តាំងឡើង ដោយសមុដ្ឋានប៉ុន្មាន ។ បណ្តាអធិករណ៍ ៤ ចាត់ជាអធិករណ៍អ្វី ។ បណ្តាសមថៈ ៧ រម្ងាប់ដោយសមថៈប៉ុន្មាន ។

## វីសតិ វារា ឆអាបត្តិសមុដ្ឋានកតាបត្តិវារំ

តា អាបត្តិយោ ចតុន្នំ វិបត្តីនំ ទ្វេ វិបត្តិយោ ភជន្តិ សិយា សីលវិបត្តឹ សិយា អាចារវិបត្តឹ ។ សត្តន្នំ អាបត្តិក្ខន្ធានំ បញ្ចហិ អាបត្តិក្ខន្ធេហិ សង្គហិតា សិយា សង្ឃាទិសេសាបត្តិក្ខន្ធេន សិយា ថុល្លច្ចយាបត្តិក្ខន្ធេន សិយា បាចិត្តិយាបត្តិក្ខន្ធេន សិយា បាដិទេសនីយាបត្តិក្ខន្ធេន សិយា ទុក្កដាបត្តិក្ខន្ធេន ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋហន្តិ កាយតោ សមុដ្ឋហន្តិ ន វាចតោ ន ចិត្តតោ ។ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មន្តិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។

[៨៦៨] ទុតិយេន អាបត្តិសមុដ្ឋានេន កតិ អាបត្តិយោ អាបជ្ជតិ ។ ទុតិយេន អាបត្តិសមុដ្ឋានេន ចតស្សោ អាបត្តិយោ អាបជ្ជតិ ភិក្ខុ កប្បិយសញ្ញី

វីសតិវារៈ សមុដ្ឋាននៃអាបត្តិ ៦ យ៉ាងនិងកតាបត្តិវារៈ

បណ្ដាវិបត្តិ ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ ២ គឺសីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន ។ បណ្ដាកងនៃអាបត្តិ ៧ លោកសង្គ្រោះ ដោយកងនៃអាបត្តិ ៥ គឺកងនៃអាបត្តិសង្ឃាទិសេសក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិបាដិទេសនីយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន ។ បណ្ដាសមុដ្ឋាននៃអាបត្តិ ៦ តាំងឡើង ដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយ មិនបានតាំងឡើងអំពីវាចា ទាំងមិនបានតាំងឡើងអំពីចិត្តឡើយ ។ បណ្ដាអធិករណ៍ ៤ អាបត្តិទាំងនោះ ចាត់ជាអាបត្តាធិករណ៍ ។ បណ្ដាសមថៈ ៧ រម្ងាប់ដោយសមថៈ ៣ គឺដោយសម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន ។

[៨៦៨] ភិក្ខុត្រូវអាបត្តិប៉ុន្មាន ដោយសមុដ្ឋាននៃអាបត្តិទី ២ ។ ភិក្ខុត្រូវអាបត្តិ ៤ ដោយសមុដ្ឋាននៃអាបត្តិទី ២ គឺភិក្ខុសំគាល់ថា គួរ

សមាធិសតិ កុដឹ មេ ករោថាតិ តស្ស កុដឹ ករោន្តិ អទេសិតវត្ថុកំ បមាណាតិក្កន្តំ សារម្ភំ អបរិក្កមនំ បយោគេ ទុក្កដំ ឯកបិណ្ឌេ អនាគតេ អាបត្តិ ថុល្លច្ចយស្ស តស្មឹ បិណ្ឌេ អាគតេ អាបត្តិ សង្ឃាទិសេសស្ស ។ ភិក្ខុ កប្បិយសញ្ញី អនុបសម្បន្នំ បទសោ ធម្មំ វាចេតិ អាបត្តិ បាចិត្តិយស្ស ។ ទុតិយេន អាបត្តិសមុដ្ឋានេន ឥមា ចតស្សោ អាបត្តិយោ អាបជ្ជតិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ បេ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មន្តិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ ទ្វេ វិបត្តិយោ ភជន្តិ សិយា សីលវិបត្តឹ សិយា អាចារវិបត្តឹ ។ សត្តន្នំ អាបត្តិក្ខន្ធានំ ចតូហិ អាបត្តិក្ខន្ធេហិ សង្គហិតា សិយា សង្ឃាទិសេសាបត្តិក្ខន្ធេន សិយា ថុល្លច្ចយាបត្តិក្ខន្ធេន សិយា បាចិត្តិយាបត្តិក្ខន្ធេន សិយា ទុក្កដាបត្តិក្ខន្ធេន ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋហន្តិ វាចតោ សមុដ្ឋហន្តិ ន កាយតោ ន ចិត្តតោ ។ ចតុន្នំ អធិករណានំ

ក៏បបួល (ពួកភិក្ខុផងគ្នា) ថា លោកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ ភិក្ខុទាំងឡាយក៏ធ្វើកុដិ ចំពោះភិក្ខុនោះ ឥតមានពួកភិក្ខុសម្តែងទីឲ្យ ធ្វើឲ្យហួសប្រមាណ មានហេតុទាស់ មិនមានទីឧបចារៈ ត្រូវអាបត្តិទុក្កដរាល់ប្រយោគ កាលនៅតែបាយអបូកមួយដុំនឹងហើយ ត្រូវអាបត្តិថុល្លច្ច័យ លុះបូកបាយអមួយដុំនោះហើយស្រេច ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុសំគាល់ថា គួរ ក៏បង្រៀនធម៌ជាបទ ចំពោះអនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយៈ ។ ភិក្ខុត្រូវអាបត្តិ ៤ នេះ ដោយសមុដ្ឋាននៃអាបត្តិទី ២ ។ បណ្តាវិបត្តិ ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន ។ បេ ។ បណ្តាសមថៈ ៧ រម្ងាប់ដោយសមថៈប៉ុន្មាន ។ បណ្តាវិបត្តិ ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ ២ គឺសីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន ។ បណ្តាកងនៃអាបត្តិ ៧ លោកសង្គ្រោះ ដោយកងអាបត្តិ ៤ គឺកងនៃអាបត្តិសង្ឃាទិសេសក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិ ៦ តាំងឡើងដោយសមុដ្ឋានតែ ១ គឺតាំងឡើងអំពីវាចា មិនតាំងឡើងអំពីកាយ មិនតាំងឡើងអំពីចិត្តឡើយ ។ បណ្តាអធិករណ៍ ៤ ចាត់ជា

អាបត្តាធិករណំ ។ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មន្តិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។

[៨៦៩] តតិយេន អាបត្តិសមុដ្ឋានេន កតិ អាបត្តិយោ អាបជ្ជតិ ។ តតិយេន អាបត្តិសមុដ្ឋានេន បញ្ច អាបត្តិយោ អាបជ្ជតិ ភិក្ខុ កប្បិយសញ្ញី សំវិធហិត្វា កុដឹ ករោតិ អទេសិតវត្ថុកំ បមាណាតិក្កន្តំ សារម្ភំ អបរិក្កមនំ បយោគេ ទុក្កដំ ឯកបិណ្ឌេ អនាគតេ អាបត្តិ ថុល្លច្ចយស្ស តស្មឹ បិណ្ឌេ អាគតេ អាបត្តិ សង្ឃាទិសេសស្ស ។ ភិក្ខុ កប្បិយសញ្ញី បណីតភោជនានិ អត្តនោ អត្ថាយ វិញ្ញាបេត្វា កុញ្ជតិ អាបត្តិ ចាចិត្តិយស្ស ។ ភិក្ខុ កប្បិយសញ្ញី ភិក្ខុនិយា វោសាសន្តិយា ន និវារេត្វា កុញ្ជតិ អាបត្តិ ចាដិទេសនីយស្ស ។ តតិយេ អាបត្តិសមុដ្ឋានេន ឥមា បញ្ច អាបត្តិយោ អាបជ្ជតិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ បេ ។ សត្តន្នំ សមថានំ

អាបត្តាធិករណ៍ ។ បណ្តាសមថៈ ៧ រម្ងាប់ដោយសមថៈ ៣ គឺ ដោយសម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន ។

[៨៦៩] ភិក្ខុត្រូវអាបត្តិប៉ុន្មាន ដោយសមុដ្ឋាននៃអាបត្តិទី ៣ ។ ត្រូវអាបត្តិ ៥ ដោយសមុដ្ឋាននៃអាបត្តិទី ៣ គឺភិក្ខុសំគាល់ថា គួរក៏ចាត់ចែងធ្វើកុដិ ឥតមានពួកភិក្ខុសម្តែងទីឲ្យ ធ្វើឲ្យហួសប្រមាណ មានហេតុទាស់ មិនមានទីឧបចារៈ ត្រូវអាបត្តិទុក្កដរាល់ប្រយោគ កាលនៅតែបាយអបូកមួយដុំនឹងហើយ ត្រូវអាបត្តិថុល្លច្ច័យ លុះបូកបាយអមួយដុំនោះហើយស្រេច ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុសំគាល់ថា គួរក៏សូមបណីតភោជន ដើម្បីខ្លួនមកឆាន់ ត្រូវអាបត្តិបាចិត្តិយៈ ។ ភិក្ខុសំគាល់ថា គួរហើយ កាលបើមានភិក្ខុនីមកឈរបង្គាប់ (ឲ្យគេអង្គាសភោជន) មិនបានហាមឃាត់ហើយឆាន់ ត្រូវអាបត្តិបាដិទេសនីយៈ ។ ភិក្ខុត្រូវអាបត្តិ ៥ នេះ ដោយសមុដ្ឋាននៃអាបត្តិទី ៣ បណ្តាវិបត្តិ ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន ។ បេ ។ បណ្តាសមថៈ ៧ យ៉ាង

កតីហិ សមថេហិ សម្មន្តិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ ទ្វេ វិបត្តិយោ ភជន្តិ សិយា សីលវិបត្តឹ សិយា អាចារវិបត្តឹ ។ សត្តន្នំ អាបត្តិក្ខន្ធានំ បញ្ចហិ អាបត្តិក្ខន្ធេហិ សង្គហិតា សិយា សង្ឃាទិសេសាបត្តិក្ខន្ធេន សិយា ថុល្លច្ចយាបត្តិក្ខន្ធេន សិយា បាចិត្តិយាបត្តិក្ខន្ធេន សិយា បាដិទេសនីយាបត្តិក្ខន្ធេន សិយា ទុក្កដាបត្តិក្ខន្ធេន ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋហន្តិ កាយតោ ច វាចតោ ច សមុដ្ឋហន្តិ ន ចិត្តតោ ។ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មន្តិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។

[៨៧០] ចតុត្ថេន អាបត្តិសមុដ្ឋានេន កតិ អាបត្តិយោ អាបជ្ជតិ ។ ចតុត្ថេន អាបត្តិសមុដ្ឋានេន ឆ អាបត្តិយោ អាបជ្ជតិ ភិក្ខុ មេថុនំ ធម្មំ បដិសេវតិ អាបត្តិ បារាជិកស្ស ។ ភិក្ខុ អកប្បិយសញ្ញី សញ្ញាចិកាយ កុដឹ ករោតិ អទេសិតវត្ថុកំ បមាណាតិក្កន្តំ

រម្ងាប់ដោយសមថៈប៉ុន្មាន ។ បណ្តាវិបត្តិ ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ ២ គឺសីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន ។ បណ្តាកងនៃអាបត្តិ ៧ លោកសង្គ្រោះដោយកងនៃអាបត្តិ ៥ គឺកងនៃអាបត្តិសង្ឃាទិសេសក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិបាដិទេសនីយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិ ៦ តាំងឡើងដោយសមុដ្ឋានតែ ១ គឺតាំងឡើងអំពីកាយនិងវាចា មិនតាំងឡើងអំពីចិត្ត ។ បណ្តាអធិករណ៍ ៤ ចាត់ជាអាបត្តាធិករណ៍ ។ បណ្តាសមថៈ ៧ រម្ងាប់ដោយសមថៈ ៣ គឺដោយសម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន ។

[៨៧០] ភិក្ខុត្រូវអាបត្តិប៉ុន្មាន ដោយសមុដ្ឋាន នៃអាបត្តិទី ៤ ។ ភិក្ខុត្រូវអាបត្តិ ៦ ដោយសមុដ្ឋាននៃអាបត្តិទី ៤ គឺភិក្ខុសេពមេថុនធម្ម ត្រូវអាបត្តិបារាជិក ។ ភិក្ខុសំគាល់ថា មិនគួរ ក៏ធ្វើកុដិដោយការសូមគេខ្លួនឯង ឥតមានពួកភិក្ខុសម្តែងទីឲ្យ ធ្វើឲ្យហួសប្រមាណ មាន

៣៨៧

វីសតិ វារា ឆអាបត្តិសមុដ្ឋានកតាបត្តិវារំ

សារម្ភំ អបរិក្កមនំ បយោគេ ទុក្កដំ ឯកបិណ្ឌេ អនាគតេ អាបត្តិ ថុល្លច្ចយស្ស តស្មឹ បិណ្ឌេ អាគតេ អាបត្តិ សង្ឃាទិសេសស្ស ។ ភិក្ខុ អកប្បិយសញ្ញី វិកាលេ ភោជនំ ភុញ្ជតិ អាបត្តិ ចាចិត្តិយស្ស ។ ភិក្ខុ អកប្បិយសញ្ញី អញ្ញាតិកាយ ភិក្ខុនិយា អន្តរឃរំ បវិដ្ឋាយ ហត្ថតោ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ភុញ្ជតិ អាបត្តិ ចាដិទេសនីយស្ស ។ ចតុត្ថេន អាបត្តិសមុដ្ឋានេន ឥមា ឆ អាបត្តិយោ អាបជ្ជតិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ បេ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មន្តិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ ទ្វេ វិបត្តិយោ ភជន្តិ សិយា សីលវិបត្តឹ សិយា អាចារវិបត្តឹ ។ សត្តន្នំ អាបត្តិក្ខន្ធានំ ឆហិ អាបត្តិក្ខន្ធេហិ សង្គហិតា សិយា ចារាជិកាបត្តិក្ខន្ធេន សិយា សង្ឃាទិសេសាបត្តិក្ខន្ធេន សិយា ថុល្លច្ចយាបត្តិក្ខន្ធេន សិយា ចាចិត្តិយាបត្តិក្ខន្ធេន សិយា ចាដិទេសនីយាបត្តិក្ខន្ធេន សិយា ទុក្កដាបត្តិក្ខន្ធេន ។

ហេតុទាស់ មិនមានទីឧបចារៈត្រូវអាបត្តិទុក្កដរាល់ប្រយោគ កាលនៅតែបាយអបូកមួយដុំនឹងហើយ ត្រូវអាបត្តិថុល្លច្ច័យ លុះបូកបាយអមួយដុំនោះហើយស្រេច ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុសំគាល់ថា មិនគួរក៏បរិភោគភោជនាហារក្នុងវិកាល ត្រូវអាបត្តិបាចិត្តិយៈ ។ ភិក្ខុសំគាល់ថា មិនគួរ ក៏ទទួលខាទនីយភោជនីយាហារ អំពីដៃភិក្ខុនី មិនមែនជាញាតិដែលចូលទៅក្នុងចន្លោះផ្ទះ ដោយដៃរបស់ខ្លួន យកមកឆាន់ ត្រូវអាបត្តិបាដិទេសនីយៈ ។ ភិក្ខុត្រូវអាបត្តិ ៦ នេះ ដោយសមុដ្ឋាននៃអាបត្តិទី ៤ ។ បណ្តាវិបត្តិ ៤ អាបត្តិទាំងនោះ អាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន ។ បេ ។ បណ្តាសមថៈ ៧ រម្ងាប់ដោយសមថៈប៉ុន្មាន ។ បណ្តាវិបត្តិ ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ ២ គឺសីលវិបត្តិក៏មាន អាចារ-វិបត្តិក៏មាន ។ បណ្តាកងនៃអាបត្តិ ៧ លោកសង្គ្រោះដោយកងនៃអាបត្តិ ៦ គឺកងនៃអាបត្តិបារាជិកក៏មាន កងនៃអាបត្តិសង្ឃា-ទិសេសក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិបាដិទេសនីយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន ។

ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋហន្តិ កាយតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន វាចតោ ។ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មន្តិ សិយា សម្មុខា-វិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខា-វិនយេន ច តិណវត្ថារកេន ច ។

[៨៧១] បញ្ចមេន អាបត្តិសមុដ្ឋានេន កតិ អា-បត្តិយោ អាបជ្ជតិ ។ បញ្ចមេន អាបត្តិសមុដ្ឋានេន ឆ អាបត្តិយោ អាបជ្ជតិ ភិក្ខុ ចាបិច្ឆោ ឥច្ឆាបកតោ អសន្តំ អភូតំ ឧត្តរិមនុស្សធម្មំ ឧល្លបតិ អាបត្តិ បារា-ជិកស្ស ។ ភិក្ខុ អកប្បិយសញ្ញី សមាទិសតិ កុដឹ មេ ករោថាតិ តស្ស កុដឹ ករោន្តិ អទេសិតវត្ថុកំ បមាណាតិក្កន្តំ សារម្ភំ អបរិក្កមនំ បយោគេ ទុក្កដំ ឯកបិណ្ឌេ អនាគតេ អាបត្តិ ថុល្លច្ចយស្ស តស្មឹ បិណ្ឌេ អាគតេ អាបត្តិ សង្ឃាទិសេសស្ស ។ ភិក្ខុ អកប្បិ-យសញ្ញី អនុបសម្បន្នំ បទសោ ធម្មំ វាចេតិ អាបត្តិ បាចិត្តិយស្ស ។ ន ខុំសេតុកាមោ ន វម្ភេតុកាមោ

បណ្តាសមុដ្ឋាននៃអាបត្តិ ៦ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចា ។ បណ្តាអធិករណ៍ ៤ ចាត់ជាអាបត្តាធិករណ៍ ។ បណ្តាសមថៈ ៧ រម្ងាប់ដោយសមថៈ ៣ គឺដោយសម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន ។

[៨៧១] ភិក្ខុត្រូវអាបត្តិប៉ុន្មាន ដោយសមុដ្ឋាន នៃអាបត្តិទី ៥ ។ ត្រូវអាបត្តិ ៦ ដោយសមុដ្ឋាននៃអាបត្តិទី ៥ គឺ ភិក្ខុមានសេចក្តីប្រាថ្នាអាក្រក់ លុះក្នុងអំណាចនៃសេចក្តីប្រាថ្នា ក៏ពោលអួតឧត្តរិមនុស្សធម្ម ដែលមិនមាន មិនពិត ត្រូវអាបត្តិបារាជិក ។ ភិក្ខុសំគាល់ថា មិនគួរ ក៏បបួល (ភិក្ខុផងគ្នា) ថា លោកទាំងឡាយ ចូរធ្វើកុដិដើម្បីយើង ភិក្ខុទាំងឡាយ ក៏ធ្វើកុដិចំពោះភិក្ខុនោះ ឥតមានពួកភិក្ខុសម្តែងទីឲ្យ ធ្វើឲ្យហួសប្រមាណ មានហេតុទាស់ មិនមានទីឧបចារៈ ត្រូវអាបត្តិទុក្កដរាល់ប្រយោគ កាលនៅតែបាយអបូកមួយដុំនឹងហើយ ត្រូវអាបត្តិថុល្លច្ច័យ លុះបូកបាយអមួយដុំនោះហើយស្រេច ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុសំគាល់ថា មិនគួរ ក៏បង្រៀនធម៌ជាបទចំពោះអនុបសម្ប័ន្ន ត្រូវអាបត្តិបាចិត្តិយៈ ។ ភិក្ខុមិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច

ន មត្តុំ កត្តុកាមោ ជវកម្យតា ហីនេន ហីនំ វេធតិ អាបត្តិ ទុព្ភាសិតស្ស ។ បញ្ចមេន អាបត្តិសមុដ្ឋានេន ឥមា ឆ អាបត្តិយោ អាបជ្ជតិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ បេ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មន្តិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ ទ្វេ វិបត្តិយោ ភជន្តិ សិយា សីលវិបត្តឹ សិយា អាចារវិបត្តឹ ។ សត្តន្នំ អាបត្តិក្ខន្ធានំ ឆហិ អាបត្តិក្ខន្ធេហិ សង្គហិតា សិយា ថារជិកាបត្តិក្ខន្ធេន សិយា សង្ឃាទិសេសាបត្តិក្ខន្ធេន សិយា ថុល្លច្ចយា-បត្តិក្ខន្ធេន សិយា ចាចិត្តិយាបត្តិក្ខន្ធេន សិយា ទុក្ក-ដាបត្តិក្ខន្ធេន សិយា ទុព្ភាសិតាបត្តិក្ខន្ធេន ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋហន្តិ វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន កាយតោ ។ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។ សត្តន្នំ សម-ថានំ តីហិ សមថេហិ សម្មន្តិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។

មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ប្រាថ្នាតែនិយាយលេង ពោលសំដៅបុគ្គលថោកទាបដោយពាក្យដ៏ថោកទាប ត្រូវអាបត្តិទុព្ភាសិត ។ ភិក្ខុត្រូវអាបត្តិ ៦ នេះ ដោយសមុដ្ឋាននៃអាបត្តិទី ៥ ។ បណ្ដាវិបត្តិ ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន ។ បេ ។ បណ្ដាសមថៈ ៧ រម្ងាប់ដោយសមថៈប៉ុន្មាន ។ បណ្ដាវិបត្តិ ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ ២ គឺសីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន ។ បណ្ដាកងនៃអាបត្តិ ៧ លោកសង្គ្រោះដោយកងនៃអាបត្តិ ៦ គឺកងនៃអាបត្តិបារាជិកក៏មាន កងនៃអាបត្តិសង្ឃាទិសេសក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន កងនៃអាបត្តិទុព្ភាសិតក៏មាន ។ បណ្ដាសមុដ្ឋាននៃអាបត្តិ ៦ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីវាចានិងចិត្ត មិនតាំងឡើងអំពីកាយ ។ បណ្ដាអធិករណ៍ទាំង ៤ ចាត់ជាអាបត្តាធិ-ករណ៍ ។ បណ្ដាសមថៈទាំង ៧ រម្ងាប់ដោយសមថៈ ៣ គឺដោយសម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណ-វត្ថារកៈក៏មាន ។

[៨៧២] ឆព្ពេន អាបត្តិសមុដ្ឋានេន កតិ អាបត្តិ-យោ អាបជ្ជតិ ។ ឆព្ពេន អាបត្តិសមុដ្ឋានេន ឆ អាបត្តិ-យោ អាបជ្ជតិ ភិក្ខុ សំវិទហិត្វា ភណ្ឌំ អវហរតិ អាបត្តិ ថាវាជិកស្ស ។ ភិក្ខុ អកប្បិយសញ្ញី សំវិទហិត្វា កុដឹ ករោតិ អទេសិតវត្ថុកំ បមាណាតិក្កន្តំ សារម្ភំ អបរិក្កមនំ បយោគេ ទុក្កដំ ឯកបិណ្ឌេ អនាគតេ អាបត្តិ ថុល្លច្ចយស្ស តស្មឹ បិណ្ឌេ អាគតេ អាបត្តិ សង្ឃាទិសេសស្ស ។ ភិក្ខុ អកប្បិយសញ្ញី បណីត-ភោជនានិ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជតិ អាបត្តិ ថាចិត្តិយស្ស ។ ភិក្ខុ អកប្បិយសញ្ញី ភិក្ខុនិយា ពោសាសន្តិយា ន និវារេត្វា ភុញ្ជតិ អាបត្តិ ថាដិទេស-នីយស្ស ។ ឆព្ពេន អាបត្តិសមុដ្ឋានេន ឥមា ឆ អា-បត្តិយោ អាបជ្ជតិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតីហិ អាបត្តិក្ខន្ធេហិ សង្គហិតា ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ ។ ចតុន្នំ អធិក-រណានំ កតមំ អធិករណំ ។ សត្តន្នំ សមថានំ

[៨៧២] ភិក្ខុត្រូវអាបត្តិប៉ុន្មាន ដោយសមុដ្ឋាន នៃអាបត្តិទី ៦ ។ ភិក្ខុត្រូវអាបត្តិ ៦ ដោយសមុដ្ឋាននៃអាបត្តិទី ៦ គឺ ភិក្ខុបបួល (ភិក្ខុផងគ្នា) ទៅលួចទ្រព្យគេ ត្រូវអាបត្តិបារាជិក ។ ភិក្ខុសំគាល់ថា មិនគួរ ក៏ចាត់ចែងធ្វើកុដិ ឥតមានពួកភិក្ខុសម្តែងទីឲ្យ ធ្វើឲ្យហួសប្រមាណ មានហេតុទាស់ មិនមានទីឧបចារៈ ត្រូវអាបត្តិទុក្កដរាល់ប្រយោគ កាលនៅតែបាយអបូកមួយដុំនឹងហើយ ត្រូវអាបត្តិថុល្លច្ច័យ លុះបូកបាយអមួយដុំនោះហើយស្រេច ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុសំគាល់ថា មិនគួរ ក៏សូមបណីតភោជនដើម្បីខ្លួនយកមកឆាន់ ត្រូវអាបត្តិបាចិត្តិយៈ ។ ភិក្ខុសំគាល់ថា មិនគួរ កាលបើមានភិក្ខុនីមកឈរបង្គាប់ (ឲ្យគេអង្គាសខាទនីយភោជនីយាហារ) មិនបានហាមឃាត់ហើយឆាន់ ត្រូវអាបត្តិបាដិទេសនីយៈ ។ ភិក្ខុត្រូវអាបត្តិ ៦ នេះ ដោយសមុដ្ឋាននៃអាបត្តិទី ៦ ។ បណ្តាវិបត្តិទាំង ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន ។ បណ្តាកងនៃអាបត្តិ ៧ លោកសង្គ្រោះដោយកង នៃអាបត្តិប៉ុន្មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិ ៦ តាំងឡើង ដោយសមុដ្ឋានប៉ុន្មាន ។ បណ្តាអធិករណ៍ ៤ ចាត់ជាអធិករណ៍ណា ។ បណ្តាសមថៈ ៧

វីសតិ វារា ឆអាបត្តិសមុដ្ឋានកតាបត្តិវារំ

កតីហិ សមថេហិ សម្មន្តិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ ទ្វេ វិបត្តិយោ ភជន្តិ សិយា សីលវិបត្តឹ សិយា អាចារវិបត្តឹ ។ សត្តន្នំ អាបត្តិក្ខន្ធានំ ឆហិ អាបត្តិក្ខន្ធេហិ សង្គហិតា សិយា ថុល្លច្ចយាបត្តិក្ខន្ធេន សិយា សង្ឃាទិសេសាបត្តិក្ខន្ធេន សិយា ថុល្លច្ចយាបត្តិក្ខន្ធេន សិយា បាចិត្តិយាបត្តិក្ខន្ធេន សិយា បាដិទេសនីយាបត្តិក្ខន្ធេន សិយា ទុក្កដាបត្តិក្ខន្ធេន ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋហន្តិ កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ។ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មន្តិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច[១] ។

ឆអាបត្តិសមុដ្ឋានកតាបត្តិវារំ និដ្ឋិតំ ទុតិយំ ។

---

១ ឱ. ម. ចាតិ ។

រម្ងាប់ដោយសមថៈប៉ុន្មាន ។ បណ្ដាវិបត្តិ ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ ២ គឺ សីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន ។ បណ្ដាកងនៃអាបត្តិ ៧ លោកសង្គ្រោះ ដោយកងនៃអាបត្តិ ៦ គឺកងនៃអាបត្តិបារាជិកក៏មាន កងនៃអាបត្តិសង្ឃាទិសេសក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិបាដិទេសនីយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន ។ បណ្ដាសមុដ្ឋាននៃអាបត្តិ ៦ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយវាចាចិត្ត ។ បណ្ដាអធិករណ៍ ៤ ចាត់ជាអាបត្តាធិករណ៍ ។ បណ្ដាសមថៈ ៧ រម្ងាប់ដោយសមថៈ ៣ គឺដោយសម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន ។

ចប់ សមុដ្ឋាននៃអាបត្តិ ៦ និងកតាបត្តិវារៈ ជាគម្រប់ពីរ ។

[៨៧៣] សមុដ្ឋានា កាយិកា អនន្តនស្សិនា
អក្ខាតា លោកហិតេន វិវេកទស្សិនា
អាបត្តិយោ តេន សមុដ្ឋិតា កតិ
បុច្ឆាមិ តំ ព្រូហិ វិភង្គកោវិទ ។
សមុដ្ឋានា កាយិកា អនន្តនស្សិនា
អក្ខាតា លោកហិតេន វិវេកទស្សិនា
អាបត្តិយោ តេន សមុដ្ឋិតា បញ្ច ។
ឯតន្តេ អក្ខាមិ វិភង្គកោវិទ ។
សមុដ្ឋានា វាចសិកា អនន្តនស្សិនា
អក្ខាតា លោកហិតេន វិវេកទស្សិនា
អាបត្តិយោ តេន សមុដ្ឋិតា កតិ
បុច្ឆាមិ តំ ព្រូហិ វិភង្គកោវិទ ។

[៨៧៣] សួរថា សមុដ្ឋានដែលប្រកបដោយកាយ ព្រះមានព្រះភាគ ទ្រង់ឃើញនូវធម៌គ្មានទីបំផុត មានព្រះហឫទ័យជាប្រយោជន៍ដល់សត្វលោក ទ្រង់ឃើញនូវវិវេកធម៌ បានសម្តែងហើយថា អាបត្តិប៉ុន្មាន ដែលតាំងឡើងអំពីកាយនោះ បពិត្រលោកអ្នកឈ្លាសក្នុងវិភង្គ ខ្ញុំសូមសួរសមុដ្ឋានដែលកើតអំពីកាយនោះ សូមលោកឆ្លើយមក ។ ឆ្លើយថា សមុដ្ឋានដែលប្រកបដោយកាយ ព្រះមានព្រះភាគ ទ្រង់ឃើញនូវធម៌គ្មានទីបំផុត មានព្រះហឫទ័យជាប្រយោជន៍ដល់សត្វលោក ទ្រង់ឃើញនូវវិវេកធម៌ បានសម្តែងហើយថា អាបត្តិដែលតាំងឡើងអំពីកាយនោះ មាន ៥ កង ។ បពិត្រលោកអ្នកឈ្លាសក្នុងវិភង្គ ខ្ញុំនឹងប្រាប់សមុដ្ឋាន ដែលកើតឡើងអំពីកាយនុ៎ះដល់លោក ។ សមុដ្ឋានដែលប្រកបដោយវាចា ព្រះមានព្រះភាគ ទ្រង់ឃើញនូវធម៌គ្មានទីបំផុត មានព្រះហឫទ័យជាប្រយោជន៍ ដល់សត្វលោក ទ្រង់ឃើញនូវវិវេកធម៌ បានសម្តែងហើយថា អាបត្តិប៉ុន្មាន ដែលតាំងឡើងអំពីវាចានោះ បពិត្រលោកអ្នកឈ្លាសក្នុងវិភង្គ ខ្ញុំសូមសួរសមុដ្ឋានដែលកើតអំពីវាចានោះ សូមលោកឆ្លើយមក ។

៣៩៣

វីសតិ វារា អាបត្តិសមុដ្ឋានគាថា

សមុដ្ឋានា វាចសិកា អនត្តនស្សិនា
អក្ខាតា លោកហិតេន វិវេកទស្សិនា
អាបត្តិយោ តេន សមុដ្ឋិតា ចតស្សោ ។
ឯតន្តេ អក្ខាមិ វិភង្គកោវិទ ។
សមុដ្ឋានា កាយិកា វាចសិកា អនត្តនស្សិនា
អក្ខាតា លោកហិតេន វិវេកទស្សិនា
អាបត្តិយោ តេន សមុដ្ឋិតា កតិ
បុច្ឆាមិ តំ ព្រូហិ វិភង្គកោវិទ ។
សមុដ្ឋានា កាយិកា វាចសិកា អនត្តនស្សិនា
អក្ខាតា លោកហិតេន វិវេកទស្សិនា

សមុដ្ឋានដែលប្រកបដោយវាចា ព្រះមានព្រះភាគ ទ្រង់ឃើញនូវធម៌គ្មានទីបំផុត មានព្រះហឫទ័យជាប្រយោជន៍ ដល់សត្វលោក ទ្រង់ឃើញនូវវិវេកធម៌ បានសម្តែងហើយថា អាបត្តិ ដែលតាំងឡើងអំពីវាចានោះ មាន ៤ ។ បពិត្រលោកអ្នកឈ្លាសក្នុងវិភង្គ ខ្ញុំប្រាប់សមុដ្ឋាន ដែលកើតអំពីវាចានោះដល់លោក ។ សមុដ្ឋានដែលតាំងឡើងអំពីកាយនិងតាំងឡើងអំពីវាចា ព្រះមានព្រះភាគ ទ្រង់ឃើញនូវធម៌គ្មានទីបំផុត មានព្រះហឫទ័យជាប្រយោជន៍ ដល់សត្វលោកទ្រង់ឃើញនូវវិវេកធម៌ បានសម្តែងហើយថា អាបត្តិប៉ុន្មាន ដែលតាំងឡើងអំពីកាយនិងវាចានោះ បពិត្រលោកអ្នកឈ្លាសក្នុងវិភង្គ ខ្ញុំសូមសួរសមុដ្ឋាន ដែលតាំងឡើងអំពីកាយនិងវាចានោះ សូមលោកឆ្លើយមក ។ សមុដ្ឋានដែលតាំងឡើង អំពីកាយនិងវាចា ព្រះមានព្រះភាគ ទ្រង់ឃើញនូវធម៌គ្មានទីបំផុត មានព្រះហឫទ័យ ជាប្រយោជន៍ ដល់សត្វលោក ទ្រង់ឃើញនូវវិវេកធម៌ បានសម្តែងហើយ

អាបត្តិយោ តេន សមុដ្ឋិតា បញ្ច ។
ឯតេន្តេ អក្ខាមិ វិភង្គកោវិទ ។
សមុដ្ឋានា កាយិកា មានសិកា អនន្តទស្សិនា
អក្ខាតា លោកហិតេន វិវេកទស្សិនា
អាបត្តិយោ តេន សមុដ្ឋិតា កតិ
បុច្ឆាមិ តំ ព្រូហិ វិភង្គកោវិទ ។
សមុដ្ឋានា កាយិកា មានសិកា អនន្តទស្សិនា
អក្ខាតា លោកហិតេន វិវេកទស្សិនា
អាបត្តិយោ តេន សមុដ្ឋិតា ឆ ។
ឯតេន្តេ អក្ខាមិ វិភង្គកោវិទ ។
សមុដ្ឋានា វាចសិកា មានសិកា អនន្តទស្សិនា

ថា អាបត្តិដែលតាំងឡើងអំពីកាយនិងវាចានោះ មាន ៥ ។ បពិត្រលោកអ្នកឈ្លាស ក្នុងវិភង្គ ខ្ញុំប្រាប់នូវសមុដ្ឋានទាំង៥នុ៎ះ ដល់លោក ។ សមុដ្ឋានដែលតាំងឡើងអំពីកាយនិងចិត្ត ព្រះមានព្រះភាគ ទ្រង់ឃើញនូវធម៌គ្មានទីបំផុត មានព្រះហឫទ័យជាប្រយោជន៍ ដល់សត្វលោក ទ្រង់ឃើញនូវវិវេកធម៌ បានសម្តែងហើយថា អាបត្តិប៉ុន្មាន ដែលតាំងឡើងអំពីកាយនិងចិត្តនោះ បពិត្រលោកអ្នកឈ្លាសក្នុងវិភង្គ ខ្ញុំសូមសួរនូវសមុដ្ឋាន ដែលតាំងឡើងអំពីកាយនិងចិត្តនោះ សូមលោកឆ្លើយមក ។ សមុដ្ឋានដែលតាំងឡើងអំពីកាយនិងចិត្ត ព្រះមានព្រះភាគ ទ្រង់ឃើញនូវធម៌គ្មានទីបំផុត មានព្រះហឫទ័យជាប្រយោជន៍ដល់សត្វលោក ទ្រង់ឃើញនូវវិវេកធម៌ បានសម្តែងហើយថា អាបត្តិដែលតាំងឡើងអំពីកាយនិងចិត្តនោះ មាន ៦ ។ បពិត្រលោកអ្នកឈ្លាសក្នុងវិភង្គ ខ្ញុំប្រាប់សមុដ្ឋាន ដែលតាំងឡើងអំពីកាយនិងចិត្តិនោះ ដល់លោក ។ សមុដ្ឋានដែលតាំងឡើងអំពីវាចានិងចិត្ត ព្រះមានព្រះភាគទ្រង់ឃើញនូវធម៌គ្មានទីបំផុត

វីសតិ វារា អាបត្តិសមុដ្ឋានគាថា

អក្ខាតា លោកហិតេន វិវេកទស្សិនា

អាបត្តិយោ តេន សមុដ្ឋិតា កតិ

បុច្ឆាមិ តំ ព្រូហិ វិភង្គកោវិទ ។

សមុដ្ឋានា វាចសិកា មានសិកា អនន្តទស្សិនា

អក្ខាតា លោកហិតេន វិវេកទស្សិនា

អាបត្តិយោ តេន សមុដ្ឋិតា ឆ ។

ឯតន្តេ អក្ខាមិ វិភង្គកោវិទ ។

សមុដ្ឋានា កាយិកា វាចសិកា មានសិកា អនន្តទស្សិនា

អក្ខាតា លោកហិតេន វិវេកទស្សិនា

អាបត្តិយោ តេន សមុដ្ឋិតា កតិ

បុច្ឆាមិ តំ ព្រូហិ វិភង្គកោវិទ ។

វីសតិវារៈ អាបត្តិសមុដ្ឋានគាថា

មានព្រះហឫទ័យជាប្រយោជន៍ ដល់សត្វលោក ទ្រង់ឃើញនូវវិវេកធម៌ បានសម្តែងហើយថា អាបត្តិប៉ុន្មាន ដែលតាំងឡើងអំពីវាចានិងចិត្តនោះ បពិត្រលោកអ្នកឈ្លាសក្នុងវិភង្គ ខ្ញុំសូមសួរសមុដ្ឋាន ដែលតាំងឡើងអំពីវាចានិងចិត្តនោះ សូមលោកឆ្លើយមក ។ សមុដ្ឋានដែលតាំងឡើងអំពីវាចានិងចិត្ត ព្រះមានព្រះភាគ ទ្រង់ឃើញនូវធម៌គ្មានទីបំផុត មានព្រះហឫទ័យជាប្រយោជន៍ ដល់សត្វលោក ទ្រង់ឃើញនូវវិវេកធម៌ បានសម្តែងមកហើយថា អាបត្តិដែលតាំងឡើងអំពីវាចានិងចិត្តនោះ មាន ៦ ។ បពិត្រលោកអ្នកឈ្លាសក្នុងវិភង្គ ខ្ញុំប្រាប់សមុដ្ឋាន ដែលតាំងឡើងអំពីវាចានិងចិត្តនោះ ដល់លោក ។ សមុដ្ឋានដែលតាំងឡើងអំពីកាយវាចានិងចិត្ត ព្រះមានព្រះភាគ ទ្រង់ឃើញនូវធម៌គ្មានទីបំផុត មានព្រះហឫទ័យជាប្រយោជន៍ ដល់សត្វលោក ទ្រង់ឃើញ នូវវិវេកធម៌ បានសម្តែងហើយថា អាបត្តិប៉ុន្មាន ដែលតាំងឡើងអំពីកាយវាចានិងចិត្តនោះ បពិត្រលោកអ្នកឈ្លាសក្នុងវិភង្គ ខ្ញុំសូមសួរសមុដ្ឋាន ដែលតាំងឡើងអំពីកាយវាចានិងចិត្តនោះ សូមលោកឆ្លើយមក ។

សមុដ្ឋានា កាយិកា វាចសិកា មានសិកា អឆន្ទនស្សិតា
អក្ខាតា លោកហិតេន វិវេកទស្សិនា
អាបត្តិយោ តេន សមុដ្ឋិតា ឆ ។
ឯតន្តេ អក្ខាមិ វិភង្គកោវិទាតិ ។

អាបត្តិសមុដ្ឋានគាថា និដ្ឋិតា តតិយា ។

[៨៧៤] សីលវិបត្តិប្បច្ចយា កតិ អាបត្តិយោ អាបជ្ជតិ ។ សីលវិបត្តិប្បច្ចយា ចតស្សោ អាបត្តិយោ អាបជ្ជតិ ភិក្ខុនី ជានំ បារាជិកំ ធម្មំ បដិច្ឆាទេតិ អាបត្តិ បារាជិកស្ស ។ វេមតិកា បដិច្ឆាទេតិ អាបត្តិ ថុល្លច្ចយស្ស ។ ភិក្ខុ សង្ឃាទិសេសំ បដិច្ឆាទេតិ អាបត្តិ បាចិត្តិយស្ស ។ អត្តនោ ទុដ្ឋុល្លំ អាបត្តឹ បដិច្ឆាទេតិ អាបត្តិ ទុក្កដស្ស ។ សីលវិបត្តិប្បច្ចយា ឥមា ចតស្សោ អាបត្តិយោ អាបជ្ជតិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ បេ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មន្តិ ។

សមុដ្ឋានដែលតាំងឡើង អំពីកាយវាចានិងចិត្ត ព្រះមានព្រះភាគទ្រង់ឃើញនូវធម៌គ្មានទីបំផុត មានព្រះហឫទ័យជាប្រយោជន៍ ដល់សត្វលោក ទ្រង់ឃើញនូវវិវេកធម៌ បានសម្តែងហើយថា អាបត្តិ ដែលតាំងឡើងអំពីកាយវាចានិងចិត្តនោះមាន ៦ ។ បពិត្រលោកអ្នកឈ្លាសក្នុងវិកប្ប ខ្ញុំប្រាប់សមុដ្ឋានដែលតាំងឡើងអំពីកាយវាចានិងចិត្តនោះ ដល់លោក ។

ចប់ អាបត្តិសមុដ្ឋានគាថាជាគម្រប់ ៣ ។

[៨៧៤] សួរថា ភិក្ខុ ភិក្ខុនីត្រូវអាបត្តិប៉ុន្មាន ព្រោះសីលវិបត្តិជាបច្ច័យ ។ ឆ្លើយថា ត្រូវអាបត្តិ ៤ ព្រោះសីលវិបត្តិ ជាបច្ច័យ គឺភិក្ខុនីដឹងថា (ភិក្ខុនីផងគ្នា) ត្រូវអាបត្តិបារាជិកហើយបិទបាំងទុក ត្រូវអាបត្តិបារាជិក ។ ភិក្ខុនីមានសេចក្តីសង្ស័យហើយបិទបាំងទុក ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុបិទបាំងអាបត្តិសង្ឃាទិសេស ត្រូវអាបត្តិបាចិត្តិយៈ ។ ភិក្ខុបិទបាំងអាបត្តិអាក្រក់របស់ខ្លួន ត្រូវអាបត្តិទុក្កដ ។ ភិក្ខុត្រូវអាបត្តិ ៤ នេះ ព្រោះសីលវិបត្តិជាបច្ច័យ ។ បណ្តាវិបត្តិ ៤ អាបត្តិទាំងនោះរាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន ។ បេ ។ បណ្តាសមថៈ ៧ រម្ងាប់ដោយ

តា អាបត្តិយោ ចតុន្នំ វិបត្តីនំ ទ្វេ វិបត្តិយោ ភជន្តិ សិយា សីលវិបត្តឹ សិយា អាចារវិបត្តឹ ។ សត្តន្នំ អាបត្តិក្ខន្ធានំ ចតូហិ អាបត្តិក្ខន្ធេហិ សង្គហិតា សិយា ចារាជិកាបត្តិក្ខន្ធេន សិយា ថុល្លច្ចយាបត្តិក្ខន្ធេន សិយា ចាចិត្តិយាបត្តិក្ខន្ធេន សិយា ទុក្កដាបត្តិក្ខន្ធេន ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋហន្តិ កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ។ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មន្តិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។

[៨៧៤] អាចារវិបត្តិប្បច្ចយា កតិ អាបត្តិយោ អាបជ្ជតិ អាចារវិបត្តិប្បច្ចយា ឯកំ អាបត្តឹ អាបជ្ជតិ អាចារវិបត្តឹ បដិច្ឆាទេតិ អាបត្តិ ទុក្កដស្ស ។ អាចារវិបត្តិប្បច្ចយា ឥមំ ឯកំ អាបត្តឹ អាបជ្ជតិ ។ សា អាបត្តិ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជតិ ។ បេ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មតិ ។ សា អាបត្តិ ចតុន្នំ វិបត្តីនំ ឯកំ

សមថៈប៉ុន្មាន ។ បណ្តាវិបត្តិទាំង ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ ២ គឺសីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន ។ បណ្តាកងនៃអាបត្តិ ៧ លោកសង្គ្រោះ ដោយកងនៃអាបត្តិ ៤ គឺកងនៃអាបត្តិ បារាជិកក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិ ៦ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយវាចានិងចិត្ត ។ បណ្តាអធិករណ៍ ៤ ចាត់ជាអាបត្តាធិករណ៍ ។ បណ្តាសមថៈ ៧ រម្ងាប់ដោយសមថៈ ៣ គឺដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យ និងតិណវត្ថារកៈក៏មាន ។

[៨៧៥] ភិក្ខុត្រូវអាបត្តិប៉ុន្មាន ព្រោះអាចារវិបត្តិ ជាបច្ច័យ ។ ភិក្ខុត្រូវអាបត្តិ ១ ព្រោះអាចារវិបត្តិ ជាបច្ច័យ គឺភិក្ខុបិទបាំងអាចារវិបត្តិ (របស់ភិក្ខុផងគ្នា) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុត្រូវអាបត្តិ ១ នេះ ព្រោះអាចារវិបត្តិ ជាបច្ច័យ ។ បណ្តាវិបត្តិ ៤ អាបត្តិនោះ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន ។ បេ ។ បណ្តាសមថៈ ៧ រម្ងាប់ដោយសមថៈប៉ុន្មាន ។ បណ្តាវិបត្តិ ៤ អាបត្តិនោះ រាប់បញ្ចូល ក្នុងវិបត្តិ ១

វិបត្តឹ ភជតិ អាចារវិបត្តឹ ។ សត្តន្នំ អាបត្តិក្ខន្ធានំ ឯកេន អាបត្តិក្ខន្ធេន សង្គហិតា ទុក្កដាបត្តិក្ខន្ធេន ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋាតិ កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋាតិ ។ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មតិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។

[៨៧៦] ទិដ្ឋិវិបត្តិប្បច្ចយា កតិ អាបត្តិយោ អាបជ្ជតិ ។ ទិដ្ឋិវិបត្តិប្បច្ចយា ទ្វេ អាបត្តិយោ អាបជ្ជតិ បាបិកាយ ទិដ្ឋិយា យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជតិ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ទុក្កដា កម្មវាចាបរិយោសានេ អាបត្តិ បាចិត្តិយស្ស ។ ទិដ្ឋិវិបត្តិប្បច្ចយា ឥមា ទ្វេ អាបត្តិយោ អាបជ្ជតិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ បេ ។

គឺអាចារវិបត្តិ ។ បណ្តាកងនៃអាបត្តិ ៧ លោកសង្គ្រោះដោយកងនៃអាបត្តិ ១ គឺកងនៃអាបត្តិទុក្កដ ។ បណ្តាសមុដ្ឋាននៃអាបត្តិ ៦ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយវាចានិងចិត្ត ។ បណ្តាអធិករណ៍ ៤ ចាត់ជាអាបត្តាធិករណ៍ ។ បណ្តាសមថៈ ៧ រម្ងាប់ដោយសមថៈ ៣ គឺដោយសម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន ។

[៨៧៦] ភិក្ខុត្រូវអាបត្តិប៉ុន្មាន ព្រោះទិដ្ឋិវិបត្តិ ជាបច្ច័យ ។ ត្រូវអាបត្តិ ២ ព្រោះទិដ្ឋិវិបត្តិ ជាបច្ច័យ គឺកាលភិក្ខុទាំងឡាយសូត្រសមនុភាសនកម្មចប់ ជាគម្រប់ ៣ ដងហើយ ភិក្ខុមិនព្រមលះបង់ទិដ្ឋិអាក្រក់ចេញ កាលបើចប់ញត្តិ ត្រូវអាបត្តិទុក្កដ កាលបើចប់កម្មវាចា ២ លើក ត្រូវអាបត្តិទុក្កដទាំងឡាយ លុះចប់កម្មវាចា ត្រូវអាបត្តិបាចិត្តិយៈ ។ ភិក្ខុត្រូវអាបត្តិ ២ នេះ ព្រោះទិដ្ឋិវិបត្តិ ជាបច្ច័យ ។ បណ្តាវិបត្តិ ៤ អាបត្តិទាំងនោះ រាប់បញ្ចូល ក្នុងវិបត្តិប៉ុន្មាន ។ បេ ។

សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មន្តិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ ឯកំ វិបត្តឹ ភជន្តិ អាចារវិបត្តឹ ។ សត្តន្នំ អាបត្តិក្ខន្ធានំ ទ្វីហិ អាបត្តិក្ខន្ធេហិ សង្គហិតា សិយា ថុល្លច្ចយាបត្តិក្ខន្ធេន សិយា ទុក្កដាបត្តិក្ខន្ធេន ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋហន្តិ កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ។ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មន្តិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។

[៨៧៧] អាជីវវិបត្តិប្បច្ចយា កតិ អាបត្តិយោ អាបជ្ជតិ ។ អាជីវវិបត្តិប្បច្ចយា ឆ អាបត្តិយោ អាបជ្ជតិ អាជីវហេតុ អាជីវការណា បាបិច្ឆោ ឥច្ឆាបកតោ អសន្តំ អភូតំ ឧត្តរិមនុស្សធម្មំ ឧល្លបតិ អាបត្តិ បារាជិកស្ស ។ អាជីវហេតុ អាជីវការណា សញ្ចរិត្តំ សមាបជ្ជតិ អាបត្តិ សង្ឃាទិសេសស្ស ។ អាជីវហេតុ អាជីវការណា យោ តេ វិហារេ វសតិ សោ ភិក្ខុ អរហាតិ

បណ្តាសមថៈ ៧ រម្ងាប់ដោយសមថៈប៉ុន្មាន ។ បណ្តាវិបត្តិ ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ ១ គឺអាចារវិបត្តិ ។ បណ្តាកងនៃអាបត្តិទាំង ៧ លោកសង្គ្រោះដោយកងនៃអាបត្តិ ២ គឺកងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិ ៦ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយវាចាចិត្ត ។ បណ្តាអធិករណ៍ ៤ ចាត់ជាអាបត្តាធិករណ៍ ។ បណ្តាសមថៈ ៧ រម្ងាប់ដោយសមថៈ ៣ គឺដោយសម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន ។

[៨៧៧] ភិក្ខុ ភិក្ខុនី ត្រូវអាបត្តិប៉ុន្មាន ព្រោះអាជីវវិបត្តិជាបច្ច័យ ។ ត្រូវអាបត្តិ ៦ ព្រោះអាជីវវិបត្តិជាបច្ច័យ គឺ ភិក្ខុមានសេចក្តីប្រាថ្នាអាក្រក់ លុះក្នុងអំណាចសេចក្តីប្រាថ្នា ក៏ពោលអួតឧត្តរិមនុស្សធម្ម ដែលមិនមាន មិនពិត ព្រោះហេតុអាជីវៈ ព្រោះដំណើរអាជីវៈ ត្រូវអាបត្តិបារាជិក ។ ភិក្ខុនិយាយដឹកនាំបុរសស្ត្រីឲ្យបានគ្នាជាប្តីប្រពន្ធ ព្រោះហេតុអាជីវៈ ព្រោះដំណើរអាជីវៈ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុនិយាយ (ប្រាប់គេ) ថា ភិក្ខុណា នៅក្នុងវិហាររបស់អ្នក ភិក្ខុនោះ ជាអរហន្ត ដូច្នេះ ព្រោះហេតុអាជីវៈ ព្រោះដំណើរអាជីវៈ កាលបើអ្នកស្តាប់ដឹង

ភណតិ បដិវិជានន្តស្ស អាបត្តិ ថុល្លច្ចយស្ស ។ អាជីវហេតុ អាជីវការណា ភិក្ខុ បណីតភោជនានិ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជតិ អាបត្តិ បាចិត្តិយស្ស ។ អាជីវហេតុ អាជីវការណា ភិក្ខុនី បណីតភោជនានិ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជតិ អាបត្តិ បាដិទេសនីយស្ស ។ អាជីវហេតុ អាជីវការណា ភិក្ខុ[១] សូបំ វា ឱទនំ វា អគិលានោ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជតិ អាបត្តិ ទុក្កដស្ស ។ អាជីវវិបត្តិប្បច្ចយា ឥមា ច អាបត្តិយោ អាបជ្ជតិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ បេ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មន្តិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ ទ្វេ វិបត្តិយោ ភជន្តិ សិយា សីលវិបត្តឹ សិយា អាចារវិបត្តឹ ។ សត្តន្នំ អាបត្តិក្ខន្ធានំ ឆហិ អាបត្តិក្ខន្ធេហិ សង្គហិតា សិយា បារាជិកាបត្តិក្ខន្ធេន សិយា សង្ឃាទិសេសាបត្តិក្ខន្ធេន សិយា ថុល្លច្ចយាបត្តិក្ខន្ធេន សិយា បាចិត្តិយាបត្តិក្ខន្ធេន សិយា

១ ឱ. ម. បោត្ថកេសុ ភិក្ខូតិ បាឋោ ន បញ្ញាយតិ ។

សេចក្តីច្បាស់ (ភិក្ខុនោះ) ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុសូមបណីតភោជន ដើម្បីប្រយោជន៍ខ្លួនឆាន់ ព្រោះហេតុអាជីវៈ ព្រោះដំណើរអាជីវៈ ត្រូវអាបត្តិបាចិត្តិយៈ ។ ភិក្ខុនីសូមបណីតភោជន ដើម្បីប្រយោជន៍ខ្លួនឆាន់ ព្រោះហេតុអាជីវៈ ព្រោះដំណើរអាជីវៈ ត្រូវអាបត្តិបាដិទេសនីយៈ ។ ភិក្ខុមិនឈឺ សូមសម្លក្តី បាយក្តី ដើម្បីប្រយោជន៍ខ្លួនយកមកឆាន់ ព្រោះហេតុអាជីវៈ ព្រោះដំណើរអាជីវៈ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុភិក្ខុនីត្រូវអាបត្តិ ៦ នេះ ព្រោះអាជីវវិបត្តិជាបច្ច័យ ។ បណ្តាវិបត្តិ ៤ អាបត្តិទាំងនោះ រាប់បញ្ចូល ក្នុងវិបត្តិប៉ុន្មាន ។ បេ ។ បណ្តាសមថៈ ៧ រម្ងាប់ដោយសមថៈប៉ុន្មាន ។ បណ្តាវិបត្តិ ៤ អាបត្តិទាំងនោះ រាប់បញ្ចូល ក្នុងវិបត្តិ ២ គឺ សីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន ។ បណ្តាកងនៃអាបត្តិ ៧ លោកសង្គ្រោះដោយកងនៃអាបត្តិ ៦ គឺ កងនៃអាបត្តិបារាជិកក៏មាន កងនៃអាបត្តិសង្ឃាទិសេសក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃ

ចាជិនេសនីយាបត្តិក្ខន្ធេន សិយា ទុក្កដាបត្តិក្ខន្ធេន ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឆហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ សិយា កាយតោ សមុដ្ឋហន្តិ ន វាចតោ ន ចិត្តតោ សិយា វាចតោ សមុដ្ឋហន្តិ ន កាយតោ ន ចិត្តតោ សិយា កាយតោ ច វាចតោ ច សមុដ្ឋហន្តិ ន ចិត្ត-តោ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ។ ចតុន្នំ អធិករណានំ អាបត្តាធិ-ករណំ ។ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មន្តិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។

វិបត្តិប្បច្ចយវារំ និដ្ឋិតំ ចតុត្ថំ ។

[៨៧៨] វិវាទាធិករណប្បច្ចយា កតិ អាបត្តិយោ អាបជ្ជតិ ។ វិវាទាធិករណប្បច្ចយា ទ្វេ អាបត្តិយោ

អាបត្តិបាដិទេសនីយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន ។ បណ្ដាសមុដ្ឋាន នៃអាបត្តិ ៦ អាបត្តិទាំងនោះ តាំងឡើងដោយសមុដ្ឋាន ៦ គឺតាំងឡើង អំពីកាយ មិនតាំងឡើងអំពីវាចា មិនបានតាំងឡើងអំពីចិត្តក៏មាន តាំងឡើង អំពីវាចា មិនតាំងឡើងអំពីកាយ មិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើង អំពីកាយនិងវាចា មិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយចិត្ត មិនតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចាចិត្ត មិនតាំងឡើង អំពីកាយក៏មាន តាំងឡើងអំពីកាយវាចានិងចិត្តក៏មាន ។ បណ្ដាអធិក-រណ៍ ៤ ចាត់ជាអាបត្តាធិករណ៍ ។ បណ្ដាសមថៈ ៧ រម្ងាប់ ដោយសមថៈ ៣ គឺដោយសម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មាន ដោយ សម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន ។

ចប់ វិបត្តិប្បច្ចយវារៈជាគម្រប់ ៤ ។

[៨៧៨] ភិក្ខុត្រូវអាបត្តិប៉ុន្មាន ព្រោះវិវាទាធិករណ៍ ជាបច្ច័យ ។ ភិក្ខុត្រូវអាបត្តិ ២ ព្រោះវិវាទាធិករណ៍ ជាបច្ច័យ គឺភិក្ខុពោលពាក្យ

៤០២



អាបជ្ជតិ ឧបសម្បន្នំ ឱមសតិ អាបត្តិ បាចិត្តិយស្ស ។ អនុបសម្បន្នំ ឱមសតិ អាបត្តិ ទុក្កដស្ស ។ វិវាទាធិករណប្បច្ចយា ឥមា ទ្វេ អាបត្តិយោ អាបជ្ជតិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ បេ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មន្តិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ ឯកំ វិបត្តឹ ភជន្តិ អាចារវិបត្តឹ ។ សត្តន្នំ អាបត្តិក្ខន្ធានំ ទ្វីហិ អាបត្តិក្ខន្ធេហិ សង្គហិតា សិយា បាចិត្តិយាបត្តិក្ខន្ធេន សិយា ទុក្កដាបត្តិក្ខន្ធេន ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ សិយា កាយតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ។ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មន្តិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។

ចាក់ដោតឧបសម្ប័ន្ន ត្រូវអាបត្តិបាចិត្តិយៈ ។ ភិក្ខុពោលពាក្យចាក់ដោតអនុបសម្ប័ន្ន ត្រូវអាបត្តិទុក្កដ ។ ភិក្ខុត្រូវអាបត្តិ ២ នេះ ព្រោះវិវាទាធិករណ៍ជាបច្ច័យ ។ បណ្តាវិបត្តិ ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន ។ បេ ។ បណ្តាសមថៈ ៧ រម្ងាប់ដោយសមថៈប៉ុន្មាន ។ បណ្តាវិបត្តិ ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ ១ គឺអាចារវិបត្តិ ។ បណ្តាកងនៃអាបត្តិ ៧ លោកសង្រ្គោះដោយកងនៃអាបត្តិ ២ គឺកងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិ ៦ អាបត្តិទាំងនោះ តាំងឡើងដោយសមុដ្ឋាន ៣ គឺតាំងឡើងអំពីកាយបិត្ត មិនតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចាចិត្ត មិនតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយវាចាចិត្តក៏មាន ។ បណ្តាអធិករណ៍ ៤ ចាត់ជាអាបត្តាធិករណ៍ ។ បណ្តាសមថៈ ៧ រម្ងាប់ដោយសមថៈ ៣ គឺដោយសម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន ។

វីសតិ វារា អធិករណប្បច្ចយវារំ

[៨៧៩] អនុវាទាធិករណប្បច្ចយា កតិ អាបត្តិយោ អាបជ្ជតិ ។ អនុវាទាធិករណប្បច្ចយា តិស្សោ អាបត្តិយោ អាបជ្ជតិ ភិក្ខុំ អមូលកេន បារាជិកេន ធម្មេន អនុទ្ធំសេតិ អាបត្តិ សង្ឃាទិសេសស្ស ។ អមូលកេន សង្ឃាទិសេសេន អនុទ្ធំសេតិ អាបត្តិ បាចិត្តិយស្ស ។ អមូលិកាយ អាចារវិបត្តិយា អនុទ្ធំសេតិ អាបត្តិ ទុក្កដស្ស ។ អនុវាទាធិករណប្បច្ចយា ឥមា តិស្សោ អាបត្តិយោ អាបជ្ជតិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ បេ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មន្តិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ ទ្វេ វិបត្តិយោ ភជន្តិ សិយា សីលវិបត្តឹ សិយា អាចារវិបត្តឹ ។ សត្តន្នំ អាបត្តិក្ខន្ធានំ តីហិ អាបត្តិក្ខន្ធេហិ សង្គហិតា សិយា សង្ឃាទិសេសាបត្តិក្ខន្ធេន សិយា បាចិត្តិយាបត្តិក្ខន្ធេន សិយា ទុក្កដាបត្តិក្ខន្ធេន ។ ឆន្នំ អាបត្តិសមុដ្ឋានានំ តីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ សិយា កាយតោ ច

[៨៧៩] ភិក្ខុត្រូវអាបត្តិប៉ុន្មាន ព្រោះអនុវាទាធិករណ៍ ជាបច្ច័យ ។ ភិក្ខុត្រូវអាបត្តិ ៣ ព្រោះអនុវាទាធិករណ៍ ជាបច្ច័យ គឺភិក្ខុចោទភិក្ខុផងគ្នា ដោយអាបត្តិបារាជិកមិនមានមូល ត្រូវអាបត្តិសង្ឃាទិ-សេស ។ ភិក្ខុចោទភិក្ខុផងគ្នា ដោយអាបត្តិសង្ឃាទិសេស មិនមានមូល ត្រូវអាបត្តិបាចិត្តិយៈ ។ ភិក្ខុចោទភិក្ខុផងគ្នា ដោយអាចារវិបត្តិ មិនមានមូល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុត្រូវអាបត្តិ ៣ នេះ ព្រោះអនុវាទាធិករណ៍ជាបច្ច័យ ។ បណ្តាវិបត្តិ ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន ។ បេ ។ បណ្តាសមថៈ ៧ រម្ងាប់ដោយសមថៈប៉ុន្មាន ។ បណ្តាវិបត្តិ ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ ២ គឺសីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន ។ បណ្តាកងនៃអាបត្តិ ៧ លោកសង្គ្រោះដោយកងនៃអាបត្តិ ៣ គឺ កងនៃអាបត្តិសង្ឃាទិសេសក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិ ៦ តាំងឡើងដោយសមុដ្ឋាន ៣ គឺតាំងឡើងអំពី

ចិត្តតោ ច សមុដ្ឋហន្តិ ន វាចតោ សិយា វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ន កាយតោ សិយា កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ។ ចតុន្នំ អធិក-រណានំ អាបត្តាធិករណំ ។ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មន្តិ សិយា សម្មុខាវិនយេន ច បដិញ្ញា-តករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថា-រកេន ច ។

[៨៨០] អាបត្តាធិករណប្បច្ចយា កតិ អាបត្តិយោ អាបជ្ជតិ ។ អាបត្តាធិករណប្បច្ចយា ចតស្សោ អាបត្តិ-យោ អាបជ្ជតិ ភិក្ខុនី ជានំ បារាជិកំ ធម្មំ បដិច្ឆាទេតិ អាបត្តិ បារាជិកស្ស ។ វេមតិកា បដិច្ឆាទេតិ អាបត្តិ ថុល្លច្ចយស្ស ។ ភិក្ខុ សង្ឃាទិសេសំ បដិច្ឆាទេតិ អាបត្តិ បាចិត្តិយស្ស ។ អាចារវិបត្តឹ បដិច្ឆាទេតិ អា-បត្តិ ទុក្កដស្ស ។ អាបត្តាធិករណប្បច្ចយា ឥមា ចតស្សោ អាបត្តិយោ អាបជ្ជតិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ បេ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មន្តិ ។ តា អាបត្តិ-

កាយចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចាចិត្ត មិនតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយវាចាចិត្ត ក៏មាន ។ បណ្តាអធិករណ៍ ៤ ចាត់ជាអាបត្តាធិករណ៍ ។ បណ្តាសមថៈ ៧ រម្ងាប់ដោយសមថៈ ៣ គឺដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន ។

[៨៨០] ភិក្ខុ ភិក្ខុនី ត្រូវអាបត្តិប៉ុន្មាន ព្រោះអាបត្តាធិករណ៍ ជាបច្ច័យ ។ ត្រូវអាបត្តិ ៤ ព្រោះអាបត្តាធិករណ៍ជាបច្ច័យ គឺភិក្ខុនីដឹងថា (ភិក្ខុនីផងគ្នា) ត្រូវអាបត្តិបារាជិក ហើយបិទបាំងទុក ត្រូវអាបត្តិបារាជិក ។ ភិក្ខុនីមានសេចក្តីសង្ស័យហើយ បិទបាំង (នូវអាបត្តិបារាជិកដែលខ្លួនដឹងហើយ) ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុបិទបាំងអាបត្តិសង្ឃាទិសេស ត្រូវអាបត្តិបាចិត្តិយៈ ។ ភិក្ខុបិទបាំងអាចារវិបត្តិ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុ ភិក្ខុនី ត្រូវអាបត្តិ ៤ នេះ ព្រោះអាបត្តាធិករណ៍ជាបច្ច័យ ។ បណ្តាវិបត្តិ ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន ។ បេ ។ បណ្តាសមថៈ ៧ រម្ងាប់ដោយសមថៈប៉ុន្មាន ។ បណ្តា

យោ ចតុន្នំ វិបត្តីនំ ទ្វេ វិបត្តិយោ ភជន្តិ សិយា សីលវិបត្តី សិយា អាចារវិបត្តី ។ សត្តន្នំ អាបត្តិក្ខន្ធានំ ចតូហិ អាបត្តិក្ខន្ធេហិ សង្គហិតា សិយា ថាបជិកាបត្តិក្ខន្ធេន សិយា ថុល្លច្ចយាបត្តិក្ខន្ធេន សិយា ថាចិត្តិយាបត្តិក្ខន្ធេន សិយា ទុក្កដាបត្តិក្ខន្ធេន ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋហន្តិ កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ។ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មន្តិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។

[៨៨១] កិច្ចាធិករណប្បច្ចយា កតិ អាបត្តិយោ អាបជ្ជតិ ។ កិច្ចាធិករណប្បច្ចយា បញ្ច អាបត្តិយោ អាបជ្ជតិ ឧក្ខិត្តានុវត្តិកា ភិក្ខុនី យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជតិ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា កម្មវាចាបរិយោសានេ អាបត្តិ ថារាជិកស្ស ។ ភេទកានុវត្តកា ភិក្ខូ យាវតតិយំ សម-

វិបត្តិ ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ ២ គឺសីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន ។ បណ្តាកងនៃអាបត្តិទាំង ៧ លោកសង្គ្រោះដោយកងនៃអាបត្តិ ៤ គឺកងនៃអាបត្តិបារាជិកក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន ។ បណ្តាសមុដ្ឋាននៃអាបត្តិ ៦ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយវាចាចិត្ត ។ បណ្តាអធិករណ៍ ៤ ចាត់ជាអាបត្តាធិករណ៍ ។ បណ្តាសមថៈ ៧ រម្ងាប់ដោយសមថៈ ៣ គឺដោយសម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន ។

[៨៨១] ភិក្ខុ ភិក្ខុនី ត្រូវអាបត្តិប៉ុន្មាន ព្រោះកិច្ចាធិករណ៍ ជាបច្ច័យ ។ ត្រូវអាបត្តិ ៥ ព្រោះកិច្ចាធិករណ៍ ជាបច្ច័យ គឺភិក្ខុនីជាអ្នកប្រព្រឹត្តតាមភិក្ខុនី ដែលសង្ឃលើកវត្ត កាលបើសង្ឃសូត្រសមនុភា-សនកម្មជាគម្រប់ ៣ ដងចប់ហើយ នៅតែមិនលះបង់ លុះចប់ញត្តិ ត្រូវអាបត្តិទុក្កដ ចប់កម្មវាចាពីរលើក ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ លុះចប់កម្មវាចា ត្រូវអាបត្តិបារាជិក ។ ពួកភិក្ខុប្រព្រឹត្តតាមភិក្ខុអ្នកបំបែកសង្ឃ កាលបើសង្ឃសូត្រសមនុភាសនកម្មជាគម្រប់ ៣ ដងចប់ហើយ នៅ

នុភាសនាយ នប្បដិនិស្សជ្ជន្តិ អាបត្តិ សង្ឃាទិសេសស្ស ។ បាបិកាយ ទិដ្ឋិយា យាវតតិយំ សមនុភាសនាយ នប្បដិនិស្សជ្ជតិ អាបត្តិ បាចិត្តិយស្ស ។ កិច្ចាធិករណប្បច្ចយា ឥមា បញ្ច អាបត្តិយោ អាបជ្ជតិ ។ តា អាបត្តិយោ សត្តន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ បេ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មន្តិ ។ តា អាបត្តិយោ ចតុន្នំ វិបត្តីនំ ទ្វេ វិបត្តិយោ ភជន្តិ សិយា សីលវិបត្តឹ សិយា អាចារវិបត្តឹ ។ សត្តន្នំ អាបត្តិក្ខន្ធានំ បញ្ចហិ អាបត្តិក្ខន្ធេហិ សង្គហិតា សិយា បារាជិកាបត្តិក្ខន្ធេន សិយា សង្ឃាទិសេសាបត្តិក្ខន្ធេន សិយា ថុល្លច្ចយាបត្តិក្ខន្ធេន សិយា បាចិត្តិយាបត្តិក្ខន្ធេន សិយា ទុក្កដាបត្តិក្ខន្ធេន ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ឯកេន សមុដ្ឋានេន សមុដ្ឋហន្តិ ។ កាយតោ ច វាចតោ ច ចិត្តតោ ច សមុដ្ឋហន្តិ ។ ចតុន្នំ អធិករណានំ អាបត្តាធិករណំ ។ សត្តន្នំ សមថានំ តីហិ សមថេហិ សម្មន្តិ សិយា សម្មុខាវិនយេន ច បដិញ្ញាតករណេន ច សិយា សម្មុខាវិនយេន ច តិណវត្ថារកេន ច ។

តែមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុមានទិដ្ឋិអាក្រក់ កាលបើសង្ឃសូត្រសមនុភាសនកម្មជាគម្រប់ ៣ ដងចប់ហើយ នៅតែមិនលះបង់ ត្រូវអាបត្តិបាចិត្តិយៈ ។ ភិក្ខុ ភិក្ខុនី ត្រូវអាបត្តិ ៥ នេះ ព្រោះកិច្ចាធិករណ៍ ជាបច្ច័យ ។ បណ្ដាវិបត្តិ ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន ។ បេ ។ បណ្ដាសមថៈ ៧ រម្ងាប់ដោយសមថៈប៉ុន្មាន ។ បណ្ដាវិបត្តិ ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ ២ គឺសីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន ។ បណ្ដាកងនៃអាបត្តិ ៧ លោកសង្គ្រោះដោយកងនៃអាបត្តិ ៥ គឺកងនៃអាបត្តិបារាជិកក៏មាន កងនៃអាបត្តិសង្ឃាទិសេសក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន ។ បណ្ដាសមុដ្ឋាននៃអាបត្តិ ៦ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយវាចាចិត្ត ។ បណ្ដាអធិករណ៍ ៤ ចាត់ជាអាបត្តាធិករណ៍ ។ បណ្ដាសមថៈ ៧ រម្ងាប់ដោយសមថៈ ៣ គឺ ដោយសម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មាន សម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន ។

## វីសតិ វារា អធិករណប្បច្ចយវារំ

[៨៨២] ឋបេត្វា សត្ត អាបត្តិយោ សត្ត អាបត្តិក្ខន្ធេ អវសេសា អាបត្តិយោ ចតុន្នំ វិបត្តីនំ កតិ វិបត្តិយោ ភជន្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ កតីហិ អាបត្តិក្ខន្ធេហិ សង្គហិតា ។ ឆន្នំ អាបត្តិសមុដ្ឋានានំ កតីហិ សមុដ្ឋានេហិ សមុដ្ឋហន្តិ ។ ចតុន្នំ អធិករណានំ កតមំ អធិករណំ ។ សត្តន្នំ សមថានំ កតីហិ សមថេហិ សម្មន្តិ ។ ឋបេត្វា សត្ត អាបត្តិយោ សត្ត អាបត្តិក្ខន្ធេ អវសេសា អាបត្តិយោ ចតុន្នំ វិបត្តីនំ ន កតមំ វិបត្តឹ ភជន្តិ ។ សត្តន្នំ អាបត្តិក្ខន្ធានំ ន[១] កតមេន អាបត្តិក្ខន្ធេន សង្គហិតា ។ ឆន្នំ អាបត្តិសមុដ្ឋានានំ ន[២] កតមេន សមុដ្ឋានេន សមុដ្ឋហន្តិ ។ ចតុន្នំ អធិករណានំ ន[៣] កតមំ អធិករណំ ។ សត្តន្នំ សមថានំ ន[៤] កតមេន សមថេន សម្មន្តិ ។ តំ កិស្ស ហេតុ ។ ឋបេត្វា សត្ត អាបត្តិយោ សត្ត អាបត្តិក្ខន្ធេ នត្ថញ្ញា អាបត្តិយោតិ ។

អធិករណប្បច្ចយវារំ និដ្ឋិតំ បញ្ចមំ ។

អនន្តរបេយ្យាលំ និដ្ឋិតំ ។

---

១-២-៣-៤ ឱ. បោត្ថកេ នសទ្ទោ ន បញ្ញាយតិ ។

វីសតិវារៈ អធិករណប្បច្ចយវារៈ

[៨៨២] បណ្ដាវិបត្តិ ៤ អាបត្តិទាំងឡាយដ៏សេស ក្រៅអំពីអាបត្តិ ៧ និងកងនៃអាបត្តិ ៧ (នោះ) រាប់បញ្ចូល ក្នុងវិបត្តិប៉ុន្មាន ។ បណ្ដាកងនៃអាបត្តិ ៧ លោកសង្គ្រោះ ដោយកងនៃអាបត្តិប៉ុន្មាន ។ បណ្ដាសមុដ្ឋាននៃអាបត្តិ ៦ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន ។ បណ្ដាអធិករណ៍ ៤ ចាត់ជាអធិករណ៍ណា ។ បណ្ដាសមថៈ ៧ រម្ងាប់ដោយសមថៈប៉ុន្មាន ។ បណ្ដាវិបត្តិ ៤ អាបត្តិទាំងឡាយដ៏សេស ក្រៅអំពីអាបត្តិ ៧ និងកងនៃអាបត្តិ ៧ (នោះ) មិនរាប់បញ្ចូលក្នុងវិបត្តិណាមួយឡើយ ។ បណ្ដាកងនៃអាបត្តិ ៧ លោកមិនសង្គ្រោះ ដោយកងនៃអាបត្តិណាមួយឡើយ ។ បណ្ដាសមុដ្ឋាននៃអាបត្តិ ៦ មិនបានតាំងឡើង ដោយសមុដ្ឋានណាមួយឡើយ ។ បណ្ដាអធិករណ៍ ៤ មិនបានចាត់ជាអធិករណ៍ណាមួយឡើយ ។ បណ្ដាសមថៈ ៧ មិនបានរម្ងាប់ដោយសមថៈណាមួយឡើយ ។ សេចក្ដីនោះ ព្រោះហេតុអ្វី ។ ព្រោះហេតុអាបត្តិដទៃ ក្រៅអំពីអាបត្តិ ៧ នោះក៏ឥតមានឡើយ ។

ចប់ អធិករណប្បច្ចយវារៈ ជាគម្រប់ ៥ ។

ចប់ អនន្តរបេយ្យាលតែប៉ុណ្ណោះ ។

# តស្សុទ្ទានំ

[៨៨៣] កតិបុច្ឆា សមុដ្ឋានា
កតាបត្តិ តថេវ ច
សមុដ្ឋានា វិបត្តិ ច
តថាធិករណេន ចាតិ ។

[៨៨៤] វិវាទាធិករណស្ស កឹ បុព្វង្គមំ កតិ ឋានានិ កតិ វត្ថូនិ កតិ ភូមិយោ កតិ ហេតូ កតិ មូលានិ កតីហាការេហិ វិវទតិ វិវាទាធិករណំ កតីហិ សមថេហិ សម្មតិ ។ អនុវាទាធិករណស្ស កឹ បុព្វង្គមំ កតិ ឋានានិ កតិ វត្ថូនិ កតិ ភូមិយោ កតិ ហេតូ កតិ មូលានិ កតីហាការេហិ អនុវ-ទតិ អនុវាទាធិករណំ កតីហិ សមថេហិ សម្មតិ ។ អាបត្តាធិករណស្ស កឹ បុព្វង្គមំ កតិ ឋានានិ កតិ វត្ថូនិ កតិ ភូមិយោ កតិ ហេតូ កតិ មូលានិ កតីហាការេហិ អាបត្តឹ អាបជ្ជតិ អាបត្តាធិករណំ

# ឧទ្ទានគឺបញ្ជីរឿងនៃអនន្តរបេយ្យាលនោះ ដូច្នេះ

[៨៨៣] និយាយអំពីកតិបុច្ឆាវារៈ ១ សមុដ្ឋានវារៈ ១ កតាបត្តិវារៈ ១ សមុដ្ឋានវារៈដូចគ្នា ១ អាបត្តិសមុដ្ឋានវារៈ ១ វិបត្តិវារៈ ១ អធិករណវារៈ ១ ។

[៨៨៤] សួរថា អ្វីជាប្រធាននៃវិវាទាធិករណ៍ វិវាទាធិករណ៍នោះ មានឋានប៉ុន្មាន មានវត្ថុប៉ុន្មាន មានភូមិប៉ុន្មាន មានហេតុប៉ុន្មាន មានមូលប៉ុន្មាន ភិក្ខុជជែកគ្នាដោយអាការប៉ុន្មាន វិវាទាធិករណ៍រម្ងាប់ដោយសមថៈប៉ុន្មាន ។ អ្វីជាប្រធាននៃអនុវាទាធិករណ៍ អនុវាទាធិករណ៍នោះ មានឋានប៉ុន្មាន មានវត្ថុប៉ុន្មាន មានភូមិប៉ុន្មាន មានហេតុប៉ុន្មាន មានមូលប៉ុន្មាន ភិក្ខុចោទប្រកាន់គ្នាដោយអាការប៉ុន្មាន អនុវាទាធិករណ៍រម្ងាប់ដោយសមថៈប៉ុន្មាន ។ អ្វីជាប្រធាននៃអាបត្តាធិករណ៍ អាបត្តាធិករណ៍នោះ មានឋានប៉ុន្មាន មានវត្ថុប៉ុន្មាន ភូមិប៉ុន្មាន មានហេតុប៉ុន្មាន មានមូលប៉ុន្មាន ភិក្ខុត្រូវអាបត្តិដោយអាការប៉ុន្មាន អាបត្តាធិករណ៍

កតីហិ សមថេហិ សម្មតិ ។ កិច្ចាធិករណស្ស កឹ បុព្វង្គមំ កតិ ឋានានិ កតិ វត្ថូនិ កតិ ភូមិយោ កតិ ហេតូ កតិ មូលានិ កតីហាការេហិ កិច្ចំ ជាយតិ កិច្ចាធិករណំ កតីហិ សមថេហិ សម្មតិ ។

[៨៨៥] វិវាទាធិករណស្ស កឹ បុព្វង្គមន្តិ ។ លោភោ បុព្វង្គមោ ទោសោ បុព្វង្គមោ មោហោ បុព្វង្គមោ អលោភោ បុព្វង្គមោ អទោសោ បុព្វង្គមោ អមោហោ បុព្វង្គមោ ។ កតិ ឋានានីតិ ។ អដ្ឋារស ភេទករវត្ថូនិ ឋានានិ ។ កតិ វត្ថូនីតិ ។ អដ្ឋារស ភេទករវត្ថូនិ ។ កតិ ភូមិយោតិ ។ អដ្ឋារស ភេទករវត្ថូនិ ភូមិយោ ។ កតិ ហេតូតិ ។ នវ ហេតូ តយោ កុសលហេតូ តយោ អកុសលហេតូ តយោ អព្យាកតហេតូ ។ កតិ មូលានីតិ ។ ទ្វាទស មូលានិ ។ កតីហាការេហិ វិវទតីតិ ។ ទ្វីហាការេហិ វិវទតិ ធម្មទិដ្ឋិ វា អធម្មទិដ្ឋិ វា ។ វិវាទាធិករណំ កតីហិ សមថេហិ សម្មតីតិ ។ វិវាទាធិករណំ ទ្វីហិ សមថេហិ សម្មតិ សម្មុខាវិនយេន ច យេភុយ្យសិកាយ ច ។

រម្ងាប់ដោយសមថៈប៉ុន្មាន ។ អ្វីជាប្រធាននៃកិច្ចាធិករណ៍ កិច្ចាធិករណ៍នោះ មានឋានប៉ុន្មាន មានវត្ថុប៉ុន្មាន មានភូមិប៉ុន្មាន មានហេតុប៉ុន្មាន មានមូលប៉ុន្មាន កិច្ចកើតឡើងដោយអាការប៉ុន្មាន កិច្ចាធិករណ៍រម្ងាប់ដោយសមថៈប៉ុន្មាន ។

[៨៨៥] ត្រង់ពាក្យសួរថា អ្វីជាប្រធាននៃវិវាទាធិករណ៍ ។ ឆ្លើយថា លោភៈជាប្រធាន ទោសៈជាប្រធាន មោហៈជាប្រធាន អលោភៈជាប្រធាន អទោសៈជាប្រធាន អមោហៈជាប្រធាន ។ ត្រង់ពាក្យសួរថា វិវាទធរណ៍មានឋានប៉ុន្មាន ។ ឆ្លើយថា មានភេទករវត្ថុ ១៨ ជាឋាន ។ ត្រង់ពាក្យសួរថា មានភូមិប៉ុន្មាន ។ ឆ្លើយថា មានភេទករវត្ថុ ១៨ ជាវត្ថុ ។ ត្រង់ពាក្យសួរថា មានភូមិប៉ុន្មាន ។ ឆ្លើយថា មានភេទករវត្ថុ ១៨ ជាភូមិ ។ ត្រង់ពាក្យសួរថា មានហេតុប៉ុន្មាន ។ ឆ្លើយថា មានហេតុ ៩ គឺកុសល-ហេតុ ៣ អកុសលហេតុ ៣ អព្យាកតហេតុ ៣ ។ ត្រង់ពាក្យសួរថា មានមូលប៉ុន្មាន ។ ឆ្លើយថា មានមូល ១២ ។ ត្រង់ពាក្យសួរថា ភិក្ខុជជែកគ្នាដោយអាការប៉ុន្មាន ។ ឆ្លើយថា ភិក្ខុជជែកគ្នាដោយអាការ ២ គឺ សេចក្ដីយល់ឃើញថា ជាធម៌ ១ សេចក្ដីយល់ឃើញថា មិនមែនធម៌ ១ ។ ត្រង់ពាក្យសួរថា វិវាទាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មាន ។ ឆ្លើយថា វិវាទាធិករណ៍រម្ងាប់ដោយសមថៈ ២ គឺ សម្មុខាវិន័យ ១ យេភុយ្យសិកា ១ ។

[៨៨៦] អនុវាទាធិករណស្ស កឹ បុព្វង្គមន្តិ ។ លោភោ បុព្វង្គមោ ទោសោ បុព្វង្គមោ មោហោ បុព្វង្គមោ អលោភោ បុព្វង្គមោ អទោសោ បុព្វង្គមោ អមោហោ បុព្វង្គមោ ។ កតិ ឋានានីតិ ។ ចតស្សោ វិបត្តិយោ ឋានានិ ។ កតិ វត្ថូនីតិ ។ ចតស្សោ វិបត្តិយោ វត្ថូនិ ។ កតិ ភូមិយោតិ ។ ចតស្សោ វិបត្តិយោ ភូមិយោ ។ កតិ ហេតូតិ ។ នវ ហេតូ តយោ កុសលហេតូ តយោ អកុសលហេតូ តយោ អព្យា-កតហេតូ ។ កតិ មូលានីតិ ។ ចុទ្ទស មូលានិ ។ កតីហាការេហិ អនុវទតីតិ ។ ទ្វីហាការេហិ អនុវទតិ វត្ថុតោ វា អាបត្តិតោ វា ។ អនុវាទាធិករណំ កតីហិ សមថេហិ សម្មតីតិ ។ អនុវាទាធិករណំ ចតូហិ សមថេហិ សម្មតិ សម្មុខាវិនយេន ច សតិវិនយេន ច អមូឡ្ហវិនយេន ច តស្សបាបិយសិកាយ ច ។

[៨៨៦] ត្រង់ពាក្យសួរថា អ្វីជាប្រធាននៃអនុវាទាធិករណ៍ ។ ឆ្លើយថា លោភៈជាប្រធាន ទោសៈជាប្រធាន មោហៈជាប្រធាន អលោភៈជាប្រធាន អទោសៈជាប្រធាន អមោហៈជាប្រធាន ។ ត្រង់ពាក្យសួរថា អនុវាទាធិករណ៍មានឋានប៉ុន្មាន ។ ឆ្លើយថា មានវិបត្តិ ៤ ជាឋាន ។ ត្រង់ពាក្យសួរថា មានវត្ថុប៉ុន្មាន ។ ឆ្លើយថា មានវិបត្តិ ៤ ជាវត្ថុ ។ ត្រង់ពាក្យសួរថា មានភូមិប៉ុន្មាន ។ ឆ្លើយថា មានវិបត្តិ ៤ ជាភូមិ ។ ត្រង់ពាក្យសួរថា មានហេតុប៉ុន្មាន ។ ឆ្លើយថា មានហេតុ ៩ គឺកុសលហេតុ ៣ អកុសលហេតុ ៣ អព្យាកតហេតុ ៣ ។ ត្រង់ពាក្យសួរថា មានមូលប៉ុន្មាន ។ ឆ្លើយថា មានមូល ១៤ ។ ត្រង់ពាក្យសួរថា ភិក្ខុចោទប្រកាន់គ្នាដោយអាការប៉ុន្មាន ។ ឆ្លើយថា ភិក្ខុចោទប្រកាន់គ្នាដោយអាការ ២ គឺ វត្ថុ ១ អាបត្តិ ១ ។ ត្រង់ពាក្យសួរថា អនុវាទាធិករណ៍រម្ងាប់ដោយសមថៈប៉ុន្មាន ។ ឆ្លើយថា អនុវាទាធិករណ៍រម្ងាប់ដោយសមថៈ ៤ គឺ ដោយសម្មុខាវិន័យ ១ សតិវិន័យ ១ អមូឡ្ហវិន័យ ១ តស្សបាបិយសិកា ១ ។

វីសតិ វារា បរិយាយវារំ

[៨៨៧] អាបត្តាធិករណស្ស កឹ បុព្វង្គមន្តិ ។ លោភោ បុព្វង្គមោ ទោសោ បុព្វង្គមោ មោហោ បុព្វង្គមោ អលោភោ បុព្វង្គមោ អទោសោ បុព្វង្គមោ អមោហោ បុព្វង្គមោ ។ កតិ ឋានានីតិ ។ សត្ត អាបត្តិក្ខន្ធា ឋានានិ ។ កតិ វត្ថូនីតិ ។ សត្ត អាបត្តិក្ខន្ធា វត្ថូនិ ។ កតិ ភូមិយោតិ ។ សត្ត អាបត្តិក្ខន្ធា ភូមិយោ ។ កតិ ហេតូតិ ។ ឆ ហេតូ តយោ កុសលហេតូ តយោ អកុសលហេតូ តយោ អព្យាកតហេតូ ។ កតិ មូលានីតិ ។ ឆ អាបត្តិសមុដ្ឋានា[១] មូលានិ ។ កតីហាការេហិ អាបត្តឹ អាបជ្ជតីតិ ។ ឆហាការេហិ អាបត្តឹ អាបជ្ជតិ អលជ្ជិតា អញ្ញាណតា កុក្កុច្ចបកតតា អកប្បិយេ កប្បិយសញ្ញិតា កប្បិយេ អកប្បិយសញ្ញិតា សតិសម្មោសា ។ អាបត្តាធិករណំ កតីហិ សមថេហិ សម្មតីតិ ។ អាបត្តាធិករណំ តីហិ សមថេហិ សម្មតិ សម្មុខាវិនយេន ច បដិញ្ញាតករណេន ច តិណវត្ថារកេន ច ។

---

១ ឱ. ម. អាបត្តិសមុដ្ឋានានិ ។

វីសតិវារៈ បរិយាយវារៈ

[៨៨៧] ត្រង់ពាក្យសួរថា អ្វីជាប្រធាននៃអាបត្តាធិករណ៍ ។ ឆ្លើយថា លោភៈជាប្រធាន ទោសៈជាប្រធាន មោហៈជាប្រធាន អលោភៈជាប្រធាន អទោសៈជាប្រធាន អមោហៈជាប្រធាន ។ ត្រង់ពាក្យសួរថា អាបត្តាធិករណ៍មានឋានប៉ុន្មាន ។ ឆ្លើយថា មានកងនៃអាបត្តិ ៧ ជាឋាន ។ ត្រង់ពាក្យសួរថា មានវត្ថុប៉ុន្មាន ។ ឆ្លើយថា មានកងនៃអាបត្តិ ៧ ជាវត្ថុ ។ ត្រង់ពាក្យសួរថា មានភូមិប៉ុន្មាន ។ ឆ្លើយថា មានកងនៃអាបត្តិ ៧ ជាភូមិ ។ ត្រង់ពាក្យសួរថា មានហេតុប៉ុន្មាន ។ ឆ្លើយថា មានហេតុ ៩ គឺកុសលហេតុ ៣ អកុសលហេតុ ៣ អព្យាកតហេតុ ៣ ។ ត្រង់ពាក្យសួរថា មានមូលប៉ុន្មាន ។ ឆ្លើយថា មានសមុដ្ឋាននៃអាបត្តិ ៦ ជាមូល ។ ត្រង់ពាក្យសួរថា ភិក្ខុត្រូវអាបត្តិដោយអាការប៉ុន្មាន ។ ឆ្លើយថា ត្រូវអាបត្តិដោយអាការ ៦ គឺត្រូវដោយមិនមានខ្មាស ១ ដោយមិនស្គាល់អាបត្តិ ១ ដោយសង្ស័យហើយធ្វើបំពាន ១ ដោយសំគាល់ថាគួរក្នុងវត្ថុដែលមិនគួរ ១ ដោយសំគាល់ថា មិនគួរក្នុងវត្ថុដែលគួរ ១ ដោយភ្លេចស្មារតី ១ ។ ត្រង់ពាក្យសួរថា អាបត្តាធិករណ៍រម្ងាប់ដោយសមថៈប៉ុន្មាន ។ ឆ្លើយថា អាបត្តាធិករណ៍រម្ងាប់ដោយសមថៈ ៣ គឺ ដោយសម្មុខាវិន័យ ១ បដិញ្ញាតករណៈ ១ តិណវត្ថារកៈ ១ ។

[៨៨៨] កិច្ចាធិករណស្ស កឹ បុព្វង្គមន្តិ ។ លោភោ បុព្វង្គមោ ទោសោ បុព្វង្គមោ មោហោ បុព្វង្គមោ អលោភោ បុព្វង្គមោ អទោសោ បុព្វង្គមោ អមោហោ បុព្វង្គមោ ។ កតិ ឋានានីតិ ។ ចត្តារិ កម្មានិ ឋានានិ ។ កតិ វត្ថូនីតិ ។ ចត្តារិ កម្មានិ វត្ថូនិ ។ កតិ ភូមិយោតិ ។ ចត្តារិ កម្មានិ ភូមិយោ ។ កតិ ហេតូតិ ។ នវ ហេតូ តយោ កុសលហេតូ តយោ អកុសលហេតូ តយោ អព្យាកតហេតូ ។ កតិ មូលានីតិ ។ ឯកំ មូលំ សង្ឃោ ។ កតីហាការេហិ កិច្ចំ ជាយតីតិ ។ ទ្វីហាការេហិ កិច្ចំ ជាយតិ ញត្តិតោ វា អបលោកនតោ វា ។ កិច្ចាធិករណំ កតីហិ សមថេហិ សម្មតីតិ ។ កិច្ចាធិករណំ ឯកេន សមថេន សម្មតិ សម្មុខាវិនយេន ។

[៨៨៩] កតិ សមថាតិ ។ សត្ត សមថា សម្មុខា-វិនយោ សតិវិនយោ អមូឡ្ហវិនយោ បដិញ្ញាតករណំ

[៨៨៨] ត្រង់ពាក្យសួរថា អ្វីជាប្រធាននៃកិច្ចាធិករណ៍ ។ ឆ្លើយថា លោភៈជាប្រធាន ទោសៈជាប្រធាន មោហៈជាប្រធាន អលោភៈជាប្រធាន អទោសៈជាប្រធាន អមោហៈជាប្រធាន ។ ត្រង់ពាក្យសួរថា កិច្ចាធិករណ៍ មានឋានប៉ុន្មាន ។ ឆ្លើយថា មានកម្ម ៤ យ៉ាង ជាឋាន ។ ត្រង់ពាក្យសួរថា មានវត្ថុប៉ុន្មាន ។ ឆ្លើយថា មានកម្ម ៤ ជាវត្ថុ ។ ត្រង់ពាក្យសួរថា មានភូមិប៉ុន្មាន ។ ឆ្លើយថា មានកម្ម ៤ ជាភូមិ ។ ត្រង់ពាក្យសួរថា មានហេតុប៉ុន្មាន ។ ឆ្លើយថា មានហេតុ ៩ គឺ កុសលហេតុ ៣ អកុសលហេតុ ៣ អព្យាកតហេតុ ៣ ។ ត្រង់ពាក្យសួរថា មានមូលប៉ុន្មាន ។ ឆ្លើយថា មានមូល ១ គឺសង្ឃ ។ ត្រង់ពាក្យសួរថា កិច្ចកើតអំពីអាការប៉ុន្មាន ។ ឆ្លើយថា កិច្ចកើតអំពីអាការ ២ គឺ ញត្តិ ១ អបលោកនៈ ១ ។ ត្រង់ពាក្យសួរថា កិច្ចាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មាន ។ ឆ្លើយថា កិច្ចាធិករណ៍ រម្ងាប់ដោយសមថៈ ១ គឺ សម្មុខាវិន័យ ។

[៨៨៩] សួរថា សមថៈមានប៉ុន្មាន ។ ឆ្លើយថា សមថៈមាន ៧ គឺសម្មុខាវិន័យ ១ សតិវិន័យ ១ អមូឡ្ហវិន័យ ១ បដិញ្ញាតករណៈ ១

យេភុយ្យសិកា តស្សបាបិយសិកា តិណវត្ថារកោ ឥមេ សត្ត សមថា ។ សិយា ឥមេ សត្ត សមថា ទស សមថា ហោន្តិ ទស សមថា សត្ត សមថា ហោន្តិ វត្ថុវសេន បរិយាយេន ។ សិយាតិ ។ កថញ្ច សិយា ។ វិវាទាធិករណស្ស ទ្វេ សមថា អនុវាទាធិករណស្ស ចត្តារោ សមថា អាបត្តាធិករណស្ស តយោ សមថា កិច្ចាធិករណស្ស ឯកោ សមថោ ។ ឯវំ ឥមេ សត្ត សមថា ទស សមថា ហោន្តិ ទស សមថា សត្ត សមថា ហោន្តិ វត្ថុវសេន បរិយាយេន ។

បរិយាយវារំ និដ្ឋិតំ ឆដ្ឋំ ។

[៨៩០] កតិ សមថា វិវាទាធិករណស្ស សាធារណា កតិ សមថា វិវាទាធិករណស្ស អសាធារណា ។ កតិ សមថា អនុវាទាធិករណស្ស សាធារណា កតិ សមថា អនុវាទាធិករណស្ស អសាធារណា កតិ សមថា អាបត្តាធិករណស្ស សាធារណា កតិ សមថា

យេភុយ្យសិកា ១ តស្សបាបិយសិកា ១ តិណវត្ថារកៈ ១ នេះជាសមថៈ ៧ ។ សមថៈទាំង ៧ នេះ ចែកទៅជាសមថៈ ១០ មានដែរឬ សមថៈ ១០ (បំប្រួញ) ជាសមថៈ ៧ ដោយអំណាចនៃវត្ថុនិងបរិយាយ មានដែរឬ ។ ឆ្លើយថា មាន ។ ព្រោះហេតុអ្វីបានជាថា មាន ។ ព្រោះវិវាទាធិករណ៍មានសមថៈ ២ អនុវាទាធិករណ៍មានសមថៈ ៤ អាបត្តាធិករណ៍មានសមថៈ ៣ កិច្ចាធិករណ៍មានសមថៈ ១ ។ សមថៈទាំង ៧ នេះ (ចែកទៅ) ជាសមថៈ ១០ សមថៈទាំង ១០ (បំប្រួញទៅ) ជាសមថៈ ៧ ដោយអំណាចនៃវត្ថុនិងបរិយាយ ដូចចែកមកនេះ ។

ចប់ បរិយាយវារៈ ជាគម្រប់ ៦ ។

[៨៩០] សួរថា សមថៈដែលទួទៅ ដល់វិវាទាធិករណ៍ មានប៉ុន្មាន សមថៈដែលមិនទួទៅដល់វិវាទាធិករណ៍ មានប៉ុន្មាន ។ សមថៈដែលទួទៅដល់អនុវាទាធិករណ៍ មានប៉ុន្មាន សមថៈដែលមិនទួទៅដល់អនុវាទាធិករណ៍ មានប៉ុន្មាន ។ សមថៈដែលទួទៅដល់អាបត្តាធិករណ៍ មានប៉ុន្មាន

អាបត្តាធិករណស្ស អសាធារណា ។ កតិ សមថា កិច្ចាធិករណស្ស សាធារណា កតិ សមថា កិច្ចាធិករណស្ស អសាធារណា ។ ទ្វេ សមថា វិវាទាធិករណស្ស សាធារណា សម្មុខាវិនយោ យេភុយ្យសិកា ។ បញ្ច សមថា វិវាទាធិករណស្ស អសាធារណា សតិវិនយោ អមូឡ្ហវិនយោ បដិញ្ញាតករណំ តស្សបាបិយសិកា តិណវត្ថារកោ ។ ចត្តារោ សមថា អនុវាទាធិករណស្ស សាធារណា សម្មុខាវិនយោ សតិវិនយោ អមូឡ្ហវិនយោ តស្សបាបិយសិកា ។ តយោ សមថា អនុវាទាធិករណស្ស អសាធារណា យេភុយ្យសិកា បដិញ្ញាតករណំ តិណវត្ថារកោ ។ តយោ សមថា អាបត្តាធិករណស្ស សាធារណា សម្មុខាវិនយោ បដិញ្ញាតករណំ តិណវត្ថារកោ ។ ចត្តារោ សមថា អាបត្តាធិករណស្ស អសាធារណា យេភុយ្យសិកា សតិវិនយោ អមូឡ្ហវិនយោ តស្សបាបិយសិកា ។ ឯកោ សមថោ កិច្ចាធិករណស្ស សាធារណោ សម្មុខាវិនយោ ។

សមថៈដែលមិនទូទៅដល់អាបត្តាធិករណ៍ មានប៉ុន្មាន ។ សមថៈដែលទូ-ទៅដល់កិច្ចាធិករណ៍ មានប៉ុន្មាន សមថៈដែលមិនទូទៅដល់កិច្ចាធិករណ៍ មានប៉ុន្មាន ។ ឆ្លើយថា សមថៈដែលទូទៅដល់វិវាទាធិករណ៍ មាន ២ គឺ សម្មុខាវិន័យ ១ យេភុយ្យសិកា ១ ។ សមថៈដែលមិនទូទៅដល់វិវាទាធិ-ករណ៍ មាន ៥ គឺ សតិវិន័យ ១ អមូឡ្ហវិន័យ ១ បដិញ្ញាតករណៈ ១ តស្សបាបិយសិកា ១ តិណវត្ថារកៈ ១ ។ សមថៈដែលទូទៅដល់អនុវាទា-ធិករណ៍ មាន ៤ គឺ សម្មុខាវិន័យ ១ សតិវិន័យ ១ អមូឡ្ហវិន័យ ១ តស្ស-បាបិយសិកា ១ ។ សមថៈដែលមិនទូទៅដល់អនុវាទាធិករណ៍ មាន ៣ គឺ យេភុយ្យសិកា ១ បដិញ្ញាតករណៈ ១ តិណវត្ថារកៈ ១ ។ សមថៈ ដែលទូទៅដល់អាបត្តាធិករណ៍ មាន ៣ គឺ សម្មុខាវិន័យ ១ បដិញ្ញាត-ករណៈ ១ តិណវត្ថារកៈ ១ ។ សមថៈដែលមិនទូទៅដល់អាបត្តាធិករណ៍ មាន ៤ គឺ យេភុយ្យសិកា ១ សតិវិន័យ ១ អមូឡ្ហវិន័យ ១ តស្សបាបិយ-សិកា ១ ។ សមថៈដែលទូទៅដល់កិច្ចាធិករណ៍ មាន ១ គឺ សម្មុខាវិន័យ

ឆ សមថា កិច្ចាធិករណស្ស អសាធារណា យេ-
ភុយ្យសិកា សតិវិនយោ អមូឡ្ហវិនយោ បដិញ្ញាតក-
រណំ តស្សបាបិយសិកា តិណវត្ថារកោ ។

សាធារណវារំ និដ្ឋិតំ សត្តមំ ។

[៨៩១] កតិ សមថា វិវាទាធិករណស្ស តព្ភាគិយា
កតិ សមថា វិវាទាធិករណស្ស អញ្ញភាគិយា ។ កតិ
សមថា អនុវាទាធិករណស្ស តព្ភាគិយា កតិ សមថា
អនុវាទាធិករណស្ស អញ្ញភាគិយា ។ កតិ សមថា
អាបត្តាធិករណស្ស តព្ភាគិយា កតិ សមថា អាបត្តា-
ធិករណស្ស អញ្ញភាគិយា ។ កតិ សមថា កិច្ចាធិ-
ករណស្ស តព្ភាគិយា កតិ សមថា កិច្ចាធិករណស្ស
អញ្ញភាគិយា ។ ទ្វេ សមថា វិវាទាធិករណស្ស តព្ភា-
គិយា សម្មុខាវិនយោ យេភុយ្យសិកា ។ បញ្ច សមថា
វិវាទាធិករណស្ស អញ្ញភាគិយា សតិវិនយោ អមូឡ្ហវិ-
នយោ បដិញ្ញាតករណំ តស្សបាបិយសិកា តិណ-
វត្ថារកោ ។ ចត្តារោ សមថា អនុវាទាធិករណស្ស

សមថៈដែលមិនទួទៅ ដល់កិច្ចាធិករណ៍មាន ៦ គឺយេភុយ្យសិកា ១ សតិវិន័យ ១ អមូឡ្ហវិន័យ ១ បដិញ្ញាតករណៈ ១ តស្សបាបិយសិកា ១ តិណវត្ថារកៈ ១ ។

ចប់ សាធារណវារៈ ជាគម្រប់ ៧ ។

[៨៩១] សួរថា សមថៈដែលមានចំណែកត្រូវគ្នានឹងវិវាទាធិករណ៍ មានប៉ុន្មាន សមថៈដែលមានចំណែកផ្សេងអំពីវិវាទាធិករណ៍ មានប៉ុន្មាន ។ សមថៈដែលមានចំណែកត្រូវគ្នានឹងអនុវាទាធិករណ៍ មានប៉ុន្មាន សមថៈដែលមានចំណែកផ្សេងអំពីអនុវាទាធិករណ៍ មានប៉ុន្មាន ។ សមថៈដែលមានចំណែកត្រូវគ្នានឹងអាបត្តាធិករណ៍ មានប៉ុន្មាន សមថៈដែលមានចំណែកផ្សេងអំពីអាបត្តាធិករណ៍ មានប៉ុន្មាន ។ សមថៈដែលមានចំណែកត្រូវគ្នានឹងកិច្ចាធិករណ៍ មានប៉ុន្មាន សមថៈដែលមានចំណែកផ្សេងអំពីកិច្ចាធិករណ៍ មានប៉ុន្មាន ។ ឆ្លើយថា សមថៈដែលមានចំណែកត្រូវគ្នានឹងវិវាទាធិករណ៍ មាន ២ គឺ សម្មុខាវិន័យ ១ យេភុយ្យសិកា ១ ។ សមថៈដែលមានចំណែកផ្សេងអំពីវិវាទាធិករណ៍ មាន ៥ គឺ សតិវិន័យ ១ អមូឡ្ហវិន័យ ១ បដិញ្ញាតករណៈ ១ តស្សបាបិយសិកា ១ តិណវត្ថារកៈ ១ ។ សមថៈដែលមានចំណែកត្រូវគ្នានឹងអនុវាទាធិករណ៍ មាន ៤ គឺ

តព្ភាគិយា សម្មុខាវិនយោ សតិវិនយោ អមូឡ្ហវិនយោ តស្សបាបិយសិកា ។ តយោ សមថា អនុវាទាធិករណស្ស អញ្ញភាគិយា យេភុយ្យសិកា បដិញ្ញាតករណំ តិណវត្ថារកោ ។ តយោ សមថា អាបត្តាធិករណស្ស តព្ភាគិយា សម្មុខាវិនយោ បដិញ្ញាតករណំ តិណវត្ថារកោ ។ ចត្តារោ សមថា អាបត្តាធិករណស្ស អញ្ញភាគិយា យេភុយ្យសិកា សតិវិនយោ អមូឡ្ហវិនយោ តស្សបាបិយសិកា ។ ឯកោ សមថោ កិច្ចាធិករណស្ស តព្ភាគិយោ សម្មុខាវិនយោ ។ ឆ សមថា កិច្ចាធិករណស្ស អញ្ញភាគិយា យេភុយ្យសិកា សតិវិនយោ អមូឡ្ហវិនយោ បដិញ្ញាតករណំ តស្សបាបិយសិកា តិណវត្ថារកោ ។

តព្ភាគិយវារំ និដ្ឋិតំ អដ្ឋមំ ។

[៨៩២] សមថា សមថស្ស សាធារណា សមថា សមថស្ស អសាធារណា សិយា សមថា សមថស្ស សាធារណា សិយា សមថស្ស អសាធារណា ។

សម្មុខាវិន័យ ១ សតិវិន័យ ១ អមូឡ្ហវិន័យ ១ តស្សបាបិយសិកា ១ ។ សមថៈដែលមានចំណែកផ្សេងអំពីអនុវាទាធិករណ៍ មាន ៣ គឺ យេភុយ្យសិកា ១ បដិញ្ញាតករណៈ ១ តិណវត្ថារកៈ ១ ។ សមថៈដែលមានចំណែកត្រូវគ្នានឹងអាបត្តាធិករណ៍ មាន ៣ គឺ សម្មុខាវិន័យ ១ បដិញ្ញាតករណៈ ១ តិណ-វត្ថារកៈ ១ ។ សមថៈដែលមានចំណែកផ្សេងអំពីអាបត្តាធិករណ៍ មាន ៤ គឺ យេភុយ្យសិកា ១ សតិវិន័យ ១ អមូឡ្ហវិន័យ ១ តស្សបាបិយសិកា ១ ។ សមថៈដែលមានចំណែកត្រូវគ្នានឹងកិច្ចាធិករណ៍ មាន ១ គឺ សម្មុខា-វិន័យ ។ សមថៈដែលមានចំណែកផ្សេងអំពីកិច្ចាធិករណ៍ មាន ៦ គឺ យេភុយ្យសិកា ១ សតិវិន័យ ១ អមូឡ្ហវិន័យ ១ បដិញ្ញាតករណៈ ១ តស្ស-បាបិយសិកា ១ តិណវត្ថារកៈ ១ ។

ចប់ តព្ភាគិយវារៈ ជាគម្រប់ ៨ ។

[៨៩២] សមថៈទូទៅដល់សមថៈ សមថៈមិនទូទៅដល់សមថៈ សមថៈទូទៅដល់សមថៈក៏មាន សមថៈមិនទូទៅដល់សមថៈក៏មាន ។

៤១៧

វីសតិ វារា សមថា សមថស្ស សាធារណាវារំ

កថំ សិយា សមថា សមថស្ស សាធារណា កថំ សិយា សមថា សមថស្ស អសាធារណា ។ យេភុយ្យសិកា សម្មុខាវិនយស្ស សាធារណា សតិវិនយស្ស អមូឡ្ហវិនយស្ស បដិញ្ញាតករណស្ស តស្សបាបិយសិកាយ តិណវត្ថារកស្ស អសាធារណា ។ សតិវិនយោ សម្មុខាវិនយស្ស សាធារណា អមូឡ្ហវិនយស្ស បដិញ្ញាតករណស្ស តស្សបាបិយសិកាយ តិណវត្ថារកស្ស យេភុយ្យសិកាយ អសាធារណោ ។ អមូឡ្ហវិនយោ សម្មុខាវិនយស្ស សាធារណោ បដិញ្ញាតករណស្ស តស្សបាបិយសិកាយ តិណវត្ថារកស្ស យេភុយ្យសិកាយ សតិវិនយស្ស អសាធារណោ ។ បដិញ្ញាតករណំ សម្មុខាវិនយស្ស សាធារណំ តស្សបាបិយសិកាយ តិណវត្ថារកស្ស យេភុយ្យសិកាយ សតិវិនយស្ស អមូឡ្ហវិនយស្ស អសាធារណំ ។ តស្សបាបិយសិកា សម្មុខាវិនយស្ស សាធារណា តិណវត្ថារកស្ស យេភុយ្យសិកាយ សតិវិនយស្ស អមូឡ្ហវិនយស្ស បដិញ្ញាតករណស្ស អសាធារណា ។

វីសតិវារៈ វារៈនៃសមថៈដែលទូទៅដល់សមថៈ

សួរថា សមថៈដែលទូទៅដល់សមថៈក៏មាន នោះ តើដូចម្តេច សមថៈមិនទូ-ទៅដល់សមថៈក៏មាន នោះ តើដូចម្តេច ។ ឆ្លើយថា យេភុយ្យសិកាទូទៅដល់សម្មុខាវិន័យ (តែម្យ៉ាង) មិនទូទៅដល់សតិវិន័យ អមូឡ្ហវិន័យ បដិញ្ញាតករណៈ តស្សបាបិយសិកា និងតិណវត្ថារកៈទេ ។ សតិវិន័យទូទៅដល់សម្មុខាវិន័យ (តែម្យ៉ាង) មិនទូទៅដល់អមូឡ្ហវិន័យ បដិញ្ញាតករណៈ តស្សបាបិយសិកា តិណវត្ថារកៈ និងយេភុយ្យសិកាទេ ។ អមូឡ្ហវិន័យទូ-ទៅដល់សម្មុខាវិន័យ (តែម្យ៉ាង) មិនទូទៅដល់បដិញ្ញាតករណៈ តស្សបា-បិយសិកា តិណវត្ថារកៈ យេភុយ្យសិកា និងសតិវិន័យទេ ។ បដិញ្ញាត-ករណៈទូទៅដល់សម្មុខាវិន័យ (តែម្យ៉ាង) មិនទូទៅដល់តស្សបាបិយ-សិកា តិណវត្ថារកៈ យេភុយ្យសិកា សតិវិន័យ និងអមូឡ្ហវិន័យទេ ។ តស្សបាបិយសិកាទូទៅដល់សម្មុខាវិន័យ (តែម្យ៉ាង) មិនទូទៅដល់តិណ-វត្ថារកៈ យេភុយ្យសិកា សតិវិន័យ អមូឡ្ហវិន័យ និងបដិញ្ញាតករណៈទេ ។

តិណវត្ថារកោ សម្មុខាវិនយស្ស សាធារណោ យេភុយ្យសិកាយ សតិវិនយស្ស អមូឡ្ហវិនយស្ស បដិញ្ញាតករណស្ស តស្សបាបិយសិកាយ អសាធារណោ ។ ឯវំ សិយា សមថា សមថស្ស សាធារណា ឯវំ សិយា សមថា សមថស្ស អសាធារណា ។

សមថា សមថស្ស សាធារណវារំ និដ្ឋិតំ នវមំ ។

[៨៩៣] សមថា សមថស្ស តព្ភាគិយា សមថា សមថស្ស អញ្ញភាគិយា សិយា សមថា សមថស្ស តព្ភាគិយា សិយា សមថា សមថស្ស អញ្ញភាគិយា ។ កថំ សិយា សមថា សមថស្ស តព្ភាគិយា កថំ សិយា សមថា សមថស្ស អញ្ញភាគិយា ។ យេភុយ្យសិកា សម្មុខាវិនយស្ស តព្ភាគិយា សតិវិនយស្ស អមូឡ្ហវិនយស្ស បដិញ្ញាតករណស្ស តស្សបាបិយសិកាយ តិណវត្ថារកស្ស អញ្ញភាគិយា ។ សតិវិនយោ សម្មុខាវិនយស្ស តព្ភាគិយោ អមូឡ្ហវិ-

តិណវត្ថារកៈទួទៅដល់សម្មុខាវិន័យ (តែម្យ៉ាង) មិនទួទៅដល់យេភុយ្យ-សិកា សតិវិន័យ អមូឡ្ហវិន័យ បដិញ្ញាតករណៈ និងតស្សបាបិយសិកាទេ ។ សមថៈដែលទួទៅដល់សមថៈក៏មាន យ៉ាងនេះ សមថៈដែលមិនទួទៅដល់សមថៈក៏មាន យ៉ាងនេះ ។

ចប់ វារៈនៃសមថៈដែលទួទៅដល់សមថៈ ជាគម្រប់ ៩ ។

[៨៩៣] សមថៈមានចំណែកត្រូវគ្នានឹងសមថៈ សមថៈមានចំណែកផ្សេងអំពីសមថៈ សមថៈមានចំណែកត្រូវគ្នានឹងសមថៈក៏មាន សមថៈមានចំណែកផ្សេងអំពីសមថៈក៏មាន ។ សួរថា សមថៈដែលមានចំណែកត្រូវគ្នានឹងសមថៈក៏មាន នោះ តើដូចម្ដេច សមថៈដែលមានចំណែកផ្សេងអំពីសមថៈក៏មាន នោះ តើដូចម្ដេច ។ ឆ្លើយថា យេភុយ្យសិកា មានចំណែកត្រូវគ្នានឹងសម្មុខាវិន័យ មានចំណែកផ្សេងអំពីសតិវិន័យ អមូឡ្ហ-វិន័យ បដិញ្ញាតករណៈ តស្សបាបិយសិកា និងតិណវត្ថារកៈ ។ សតិវិន័យមានចំណែកត្រូវគ្នានឹងសម្មុខាវិន័យ មានចំណែកផ្សេងអំពីអមូឡ្ហវិន័យ

ឋយស្ស បដិញ្ញាតករណស្ស តស្សបាបិយសិកា-
យ តិណវត្ថារកស្ស យេភុយ្យសិកាយ អញ្ញភា-
គិយោ ។ អមូឡ្ហវិនយោ សម្មុខាវិនយស្ស តព្ភាគិ-
យោ បដិញ្ញាតករណស្ស តស្សបាបិយសិកាយ តិ-
ណវត្ថារកស្ស យេភុយ្យសិកាយ សតិវិនយស្ស អញ្ញ-
ភាគិយោ ។ បដិញ្ញាតករណំ សម្មុខាវិនយស្ស តព្ភាគិ-
យំ តស្សបាបិយសិកាយ តិណវត្ថារកស្ស យេភុយ្យ-
សិកាយ សតិវិនយស្ស អមូឡ្ហវិនយស្ស អញ្ញភាគិយំ ។
តស្សបាបិយសិកា សម្មុខាវិនយស្ស តព្ភាគិយា តិ-
ណវត្ថារកស្ស យេភុយ្យសិកាយ សតិវិនយស្ស
អមូឡ្ហវិនយស្ស បដិញ្ញាតករណស្ស អញ្ញភាគិយា ។
តិណវត្ថារកោ សម្មុខាវិនយស្ស តព្ភាគិយោ យេភុយ្យ-
សិកាយ សតិវិនយស្ស អមូឡ្ហវិនយស្ស បដិញ្ញាត-
ករណស្ស តស្សបាបិយសិកាយ អញ្ញភាគិយោ ។
ឯវំ សិយា សមថា សមថស្ស តព្ភាគិយា ឯវំ សិយា
សមថា សមថស្ស អញ្ញភាគិយា ។

សមថា សមថស្ស តព្ភាគិយវារំ និដ្ឋិតំ ទសមំ ។

បដិញ្ញាតករណៈ តស្សបាបិយសិកា តិណវត្ថារកៈ និងយេភុយ្យសិកា ។ អមូឡ្ហវិន័យ មានចំណែកត្រូវគ្នានឹងសម្មុខាវិន័យ មានចំណែកផ្សេងអំពីបដិញ្ញាតករណៈ តស្សបាបិយសិកា តិណវត្ថារកៈ យេភុយ្យសិកា និងសតិវិន័យ ។ បដិញ្ញាតករណៈ មានចំណែកត្រូវគ្នានឹងសម្មុខាវិន័យ មានចំណែកផ្សេងអំពីតស្សបាបិយសិកា តិណវត្ថារកៈ យេភុយ្យសិកា សតិ-វិន័យ និងអមូឡ្ហវិន័យ ។ តស្សបាបិយសិកា មានចំណែកត្រូវគ្នានឹងសម្មុខាវិន័យ មានចំណែកផ្សេងអំពីតិណវត្ថារកៈ យេភុយ្យសិកា សតិ-វិន័យ អមូឡ្ហវិន័យនិងបដិញ្ញាតករណៈ ។ តិណវត្ថារកៈ មានចំណែកត្រូវគ្នានឹងសម្មុខាវិន័យ មានចំណែកផ្សេងអំពីយេភុយ្យសិកា សតិវិន័យ អមូឡ្ហវិន័យ បដិញ្ញាតករណៈនិងតស្សបាបិយសិកា ។ សមថៈដែលមានចំណែកត្រូវគ្នានឹងសមថៈក៏មាន យ៉ាងនេះ សមថៈដែលមានចំណែកផ្សេងអំពីសមថៈក៏មាន យ៉ាងនេះ ។

ចប់ វារៈនៃសមថៈដែលមានចំណែកត្រូវគ្នានឹងសមថៈ ជាគម្រប់ ១០ ។

[៨៩៤] សមថោ សម្មុខាវិនយោ សម្មុខាវិនយោ សមថោ ។ សមថោ យេភុយ្យសិកា យេភុយ្យសិកា សមថោ ។ សមថោ សតិវិនយោ សតិវិនយោ សមថោ ។ សមថោ អមូឡ្ហវិនយោ អមូឡ្ហវិនយោ សមថោ ។ សមថោ បដិញ្ញាតករណំ បដិញ្ញាតករណំ សមថោ ។ សមថោ តស្សបាបិយសិកា តស្សបាបិយសិកា សមថោ ។ សមថោ តិណវត្ថារកោ តិណវត្ថារកោ សមថោ ។ យេភុយ្យសិកា សតិវិនយោ អមូឡ្ហវិនយោ បដិញ្ញាតករណំ តស្សបាបិយសិកា តិណវត្ថារកោ ឥមេ សមថា សមថា ន សម្មុខាវិនយោ សម្មុខាវិនយោ សមថោ ចេវ សម្មុខាវិនយោ ច ។ សតិវិនយោ អមូឡ្ហវិនយោ បដិញ្ញាតករណំ តស្សបាបិយសិកា តិណវត្ថារកោ សម្មុខាវិនយោ ឥមេ សមថា សមថា ន យេភុយ្យសិកា យេភុយ្យសិកា សមថោ ចេវ យេភុយ្យសិកា ច ។ អមូឡ្ហវិនយោ បដិញ្ញាតករណំ

[៨៩៤] សមថៈ ហៅថា សម្មុខាវិន័យ សម្មុខាវិន័យ ហៅថា សមថៈវិញក៏បាន ។ សមថៈ ហៅថា យេភុយ្យសិកា យេភុយ្យសិកា ហៅថា សមថៈវិញក៏បាន ។ សមថៈហៅថា សតិវិន័យ សតិវិន័យហៅថា សមថៈវិញក៏បាន ។ សមថៈ ហៅថា អមូឡ្ហវិន័យ អមូឡ្ហវិន័យហៅថា សមថៈវិញក៏បាន ។ សមថៈ ហៅថាបដិញ្ញាតករណៈ បដិញ្ញាតករណៈ ហៅថា សមថៈវិញក៏បាន ។ សមថៈ ហៅថា តស្សបាបិយសិកា តស្សបាបិយសិកា ហៅថា សមថៈវិញក៏បាន ។ សមថៈ ហៅថា តិណវត្ថារកៈ តិណវត្ថារកៈ ហៅថា សមថៈវិញក៏បាន ។ យេភុយ្យសិកា សតិវិន័យ អមូឡ្ហវិន័យ បដិញ្ញាតករណៈ តស្សបាបិយសិកា និងតិណវត្ថារកៈ ទាំងនេះ ហៅថា សមថៈតែម្យ៉ាង ឯសម្មុខាវិន័យ មិនហៅថា សមថៈ តែម្យ៉ាងទេ ដ្បិត សម្មុខាវិន័យ ហៅថាសមថៈផង ហៅថាសម្មុខាវិន័យ ផង ។ សតិវិន័យ អមូឡ្ហវិន័យ បដិញ្ញាតករណៈ តស្សបាបិយសិកា តិណវត្ថារកៈ និងសម្មុខាវិន័យ ទាំងនេះ ហៅថា សមថៈតែម្យ៉ាង ឯ យេភុយ្យសិកា មិនហៅថា សមថៈតែម្យ៉ាងទេ ដ្បិត យេភុយ្យសិកា ហៅថា សមថៈផង ហៅថា យេភុយ្យសិកាផង ។ អមូឡ្ហវិន័យ បដិញ្ញាតករណៈ

៤២១

វីសតិ វារា សមថសម្មុខាវិនយវារំ

តស្សចាបិយសិកា តិណវត្ថារកោ សម្មុខាវិនយោ យេភុយ្យសិកា ឥមេ សមថា សមថា ដោ សតិវិនយោ សតិវិនយោ សមថោ ចេវ សតិវិនយោ ច ។ បដិញ្ញាតករណំ តស្សចាបិយសិកា តិណវត្ថារកោ សម្មុខាវិនយោ យេភុយ្យសិកា សតិវិនយោ ឥមេ សមថា សមថា ដោ អមូឡ្ហវិនយោ អមូឡ្ហវិនយោ សមថោ ចេវ អមូឡ្ហវិនយោ ច ។ តស្សចាបិយសិកា តិណវត្ថារកោ សម្មុខាវិនយោ យេភុយ្យសិកា សតិវិនយោ អមូឡ្ហវិនយោ ឥមេ សមថា សមថា ដោ បដិញ្ញាតករណំ បដិញ្ញាតករណំ សមថោ ចេវ បដិញ្ញាតករណញ្ច ។ តិណវត្ថារកោ សម្មុខាវិនយោ យេភុយ្យសិកា សតិវិនយោ អមូឡ្ហវិនយោ បដិញ្ញាតករណំ ឥមេ សមថា សមថា ដោ តស្សចាបិយសិកា តស្សចាបិយសិកា សមថោ ចេវ តស្សចាបិយសិកា ច ។ សម្មុខាវិនយោ យេភុយ្យសិកា សតិវិនយោ អមូឡ្ហវិនយោ បដិញ្ញាតករណំ

តស្សបាបិយសិកា តិណវត្ថារកៈ សម្មុខាវិន័យ និងយេភុយ្យសិកា ទាំងនេះ ហៅថា សមថៈតែម្យ៉ាង ឯសតិវិន័យមិនហៅថា សមថៈតែម្យ៉ាងទេ ដ្បិត សតិវិន័យ ហៅថា សមថៈផង ហៅថា សតិវិន័យផង ។ បដិញ្ញាតករណៈ តស្សបាបិយសិកា តិណវត្ថារកៈ សម្មុខាវិន័យ យេភុយ្យសិកា និងសតិ-វិន័យទាំងនេះ ហៅថា សមថៈតែម្យ៉ាង ឯអមូឡ្ហវិន័យ មិនហៅថា សមថៈតែម្យ៉ាងទេ ដ្បិត អមូឡ្ហវិន័យ ហៅថា សមថៈផង ហៅថា អមូឡ្ហវិន័យផង ។ តស្សបាបិយសិកា តិណវត្ថារកៈ សម្មុខាវិន័យ យេភុយ្យសិកា សតិវិន័យ និងអមូឡ្ហវិន័យ ទាំងនេះ ហៅថា សមថៈតែម្យ៉ាង ឯបដិញ្ញាតករណៈ មិនហៅថា សមថៈតែម្យ៉ាងទេ ដ្បិត បដិញ្ញាតករណៈ ហៅថា សមថៈផង ហៅថាបដិញ្ញាតករណៈផង ។ តិណវត្ថារកៈ សម្មុខាវិន័យ យេភុយ្យសិកា សតិវិន័យ អមូឡ្ហវិន័យ និងបដិញ្ញាតករណៈ ទាំងនេះ ហៅថា សមថៈតែម្យ៉ាង ឯតស្សបាបិយសិកា មិនហៅថា សមថៈតែម្យ៉ាងទេ ដ្បិត តស្សបាបិយសិកា ហៅថា សមថៈផង ហៅថា តស្សបាបិយសិកាផង ។ សម្មុខាវិន័យ យេភុយ្យសិកា សតិវិន័យ អមូឡ្ហវិន័យ បដិញ្ញាតករណៈ

តស្សបាបិយសិកា ឥមេ សមថា សមថា ដោ តិណវត្ថារកោ តិណវត្ថារកោ សមថោ ចេវ តិណ-វត្ថារកោ ច ។

[៨៩៥] វិនយោ សម្មុខាវិនយោ សម្មុខាវិនយោ វិនយោ ។ វិនយោ យេភុយ្យសិកា យេភុយ្យសិកា វិនយោ ។ វិនយោ សតិវិនយោ សតិវិនយោ វិនយោ ។ វិនយោ អមូឡ្ហវិនយោ អមូឡ្ហវិនយោ វិនយោ ។ វិនយោ បដិញ្ញាតករណំ បដិញ្ញាតករណំ វិនយោ ។ វិនយោ តស្សបាបិយសិកា តស្សបាបិយសិកា វិនយោ ។ វិនយោ តិណវត្ថារកោ តិណវត្ថារកោ វិនយោ ។

សមថសម្មុខាវិនយវារំ និដ្ឋិតំ ឯកាទសមំ ។

[៨៩៦] វិនយោ សិយា សម្មុខាវិនយោ សិយា ន សម្មុខាវិនយោ សម្មុខាវិនយោ វិនយោ ចេវ សម្មុខាវិន-យោ ច ។ វិនយោ សិយា យេភុយ្យសិកា សិយា ន យេភុយ្យសិកា យេភុយ្យសិកា វិនយោ ចេវ យេ-ភុយ្យសិកា ច ។ វិនយោ សិយា សតិវិនយោ សិយា

និងតស្សបាបិយសិកា ទាំងនេះ ហៅថា សមថៈតែម្យ៉ាង ឯតិណវត្ថារកៈ មិនហៅថា សមថៈតែម្យ៉ាង ដ្បិត តិណវត្ថារកៈ ហៅថា សមថៈផង ហៅថា តិណវត្ថារកៈផង ។

[៨៩៥] វិន័យ ហៅថា សម្មុខាវិន័យ សម្មុខាវិន័យ ហៅថា វិន័យវិញក៏បាន ។ វិន័យ ហៅថា យេភុយ្យសិកា យេភុយ្យសិកា ហៅថា វិន័យវិញក៏បាន ។ វិន័យ ហៅថា សតិវិន័យ សតិវិន័យ ហៅថា វិន័យវិញក៏បាន ។ វិន័យ ហៅថា អមូឡ្ហវិន័យ អមូឡ្ហវិន័យ ហៅថា វិន័យវិញក៏បាន ។ វិន័យ ហៅថា បដិញ្ញាតករណៈ បដិញ្ញាតករណៈ ហៅថា វិន័យវិញក៏បាន ។ វិន័យ ហៅថា តស្សបាបិយសិកា តស្សបាបិយសិកា ហៅថា វិន័យវិញក៏បាន ។ វិន័យ ហៅថា តិណវត្ថារកៈ តិណវត្ថារកៈ ហៅថា វិន័យវិញក៏បាន ។

ចប់ វារៈនៃសមថៈដែលហៅថា សម្មុវិន័យ ជាគម្រប់ ១១ ។

[៨៩៦] វិន័យ ជាសម្មុខាវិន័យក៏មាន មិនមែនជាសម្មុខាវិន័យក៏មាន ព្រោះថា សម្មុខាវិន័យជាវិន័យផង ជាសម្មុខាវិន័យផង ។ វិន័យជាយេភុយ្យសិកាក៏មាន មិនមែនជាយេភុយ្យសិកាក៏មាន ព្រោះថា យេភុយ្យ-សិកា ជាវិន័យផង ជាយេភុយ្យសិកាផង ។ វិន័យ ជាសតិវិន័យក៏មាន

ន សតិវិនយោ សតិវិនយោ វិនយោ ចេវ សតិវិនយោ ច ។ វិនយោ សិយា អមូឡ្ហវិនយោ សិយា ន អ-
មូឡ្ហវិនយោ អមូឡ្ហវិនយោ វិនយោ ចេវ អមូឡ្ហវិនយោ ច ។ វិនយោ សិយា បដិញ្ញាតករណំ សិយា ន បដិញ្ញាតករណំ បដិញ្ញាតករណំ វិនយោ ចេវ ប-
ដិញ្ញាតករណញ្ច ។ វិនយោ សិយា តស្សបាបិយសិកា សិយា ន តស្សបាបិយសិកា តស្សបាបិយសិកា វិ-
នយោ ចេវ តស្សបាបិយសិកា ច ។ វិនយោ សិយា តិណវត្ថារកោ សិយា ន តិណវត្ថារកោ តិណវត្ថារកោ វិនយោ ចេវ តិណវត្ថារកោ ច ។

វិនយវារំ និដ្ឋិតំ ទ្វាទសមំ ។

[៨៩៧] សម្មុខាវិនយោ កុសលោ អកុសលោ អព្យាកតោ ។ យេភុយ្យសិកា កុសលា អកុសលា អព្យាកតា ។ សតិវិនយោ កុសលោ អកុសលោ អព្យាកតោ ។ អមូឡ្ហវិនយោ កុសលោ អកុសលោ អព្យាកតោ ។ បដិញ្ញាតករណំ កុសលំ អកុសលំ អព្យាកតំ ។ តស្សបាបិយសិកា កុសលា អកុសលា

មិនមែនជាសតិវិន័យក៏មាន (ព្រោះថា) សតិវិន័យ ជាវិន័យផង ជាសតិវិន័យផង ។ វិន័យ ជាអមូឡ្ហវិន័យក៏មាន មិនមែនជាអមូឡ្ហវិន័យក៏មាន (ព្រោះថា) អមូឡ្ហវិន័យ ជាវិន័យផង ជាអមូឡ្ហវិន័យផង ។ វិន័យ ជាបដិញ្ញាតករណៈក៏មាន មិនមែនជាបដិញ្ញាតករណៈក៏មាន (ព្រោះថា) បដិញ្ញាតករណៈ ជាវិន័យផង ជាបដិញ្ញាតករណៈផង ។ វិន័យ ជាតស្សបាបិយសិកាក៏មាន មិនមែនជាតស្សបាបិយសិកាក៏មាន (ព្រោះថា) តស្សបាបិយសិកា ជាវិន័យផង ជាតស្សបាបិយសិកាផង ។ វិន័យ ជាតិណវត្ថារកៈក៏មាន មិនមែនជាតិណវត្ថារកៈក៏មាន (ព្រោះថា) តិណវត្ថារកៈ ជាវិន័យផង ជាតិណវត្ថារកៈផង ។

ចប់ វិនយវារៈ ជាគម្រប់ ១២ ។

[៨៩៧] សួរថា សម្មុខាវិន័យ ជាកុសល ឬជាអកុសល ឬជាអព្យាកតៈ ។ យេភុយ្យសិកា ជាកុសល ឬអកុសល ឬជាអព្យាកតៈ ។ សតិវិន័យ ជាកុសល ឬជាអកុសល ឬជាអព្យាកតៈ ។ អមូឡ្ហវិន័យ ជាកុសល ឬជាអកុសល ឬជាអព្យាកតៈ ។ បដិញ្ញាតករណៈ ជាកុសល ឬជាអកុសល ឬជាអព្យាកតៈ ។ តស្សបាបិយសិកា ជាកុសល ឬជាអកុសល

អព្យាកតា ។ តិណវត្ថារកោ កុសលោ អកុសលោ អព្យាកតោ ។ សម្មុខាវិនយោ សិយា កុសលោ សិយា អព្យាកតោ នត្ថិ សម្មុខាវិនយោ អកុសលោ ។ យេភុយ្យសិកា សិយា កុសលា សិយា អកុសលា សិយា អព្យាកតា ។ សតិវិនយោ សិយា កុសលោ សិយា អកុសលោ សិយា អព្យាកតោ ។ អមូឡ្ហវិនយោ សិយា កុសលោ សិយា អកុសលោ សិយា អព្យាក-តោ ។ បដិញ្ញាតករណំ សិយា កុសលំ សិយា អកុសលំ សិយា អព្យាកតំ ។ តស្សបាបិយសិកា សិយា កុសលា សិយា អកុសលា សិយា អព្យា-កតា ។ តិណវត្ថារកោ សិយា កុសលោ សិយា អកុសលោ សិយា អព្យាកតោ ។

[៨៩៨] វិវាទាធិករណំ កុសលំ អកុសលំ អព្យាកតំ ។ អនុវាទាធិករណំ កុសលំ អកុសលំ អព្យាកតំ ។ អាបត្តាធិករណំ កុសលំ អកុសលំ អព្យាកតំ ។ កិច្ចាធិករណំ កុសលំ អកុសលំ អព្យាកតំ ។ វិវាទាធិករណំ សិយា កុសលំ សិយា អកុសលំ សិយា អព្យាកតំ ។ អនុវាទាធិករណំ

ឬអព្យាកតៈ ។ តិណវត្ថារកៈ ជាកុសល ឬជាអកុសល ឬជាអព្យាកតៈ ។ ឆ្លើយថា សម្មុខាវិន័យ ជាកុសលក៏មាន ជាអព្យាតកៈក៏មាន សម្មុខាវិន័យ ជាអកុសល មិនមានទេ ។ យេភុយ្យសិកា ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន ។ សតិវិន័យ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន ។ អមូឡ្ហវិន័យ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន ។ បដិញ្ញាតករណៈ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន ។ តស្សបាបិយសិកា ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន ។ តិណវត្ថារកៈ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន ។

[៨៩៨] សួរថា វិវាទាធិករណ៍ ជាកុសល ឬជាអកុសល ឬជាអព្យាកតៈ ។ អនុវាទាធិករណ៍ ជាកុសល ឬជាអកុសល ឬជាអព្យាកតៈ ។ អាបត្តាធិករណ៍ ជាកុសល ឬជាអកុសល ឬជាអព្យាកតៈ ។ កិច្ចាធិករណ៍ ជាកុសល ឬជាអកុសល ឬជាអព្យាកតៈ ។ ឆ្លើយថា វិវាទាធិករណ៍ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន ។ អនុវាទាធិករណ៍

វីសតិ វារា ចក្កបេយ្យាលំ យត្ថវារំ

សិយា កុសលំ សិយា អកុសលំ សិយា អព្យាកតំ ។ អាបត្តាធិករណំ សិយា កុសលំ សិយា អកុសលំ សិយា អព្យាកតំ ។ នត្ថិ អាបត្តាធិករណំ កុសលំ ។ កិច្ចាធិករណំ សិយា កុសលំ សិយា អកុសលំ សិយា អព្យាកតំ ។

កុសលវារំ និដ្ឋិតំ តេរសមំ ។

[៨៩៩] យត្ថ យេភុយ្យសិកា លព្ភតិ តត្ថ សម្មុខាវិនយោ លព្ភតិ យត្ថ សម្មុខាវិនយោ លព្ភតិ តត្ថ យេភុយ្យសិកា លព្ភតិ ន តត្ថ សតិវិនយោ លព្ភតិ ន តត្ថ អមូឡ្ហវិនយោ លព្ភតិ ន តត្ថ បដិញ្ញាតករណំ លព្ភតិ ន តត្ថ តស្សបាបិយសិកា លព្ភតិ ន តត្ថ តិណវត្ថារកោ លព្ភតិ ។ យត្ថ សតិវិនយោ លព្ភតិ

ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន ។ អាបត្តាធិករណ៍ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន ។ អាបត្តាធិករណ៍ ជាកុសល មិនមានទេ ។ កិច្ចាធិករណ៍ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន ។

ចប់ កុសលវារៈ ជាគម្រប់ ១៣ ។

[៨៩៩] បើអ្នកប្រាជ្ញកំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) បាន ក្នុងអធិករណ៍ណា ក៏កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បាន ក្នុងអធិ-ករណ៍នោះ កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍ណា ក៏កំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះដែរ តែកំណត់យកសតិវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកបដិ-ញ្ញាតករណៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកតស្សបា-បិយសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកតិណវត្ថា-រកៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបានទេ ។ បើអ្នកប្រាជ្ញកំណត់យកសតិវិន័យ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍ណា ក៏កំណត់យក

តត្ថ សម្មុខាវិនយោ លព្ភតិ យត្ថ សម្មុខាវិនយោ លព្ភតិ តត្ថ សតិវិនយោ លព្ភតិ ន តត្ថ អមូឡ្ហវិនយោ លព្ភតិ ន តត្ថ បដិញ្ញាតករណំ លព្ភតិ ន តត្ថ តស្សបាបិយសិកា លព្ភតិ ន តត្ថ តិណវត្ថារកោ លព្ភតិ ន តត្ថ យេភុយ្យសិកា លព្ភតិ ។ យត្ថ អមូឡ្ហវិនយោ លព្ភតិ ន តត្ថ សម្មុខាវិនយោ លព្ភតិ យត្ថ សម្មុខាវិនយោ លព្ភតិ តត្ថ អមូឡ្ហវិនយោ លព្ភតិ ន តត្ថ បដិញ្ញាតករណំ លព្ភតិ ន តត្ថ តស្សបាបិយសិកា លព្ភតិ ន តត្ថ តិណវត្ថារកោ លព្ភតិ ន តត្ថ យេភុយ្យសិកា លព្ភតិ ន តត្ថ សតិវិនយោ លព្ភតិ ។ យត្ថ បដិញ្ញាតករណំ លព្ភតិ តត្ថ សម្មុខាវិនយោ

សម្មុខាវិន័យ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍នោះ កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍ណា ក៏កំណត់យកសតិវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះដែរ តែកំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់) ក្នុងអធិ-ករណ៍នោះ មិនបាន កំណត់យកបដិញ្ញាតករណៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកតស្សបាបិយសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកតិណវត្ថារកៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យក យេភុយ្យសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបានទេ ។ បើអ្នកប្រាជ្ញកំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់) បានក្នុងអធិករ-ណ៍ណា កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍នោះ មិនបានទេ កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍ណា ក៏កំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍នោះ ដែរ តែកំណត់យកបដិញ្ញាតករណៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកតស្សបាបិយសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកតិណវត្ថារកៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកយេភុយ្យ-សិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកសតិវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបានទេ ។ អ្នកប្រាជ្ញកំណត់យកបដិញ្ញា-តករណៈ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍ណា ក៏កំណត់យកសម្មុខាវិន័យ

៤២៧

វីសតិ វារា ចក្កបេយ្យាលំ យត្ថវារំ

លព្ភតិ យត្ថ សម្មុខាវិនយោ លព្ភតិ តត្ថ បដិញ្ញាតករណំ លព្ភតិ ន តត្ថ តស្សបាបិយសិកា លព្ភតិ ន តត្ថ តិណវត្ថារកោ លព្ភតិ ន តត្ថ យេភុយ្យសិកា លព្ភតិ ន តត្ថ សតិវិនយោ លព្ភតិ ន តត្ថ អមូឡ្ហវិនយោ លព្ភតិ ។ យត្ថ តស្សបាបិយសិកា លព្ភតិ តត្ថ សម្មុខាវិនយោ លព្ភតិ យត្ថ សម្មុខាវិនយោ លព្ភតិ តត្ថ តស្សបាបិយសិកា លព្ភតិ ន តត្ថ តិណវត្ថារកោ លព្ភតិ ន តត្ថ យេភុយ្យសិកា លព្ភតិ ន តត្ថ សតិវិនយោ លព្ភតិ ន តត្ថ អមូឡ្ហវិនយោ លព្ភតិ ន តត្ថ បដិញ្ញាតករណំ លព្ភតិ ។ យត្ថ តិណវត្ថារ-

(ទៅរម្ងាប់) បានក្នុងអធិករណ៍នោះ កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍ណា ក៏កំណត់យកបដិញ្ញាតករណៈ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍នោះដែរ តែកំណត់យកតស្សបាបិយសិកា (ទៅរម្ងាប់) ក្នុង អធិករណ៍នោះ មិនបាន កំណត់យកតិណវត្ថារកៈ (ទៅរម្ងាប់) ក្នុងអធិករណ៍ នោះ មិនបាន កំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកសតិវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបានទេ ។ បើអ្នកប្រាជ្ញកំណត់យកតស្សបាបិយសិកា (ទៅរម្ងាប់) បាន ក្នុងអធិករណ៍ ណា ក៏កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍នោះ កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍ណា ក៏កំណត់ យក តស្សបាបិយសិកា (ទៅរម្ងាប់) បាន ក្នុងអធិករណ៍នោះដែរ តែថា កំណត់យកតិណវត្ថារកៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់ យកយេភុយ្យសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យក សតិវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកអមូឡ្ហ-វិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកបដិញ្ញាត-ករណៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបានទេ ។ បើអ្នកប្រាជ្ញ កំណត់យកតិណវត្ថារកៈ (ទៅរម្ងាប់) បានក្នុងអធិករណ៍ណា ក៏កំណត់យក

កោ លព្ភតិ តត្ថ សម្មុខាវិនយោ លព្ភតិ យត្ថ សម្មុខាវិនយោ លព្ភតិ តត្ថ តិណវត្ថារកោ លព្ភតិ ន តត្ថ យេភុយ្យសិកា លព្ភតិ ន តត្ថ សតិវិនយោ លព្ភតិ ន តត្ថ អមូឡ្ហវិនយោ លព្ភតិ ន តត្ថ បដិញ្ញាតករណំ លព្ភតិ ន តត្ថ តស្សបាបិយសិកា លព្ភតិ ។

[៩០០] យត្ថ យេភុយ្យសិកា តត្ថ សម្មុខាវិនយោ យត្ថ សម្មុខាវិនយោ តត្ថ យេភុយ្យសិកា ន តត្ថ សតិវិនយោ ន តត្ថ អមូឡ្ហវិនយោ ន តត្ថ បដិញ្ញាតករណំ ន តត្ថ តស្សបាបិយសិកា ន តត្ថ តិណវត្ថារកោ ។ យត្ថ សតិវិនយោ តត្ថ សម្មុខាវិនយោ

សម្មុខាវិន័យ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍នោះ កំណត់យកសម្មុខា-
វិន័យ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍ណា ក៏កំណត់យកតិណវត្ថារកៈ
(ទៅរម្ងាប់) បាន ក្នុងអធិករណ៍នោះដែរ តែកំណត់យកយេភុយ្យសិកា
(ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកសតិវិន័យ (ទៅរម្ងាប់)
ក្នុងអធិករណ៍នោះ មិនបាន កំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់) ក្នុងអធិ-
ករណ៍នោះ មិនបាន កំណត់យកបដិញ្ញាតករណៈ (ទៅរម្ងាប់) ក្នុងអធិករ-
ណ៍នោះ មិនបាន កំណត់យកតស្សបាបិយសិកា (ទៅរម្ងាប់) ក្នុងអធិករ-
ណ៍នោះ មិនបានទេ ។

[៩០០] បើអ្នកប្រាជ្ញកំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) បាន
ក្នុងអធិករណ៍ណា ក៏កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បាន ក្នុងអធិ-
ករណ៍នោះ កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍ណា
ក៏កំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) បាន ក្នុងអធិករណ៍នោះដែរ តែ
កំណត់យកសតិវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យក
អមូឡ្ហវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកបដិញ្ញាត-
ករណៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកតស្សបាបិយ-
សិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកតិណវត្ថារកៈ (ទៅ
រម្ងាប់) ក្នុងអធិករណ៍នោះ មិនបានទេ ។ បើអ្នកប្រាជ្ញកំណត់យកសតិវិន័យ

៤២៩

វីសតិ វារា ចក្កបេយ្យាលំ យត្ថវារំ

យត្ថ សម្មាវាចិយោ តត្ថ សតិវិនយោ ន តត្ថ អមូឡ្ហវិនយោ ន តត្ថ បដិញ្ញាតករណំ ន តត្ថ តស្សបាបិយសិកា ន តត្ថ តិណវត្ថារកោ ន តត្ថ យេភុយ្យសិកា ។ (សម្មាវាចិយំ កាតូន មូលំ) ។ បេ ។ យត្ថ តិណវត្ថារកោ តត្ថ សម្មាវាចិយោ យត្ថ សម្មាវាចិយោ តត្ថ តិណវត្ថារកោ ន តត្ថ យេភុយ្យសិកា ន តត្ថ សតិវិនយោ ន តត្ថ អមូឡ្ហវិនយោ ន តត្ថ បដិញ្ញាតករណំ ន តត្ថ តស្សបាបិយសិកា ។

ចក្កបេយ្យាលំ ។ យត្ថវារំ និដ្ឋិតំ ចុទ្ទសមំ ។

(ទៅរម្ងាប់) បានក្នុងអធិករណ៍ណា ក៏កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះ កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍ណា កំណត់យកសតិវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះដែរ តែកំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកបដិញ្ញាតករណៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកតស្សបាបិយសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកតិណវត្ថារកៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបានទេ ។ (ធ្វើសម្មុខាវិន័យឲ្យជាមូល[១]) ។ បេ ។ អ្នកប្រាជ្ញកំណត់យកតិណវត្ថារកៈ (ទៅរម្ងាប់) បានក្នុងអធិករណ៍ណា ក៏កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះ កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍ណា កំណត់យកតិណវត្ថារកៈ (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះដែរ តែកំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកសតិវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកបដិញ្ញាតករណៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន នឹងកំណត់យកតស្សបាបិយសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបានទេ ។

ចប់ ចក្កបេយ្យាលៈ ។ ចប់ យត្ថវារៈជាគម្រប់ ១៤ ។

---

១ ត្រង់កន្លែងបេយ្យាលៈនេះត្រូវធ្វើសម្មុខាវិន័យមុនគេ លុះចប់ហើយត្រូវនិយាយពីសតិវិន័យរហូតដល់តិណវត្ថារកៈតទៅ ។

[៩០១] យស្មឹ សមយេ សម្មុខាវិនយេន ច យេភុយ្យ-សិកាយ ច អធិករណំ វូបសម្មតិ យត្ថ យេភុយ្យសិ-កា លព្ភតិ តត្ថ សម្មុខាវិនយោ លព្ភតិ យត្ថ សម្មុខា-វិនយោ លព្ភតិ តត្ថ យេភុយ្យសិកា លព្ភតិ ន តត្ថ សតិវិនយោ លព្ភតិ ន តត្ថ អមូឡ្ហវិនយោ លព្ភតិ ន តត្ថ បដិញ្ញាតករណំ លព្ភតិ ន តត្ថ តស្សបាបិយសិកា លព្ភតិ ន តត្ថ តិណវត្ថារកោ លព្ភតិ ។ យស្មឹ សមយេ សម្មុខាវិនយេន ច សតិវិនយេន ច អធិករណំ វូបសម្ម-តិ យត្ថ សតិវិនយោ លព្ភតិ តត្ថ សម្មុខាវិនយោ លព្ភតិ យត្ថ សម្មុខាវិនយោ លព្ភតិ តត្ថ សតិវិនយោ លព្ភតិ ន តត្ថ អមូឡ្ហវិនយោ លព្ភតិ ន តត្ថ បដិញ្ញាតករណំ លព្ភតិ ន តត្ថ តស្សបាបិយសិកា លព្ភតិ ន តត្ថ

[៩០១] អធិករណ៍ រម្ងាប់ដោយសម្មុខាវិន័យ និងយេភុយ្យសិកាក្នុងសម័យណា អ្នកប្រាជ្ញកំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) បានក្នុងអធិករណ៍ណា ក៏កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះ កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍ណា ក៏កំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះដែរ តែកំណត់យកសតិវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកបដិញ្ញាតករណៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកតស្សបាបិយសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកតិណវត្ថារកៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបានទេ ។ អធិករណ៍រម្ងាប់ដោយសម្មុខាវិន័យនិងសតិវិន័យក្នុងសម័យណា អ្នកប្រាជ្ញកំណត់យកសតិវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍ណា ក៏កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះ កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍ណា កំណត់យកសតិវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះដែរ តែកំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកបដិញ្ញាតករណៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកតស្សបាបិយសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន

តិណវត្ថារកោ លព្ភតិ ន តត្ថ យេភុយ្យសិកា លព្ភតិ ។ យស្មឹ សមយេ សម្មុខាវិនយេន ច អម្មូឡ្ហវិនយេន ច អធិករណំ វូបសម្មតិ យត្ថ អម្មូឡ្ហវិនយោ លព្ភតិ តត្ថ សម្មុខាវិនយោ លព្ភតិ យត្ថ សម្មុខាវិនយោ លព្ភតិ តត្ថ អម្មូឡ្ហវិនយោ លព្ភតិ ន តត្ថ បដិញ្ញាតករណំ លព្ភតិ ន តត្ថ តស្សបាបិយសិកា លព្ភតិ ន តត្ថ តិណ-វត្ថារកោ លព្ភតិ ន តត្ថ យេភុយ្យសិកា លព្ភតិ ន តត្ថ សតិវិនយោ លព្ភតិ ។ យស្មឹ សមយេ សម្មុខា-វិនយេន ច បដិញ្ញាតករណេន ច អធិករណំ វូប-សម្មតិ យត្ថ បដិញ្ញាតករណំ លព្ភតិ តត្ថ សម្មុខា-វិនយោ លព្ភតិ យត្ថ សម្មុខាវិនយោ លព្ភតិ តត្ថ បដិញ្ញាតករណំ លព្ភតិ ន តត្ថ តស្សបាបិយសិកា

កំណត់យកតិណវត្ថារកៈ (ទៅរម្ងាប់) ក្នុងអធិកណ៍នោះ មិនបាន កំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបានទេ ។ អធិករ-ណ៍រម្ងាប់ដោយសម្មុខាវិន័យ និងអមូឡ្ហវិន័យក្នុងសម័យណា អ្នកប្រាជ្ញកំ-ណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍ណា ក៏កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះ កំណត់យកសម្មុខា-វិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍ណា ក៏កំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះដែរ តែកំណត់យកបដិញ្ញាតករណៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកតស្សបាបិយសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកតិណវត្ថារកៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកសតិវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបានទេ ។ អធិករណ៍រម្ងាប់ដោយសម្មុខាវិន័យ និងបដិញ្ញាតក-រណៈក្នុងសម័យណា អ្នកប្រាជ្ញកំណត់យកបដិញ្ញាតករណៈ (ទៅរម្ងាប់) បានក្នុងអធិករណ៍ណា ក៏កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះ កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បានក្នុងអធិ-ករណ៍ណា ក៏កំណត់យកបដិញ្ញាតករណៈ (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះដែរ តែកំណត់យកតស្សបាបិយសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ

លព្ភតិ ន តត្ថ តិណវត្ថារកោ លព្ភតិ ន តត្ថ យេ-
ភុយ្យសិកា លព្ភតិ ន តត្ថ សតិវិនយោ លព្ភតិ ន តត្ថ
អមូឡ្ហវិនយោ លព្ភតិ ។ យស្មឹ សមយេ សម្មុខាវិន-
យេន ច តស្សបាបិយសិកាយ ច អធិករណំ វូប-
សម្មតិ យត្ថ តស្សបាបិយសិកា លព្ភតិ តត្ថ សម្មុខា-
វិនយោ លព្ភតិ យត្ថ សម្មុខាវិនយោ លព្ភតិ តត្ថ
តស្សបាបិយសិកា លព្ភតិ ន តត្ថ តិណវត្ថារកោ
លព្ភតិ ន តត្ថ យេភុយ្យសិកា លព្ភតិ ន តត្ថ សតិ-
វិនយោ លព្ភតិ ន តត្ថ អមូឡ្ហវិនយោ លព្ភតិ ន តត្ថ
បដិញ្ញាតករណំ លព្ភតិ ។ យស្មឹ សមយេ សម្មុខា-
វិនយេន ច តិណវត្ថារកេន ច អធិករណំ វូបសម្មតិ
យត្ថ តិណវត្ថារកោ លព្ភតិ តត្ថ សម្មុខាវិនយោ លព្ភតិ

មិនបាន កំណត់យកតិណវត្ថារកៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកសតិវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបានទេ ។ អធិករណ៍រម្ងាប់ដោយសម្មុខាវិន័យ និងតស្សបាបិយសិកា ក្នុងសម័យណា អ្នកប្រាជ្ញកំណត់យកតស្សបាបិយសិកា (ទៅរម្ងាប់) បានក្នុងអធិករណ៍ណា ក៏កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះ កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍ណា ក៏កំណត់យកតស្សបាបិយសិកា (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះដែរ តែកំណត់យកតិណវត្ថារកៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន ក៏កំណត់យកសតិវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកបដិញ្ញាតករណៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបានទេ ។ អធិករណ៍រម្ងាប់ដោយសម្មុខាវិន័យ នឹងតិណវត្ថារកៈក្នុងសម័យណា អ្នកប្រាជ្ញកំណត់យកតិណវត្ថារកៈ (ទៅរម្ងាប់) បានក្នុងអធិករណ៍ណា ក៏កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់)

វីសតិ វារា សំសដ្ឋារំ

យត្ថ សម្មុខាវិនយោ លព្ភតិ តត្ថ តិណវត្ថារកោ លព្ភតិ ន តត្ថ យេភុយ្យសិកា លព្ភតិ ន តត្ថ សតិវិនយោ លព្ភតិ ន តត្ថ អមូឡ្ហវិនយោ លព្ភតិ ន តត្ថ បដិញ្ញាតករណំ លព្ភតិ ន តត្ថ តស្សបាបិយសិកា លព្ភតិ ។

សមយវារំ និដ្ឋិតំ បណ្ណរសមំ ។

[៩០២] អធិករណសមថា វា សមថាតិ វា ឥមេ ធម្មា សំសដ្ឋា ឧទាហុ វិសំសដ្ឋា លព្ភា ច ឥមេសំ[១] ធម្មានំ វិនិព្ភុជិត្វា វិនិព្ភុជិត្វា[២] នានាករណំ បញ្ញាបេតុំ ។ អធិករណាន្តិ វា សមថាតិ វា ឥមេ ធម្មា សំសដ្ឋា នោ វិសំសដ្ឋា លព្ភា ច ឥមេសំ ធម្មានំ វិនិព្ភុជិត្វា វិនិព្ភុជិត្វា នានាករណំ បញ្ញាបេតុន្តិ ។ សោ មា ហេវន្តិស្ស វចនីយោ អធិករណាន្តិ វា សមថាតិ វា ឥមេ ធម្មា សំសដ្ឋា នោ វិសំសដ្ឋា ន ច លព្ភា ឥមេសំ ធម្មានំ វិនិព្ភុជិត្វា វិនិព្ភុជិត្វា នានាករណំ បញ្ញាបេតុំ ។

---

១ ឱ. ម. លព្ភាបនិមេសំ ។ ២ ម. វិនិព្ភុជ្ជិត្វា វិនិព្ភុជ្ជិត្វា ។

បានក្នុងអធិករណ៍នោះ កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍ណា ក៏កំណត់យកតិណវត្ថារកៈ (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះ តែកំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកសតិវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកបដិញ្ញាតករណៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកតស្សបាបិយសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបានទេ ។

ចប់ សមយវារៈ ជាគម្រប់ ១៥ ។

[៩០២] សួរថា អធិករណ៍និងសមថៈ ធម៌ទាំងនេះ លាយច្រឡំគ្នា ឬមិនលាយគ្នាទេ មួយទៀត លោកចែករំលែកធម៌ទាំងនេះ ហើយបញ្ញត្តឲ្យផ្សេងគ្នា បានឬទេ ។ ឆ្លើយថា អធិករណ៍និងសមថៈ ធម៌ទាំងនេះ រមែងលាយច្រឡំគ្នា មិនមែនមិនលាយគ្នាទេ តែលោកចែករំលែកធម៌ទាំងនេះ ចេញពីគ្នា ហើយបញ្ញត្តឲ្យផ្សេងគ្នា បាន ។ អ្នកចោទត្រូវពោលឃាត់អ្នកឆ្លើយនោះថា អ្នកកុំនិយាយយ៉ាងនេះឡើយ អធិករណ៍និងសមថៈ ធម៌ទាំងនេះ រមែងលាយច្រឡំគ្នា មិនមែនមិនលាយគ្នាទេ មួយទៀត លោកមិនបានចែករំលែកធម៌ទាំងនេះ ចេញពីគ្នា ហើយបញ្ញត្តឲ្យផ្សេងគ្នាទេ ។

តំ កិស្ស ហេតុ ។ ននុ វុត្តំ ភគវតា ចត្តារីមានិ[១] ភិក្ខវេ អធិករណានិ សត្ត សមថា អធិករណា សមថេហិ សម្មន្តិ សមថា អធិករណេហិ សម្មន្តិ ឯវំ ឥមេ ធម្មា សំសដ្ឋា នោ វិសំសដ្ឋា ន ច លព្ភា ឥមេសំ ធម្មានំ វិនិព្ភុជិត្វា វិនិព្ភុជិត្វា នានាករណំ បញ្ញាបេតុន្តិ ។

សំសដ្ឋវារំ និដ្ឋិតំ សោឡសមំ ។

[៩០៣] វិវាទាធិករណំ កតីហិ សមថេហិ សម្មតិ អនុវាទាធិករណំ កតីហិ សមថេហិ សម្មតិ អាបត្តាធិករណំ កតីហិ សមថេហិ សម្មតិ កិច្ចាធិករណំ កតីហិ សមថេហិ សម្មតិ ។ វិវាទាធិករណំ ទ្វីហិ សមថេហិ សម្មន្តិ សម្មុខាវិនយេន ច យេភុយ្យសិកាយ ច អនុវាទាធិករណំ ចតូហិ សមថេហិ សម្មតិ សម្មុខាវិនយេន ច សតិវិនយេន ច អមូឡ្ហវិនយេន ច តស្សបាបិយសិកាយ ច អាបត្តាធិករណំ តីហិ

១ ចត្តារិមានីតិបិ ។

